# ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២

## កងកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទប់ស្កាត់ប្រជាពលរដ្ឋបម្រុងឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ ក្នុងភូមិសាស្រ្តស្រុកសំពៅលូន

https://gdlf-kh.com/ 30/06/2022 Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង២ និង១០នាទីរំលងអាធ្រាត នាថ្ងៃព្រហស្បតិ៍ ២កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនកូនភ្នំ ចំនួន៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ខៀវ ផាត(នាយប៉ុស្តិ៍ស្តីទី)សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី១ វរសេនាតូចលេខ១ ចំនួន៣នាក់ ដឹកនាំលោកអនុសេនីយ៍ទោ ស៊ឹង ស៊ិត(មេបញ្ជាការរងកងអនុសេនាធំ) កម្លាំងយោធាកងអនុសេនាធំគាំទ្រ វរសេនាតូចលេខ៥៣៣ ចំនួន៦នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី ប៉ាត ណារ៉ុង (មេបញ្ជាការកងអនុសេនាធំ) បានធ្វើការសកម្មភាពទប់ស្កាត់ប្រជាពលរដ្ឋបម្រុងលួចឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ ត្រង់ចំណុចភូមិសាស្រ្ត ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបងចំនួន៧នាក់ ស្រី២នាក់ ក្មេង២នាក់ ក្មេងស្រី១នាក់ និងឃាត់ជនសង្ស័យនាំមនុស្សឆ្លងដែន(មេខ្យល់)ចំនួន២នាក់ ។

ប្រជាពលរដ្ឋ និងជនសង្ស័យនាំមនុស្សឆ្លងដែនមានឈ្មោះទីលំនៅដូចខាងក្រោម÷

១-ឈ្មោះ មឿន មាន ភេទប្រុសអាយុ ៣៧ឆ្នាំ។

២-ឈ្មោះ មឿន រដ្ឋា ភេទប្រុស អាយុ ២៩ឆ្នាំ ប្រជាពលរដ្ឋទាំងពីរនាក់ មានទីលំនៅភូមិត្រពាំងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង (ជាជនសង្ស័យនាំមនុស្សឆ្លងដែន)

៣-ឈ្មោះ ដួង ស្រ៊ីម ភេទប្រុស អាយុ ២៩ឆ្នាំ ៤-ឈ្មោះ ចាន់ ផា ភេទស្រី អាយុ ៤២ឆ្នាំ

៥-ឈ្មោះ ព្រំ អូ ភេទស្រី អាយុ ៤៣ឆ្នាំ ៦-ឈ្មោះ យ៉ាំ លីណា ភេទស្រី អាយុ ៣ឆ្នាំ

៧-ឈ្មោះ ភួង យ៉ីរ៉ិន ភេទស្រី អាយុ ៧ខែ បងប្អូនទាំងអស់មានទីលំនៅភូមិថ្នល់ ឃុំសម្បត្តិមានជ័យស្រុករមាសហែក ខេត្តស្វាយរៀង។

ក្រោយពីទប់ស្កាត់បាន កម្លាំងយើងបានធ្វើការសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃចុះកិច្ចសន្យា និងអប់រំណែនាំ រួចបានប្រគល់ឱ្យបងប្អូន និងជនសង្ស័យឲ្យទៅកម្លាំងជំនាញនៃអធិការដ្ឋាននគរបាលស្រុក

# ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២

## ទូតថ្មីរបស់អ៊ីស្រាអែលចង់នាំពលករកម្ពុជា១ពាន់នាក់ទៅធ្វើកសិកម្មនៅប្រទេសរបស់ខ្លួន

https://www.rfi.fr/ ចុះផ្សាយនៅថ្ងៃ៖ 02/07/2022 - 08:33 ដោយ៖អេង គីមហុង

ឯកអគ្គរដ្ឋទូតថ្មីរបស់អ៊ីស្រាអែលលោកស្រី Orna SAGIV ចង់នាំយកពលករកម្ពុជាប្រមាណ១ពាន់នាក់ជាជំហ៊ានដំបូងទៅបម្រើការក្នុងវិស័យកសិកម្មនៅប្រទេសរបស់ខ្លួន។ ភាគីអ៊ីស្រាអែល បានប្រាប់ពីបំណងនេះនៅចំពោះមុខរដ្ឋមន្ត្រីក្រសួងកសិកម្មកម្ពុជា លោក វេង សាខុន នៅក្នុងជំនួបទ្វេភាគីនៅថ្ងៃទី១កក្កដាម្សិលមិញ។ ថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិនៅថ្ងៃទី២កក្កដានេះ រដ្ឋមន្ត្រីក្រសួងកសិកម្មបានគូសបញ្ជាក់ថា ទាំងកម្ពុជានិងអ៊ីស្រាអែលសង្ឃឹម នឹងបានចុះកិច្ចព្រមព្រៀងរួមគ្នាក្នុងពេលឆាប់ៗខាងមុខ។ ប្រសិនបើកិច្ចព្រមព្រៀងស្តីពីការនាំពលករចេញរវាងកម្ពុជានិងអ៊ីស្រាអែលត្រូវបានដាក់អនុវត្ត វានឹងជួយពង្រឹងនិងពង្រីកសមត្ថភាពកសិករកម្ពុជា ទាំងផ្នែកទ្រឹស្តីនិងការអនុវត្តអំពីការប្រើប្រាស់បច្ចេកទេសកសិកម្មទំនើបរបស់អ៊ីស្រាអែលទាំងការចិញ្ចឹមសត្វនិងដាំដុះ។ នេះជាការលើកឡើងរបស់លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម។ បើតាមលោករដ្ឋមន្ត្រី ក្រៅតែពីជំនាញផ្នែកកសិកម្មពលករកម្ពុជាក៏ទទួលបានបៀវត្សខ្ពស់ចន្លោះពី១ពាន់ទៅ១៥០០ដុល្លារក្នុងមួយខែ។ មិនត្រឹមតែប៉ុណ្ណោះ ពេលត្រឡប់មកវិញពលករកម្ពុជាអាចប្រើប្រាស់បច្ចេកទេសថ្មីក្នុងការធ្វើកសិកម្មជាលក្ខណៈគ្រួសារ និងសហគមន៍របស់ពួកគេ។ លោក វេង សាខុន បានប្រាប់ឲ្យដឹងទៀតថា នេះជាលើកដំបូងហើយដែលអ៊ីស្រាអែលមានបំណងចង់នាំពលករកម្ពុជាទៅធ្វើការផ្នែកកសិកម្មនៅប្រទេសរបស់ខ្លួន ខណៈដែលប្រទេសថៃ ពលរដ្ឋរបស់គេទៅធ្វើការនៅទីនោះចន្លោះពី៣ទៅ៣៥០០០នាក់។

បើតាមលោករដ្ឋមន្ត្រីជំហររបស់លោកស្រីឯកអគ្គរដ្ឋទូតថ្មីរបស់អ៊ីស្រាអែល ចង់ឲ្យដំណើរការនាំពលករទៅធ្វើការនៅអ៊ីស្រាអែលធ្វើឡើងជាលក្ខណៈរដ្ឋនិងរដ្ឋ មិនមែននាំចេញតាមរយៈក្រុមហ៊ុនឯកជនឡើយ។ ហើយពលករកម្ពុជាដែលអាចនឹងជ្រើសរើស ដើម្បីបានទៅធ្វើកសិកម្មនៅអ៊ីស្រាអែលអាចជាកសិករមានជំនាញស្រាប់ និងមិនមានជំនាញខ្លះ រួមនឹងការប្រើប្រាស់ភាសាអង់គ្លេសបាន។ ជុំវិញគម្រោងនាំពលករកម្ពុជាចេញទៅធ្វើកសិកម្មនៅប្រទេសអ៊ីស្រាអែល មានការស្វាគមន៍ពីសំណាក់អ្នកជំនាញកសិកម្មរបស់កម្ពុជា។ ពួកគេយល់ឃើញមិនខុសពីក្រសួងកសិកម្មដោយចាត់ទុកឱកាសការងារនៅទីនោះ នឹងពង្រឹងសមត្ថភាពការងាររបស់ពលរដ្ឋខ្មែរពេលត្រឡប់មកស្រុកវិញ។ ប៉ុន្តែយ៉ាងណាមិញ លោក យ៉ង សាំងកុមារ អ្នកជំនាញកសិកម្មលើកឡើងថា ក្រសួងកសិកម្មគួរមានយន្តការរក្សាទុកធនធានដែលត្រឡប់មកពីអ៊ីស្រាអែលដើម្បីប្រើប្រាស់ក្នុងវិស័យកសិកម្មកម្ពុជា។

សូមជម្រាបជូនថា គម្រោងនាំពលករកម្ពុជាចេញទៅធ្វើកសិកម្មនៅអ៊ីស្រាអែលនាពេលនេះជំនួសឲ្យការកាត់បន្ថយចំនួននិស្សិតទៅសិក្សាផ្នែកកសិកម្មនៅទីនោះពី២០០នាក់មកនៅត្រឹម១០០នាក់។ ប៉ុន្តែកម្ពុជាស្នើឲ្យអ៊ីស្រាអែលរក្សាកូតានាំនិស្សិតចេញចំនួន២០០នាក់នេះឲ្យនៅដដែល។ រយៈពេល១៤ឆ្នាំនិស្សិតកម្ពុជាផ្នែកកសិកម្មឆ្នាំទី៣បានទៅហាត់ការនៅប្រទេសអ៊ីស្រាអែលតាំងពីឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្នចំនួន១៤៦៩នាក់។ បើតាមក្រសួងកសិកម្ម បច្ចុប្បន្នពួកគេបាន និងកំពុងចូលរួមចំណែកយ៉ាងសកម្ម មក្នុងការចែករំលែកបទពិសោធន៍ល្អៗ ទាក់ទងបច្ចេកវិទ្យាកសិកម្មទំនើបៗ ដែលទទួលបានពីប្រទេសអ៊ីស្រាអែល ដើម្បីអភិវឌ្ឍវិស័យនេះ ឲ្យកាន់តែរីកចម្រើនស្របតាមផែនការជាយុទ្ធសាស្ត្រក្នុងការធ្វើទំនើបកម្មកសិកម្ម៕

## កម្លាំងចម្រុះបង្ក្រាបមេខ្យល់ ២ នាក់ បម្រុងនាំពលករឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

https://www.postkhmer.com/ ភ្នំពេញ ប៉ុស្តិ៍ | Publication date 01 July 2022 | 13:43 ICT

**បាត់ដំបង:** កម្លាំងចម្រុះបានធ្វើការឃាត់ខ្លួនមេខ្យល់ ២ នាក់ ដែលប៉ុនប៉ងនាំពលករចំនួន ៥ នាក់ឆ្លងទៅធ្វើការនៅប្រទេសថៃ ដោយខុសច្បាប់កាលពីយប់រំលងអធ្រាត្រថ្ងៃទី ៣០ ខែមិថុនា។

ការឃាត់ខ្លួននេះត្រូវបានធ្វើឡើងនៅចំណុចមាត់អូរព្រំដែនកម្ពុជា-ថៃជាប់ភូមិសាស្ត្រក្រុមទី ០៧ ភូមិគីឡូ ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ក្រោមកិច្ចសហការរវាងនគរបាលស្រុក កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ កម្លាំងកងយោធពលខេមរភូមិន្ទក្នុងវរសេនាតូចលេខ ១ និងកម្លាំងវរសេនា តូច ៥៣៣ ប្រចាំការតាមខ្សែបន្ទាត់ព្រំដែន។ នេះបើយោងតាមស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង។

មេខ្យល់ទាំង ២ នាក់នោះមានឈ្មោះ មឿន មានអាយុ ៣៧ ឆ្នាំនិងឈ្មោះ មឿន វដ្ឋា អាយុ ២៩ ឆ្នាំរស់នៅភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ពួកគេបានធ្វើសកម្មភាពទាក់ទងនាំពលករចំនួន ៥ នាក់ ដែលនោះក៏រួមមានស្ត្រីចំនួន ២ នាក់ និងក្មេងស្រីចំនួន ២ នាក់ផងដែរ។ ពួកគេមានទីលំនៅភូមិថ្នល់ ឃុំសម្បត្តិមានជ័យ ស្រុកមោសហែក ខេត្តស្វាយរៀង។ ជនសង្ស័យបម្រុងនាំពួកគេឆ្លងដែនពីប្រទេសកម្ពុជាចូលទៅក្នុងប្រទេសថៃ ដោយខុសច្បាប់ និងយកប្រាក់ឈ្នួលថ្លៃជូនក្នុងម្នាក់ៗចំនួន ៦ ម៉ឺនរៀល។ សមត្ថកិច្ចបានធ្វើការសាកសួរ និងចាត់ការតាមនីតិវិធីច្បាប់។ រីឯពលករទាំង ៥ នាក់បានអប់រំឱ្យគាត់វិលទៅមូលដ្ឋានវិញ៕

## ស្ត្រីជាប់ចោទ ក្នុងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សុំតុលាការបន្ធូរបន្ថយទោស ដើម្បីថែទាំកូន

https://www.postkhmer.com/ គឹម សារុំ | Publication date 03 July 2022 | 10:21 ICT

**ភ្នំពេញ:** ស្ត្រីជាប់ចោទ អ៊ុំ រ៉ាដែន ក្នុងវ័យ ៣៥ឆ្នាំ ស្ថិតក្នុងសម្លៀកបំពាក់ពណ៌ខៀវខ្ចីដែលគេសម្គាល់បានថាជាអ្នកទោសដែលនៅលើ ផ្ទៃមុខមានស្បែកជ្រីវជ្រួញ នោះ បាននិយាយក្នុងបន្ទប់សវនាការជំនុំជម្រះនៃសាលាឧទ្ធរណ៍ភ្នំពេញ កាលពីដើមខែមករា ឆ្នាំ២០២២ នេះថា៖«ខ្ញុំសូមឱ្យតុលាការបន្ធូរបន្ថយទោសដល់រូបខ្ញុំ ដើម្បីឆាប់បានចេញទៅមើលថែទាំកូនតូចៗ ប្រុស ស្រី របស់ខ្ញុំចំនួន៣នាក់ដែលទើបតែមានអាយុ ៧ឆ្នាំ ១២ឆ្នាំ និងអាយុ ១៣ឆ្នាំ។ ពីមុនពួកគេមានជីតាមើលថែទាំ តែក្រោយពីជីតារបស់ពួកគេស្លាប់ដោយជំងឺកូវីដមក កូនៗរបស់ខ្ញុំត្រូវរស់នៅគ្មានទីពឹង គ្មានអ្នកមើលថែឡើយខណៈដែលខ្ញុំក៏ត្រូវជាប់ឃុំក្នុងពន្ធនាគាររហូតដល់១៦ឆ្នាំ»។

ស្ត្រីជាប់ចោទ អ៊ុំ រ៉ាដែន ត្រូវរងការចោទប្រកាន់ពីតុលាការរាជធានីភ្នំពេញក្នុងបទចោទការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនតាមមាត្រា១១នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ដោយសារតែ នាំនារីជនជាតិខ្មែរក្មេងៗចំនួន៧នាក់យកទៅ ប្រទេសម៉ាឡេស៊ី។ដោយសារតែអំពើខុសច្បាប់នេះបានធ្វើឱ្យនាងត្រូវចំណាយពេលរស់នៅក្នុងពន្ធនាគាររហូតដល់ឆ្នាំ២០៣២ទើបនាងមានសេរីភាពវិញ។ ស្ត្រីជាប់ចោទ អ៊ុំ រ៉ាដែន បាននិយាយរៀបរាប់ប្រាប់តុលាការបន្តថា នៅអំឡុងខែ មិថុនា ឆ្នាំ ២០១៦ គាត់បានស្គាល់ស្ត្រីឈ្មោះ ចាន់ សុឃីម និងស្ត្រីឈ្មោះ សំ យ៉ុង ដែលពួកគេរស់នៅខេត្តកំពង់ធំ ហើយបានទាក់ទងនារីខ្មែរដែលមានអាយុចន្លោះពី១៦ឆ្នាំ ទៅ១៩ឆ្នាំ ដែលរស់នៅតំបន់ជនបទនៃខេត្តកំពង់ធំ។ ដោយប្រើវិធីលួងលោមបញ្ចុះបញ្ចូលប្រាប់នារីក្មេងៗទាំង៧នាក់នោះថា មានគេរើសស្ត្រីខ្មែរក្មេងៗទៅធ្វើការនៅប្រទេសម៉ាឡេស៊ីបានប្រាក់ខែច្រើន។ ក្រោយពីបញ្ចុះបញ្ចូលនារីរងគ្រោះទាំងនោះបានសម្រេចហើយឈ្មោះ ចាន់ សុឃីម និងស្ត្រីឈ្មោះ សំ យ៉ុង បាននាំនារីរងគ្រោះមកផ្ទះរបស់គាត់នៅក្នុងសង្កាត់-ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញស្នាក់នៅបណ្តោះអាសន្នដើម្បីរត់ការបំពេញបែបបទធ្វើឯកសារ។

ស្ត្រីជាប់ចោទ បាននិយាយប្រាប់តុលាការបន្តទៀតថា ក្នុងអំឡុងពេលនោះស្ត្រីឈ្មោះ សំ យ៉ុង បានទៅរត់ការធ្វើឯកសារឱ្យពួកនាងនៅសាលាសង្កាត់ចោមចៅ ដោយនិយាយភូតកុហកមន្ត្រីសង្កាត់ចោមចៅឱ្យកែសម្រួលឈ្មោះ និងអាយុរបស់នារីៗទាំងនោះ ដើម្បីបានទៅធ្វើលិខិតឆ្លងដែនស្របច្បាប់។ ប៉ុន្តែត្រូវបានបែកការណ៍ហើយអាជ្ញាធរសង្កាត់ចោមចៅប្តឹងនគរបាលនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ហើយសមត្ថកិច្ចបានឃាត់ខ្លួនពួកគេទាំង ៣នាក់ និងបានរំដោះនារីទាំង ៧នាក់នោះបានវិញបន្ទាប់ពីមេខ្យល់នាំពួកនាងមកស្នាក់នៅបានប្រមាណ១០ថ្ងៃ គឺចូលដល់ខែកក្កដា ឆ្នាំ ២០១៦។

បន្ទាប់ពីត្រូវសមត្ថកិច្ចចាប់ខ្លួន ឈ្មោះ អ៊ុំ រ៉ាដែន និងឈ្មោះ ចាន់ សុឃីម ត្រូវបានតុលាការរាជធានីភ្នំពេញផ្តន្ទាទោសម្នាក់១៦ឆ្នាំដោយចោទពីបទនាំចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែនតាមមាត្រា១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ រីឯស្ត្រីឈ្មោះសំ យ៉ុង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ១ឆ្នាំចោទពីបទផ្តល់ឯកសារក្លែង។ ដោយដឹងពីកំហុស និងហាក់ស្រណោះអាណិតដល់កូនៗដែលគ្មានទីពឹងនោះស្ត្រីជាប់ចោទបាននិយាយបណ្តើរសម្រក់ទឹកភ្នែកបណ្តើរនៅក្នុងរង្វង់ក្រចកសេះជាមួយសំឡេងអួលដើមកថា៖« ខ្ញុំប្តឹងឧទ្ធរណ៍ភ្នំពេញមិនមែនជំទាស់ទៅអំពើរបស់ខ្លួនទេ តែជំទាស់ចំពោះទណ្ឌកម្មទោសច្រើនឆ្នាំពេក។ ម្យ៉ាងខ្ញុំក៏មានបញ្ហាគ្មានអ្នកថែទាំចិញ្ចឹមកូនៗទាំង ៣ នាក់របស់ខ្ញុំ។ ខ្ញុំស្នើសុំដល់តុលាការមេត្តាបន្ថយទោសដល់រូបខ្ញុំខ្លះផង»។

ពាក់ព័ន្ធអំពើជួញដូរមនុស្សនេះដែរត្រូវបានលោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានថ្លែងជាសាធារណៈ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ នៅសណ្ឋាគារសោម៉ាទេវីក្នុង ខេត្ត សៀមរាប ថា ទោះបីក្រសួងសង្គមកិច្ចអតីតយុទ្ធជនសម្រេចបានសមិទ្ធផលជាច្រើនយ៉ាងណាក៏ដោយ ក៏កិច្ចការពារ និងការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅមិនទាន់ឆ្លើយតបបានទាំងស្រុងនៅឡើយទេ ពិសេស ការផ្តល់សេវាគាំទ្រសម្រាប់ជនរងគ្រោះនៅមានកម្រិត។ លោកថ្លែងថា៖«ក្រុមជនទុច្ចរិតបានឆ្លៀតឱកាសប្រព្រឹត្តអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មលើមនុស្ស ដើម្បីកេងចំណេញពីស្ថានភាពប្រឈមរបស់ប្រជាពលរដ្ឋ និងប្រទេសជាតិក្នុងគ្រាជួបការលំបាក»។

លោកស្រី មាស សាអិម អនុប្រធានផ្នែកស្ត្រី និងកុមារនៃសមាគមការពារសិទ្ធិមនុស្ស អាដហុក បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា មួយរយៈក្រោយក្នុងស្ថានភាពជំងឺកូវីដ៦ខែនេះលោកស្រីសង្កេតឃើញមានស្ត្រីខ្មែរដែលត្រូវចាញ់បោកគេបង្ខំឱ្យរៀបការទៅប្រទេសចិនក៏ដូចជាជួញដូរទៅក្រៅប្រទេសគឺមានការត្រឡប់មកវិញមានចំនួនច្រើនដែរ។ ទាំងអង្គការសង្គមស៊ីវិលក៏ដូចជាស្ថាប័នពាក់ព័ន្ធមួយចំនួន ក៏ពិបាកនៅក្នុងការជួយជ្រោមជ្រែងពួកគាត់ហើយពួកគាត់ក៏ជួបនូវបញ្ហាជាច្រើនក្រោយពីមានការត្រឡប់មកវិញ។ លោកស្រីថ្លែងថា៖«យើងសង្កេតឃើញមានការបញ្ជូនត្រឡប់មកពីខាងប្រទេសចិនច្រើនជាងប្រទេសផ្សេងៗមួយរយៈចុងក្រោយនេះ។

នេះចំពោះទិន្នន័យដែលខាងសមាគមអាដហុកយើងទទួលបានទាក់ទងពួកគាត់ចាញ់បោកគេ»។ លោកស្រីបន្តថា ចំពោះនៅប្រទេសម៉ាឡេស៊ីវិញនៅមានករណីចាស់ៗមួយចំនួនកំពុងតែរាំងស្ទះដោយករណីដំបូងស្ត្រីខ្មែរទៅតាមទីភ្នាក់ងារជ្រើសរើសពលករហើយក្រោយមកទៀតផុតអាណត្តិការងារក៏ពួកគាត់មួយចំនួន ត្រូវបានបាត់ខ្លួនឬក៏ទៅធ្វើការនៅទីតាំងផ្សេង ដែលខាងសមាគមអាដហុកមិនបានទទួលព័ត៌មានក្នុងមួយរយៈពេលក្រោយនេះ។ ម្យ៉ាងទៀតដោយសារករណីពួកគាត់មួយចំនួនពាក់ព័ន្ធជាមួយ នីតិវិធីច្បាប់នៅខាងប្រទេសម៉ាឡេស៊ីហើយខាងសមាគមការពារសិទ្ធិមនុស្សអាដហុកកំពុងតែធ្វើអន្តរាគមន៍ ដើម្បីជួយពួកគាត់ហើយព្យាយាមរកមធ្យោបាយដែលយ៉ាងហោចណាស់ក៏ពួកគាត់ទទួលបានសំណងពីខាងថៅកែ ក៏ដូចជាទីភ្នាក់ងារនៅក្នុងការផ្តល់ជាថវិកានូវប្រាក់ខែដែលគាត់បានធ្វើក៏ដូចជាសំណងមួយចំនួនក្នុងករណី ដែលគាត់ធ្វើការមិនទទួលបានប្រាក់ខែឬក៏រូបភាពនៃការបៀតបៀនឬក៏ការកេងប្រវ័ញ្ចផ្សេងៗ។

លោកស្រី សាអិម ថា ភាគច្រើនរូបភាពគេធបោកទៅមានការងារធ្វើឬក៏ទៅរៀបការជាមួយនឹងប្តីល្អដែលមានជីវភាពធូរជា ដូច្នេះអ្វីដែលមានបញ្ហានៅពីក្រោយពាក់ព័ន្ធមួយចំនួនទើបគាត់សម្រេចចិត្តទៅទាំងអត់មានការវិភាគ ថ្លឹងថ្លែងព័ត៌មានគ្រប់ជ្រុងជ្រោយឬក៏គាត់ជឿជាក់ទៅលើមេខ្យល់ដែលមានបច្ចេកទេសនិងជំនាញក្នុងការលួងលោមពួកគាត់ថាយកទៅរៀបការឬក៏ធ្វើការនៅប្រទេសចិន។ ភាគច្រើនរូបភាពដែលត្រឡប់មកវិញគឺពួកគាត់ត្រូវបានគេបង្ខំឱ្យពពោះ ត្រូវរៀបការជាមួយអ្នកដែលគាត់មិនពេញចិត្តមិនស្រឡាញ់ហើយត្រូវរងនូវការបិទសិទ្ធិសេរីភាពឬក៏ខ្លះទៀតប៉ះពាល់ដល់សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគាត់ធ្ងន់ធ្ងរទៀត។ អ្នកខ្លះឈឺហើយមិនត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ខណៈអ្នកខ្លះទៀតរត់ទៅរកប៉ូលិសហើយហើយត្រូវប៉ូលិសបញ្ជូនមកវិញ។ ចំពោះអ្នកចាញ់បោកគេនៅប្រទេសម៉ាឡេស៊ីមានការងារតាមផ្ទះ និងមួយចំនួនទៀត ទៅតាមបងប្អូនជាជនជាតិខ្មែរអ៊ីស្លាមដែលគាត់មានបណ្តាញរបស់គាត់ និងខ្លះទៀតគាត់ជឿអ្នកជិតខាង និងអ្នកខ្លះទៅធ្វើការមានឯកសារ ខ្លះមានត្រឹមតែលិខិតឆ្លងដែនដោយគ្មានឯកសារការងារត្រឹមត្រូវទេ។

លោកស្រីបញ្ជាក់ថា៖«អ៊ីចឹងខ្លះត្រូវបានឃុំខ្លួនរយៈពេលបណ្តោះអាសន្ននៅខាងប៉ូលិសខាងអីហើយអ្នកខ្លះត្រូវបាត់ព័ត៌មានអីចឹងទៅ។ យើងមើលឃើញកន្លងមកមានចំពោះស្ត្រីដែលចាញ់បោកគេមានអាយុចន្លោះពី១៥ឆ្នាំ ២០ឆ្នាំទៅអាយុជាង៣០ឆ្នាំនិងជាង៤០ឆ្នាំ និងមានអាយុក្រោម៤៥ឆ្នាំគឺមានចំនួនច្រើន»។សំពៅលូនចាត់ការបន្តតាមនីតិវិធី។

# ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

## ពលករខ្មែរពីកូរ៉េ ខិតខំទ្រាំបចំណេះ ជំនាញ និងដើមទុនមកអភិវឌ្ឍប្រទេស

https://www.postkhmer.com/ ហុង រស្មី | Publication date 05 July 2022 | 09:26 ICT

**ភ្នំពេញ:** ដោយចង់ឱ្យជីវភាពគ្រួសារបានប្រសើរឡើង យុវជន ឆាន គឹមម៉េន បានសម្រេចចិត្តដាក់ពាក្យទៅធ្វើជាពលករនៅស្រុកគេ ដោយឃ្លាតឆ្ងាយពីក្រុមគ្រួសារ រួមទាំងបងប្រុសភ្លោះរបស់លោក។ ក្រៅពីមើលឃើញពីការអាចរកប្រាក់ចំណូលបានច្រើនយុវជនរូបនេះក៏បានសម្លឹងឃើញនូវចំណេះ និងជំនាញពីប្រទេសកូរ៉េ ដែលខ្លួនអាចច្នៃបង្កើតជាអាជីវកម្ម ដើម្បីអភិវឌ្ឍនៅមាតុភូមិកំណើតវិញ។ បច្ចុប្បន្ននេះ លោក គឹមម៉េន បានចាប់ដៃគូជាមួយបងប្រុសភ្លោះបង្កើតជាក្រុមហ៊ុនអចលនទ្រព្យ អាណាចក្រ ហេរ៉ូមែន ឯ.ក (Anachak Heroman Property Co., Ltd) ដែលមានទុនវិនិយោគខ្ទង់លានដុល្លារ និងបុគ្គលិកជិត ១០០ នាក់។ លោក គឹមម៉េន និយាយថា៖ «ខ្ញុំចង់ជួយគ្រួសារឱ្យមានជីវភាពល្អប្រសើរ ដោយសារយើងមិនសូវធូរជារ។ ខ្ញុំក៏សម្រេចចិត្តវេចសម្ភាយឡើងយន្តហោះទៅធ្វើពលករនៅកូរ៉េ ដោយសារនៅទីនោះមានប្រាក់ខែច្រើនចន្លោះពី ១ ៥០០ ទៅ ២ ៥០០ ដុល្លារក្នុង ១ ខែ។ នេះជាការសម្រេចចិត្តដំបូង គឺទៅធ្វើការដើម្បីទទួលបានប្រាក់ខែច្រើនផ្ញើមកគ្រួសារ»។ យុវជន ជាកូនកសិករមកពីស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដែលខិតខំប្រវេប្រវាស្រវាំវិជ្ជារហូតដល់ចប់បរិញ្ញាបត្រផ្នែកច្បាប់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងរូបនេះបន្តថា៖ «មួយវិញទៀតយើងបានចំណេះជំនាញ និងបទពិសោធពីប្រទេសកូរ៉េមកស្រុកខ្មែរដើម្បីបង្កើតដើមទុនប្រកបអាជីវកម្ម»។

លោក ហេង សួរ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឱ្យដឹងថា បច្ចុប្បន្នមានពលករកម្ពុជាកំពុងរស់នៅ និងធ្វើការនៅប្រទេសកូរ៉េខាងត្បូងចំនួន ៤៦ ១៩៩ នាក់ ស្រី ១០ ៧២៧ នាក់ ហើយអ្នកដែលបានបញ្ចប់កិច្ចសន្យា និងវិលមកស្រុកវិញមាន ២៦ ៥៩៩ នាក់ ស្រី ៤៧ ៩៦ នាក់។ លោកប្រាប់ភ្នំពេញប៉ុស្តិ៍ថា៖ «បងប្អូនដែលត្រឡប់មកវិញភាគច្រើនលើសលប់ មានជីវភាពល្អប្រសើរ មានជំនាញ មានគំនិតសហគ្រិនភាពដែលអាចធ្វើការ និងបង្កើតមុខរបររកស៊ីដោយខ្លួនឯងបាន»។ «ជំនាញរបស់បងប្អូនមានទីផ្សារ ហើយការងារក៏មានដែរ តែភាគច្រើនបងប្អូនយើងមិនទទួលធ្វើដោយសារបងប្អូនចង់បានកម្រៃច្រើនដូចនៅកូរ៉េ។ ដូច្នេះ បងប្អូនភាគ

ច្រើនសម្រេចចិត្តប្រកបមុខរបរ និងការងារខ្លួនឯង»។ អតីតគ្រូបង្រៀនភាសាកូរ៉េ និងបុគ្គលិកប៉ុស្តិ៍វិទ្យុ ៩៩,៥ ខេត្តក្រចេះ លោក គីមម៉េន បានជិះយន្តហោះជាលើកដំបូងក្នុងឆាកជីវិតឆ្ពោះទៅប្រទេសកូរ៉េខាងត្បូងក្នុងឆ្នាំ ២០១២ និងត្រឡប់មកវិញក្នុងឆ្នាំ ២០១៦ ដោយសារតែផុតអាណត្តិ។

ដោយមិនទាន់មានគោលដៅច្បាស់លាស់នៅ ១ ឆ្នាំបន្ទាប់ គីមម៉េន បានធ្វើចំណាកស្រុកជាលើកទី ២ ដោយមានរយៈពេលត្រឹមស្ត្រីពពោះឆ្លងទន្លេ ៩ ខែ ១០ ថ្ងៃប៉ុណ្ណោះ។ នៅ ៤ ឆ្នាំដំបូង លោក គីមម៉េន ធ្វើការងារផ្នែកលក់គ្រឿងសំណង់ ហើយក្នុងអាណត្តិទី ២ យុវជនរូបនេះបន្តទៅធ្វើការក្នុងរោងចក្រផលិតរ៉ងឡាន។ ស្ថិតក្នុងចំណោមពលករបញ្ចប់កិច្ចសន្យាទាំងជាង ២ ម៉ឺននាក់ ដោយមើលឃើញឱកាសអាជីវកម្មក្នុងវិស័យអចលនទ្រព្យនៅស្រុកខ្មែរយុវជន គីមម៉េន បានវិលត្រឡប់មកស្រុកវិញជាមួយធនធានមួយចំនួនពីកូរ៉េមកធ្វើការវិនិយោគ ដោយចាប់ដៃជាមួយបងប្រុសភ្លោះក្នុងការបង្កើតក្រុមហ៊ុនអចលនទ្រព្យ ១១។

ច្បាស់ណាស់លោក ឡេង ណារ៉ាត្រា ក៏ជាអតីតពលករបម្រើការនៅប្រទេសកូរ៉េខាងត្បូងម្នាក់ គឺជាបុគ្គលគំរូ ១ រូបរបស់លោក គីមម៉េន ដែលលោកសម្រេចធ្វើការវិនិយោគលើវិស័យដីឡូត៍ក្នុងស្រុក។ លោក គីមម៉េន អាយុ ៣៤ ឆ្នាំ ជាអគ្គនាយករងក្រុមហ៊ុនបានប្រាប់ភ្នំពេញប៉ុស្តិ៍ថា៖ «ពេលឃើញគាត់មកប្រកបរបរអចលនទ្រព្យអ៊ីចឹង វាហាក់ដូចជាចាក់ចំបេះដូងខ្ញុំ ដែលជំរុញចិត្តខ្ញុំឱ្យវិលត្រឡប់មកស្រុកវិញ ដើម្បីបង្កើតអាជីវកម្មមួយដែរ»។ ពេលនោះលោកបានចាប់ដៃគូជាមួយបងប្រុសភ្លោះ ដែលមានចំណេះដឹងស្រាប់ផ្នែកអចលនទ្រព្យ ដើម្បីបង្កើតជាក្រុមហ៊ុនមួយចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម។ ជាមួយដើមទុន ៥ ម៉ឺនដុល្លារ វិនិយោគផ្នែកអចលនទ្រព្យ បងប្អូនភ្លោះទាំង ២ មានលទ្ធភាពទិញដីត្រឹម ៥ ហិកតា ដើម្បីធ្វើការពុះជាឡូត៍តូចៗលក់នៅក្នុងទឹកដីនៃខេត្តសៀមរាប។

លោក គីមម៉េន បានអះអាងថា ត្រឹមរយៈពេល ៣ ខែ ទុនវិនិយោគបានកើនរហូតដល់ ៨៤ ម៉ឺនដុល្លារ។ វាពិតជាមិនគួរឱ្យជឿថាមានប្រជាពលរដ្ឋនាំគ្នាសម្រុកមកទិញដីច្រើនមែនទែន។ លោកឱ្យដឹងថា៖ «ដោយសារតែយើងសម្រេចចិត្តចាកចេញពីការងារនៅកូរ៉េមកមាតុភូមិវិញ ចំពេលវេលាដ៏ត្រឹមត្រូវ។ យើងចាប់ផ្តើមបោះទុនទឹកប្រាក់ ៨៤ ម៉ឺនដុល្លារនោះបន្តទៅទៀត ដោយបច្ចុប្បន្ន យើងមានដី ៣ កន្លែង ដែល ២ កន្លែងនៅសៀមរាប និង ១ កន្លែងនៅក្រុងបាវិត»។ បច្ចុប្បន្ន ស្ថាបនិកក្រុមហ៊ុនអចលនទ្រព្យបងប្អូនភ្លោះទាំង ២ មានបុគ្គលិកទាំងអស់ជិត ១០០ នាក់ ហើយបើទោះបីជាស្ថិតក្នុងកូវីដ ដែលលោក គីមម៉េន សារភាពថា ជួបបញ្ហាខ្លះដែរក៏ក្រុមហ៊ុននៅតែអាចរក្សាចំនួនបុគ្គលិកបានដដែល និងបន្តដំណើរការលក់ដីឡូត៍សន្សឹមៗ។

ជាអតីតពលករចំណាកស្រុករយៈពេល ២ អាណត្តិដូចគ្នា លោក គង់ សារិទ្ធិ ក៏បានយកចំណេះជំនាញ និងបទពិសោធ ក៏ដូចជាដើមទុនពីញើសឈាមការងារក្នុងឧស្សាហកម្មស្លដែកដ៏គ្រោះថ្នាក់នៅកូរ៉េមកអភិវឌ្ឍជាមុខរបរសិប្បកម្មធ្យូងអនាម័យ ដើម្បីជួយលើកស្ទួយដល់បរិស្ថាន។ យុវជនដែលចាប់ផ្តើមការងារនៅកូរ៉េដំបូងក្នុងឆ្នាំ ២០០៦ រូបនេះនិយាយថា លោកធ្វើការនៅតាមបណ្តារោងចក្រជាច្រើន ដូចជា រោងចក្រផ្គុំឡាន រោងចក្រផលិតអំបោះ ដោយសារវាមានប្រាក់ខែខ្ពស់។ លោក សារិទ្ធិ ឱ្យដឹងថា៖ «ដោយសារការងារនៅរោងចក្រឡានដែលស្រុកខ្មែរមិនទាន់មាន អ៊ីចឹងខ្ញុំមិនអាចយកជំនាញនេះមកអនុវត្តនៅស្រុកខ្មែរបានទេ។ ខ្ញុំមានជំនាញក្នុងវិស័យបង្គុំឡាននេះស្មើនឹងជនជាតិកូរ៉េ និងមានប្រាក់ខែប្រហាក់ប្រហែលជនជាតិកូរ៉េផងដែរ»។ ពេលត្រឡប់មកខ្មែរវិញ លោកចាប់ផ្តើមអាជីវកម្មដីឡូត៍ ហើយចំពោះគំនិតបើកអាជីវកម្មធ្យូងអនាម័យនេះ ដោយសារលោកមើលឃើញព្រៃឈើក្នុងស្រុកកាន់តែខើច លោកចង់ធ្វើផ្នែកសិប្បកម្មតាមរយៈការកែច្នៃកាកសំណល់ខ្លះដែលជួយលើកស្ទួយដល់បរិស្ថាន។ នេះជាជំហានសាកល្បងដំបូង។ លោកថា សិប្បកម្មផលិតធ្យូងអនាម័យនេះ ទើបចេញដំណើរបានរយៈពេល ១ ខែ ក្នុងដំណាក់កាលស្វែងរកបទពិសោធនៅឡើយ។ នៅពេលដំណើរការល្អ លោកនឹងមានដៃគូសម្រាប់នាំចេញទៅក្រៅប្រទេសថែមទៀត។ ម្ចាស់សិប្បកម្មធ្យូងអនាម័យស្នាដៃកូនខ្មែរ លោក សារិទ្ធិ រស់នៅភូមិទី ៤ សង្កាត់ខ្សាម

ក្រុងកំពង់ឆ្នាំង ថ្លែងថា៖ «ខ្ញុំគិតថា ពលករខ្មែរយើងអាចយកជំនាញ និងគំនិតបង្កើតអាជីវកម្មផ្ទាល់ខ្លួនមកធ្វើនៅស្រុកខ្មែរបានដោយការទិញម៉ាស៊ីនពីប្រទេសចិន ដូចជា រោងចក្រផលិតមី និងកែវដាក់កាហ្វេ។ អ្នកមានដើមទុន ២ ទៅ ៣ ម៉ឺនដុល្លារអាចធ្វើបាន»។

ម្ចាស់ក្រុមហ៊ុនអចលនទ្រព្យអាណាចក្រ ហេរូមែន ឯ.ក នឹងមិនបញ្ចប់ត្រឹមគម្រោងដីឡូត៍ ៣ ទីតាំងនោះទេ ដោយលោកនឹងពង្រីកខ្លួនកសាងបុរី និងខុនដូ នៅក្រុងព្រះសីហនុ ដែលក្រុមហ៊ុនមានដីនៅទីនោះស្រាប់ដែលអាចចេញជារូបរាងនៅក្នុងឆ្នាំ ២០៣០។ ទាំងនេះជាលទ្ធផល ដែលលោក គីមម៉េន ប្រែក្លាយការលំបាកពីពលករទៅជាសហគ្រិនវ័យក្មេង។ លោក គីមម៉េន បានរំឭកអំពីគំនិតអាជីវកម្មនេះ ដោយសារតែការបង្ហាត់បង្ហាញពីសំណាក់គ្រូបង្រៀនជនជាតិកូរ៉េ ដែលរៀបរាប់អំពីការអភិវឌ្ឍខ្លួនរបស់ប្រជាជនកូរ៉េក្រោយពេលធ្វើជាពលករនៅបរទេស។ លោកបានដកស្រង់សម្ដីគ្រូបង្រៀនរបស់លោកថា៖«ប្រទេសកូរ៉េរីកចម្រើនទៅបានដោយអាស្រ័យលើប្រជាជនគេ។ ប្រជាជនកូរ៉េបានទៅធ្វើការនៅអារ៉ាប៊ីសាអ៊ូឌីតបានរយៈពេលតែប៉ុន្មានឆ្នាំ ហើយក៏បានសម្រេចចិត្តមកប្រទេសវិញទាំងអស់ និងនាំយកជំនាញទាំងនោះមកអភិវឌ្ឍប្រទេស។ អ៊ីចឹង ពលករខ្មែរទាំងអស់ដែលធ្វើការនៅកូរ៉េក៏ត្រូវធ្វើបែបនេះដែរ»។ លោកបន្តថា៖ «គាត់និយាយថា ពេលត្រឡប់ទៅស្រុកវិញ ប្អូនឯងត្រូវខិតខំប្រឹងប្រែងធ្វើជាថៅកែកុំបន្តធ្វើការឱ្យគេទៀត។ ប្អូនត្រូវយកចំណេះ ជំនាញពីកូរ៉េទៅអភិវឌ្ឍខ្លួនឯងទៅជាថៅកែ។ ប្រាក់ខែនៅកូរ៉េនេះច្រើនហើយ បើប្អូនឯងទៅដាក់ CV ធ្វើការទៀត វាទៅអត់រួចទេ»។ យ៉ាងណាមិញ លោកសារភាពថា ការបង្កើតក្រុមហ៊ុនអចលនទ្រព្យមានការលំបាកច្រើន។ ប៉ុន្តែដោយសារបងប្អូនភ្លោះមានចំណេះដឹងខាងផ្នែកនេះ ទើបអ្នកទាំង ២ ចាប់ដៃអភិវឌ្ឍក្រុមហ៊ុនបោះជំហានទៅមុខឥតឈប់ឈរ។

លោក គីមម៉េន បន្ថែមថា៖ «ខ្ញុំចង់ចែករំលែកចំណេះ ជំនាញ និងបទពិសោធស្ដីពីអាជីវកម្មអចលនទ្រព្យដល់អ្នកចង់ប្រកបរបរនេះដោយសារមានអ្នកទទួលបរាជ័យជាច្រើន។ ខ្ញុំមានគោលការណ៍ ចំនួន ៥ ចំណុចសម្រាប់ខ្លួនឯង គឺសកម្មភាពត្រឹមត្រូវ ការសម្រេចចិត្តត្រូវ ការគិតត្រូវការទទួលព័ត៌មានត្រូវ និងការសេពគប់ត្រូវ»។ ជាការតបស្នងដល់សង្គមវិញ លោក គីមម៉េន ក៏បានចូលរួមចំណែកជួយអភិវឌ្ឍសង្គមតាមរយៈការជួយថវិកាដំឡើងអំពូលភ្លើងសូឡាតាមផ្លូវក្នុងស្រុកបន្ទាយស្រី ដែលមានលោក ឃឹម ហ្វីណង់ ជាអភិបាលស្រុក។ «ខ្ញុំចូលរួមក្នុងការដាក់អំពូលភ្លើងនៅស្រុកបន្ទាយស្រីប្រហែលជិត ១០០ ដើម។ ក្នុងសម័យកូវីដ យើងក៏បានជួយទឹកអាល់កុលដល់ប្រជាពលរដ្ឋតាមខេត្តមួយចំនួន ក៏ដូចជាសកម្មភាពចែកសៀវភៅតាមសាលារៀននៅតាមតំបន់ដាច់ស្រយាល»។

យ៉ាងណាមិញ មិនសុទ្ធតែពលករមកពីកូរ៉េទាំងអស់បង្កើតមុខរបរដោយជោគជ័យ និងមានផែនការធ្វើអាជីវកម្មគ្រប់ៗគ្នានោះទេ។ លោក សូ សុខន ជាពលករកូរ៉េរយៈពេលជិត ២ អាណត្តិ ដែលលោកនឹងវិលមកមាតុប្រទេសវិញឆាប់ៗខាងមុខបានបង្ហាញពីភាពស្រពេចស្រពិលចំពោះអនាគតខ្លួន។ លោក សុខន អាយុ ៤២ ឆ្នាំ ដែលបានសន្សំលុយកាក់មួយចំនួនពីការងារជិត ១០ ឆ្នាំមកនេះបាននិយាយថា៖ «ខ្ញុំមិនទាន់ច្បាស់ថា គួរធ្វើអ្វីនៅឡើយទេរហូតមកដល់ពេលនេះ។ ចាំមើលភាពជាក់ស្ដែង»៕

## ប៉ូលិសអឺរ៉ុប ចាប់ខ្លួនក្រុមរត់ពន្ធមនុស្ស ចំនួន១៣០នាក់

https://kbn.news/ July 6, 2022

បរទេស៖ ប៉ូលិសនៅទូទាំងអឺរ៉ុប បានចាប់ខ្លួនជនសង្ស័យ ចំនួន១៣០នាក់ ពាក់ព័ន្ធនឹងសកម្មភាពរត់ពន្ធចំណាកស្រុក តាមអ្វីដែលគេហៅថា ជាប្រតិបត្តិការអន្តរជាតិដ៏ធំបំផុត ដែលមិនធ្លាប់មានពីមុនមក នៅក្នុងប្លុកលោកសេរីមួយនេះ។ ទីភ្នាក់ងារសារព័ត៌មាន Reuters បានចេញផ្សាយ កាលពីថ្ងៃអង្គារ ទី៥ ខែកក្កដា ថា ទីភ្នាក់ងារប៉ូលិសអន្តរជាតិ អឺរ៉ូប៉ូល (Europol) បានបញ្ជាក់ កាលពីថ្ងៃអង្គារ ថា ប៉ូលិស នៅទូទាំងអឺរ៉ុប បានចាប់ខ្លួន

មនុស្ស ចំនួន១៣០នាក់ ជាប់ពាក់ព័ន្ធនឹងករណីរត់ពន្ធមនុស្ស ។ នៅក្នុងប្រតិបត្តិការជាលក្ខណៈអន្តរជាតិនេះ មានការចូលរួមពីប្រទេសចំនួន២២។ ជាមួយគ្នានេះដែរ ទីភ្នាក់ងារឧក្រិដ្ឋកម្មជាតិរបស់ចក្រភពអង់គ្លេស បានបញ្ជាក់ថា មនុស្សចំនួន៦នាក់ ត្រូវបានចាប់ខ្លួន នៅក្នុងទីក្រុងដូកឡែនស៍ (Dockland) និង តំបន់កាតហ្វដ (Catford) នៃរាជធានីឡុងដ៍។ ដោយឡែក មនុស្សរាប់សិបនាក់ផ្សេងទៀត ក៏បានត្រូវបានចាប់ខ្លួន នៅក្នុងប្រទេសអាល្លឺម៉ង់ បារាំង និង ហូល្លង់ដ៍ ផងដែរ។

ដោយឡែក អាជ្ញាធរយុត្តិធម៌បារាំង បានបញ្ជាក់ថា ប្រតិបត្តិការពាសពេញតំបន់អឺរ៉ុបនេះ បានកំណត់គោលដៅ ទៅលើ«អង្គការចាត់តាំងឧក្រិដ្ឋកម្មដ៏ធំ» នៅក្នុងប្លុកនេះ។ ប៉ូលិសអឺរ៉ូប៉ូល បានបញ្ជាក់ថា « នៅក្នុងប្រតិបត្តិការដ៏ធំ ពាសពេញតំបន់អឺរ៉ុបនេះ មានមន្ត្រីអនុវត្តន៍ច្បាប់ ជាង ២២ ៤៨០នាក់ បានចូលរួម ដោយត្រួតពិនិត្យ នៅព្រំដែន តាផ្លូវសមុទ្រ ផ្លូវគោក និង ផ្លូវអាកាសរបស់អឺរ៉ុប។ កាលពីឆ្នាំ២០២១កន្លងមកនេះ មានជនចំណាកស្រុកជាង ២៨ ០០០នាក់ បានឆ្លងកាត់ច្រកសមុទ្រ ចូលទៅកាន់ទឹកដីរបស់ចក្រភពអង់គ្លេស បើធៀបនឹងឆ្នាំ២០២០ មានត្រឹមតែ ៨ ៥០០នាក់ប៉ុណ្ណោះ៕

## ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២

## តុលាការឧទ្ធរណ៍ តម្កល់ទោសស្ត្រីជាប់ចោទវៀតណាមម្នាក់ ជាប់គុក ១៥ ឆ្នាំ ជាប់ពាក់ព័ន្ធការលក់ដូរក្មេងស្រីខ្មែរចំនួន២នាក់

https://cen.com.kh/ Posted ByPen Srey NeatJuly 6, 2022

ភ្នំពេញ: សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០២២ បានប្រកាសសាលដីកា តម្កល់ទោស ស្ត្រីជនជាប់ចោទជនជាតិវៀតណាមម្នាក់ ម្នាក់ ជាប់គុក រយៈ ១៥ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការចាប់ព.ង្រត់ កុមារីខ្មែរ ចំនួន២នាក់ អាយុក្រោម ១០ ឆ្នាំ ពីក្រុងបាវិត ខេត្តស្វាយរៀង នាំមកលក់ឲ្យក្រុមគ្រួសារវៀតណាម នៅក្នុងស្រុកកោះធំ ខេត្តកណ្ដាល ប្រព្រឹត្តនៅក្នុងអំឡុងខែ មេសា ឆ្នាំ ២០១៩។

លោក ប៉ុល សំអឿន ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ បានឲ្យដឹងថា ជាប់ចោទរូបនេះមាន ឈ្មោះ ង្វៀង លីលឿង ភេទស្រី អាយុ ៣៥ ឆ្នាំ ជនជាតិវៀតណាម មុខរបរមិនពិតប្រាកដ មានទីលំនៅមុខចាប់ខ្លួន នៅក្រុងបាវិត ខេត្តស្វាយរៀង។ នៅក្នុងសំណុំរឿងក្ដីនេះ ជនជាប់ចោទ ឈ្មោះ ង្វៀង លីលឿង ត្រូវបានសាលាដំបូងខេត្តស្វាយរៀង កាលពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ កាត់ទោសដាក់ពន្ធនាគារ កំណត់ ១៥ ឆ្នាំ និងបង្គាប់ឱ្យ សងថ្លៃជំងឺចិត្ត ចំនួន ២លានរៀល ឱ្យទៅកុមារីខ្មែររងគ្រោះ ក្នុងម្នាក់ៗ ក្រោមការចោទប្រកាន់ពីបទ: នាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ តាមបញ្ញត្តិមាត្រា ១១ នៃ ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ប្រព្រឹត្តនៅខេត្តស្វាយរៀង និង ខេត្តកណ្ដាល កាលពីអំឡុងខែ មេសា ឆ្នាំ ២០១៩។ តែគាត់បានប្តឹងឧទ្ធរណ៍។ ស្ត្រីជាប់ចោទ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០១៩ នៅស្រុកកោះធំ ខេត្តកណ្ដាល តាមបណ្ដឹង របស់ឪពុកម្ដាយកុមារីរងគ្រោះ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## ករណីរំលោភបំពានផ្លូវភេទ លើកុមារតាមប្រព័ន្ធអនឡាញ កំពុងត្រូវបានយកចិត្តទុកនៅកម្ពុជា

https://www.postkhmer.com/ ឡាយ សាមាន | Publication date 06 July 2022 | 09:47 ICT

**ភ្នំពេញៈ** នៅក្នុងយុគសម័យឌីជីថល មនុស្សនៅលើពិភពលោក រួមទាំងកម្ពុជាផង បានងាកមកប្រើប្រាស់អ៊ីនធឺណិតដើម្បីទាញអត្ថប្រយោជន៍ក្នុងការសិក្សា ការប្រាស្រ័យទំនាក់ទំនងក្នុងសង្គម និងសម្រាប់កម្សាន្តជាដើម។

ទន្ទឹមនេះដែរ កុមារនិងយុវជនគឺជាអ្នកប្រើប្រាស់អ៊ីនធឺណិតយ៉ាងសកម្ម ជាពិសេសលើប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម។ យ៉ាងណាមិញ ទោះបីការប្រើប្រាស់មានការកើនឡើងក៏ដោយ ប៉ុន្តែអក្ខរកម្ម និងជំនាញឌីជីថលរបស់កុមារ និងមាតានៅមានកម្រិតនៅឡើយដែលអាចជាហេតុធ្វើឱ្យកុមារប្រឈមនឹងហានិភ័យ នៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ីនធឺណិត។ យោងតាមស្ថិតិរបស់មជ្ឈមណ្ឌលជាតិនៃកុមារបាត់ខ្លួន និងការប្រវ័ញ្ចរបស់សហរដ្ឋអាមេរិកឱ្យដឹងថា ករណីនៃការរាយការណ៍ពីការរំលោភបំពានផ្លូវភេទចំពោះកុមារលើបណ្តាញអ៊ីនធឺណិតឆ្នាំ ២០២១ បានកើនឡើងប្រមាណ ៣៥ ភាគរយ ខ្ពស់ជាង ២០២០ គឺកើនពីចំនួន ២០ លានករណីទៅប្រមាណ ២៩ លានករណី។ រីឯរបាយការណ៍របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍កម្ពុជាបានឱ្យដឹងថាករណីនេះបាន កើតមាននៅក្នុងប្រទេសកម្ពុជាចំនួនប្រមាណ ៤០ ម៉ឺនករណី គឺការកើនលើស ២០២០ ជាងទ្វេដង។ ដើម្បីចូលរួមទប់ស្កាត់និងធានាដល់កុមារទទួលបានការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាព និងទទួលអត្ថប្រយោជន៍នៅលើប្រព័ន្ធអនឡាញ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សហការជាមួយអង្គការយូនីសេហ្វចាប់ផ្តើមអនុវត្តគម្រោងស្តីពី"ការជំរុញការចូលរួមរបស់ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងកិច្ចការពារកុមារលើប្រព័ន្ធអនឡាញនៅកម្ពុជា កាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០២២។

អគ្គនាយកបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍លោក នាង ម៉ៅ បានថ្លែងថា គម្រោងនេះមានគោលដៅសំខាន់ៗចំនួន៣ ទី១- រៀបចំនិងដាក់ចេញនូវសេចក្តីណែនាំដល់ក្រុមហ៊ុនបច្ចេកវិទ្យាក្នុងស្រុកស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញស្របតាមស្តង់ដាអន្តរជាតិដោយមានការគិតគូរអំពីសិទ្ធិសេរីភាពរបស់កុមារក្នុងការប្រើប្រាស់អ៊ីនធឺណិត និងវិធីសាស្ត្រការពារកុមារពីហានិភ័យនានា ដែលអាចកើតមានលើបណ្តាញ អ៊ីនធឺណិត។ ទី២- រៀបចំកិច្ចបណ្តុះបណ្តាលដល់ក្រុមហ៊ុនបច្ចេកវិទ្យាលើកិច្ចការពារកុមារនិងវិធីសាស្ត្ររាយការណ៍អំពីករណីគ្រោះថ្នាក់ដែលបានកើតឡើង និងទី៣- រៀបចំវេទិការបច្ចេកវិទ្យាអាស៊ានស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញ ដែលនឹងពិភាក្សាបន្ថែមទៀតពីបញ្ហាប្រឈមថ្នាក់តំបន់លើបញ្ហានេះ។ លោកបន្តថា ការដាក់ចេញនូវគម្រោងនេះ ដើម្បីឆ្លើយតបឱ្យទាន់ពេលវេលាខណៈការរំលោភបំពានកុមារតាមរយៈធ្វើរូបភាពអាសអាភាស នៅតាមប្រព័ន្ធអនឡាញកើនឡើងយ៉ាងច្រើនក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ ១៩ ដែលកុមារបានផ្លាស់ប្តូរជាច្រើនក្នុងរបៀបរបបរស់នៅនិងការសិក្សារបស់ពួកគេនៅកម្ពុជា។

លោក Benjamn Wildfire ប្រធានកម្មវិធីកិច្ចគាំពារកុមារនៃអង្គការ UNICEF ប្រចាំកម្ពុជា បានថ្លែងថា យោងទៅលើការវិភាគស្ថានភាពរបស់កុមារស្តីពី"ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិត" (OCSE) ឆ្នាំ ២០២២ដែលបានសាកសួរកុមារកម្ពុជាអំពីបទពិសោធរបស់ពួកគេតាមប្រព័ន្ធអ៊ីនធឺណិតបានបង្ហាញថា ៦០ ភាគរយ នៃកុមារដែលត្រូវបានសាកសួរបានដឹងពីហានិភ័យនានាស្តីពីការកេងប្រវ័ញ្ចផ្លូវភេទនៅពេលដែលពួកគេប្រើប្រាស់ ប្រព័ន្ធអ៊ីនធឺណិតដែលមានដូចជា ការល្បួងឬការបង្ខិតបង្ខំឱ្យបង្កើតនិងចែករំលែកមាតិកានានាដែលពាក់ព័ន្ធលើការបំពានផ្លូវភេទកុមារ។ លោកបន្តថា ទន្ទឹមនោះដែរក៏បានសង្កេតឃើញថាហានិភ័យទាំងនេះត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ ១៩ ដោយសារសាលានៅប្រទេសកម្ពុជា បានប្រើប្រាស់ទម្រង់នៃការរៀនសូត្រតាមប្រព័ន្ធអ៊ីនធឺណិតរយៈពេល ១៨ ខែដែលជាហេតុផលមួយបណ្តាលឱ្យកុមារចំណាយពេលលើប្រព័ន្ធអ៊ីនធឺណិតជាងពេលណាៗទាំងអស់សម្រាប់ការសិក្សា ការទាក់ទងសង្គមនិងការកម្សាន្តនៅលើប្រព័ន្ធអ៊ីនធឺណិត។ លោកបន្តថា ក្នុងបរិបទនេះ ការធានាកុមារអាចទទួលបានអត្ថប្រយោជន៍ទាំងអស់នៅលើប្រព័ន្ធអនឡាញគឺជារឿងសំខាន់បំផុតដែលគ្រប់ភាគីពាក់ព័ន្ធត្រូវចូលរួមទាំងអស់គ្នា។ លោកបានបញ្ជាក់ថា៖ «យូនីសេហ្វក្នុងនាមជាអង្គការមួយបានផ្តែកលើសកម្មភាពរបស់ខ្លួនលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកុមារយើង

ជឿជាក់លើរដ្ឋាភិបាលកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការណែនាំនិងជំរុញសហគមន៍ធុរកិច្ចនិងរាល់សកម្មភាពរបស់ពួកគេឱ្យគោរពខ្ជាប់ខ្ជួននូវសិទ្ធិកុមារដូចដែលមានចែងនៅក្នុងសិទ្ធិសញ្ញា»។

យុវតី ឡាង សុខលាង បានលើកឡើងថា សព្វថ្ងៃរូបនាងប្រើអ៊ីនធឺណិតចន្លោះពី ៨ ទៅ ១២ ម៉ោង ដែលប្រើទៅលើកិច្ចការស្រាវជ្រាវបង្កើនចំណេះដឹងថ្មីៗនិងស្វែងយល់ពីបញ្ហាសុខភាព។
សុខ លាង បន្តថា ស្របពេលជាមួយគ្នានោះ រូបនាងក៏ធ្លាប់បានជួបបញ្ហាមួយដោយមានមនុស្សមិនស្គាល់មុខ បានផ្ញើរូបភាពមិនសមរម្យមកកាន់នាងដែលធ្វើឱ្យនាងមានអារម្មណ៍តក់ស្លុតនិងភ័យជាខ្លាំងពេលនោះ។ សុខ លាង រៀបរាប់ថា៖ «ចាប់ពីពេលនោះមកខ្ញុំមិនបានប្រើអ៊ីនធឺណិតរយៈពេល ១ ខែពេញ ព្រោះតែមានភាពភ័យខ្លាចថាមានជនមិនស្គាល់មុខផ្ញើរូបមិនសមរម្យមកម្តងទៀត សម្រាប់ខ្ញុំក្នុងនាមជាយុវតីសំណូមពរទៅដល់រាជរដ្ឋាភិបាលក៏ដូចជាស្ថាប័ននានាជួយរកវិធានការទប់ស្កាត់ពីហានិភ័យចំពោះកុមារដូចជាការរំលោភបំពានកុមារ ដែលអាចបង្កដល់គ្រោះថ្នាក់»។

អាណាព្យាបាលមួយរូបសុំមិនបញ្ចេញឈ្មោះបានថ្លែងថា៖ «ខ្ញុំមានការបារម្ភជាខ្លាំងចំពោះក្មេងប្រើទូរស័ព្ទដៃ ដែលអាចប៉ះពាល់ដល់ការសិក្សារបស់គាត់ ព្រោះគាត់លេងហ្គេម ជាពិសេសបច្ចុប្បន្នលេង TikTok ហើយគាត់ក្មេងងាយចាញ់បោកគេតាមរយៈការអូសទាញតាមអនឡាញ»។ ជាមួយគ្នានេះដែរ លោកសំណូមពរដល់ក្រុមហ៊ុនអ៊ីនធឺណិតក៏ដូចជា ក្រសួងប្រៃសណីយ៍ ប្រសិនបើអាច ត្រូវរកដំណោះស្រាយនានាដើម្បីឱ្យកុមារលេងអ៊ីនធឺណិតដោយមានសុវត្ថិភាព។

អ្នកស្រី ង៉ែត ម៉ៅ រស់នៅរាជធានីភ្នំពេញ ដែលចិញ្ចឹមចៅចំនួន ២ នាក់ ក្នុងនោះកុមារីអាយុ ៥ឆ្នាំ និងកុមាអាយុ ៤ ឆ្នាំបានថ្លែងថា អ្នកស្រីក៏ព្រួយបារម្ភដែរចំពោះផលប៉ះពាល់ដល់ចៅៗនាពេលអនាគតដោយសារ ១ ថ្ងៃៗចៅចូលចិត្តមើល Ipaid នៅលើអនឡាញ។ អ្នកស្រីបញ្ជាក់ថា៖ «ចៅៗ ២ នាក់ សុទ្ធតែមាន Ipaid ម្នាក់មួយ ហើយឱ្យតែភ្ញាក់ឡើងរកតែ Ipaid ទេ បើមិនឱ្យយំរហូត មើលពីព្រឹកដល់ថ្ងៃ ហើយបើយើងដកចេញវាយំ អ៊ីចឹងមានតែបណ្តោយសិន»។ អ្នកស្រីបន្តថា ចៅៗភាគច្រើនមើល TikTok និង Youtube ចំណែកហ្វេសប៊ុកមិនសូវមើលនោះទេ។

ប្រធានផ្នែកគោលនយោបាយសាធារណៈរបស់ក្រុមហ៊ុន Tik Tok ប្រចាំកម្ពុជា និងឡាវ កញ្ញា Kyu Kyu Thein TikTok បានឱ្យដឹងថា ក្រុមហ៊ុននេះមានគោលនយោបាយដើម្បីការពារកុមារនៅតាមបណ្តាញ TikTok ក្នុងនោះអ្នកមានអាយុក្រោម ១៣ ឆ្នាំ មិនអាចដោនឡូត App TikTok បានទេ។ កញ្ញាបានបន្តថា ក្រៅពីនេះក្រុមហ៊ុនក៏មានគោលនយោបាយប្រឆាំងនឹងមាតិកាណា ដែលប៉ះពាល់ដល់កុមារនៅលើបណ្តាញសង្គមរបស់ខ្លួនផងដែរ។ កញ្ញាថា៖ «គ្រាន់តែ៣ខែចុងក្រោយនេះ យើងបានលុបវីដេអូជាង ៨៥ លានវីដេអូ ដែលបានបំពានគោលការណ៍ណែនាំសហគមន៍ ហើយ ៤៥ ភាគរយ នៃវីដេអូដែលបានដកចេញគឺការបំពានគោលការណ៍កុមារ»។ បើតាមកញ្ញាករណីនេះក្រុមហ៊ុនកំពុងធ្វើការជាមួយរដ្ឋាភិបាល ភាគីពាក់ព័ន្ធ និងអ្នកជំនាញដើម្បីចែករំលែកពីមាតិកា ដោយប្រាកដថាគ្រប់វីដេអូដែលបង្ហោះទៅ មិនប៉ះពាល់ដល់កុមារ ។

តំណាងក្រុមហ៊ុនបច្ចេកវិទ្យាឯកជនលោក សួន សំណាង បានថ្លែងថា៖ «សម្រាប់ក្រុមហ៊ុនរបស់លោកមិនមានសមត្ថកិច្ចក្នុងការដោះស្រាយលើបញ្ហារំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញទេ ប៉ុន្តែក្រុមហ៊ុននឹងចូលរួមចែករំលែកចំណេះដឹងនិងផលិតមាតិកាដើម្បីបញ្ជ្រាបការយល់ដឹងជាសាធារណៈទៅដល់កុមារ និងអាណាព្យាបាល តាមរយៈគេហទំព័ររបស់ខ្លួន»។

អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិដើម្បីកុមារលោកស្រី សម្បត្តិ សុគន្ធា បានថ្លែងថាលោកស្រីពិតជាមានមោទនភាពដោយសាររឿងកុមារនេះមានក្រសួង និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធបានធ្វើ

សកម្មភាពទប់ស្កាត់ ហើយឥឡូវនេះក៏មានការចូលរួមពីវិស័យឯកជនថែមទៀតផង។ លោកស្រីបន្តថា ប្រព័ន្ធការពារកុមារលើបណ្តាញអ៊ីនធឺណិតដែលមានប្រសិទ្ធភាព គឺជាកិច្ចសហការរវាងតួអង្គពាក់ព័ន្ធសំខាន់ៗ រួមមានទាំងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវគោលនយោបាយ ច្បាប់និងបទដ្ឋានគតិយុត្តនានា អាជ្ញាធរអនុវត្តច្បាប់ គ្រូបង្រៀន ឪពុកម្តាយ អាណាព្យាបាល អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជនដើម្បីជួយគាំទ្រដល់ការអនុវត្តការងារទៅវិញទៅមក។

អនុប្រធានទូទៅនិងជាប្រធានការិយាល័យនគរបាលអន្តរជាតិលោក កោត កុលកុមារ បានថ្លែងដែរថា ប្រព័ន្ធបច្ចេកវិទ្យាទាំងនោះវាមានផលចំណេញផងនិងផលវិបាកផង ក៏ប៉ុន្តែដោយខ្វះការយកចិត្តទុកដាក់ឬខ្វះនូវការអប់រំបន្ថែមពាក់ព័ន្ធបច្ចេកវិទ្យាធ្វើឱ្យកុមារមួយចំនួនធ្លាក់ទៅក្នុងការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ។ លោកបន្តថា ក្នុងការស្រាវជ្រាវស៊ើបអង្កេតជនខិលខូចដែលព្យាយាមកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអនឡាញកន្លងមកគឺជួបប្រឈមដោយសារមានការឆ្លើយតបមកសមត្ថកិច្ចយឺតហើយការឆ្លើយរបស់ជនរងគ្រោះនៅមានកម្រិត ទើបធ្វើឱ្យការស៊ើបអង្កេតចំណាយពេលវេលាយូរ ។ នៅប្រទេសកម្ពុជា កិច្ចពិគ្រោះយោបល់ជាមួយយុវជននិងកុមារដែលត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០២០ ដោយអង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជាបានរកឃើញថា ១៥ ភាគរយនៃកុមារដែលចូលរួមកិច្ចពិគ្រោះយោបល់បានរាយការណ៍ ថា ពួកគេធ្លាប់មានមនុស្សមិនស្គាល់មុខទាក់ទងមកតាមបណ្តាញសង្គម។ក្នុងនោះកុមារចំនួន ២ ភាគរយ ទៀតបានរៀបរាប់ថា ពួកគេធ្លាប់ត្រូវបានគេស្នើសុំឱ្យចែករំលែករូបភាព សកម្មភាពមិនសមរម្យនិងរូបភាពបែបស្និទ្ធស្នាលនៅចំពោះមុខកាមេរ៉ាដែលភ្ជាប់ទៅនឹងអ៊ីនធឺណិត៕

## ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២

### ក្រសួងមហាផ្ទៃ និងអង្គការ IJM រួមគ្នាលុបបំបាត់បទល្មើសជួញដូរមនុស្សនៅកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ៩ កក្កដា ២០២២

ក្រសួងមហាផ្ទៃសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ( IJM )បានរួមគ្នាលុបបំបាត់បទល្មើសជួញដូរមនុស្សនៅក្នុងប្រទេសសំដៅលើកកម្ពស់សេចក្តីថ្លៃថ្នូរ សិទ្ធិ សេរីភាព សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ថ្លែងក្នុងចុះហត្ថលេខាអនុស្សរណៈនៃការយោគយល់គ្នារវាង ក្រសួងមហាផ្ទៃ និងអង្គការ IJM សម្រាប់កិច្ចសហប្រតិបត្តិការ ៣ ឆ្នាំបន្តទៀត កាលពីថ្ងៃទី ០៨ កក្កដា លោក សន្តិបណ្ឌិត តេង សាវង្ស រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ដែលបានផ្តល់កិច្ចសហប្រតិបត្តិការដ៏ល្អជាមួយ អគ្គស្នងការនគរបាលជាតិ និងអង្គភាពពាក់ព័ន្ធ ចំណុះក្រសួងមហាផ្ទៃ និងជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការការពារអនីតិជន ដែលជាអង្គភាពធ្វើប្រតិបត្តិការផ្ទាល់ជាមួយ អង្គការ IJM លើសកម្មភាពការងារដែលបានកំណត់នៅក្នុងវិសាលភាពនៃ MOU។

លោកសន្តិបណ្ឌិត តេង សាវង្សសង្ឃឹម និងជឿជាក់ថា តាមរយៈស្មារតីនៃអនុស្សរណៈដែលត្រូវចុះហត្ថលេខានាពេលនេះ នឹងរួមចំណែកកាន់តែសកម្មថែមទៀត និងបង្កលក្ខខណ្ឌកាន់តែប្រសើរឡើង សម្រាប់ភាគីទាំងពីរ ក្នុងការបន្តភារកិច្ច និងបេសកកម្មរួមគ្នា ក្រសួងមហាផ្ទៃ និងអង្គការ IJM ដើម្បីលុបបំបាត់បទល្មើសជួញដូរមនុស្ស ក្នុងគោលដៅលើកកម្ពស់សេចក្តីថ្លៃថ្នូរ សិទ្ធិ សេរីភាព សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែក លោក Jacob Sims នាយកអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) បានប្តេជ្ញាសហការជាមួយក្រសួងមហាផ្ទៃក្នុងការចូលរួម លុបបំបាត់បទល្មើសជួញដូរមនុស្សនៅប្រទេសកម្ពុជាឱ្យកាន់តែល្អប្រសើរបន្ថែមទៀត៕

## ថៃចូលរួមជាមួយកម្ពុជាក្នុងការលុបបំបាត់អ្នកឆបោកតាមមជ្ឈមណ្ឌលហៅទូរស័ព្ទ

https://www.khmertimeskh.com/ July 9, 2022

គណៈកម្មាធិការចម្រុះនឹងត្រូវបានបង្កើតឡើង ដើម្បីផ្លាស់ប្តូរព័ត៌មាន សម្របសម្រួលការចាប់ខ្លួន និងដំណើរការសំណើធ្វើបត្យាប័ន។ គណៈរដ្ឋមន្ត្រីបានអនុម័តលើអនុស្សរណៈនៃការយោគយល់គ្នា (MoU) រវាងក្រសួងសេដ្ឋកិច្ច និងសង្គមឌីជីថលរបស់ប្រទេសថៃ និងអាជ្ញាធរកម្ពុជា ដើម្បីដោះស្រាយការក្លែងបន្លំដែលប្រព្រឹត្តដោយអ្នកបោកប្រាស់មជ្ឈមណ្ឌលហៅទូរស័ព្ទ (Call Center) និងក្រុមឧក្រិដ្ឋជនផ្សេងទៀត។ កិច្ចសហការនេះត្រូវបានគេរំពឹងថានឹងបង្កើនប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងដើម្បីបង្ក្រាបឧក្រិដ្ឋជន Call Center និងជនក្លែងបន្លំផ្សេងទៀត ។ អនុស្សរណៈនៃការយោគយល់គ្នានេះត្រូវបានគេរំពឹងថានឹងត្រូវចុះហត្ថលេខានៅថ្ងៃទី ១១ ខែកក្កដា នៅពេលដែលរដ្ឋមន្ត្រីសេដ្ឋកិច្ច និងសង្គមឌីជីថល លោក Chaiwut Thanakomanusorn ដែលគ្រោងនឹងមកបំពេញទស្សនកិច្ចនៅកម្ពុជា។ ( *NNT/Pattaya Mail* )

## ម៉ាឡេស៊ីទទួលអ្នកបម្រើពីកម្ពុជា

https://www.khmertimeskh.com/ July 10, 2022

ក្រសួងធនធានមនុស្សនឹងដាក់សំណើទៅគណៈរដ្ឋមន្ត្រី លើអនុស្សរណៈនៃការយោគយល់គ្នា (MoU) ដើម្បីនាំអ្នកបម្រើការងារពីកម្ពុជា។

រដ្ឋមន្ត្រី Datuk Seri M. Saravanan បានមានប្រសាសន៍កាលពីម្សិលមិញថា ក្រសួងរបស់លោកបានឆ្លងកាត់ដំណាក់កាលជាច្រើនពាក់ព័ន្ធនឹងបញ្ហានេះ ហើយ MoU ត្រូវបានគេរំពឹងថានឹងបញ្ចប់ក្នុងពេលឆាប់ៗនេះ។ "យើងកំពុងដំណើរការ (នៃការបញ្ចប់ព័ត៌មានលម្អិត) ហើយវានឹងត្រូវការពេលវេលា ប៉ុន្តែយើងកំពុងព្យាយាមធ្វើវាឱ្យបានឆាប់។ ខ្ញុំនឹងបង្ហាញ MoU ដែលបានស្នើទៅឧទ្ទកាល័យដើម្បីនាំពលករបរទេស ជាពិសេសអ្នកបម្រើកាន់សាសនាឥស្លាមពីប្រទេសកម្ពុជា»។ លោកបានថ្លែងបែបនេះបន្ទាប់ពីបានចូលរួមក្នុងពិធីបើកការដ្ឋានសាងសង់ក្លឹបយុវជន Gopeng Bell Tamil ។

លោក Saravanan ឆ្លើយតបនឹងសំណួរអំពីសំណើរបស់រដ្ឋាភិបាលក្នុងការនាំស្ត្រីបម្រើពីប្រទេសផ្សេងក្រៅពីប្រទេសឥណ្ឌូនេស៊ី។ ខ្ញុំបានពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជា ហើយពួកគេនឹងផ្តល់ឱកាសដល់យើង (ដើម្បីនាំអ្នកបម្រើ)។ លោកបានមានប្រសាសន៍ថា ប្រទេសម៉ាឡេស៊ីបានចាប់ផ្តើមទទួលអ្នកបម្រើពីប្រទេសឥណ្ឌូណេស៊ីចាប់ពីថ្ងៃទី ១ ខែកក្កដា។ *New Straits Times*

## ជនជាតិម៉ាឡេស៊ី៤នាក់ទៀត
## ដែលត្រូវបានគេបោកប្រាស់ចូលក្នុងការឆបោកការងារនៅកម្ពុជា មកដល់ផ្ទះវិញហើយ

https://www.khmertimeskh.com/ July 10, 2022

នគរបាលម៉ាឡេស៊ីបាននិយាយកាលពីម្សិលមិញថា ជនជាតិម៉ាឡេស៊ីបួននាក់ផ្សេងទៀត ដែលត្រូវបានគេនិយាយថា ត្រូវបានបោកបញ្ឆោតដោយក្រុមឆបោក ដែលផ្តល់ការងារ ដែលមានប្រាក់ខែខ្ពស់នៅក្នុងប្រទេសកម្ពុជា ត្រូវបាននាំយកមកផ្ទះវិញ។

នាយករងនាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្ម Bukit Aman (CID) (ស៊ើបការណ៍/ប្រតិបត្តិការ) លោក Datuk Hussein Omar Khan បាននិយាយថា ពួកគេស្ថិតក្នុងចំណោមជនជាតិម៉ាឡេស៊ី៥៤នាក់ ដែលបានធ្លាក់ខ្លួនរងគ្រោះដោយសារក្រុមបោកប្រាស់ការងារបែបនេះ ហើយត្រូវបានជួយសង្គ្រោះរហូតមកដល់ពេលនេះ។ «មាន

ជនជាតិម៉ាឡេស៊ី ៥នាក់ទៀតដែលនៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានអាជ្ញាធរឃុំខ្លួននៅទីនោះ។ លោកបានប្រាប់អ្នកយកព័ត៌មានបន្ទាប់ពីការមកដល់នៃជនជាតិម៉ាឡេស៊ីទាំងបួននាក់ដែលមានអាយុចន្លោះពី២៩ ទៅ៤១ ឆ្នាំ នៅអាកាសយានដ្ឋានអន្តរជាតិគូឡាឡាំពួរថា "ពួកគេត្រូវឆ្លងកាត់ដំណើរការឯកសារផ្លូវច្បាប់មុនពេលត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅប្រទេសវិញ" ។ លោក Hussein បាននិយាយថា វិធីសាស្ត្រប្រតិបត្តិការរបស់ក្រុមឆបោកនោះ គឺផ្តល់ជូនជនរងគ្រោះនូវការងារដែលសន្យាថានឹងទទួលបានប្រាក់ខែច្រើននៅមជ្ឈមណ្ឌលហៅទូរស័ព្ទក្នុងប្រទេសកម្ពុជាតាមរយៈបណ្តាញទំនាក់ទំនងសង្គមដូចជា Facebook និង WeChat ។ «នៅពេលដែលពួកគេ (ម៉ាឡេស៊ី) ទៅដល់ទីនោះ (កម្ពុជា) ស្ថានភាពមិនដូចអ្វីដែលពួកគេបានសន្យានោះទេ។ ជនរងគ្រោះបានដឹងថាពួកគេត្រូវបានគេបោកប្រាស់ ប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅម៉ាឡេស៊ីវិញទេ។

លោក Hussein ដែលមិនបានបដិសេធពីលទ្ធភាពដែលជនជាតិម៉ាឡេស៊ីឃុបឃិតជាមួយក្រុមឆបោកទាំងនោះនៅកម្ពុជាថា នៅមានអ្នកដែលអះអាងថា រងការគំរាមកំហែង និងត្រូវបានរំលោភបំពានរាងកាយ។ មន្ត្រីកម្ពុជាដែលនិយាយទៅកាន់កាសែតខ្មែរថាមស៍ក្នុងលក្ខខណ្ឌមិនបញ្ចេញឈ្មោះបាននិយាយថា នគរបាលម៉ាឡេស៊ីក៏គួរតែយកចិត្តទុកដាក់បន្ថែមទៀត ចំពោះអ្នកជ្រើសរើសពលករ ដែលកំពុងធ្វើការនៅប្រទេសម៉ាឡេស៊ីដែលកំពុងទាក់ទាញប្រជាជនម៉ាឡេស៊ីដែលងាយរងគ្រោះមកកម្ពុជាពីការផ្តល់ជូនការងារក្លែងក្លាយ។ "ការផ្តល់ជូនការងារអាចក្លែងក្លាយ ប៉ុន្តែទោះបីជាមានព័ត៌មានជាសាធារណៈយ៉ាងទូលំទូលាយអំពីសកម្មភាពបែបនេះដែលត្រូវបានផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជា និងម៉ាឡេស៊ី និងកន្លែងផ្សេងទៀត រួមទាំងប្រទេសថៃ និងឥណ្ឌូនេស៊ីក៏ដោយ ក៏អ្នកជ្រើសរើសនៅតែអាចទាក់ទាញដោយការបញ្ឆោះបញ្ឆូល។

"ប្រសិនបើអាជ្ញាធរម៉ាឡេស៊ីអាចជួយយើងក្នុងការចាប់អ្នកជ្រើសរើស យើងអាចប្រើប្រាស់ព័ត៌មានដែលទទួលបានពីភ្នាក់ងារការងារខុសច្បាប់ទាំងនេះ ដើម្បីហាមឃាត់សមភាគីរបស់ពួកគេនៅទីនេះ។ រហូតមកដល់ពេលនេះ ស្ថានទូតម៉ាឡេស៊ី ថៃ និងឥណ្ឌូនេស៊ី បាននិងកំពុងសហការយ៉ាងល្អជាមួយយើង ដើម្បីទប់ស្កាត់សកម្មភាពទាំងនេះ ដែលនាំឲ្យខូចឈ្មោះដល់កម្ពុជា»។ *New Straits Times/Khmer Times*

# ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/07/10/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអាទិត្យ ១២កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុ៉ឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន (មេបញ្ជាការកងអនុសេនាធំ)

បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២លើក សរុបចំនួន២៣នាក់ ស្រី៨នាក់ ។

ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្វែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## ប្រទេសវៀតណាមនិយាយថាត្រូវការកិច្ចប្រឹងប្រែងបន្ថែមទៀតដើម្បីការពារប្រជាជនដែលត្រូវបានគេជួញដូរមកកម្ពុជាដើម្បីរកការងារធ្វើ

https://www.khmertimeskh.com/ Khmer Times July 11, 2022

វៀតណាម និងកម្ពុជា មានកិច្ចព្រមព្រៀងសហប្រតិបត្តិការការងារ ដើម្បីធានាការការពារផ្លូវច្បាប់ដល់ពលករគ្នាទៅវិញទៅមក ប៉ុន្តែហាក់បីដូចជាពលករវៀតណាមជាច្រើនកំពុងត្រូវបានបោកបញ្ឆោតឱ្យមកធ្វើការនៅកម្ពុជាក្នុងស្ថានភាពដ៏អាក្រក់។

ព័ត៌មាននេះត្រូវបានបង្ហាញដោយលោក Nguyễn Gia Liêm អនុប្រធាននាយកដ្ឋានការងារនៅបរទេស (DOLAB) ក្រោមក្រសួងការងារ យុទ្ធជនពិការ និងសង្គមកិច្ច។ លោកថា ពលករទាំងនោះមិនបានធ្វើការនៅបរទេសក្រោមកិច្ចសន្យាការងាររបស់សហគ្រាសដែលមានអាជ្ញាប័ណ្ណទេ ប៉ុន្តែឆ្លងដែនខុសច្បាប់តាមផ្លូវគោក។ កាលពីមុន នាយកដ្ឋានការងារនៅបរទេស បានចេញការព្រមាន និងអនុសាសន៍ទូទៅសម្រាប់ពលករដែលមានបំណងទទួលបានការងារនៅក្រៅប្រទេស។ ទោះជាយ៉ាងណាមិនដែលមានការព្រមានជាច់ដោយឡែកសម្រាប់ទីផ្សារកម្ពុជាទេ។ នាយកដ្ឋានការងារនៅបរទេស ណែនាំឱ្យពលករស្វែងរកព័ត៌មានអំពីទីផ្សារការងារបរទេសយ៉ាងសកម្ម ដើម្បីមើលថាតើពួកគេអាចបំពេញតម្រូវការការងារបានដែរឬទេ។ ពលករត្រូវទាក់ទងសហគ្រាសដែលមានលិខិតអនុញ្ញាតបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស។ បញ្ជីនៃសហគ្រាសត្រូវបានបង្ហោះនៅលើគេហទំព័ររបស់នាយកដ្ឋានការងារនៅបរទេស។ ឬពួកគេអាចទាក់ទងភ្នាក់ងារគ្រប់គ្រងការងារនៅតាមមូលដ្ឋានរបស់ពួកគេសម្រាប់ការណែនាំបន្ថែម។

លោក Liêm ក៏បានស្នើថា នៅពេលដែលកម្មករ ឬសារព័ត៌មានទទួលបានព័ត៌មានអំពីការបោកប្រាស់បុគ្គលិក ពួកគេគួរតែផ្តល់ព័ត៌មានដល់ភ្នាក់ងារគ្រប់គ្រង។ ដោយផ្អែកលើព័ត៌មាន DOLAB អាចស្នើសុំអាជ្ញាធរមូលដ្ឋានដើម្បីចុះអធិការកិច្ច។ បើស្ថាប័នណាមួយ ឬបុគ្គលណាប្រព្រឹត្តល្មើសច្បាប់ ត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់។ ទាក់ទងនឹងល្បិចបោកប្រាស់ពលករ លោក Liêm បាននិយាយថា "ការប្រើប្រាស់បណ្តាញសង្គម អង្គការ និងបុគ្គលជាច្រើនដែលមិនអនុញ្ញាតឱ្យយកពលករទៅធ្វើការនៅបរទេសបានផ្តល់ព័ត៌មានមិនពិតដល់ពួកគេ។ ពួកគេបានបង្កើតគេហទំព័រ និងក្រុមនៅលើ Zalo ដើម្បីទទួលបានការជឿទុកចិត្តពីពលករ"។ លោកបានបន្តថា៖ «អង្គការ និងបុគ្គលមួយចំនួនប្រើរូបភាពពលករដែលធ្វើការនៅបរទេសដើម្បីបង្ហោះលើគេហទំព័រក្លែងក្លាយដូចជាសហគ្រាសល្បីឈ្មោះដើម្បីទាក់ទាញការចាប់អារម្មណ៍របស់ពលករ»។ ការទប់ស្កាត់បញ្ហានេះ ទាមទារឱ្យមានការសម្របសម្រួលជាមួយសមត្ថកិច្ច និងស្ថាប័នពាក់ព័ន្ធនានា ដើម្បីស្វែងរកជនល្មើសច្បាប់ និងជូនដំណឹងដល់ពលករ។

មុននេះ ដូចដែលសារព័ត៌មានបានរាយការណ៍មកថា នៅខេត្តផ្សេងៗដូចជា Ninh Binh និង Thanh Hóa មានមនុស្សមួយចំនួនបានបង្ហោះព័ត៌មានជ្រើសរើសបុគ្គលិកនៅលើបណ្តាញសង្គម ឬបានជួបដោយផ្ទាល់ និងស្នើសុំពលករទៅធ្វើការនៅបរទេសនៅក្នុងប្រទេសកម្ពុជា។ ពួកគេបានសន្យាថា នឹងផ្តល់ប្រាក់ឈ្នួលខ្ពស់ដល់កម្មករ ប៉ុន្តែតាមពិតធ្វើការនៅក្នុងកាស៊ីណូ។ អាជ្ញាធរមូលដ្ឋានបានចេញសេចក្តីជូនដំណឹងដើម្បីទប់ស្កាត់បញ្ហានេះ។ នៅ

ក្នុងខេត្ត Gia Lai ភាគកណ្តាល ឆ្មាំព្រំដែនខេត្តក៏បានរកឃើញថា ក្មេងជំទង់មួយចំនួនដែលចង់ស្វែងរកការងារដែលមានប្រាក់ចំណូលខ្ពស់ ត្រូវបានគេបោកបញ្ឆោតឱ្យទៅប្រទេសកម្ពុជា បន្ទាប់មកត្រូវបានគេជំរិតយកលុយជាថ្លៃលោះខ្លួន។ នៅម៉ោង៦ល្ងាច ថ្ងៃទី៣ ខែកក្កដា កងកម្លាំងឆ្មាំព្រំដែនបានទទួល Pui Thái អាយុ២៨ ឆ្នាំ និង Pui Phu អាយុ១៦ ឆ្នាំ នៅអាកាសយានដ្ឋាន Pleiku ក្នុងខេត្ត Gia Lai ។ ពួកគេមកពីឃុំ Ia O ស្រុក Ia Grai ។ ពួកគេជាមនុស្សពីរនាក់ក្នុងចំណោមមនុស្សប្រាំពីរនាក់ដែលត្រូវបានគេនាំមកកម្ពុជាដោយខុសច្បាប់ដើម្បីធ្វើការ។

លោកវរសេនីយ៍ទោ Đinh Văn Sơn អនុប្រធាននាយកដ្ឋានការពារសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណែត និងបច្ចេកវិជ្ជាខ្ពស់ ក្រោមការដឹកនាំរបស់នគរបាល Gia Lai បាននិយាយថា ការជ្រើសរើសពលករទៅក្រៅប្រទេសគឺពិតជាការបោកប្រាស់។ ភាគច្រើននៃអ្នកចាញ់បោកទាំងនោះគឺជាក្មេងជំទង់ដែលត្រូវបានសន្យាថា "ការងារងាយស្រួល និងប្រាក់ខែខ្ពស់"។ ការពិតធ្វើឱ្យគ្រួសាររបស់ពួកគេស្ថិតក្នុងស្ថានភាពលំបាក។ ឧក្រិដ្ឋជនទាំងនេះតែងតែបង្ខំជនរងគ្រោះឱ្យបោកប្រាស់អ្នកដទៃ។ ប្រសិនបើពួកគេមិនព្រម ពួកគេបង្ខំជនរងគ្រោះឱ្យបង់ប្រាក់ពិន័យប្រហែល ១០០០ ដុល្លារ ឬត្រូវគេវាយដំ និងបង្អត់អាហារ។

ជាការឆ្លើយតបនឹងបញ្ហានេះ អនុប្រធានគណៈកម្មាធិការប្រជាជនខេត្ត Gia Lai លោក Nguyễn Thi Thanh Lịch កាលពីថ្ងៃសុក្រសប្តាហ៍មុនបានផ្ញើឯកសារទៅកាន់គណៈកម្មាធិការណសិរ្សមាតុភូមិខេត្ត មន្ទីរការងារ យុទ្ធជនពិការ និងសង្គមកិច្ច នគរបាល និងគណៈកម្មាធិការប្រជាជនស្រុក ដើម្បីពិនិត្យ និងរាយការណ៍ប្រសិនបើពលករ នៅតំបន់របស់ពួកគេត្រូវបានបោកបញ្ឆោតឱ្យមកធ្វើការខុសច្បាប់នៅកម្ពុជា។ គណៈកម្មាធិការប្រជាជនខេត្តក៏បានចាត់ឲ្យប៉ូលិសស្នើវិធានការបង្ការ។ ខ្លួនបានស្នើឱ្យគណៈកម្មាធិការប្រជាជនមូលដ្ឋានពិនិត្យយ៉ាងសកម្មនូវស្ថានភាពការងារនៅក្នុងតំបន់ និងពង្រឹងការអប់រំដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ខ្លួនបានណែនាំដល់ស្ថាប័នពាក់ព័ន្ធ ឱ្យធ្វើសកម្មភាពសម្របសម្រួលជាមួយស្ថានបេសកកម្មការទូត និងស្ថានកុងស៊ុលវៀតណាមប្រចាំនៅកម្ពុជា ដើម្បីមានផែនការជួយសង្គ្រោះអ្នកដែលនៅតែស្ថិតក្នុងប្រទេសកម្ពុជា។

ស្ថិតិរបស់នគរបាលខេត្តបានឲ្យដឹងថា ក្នុងរយៈពេល៦ខែ ដើមឆ្នាំនេះ ករណីឆបោកចំនួន៤៣ករណី ត្រូវបានរាយការណ៍ថា មានទឹកប្រាក់ជាង ២៦ពាន់លានដុង (១.១លានដុល្លារ)។ "អ្នកដែលត្រូវការស្វែងរកការងារធ្វើគួរតែសិក្សាឱ្យបានច្បាស់ជាមុន និងអនុវត្តតាមនីតិវិធីដែលបានកំណត់អំពីកិច្ចសន្យាការងារ។ ពួកគេគួរតែទាក់ទងអាជ្ញាធរមូលដ្ឋាន ឬនាយកដ្ឋានការងារ ជនពិការ និងកិច្ចការសង្គម ដើម្បីទទួលបានការណែនាំ និងជំបូន្មានជាក់លាក់។ ប្រជាជនត្រូវតែប្រុងប្រយ័ត្នចំពោះព័ត៌មាននៅលើបណ្តាញសង្គម ចាំបាច់ត្រូវមានការផ្ទៀងផ្ទាត់ ដើម្បីចៀសវាងការបោកប្រាស់"៕ *VNS*

## ការជួញដូរមនុស្ស ពលកម្មដោយបង្ខំ ចិញ្ចឹមទាសភាពសម័យទំនើបនៅអាមេរិក

https://dap-news.com/ ByKD102Posted on July 11, 2022

**វ៉ាស៊ីនតោន៖ លោកស្រី Flor Molina ដើមកំណើតម៉ិកស៊ិកធ្លាប់ជា ជនរងគ្រោះនៃទាសភាពសម័យទំនើបដែលត្រូវបានថ្កោលទោស ចំពោះការបង្ខំឱ្យធ្វើការនៅក្នុងឧស្សាហកម្ម កាត់ដេរនៅក្នុងទីក្រុង Los Angeles សហរដ្ឋអាមេរិក បន្ទាប់ពីបានធ្វើចំណាកស្រុក នៅទីនោះដោយមានជំនួយពីមនុស្សម្នាក់ ដែលប្រែទៅជាអ្នកជួញដូរមនុស្ស។** អស់រយៈពេល ៤០ថ្ងៃ លោកត្រូវបានបង្ខិតបង្ខំឱ្យធ្វើការ ១៨ម៉ោងក្នុងមួយថ្ងៃនៅរោងចក្រកាត់ដេរ ដោយគ្មានប្រាក់ឈ្នួលដោយ សំលៀកបំពាក់ ដែលលក់ក្នុងតម្លៃ ២០០ដុល្លារនៅក្នុងហាងទំនិញ។ លោកស្រី Molina ត្រូវបានគេធ្វើឱ្យដេកក្នុងឃ្លាំងរោងចក្រ ដោយចែកពូកតែមួយ ជាមួយជនរងគ្រោះម្នាក់ទៀត និងសម្អាតកន្លែងបន្ទាប់ ពីធ្វើការនេះបើយោងតាមការចុះផ្សាយ របស់ទីភ្នាក់ងារសារព័ត៌មានចិនស៊ិនហួ។

ទុក្ខលំបាករបស់លោកស្រី បានបញ្ចប់កាលពី ២០ឆ្នាំមុន នៅពេលដែលលោកស្រី អាចរត់គេចបានមួយថ្ងៃ ប៉ុន្តែសម្រាប់ជនចំណាកស្រុកជាច្រើន នាក់ទៀត សុបិន្តអាក្រក់របស់ពួកគេ នៅតែបន្តកើតឡើងដដែល។ មនុស្សជាង ៥០ម៉ឺននាក់នៅក្នុងសហរដ្ឋអាមេរិក ដែលភាគច្រើនជាជនចំណាកស្រុក បច្ចុប្បន្នរស់នៅក្នុងលក្ខខណ្ឌទាសភាព នេះបើយោងតាមទិន្នន័យ ពីសាកលវិទ្យាល័យ Denver ។ អ្នកផ្សេងទៀតបានស្លាប់នៅក្នុង ដំណើរការនៃការធ្វើចំណាកស្រុក ដូចជាជនចំណាកស្រុកម៉ិកស៊ិក និងអាមេរិកកណ្តាលជាង ៥០នាក់ដែលបានចាកចេញទៅ បានស្លាប់នៅក្នុងឈុតខ្លីៗ ដែលត្រូវបានចាក់សោកាលពីចុងខែមិថុនានៅ San Antonio រដ្ឋតិចសាស់។

គម្រោង "បញ្ចប់ទាសភាពឥឡូវនេះ" ដែលស្វែងរកការលើកកម្ពស់ការយល់ដឹង អំពីពលកម្មដោយបង្ខំនៅក្នុងសហរដ្ឋអាមេរិក ប្រាប់ពីស្ថានភាពរបស់លោកស្រី Molina និងអ្នកផ្សេងទៀតដូចជាលោកស្រី នៅលើបណ្តាញសង្គមរបស់ខ្លួន ដោយកត់សម្គាល់ពីប្រេវ៉ាឡង់នៃករណី បែបនេះនៅក្នុងប្រទេស ដែលប្រកាសដោយខ្លួនឯងថា ជាអ្នកការពារសិទ្ធិមនុស្ស ៕ ប្រែសម្រួល ឈូក បូរ៉ា

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/07/11/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១០ និង០០នាទី នាថ្ងៃចន្ទ ១៣កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង កម្លាំងប៉ុស្តិ៍គីឡូ១៣ បានសហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន និងកម្លាំងយោធាវរសេនាតូច៥៣៣ បានទទួលប្រជាពលរដ្ឋដែលឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១៩នាក់ ស្រី៧នាក់ ក្មេងស្រី២នាក់។

ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្តែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## លោកស្រីអនុសេនីយ៍នាយរងប៉ុស្តិ៍នគរបាលមហាខ្ញូង ស្រុកកោះសូទិន បានដឹកនាំកម្លាំងប៉ុស្តិ៍ ចុះផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពនៅក្នុងមូលដ្ឋានរបស់ខ្លួន

https://gdlf-kh.com/ 11/07/2022 Sopha កំពង់ចាម

កំពង់ចាម ៖ ដោយអនុវត្តតាមផែនការសកម្មភាពរបស់ប៉ុស្តិ៍ និងអនុវត្តការងារនគរបាល និងសហគមន៍ នៅព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ លោកនាយប៉ុស្តិ៍នគរបាលរដ្ឋបាលមហាខ្ញូង នៃអធិដ្ឋាននគរបាលស្រុកកោះសូទិន បានចាត់ឲ្យលោកស្រី ស៊ិន ស៊ាងហៃ នាយរងប៉ុស្តិ៍ ដឹកនាំកម្លាំងក្រោមឱវាទ ចុះផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់សិស្សានុសិស្សនៅវិទ្យាល័យមហាមង្គល ហ៊ុន សែន មហាសៀក ស្ថិតនៅភូមិមហាសៀកលើ ឃុំមហាខ្ញូង ស្រុកកោះសូទិន ខេត្តកំពង់ចាម ។ ឆ្លៀតក្នុងឱកាសនេះផងដែរ លោកស្រីនាយរងប៉ុស្តិ៍ បានធ្វើការផ្សព្វផ្សាយមួយចំនួន៖

-សេចក្តីជូនដំណឹងរបស់លោកឧត្តមសេនីយ៍ស្នងការនគរបាលខេត្តកំពង់ចាម

-ផលប៉ះពាល់នៃគ្រឿងញៀន

-ច្បាប់ចរាចរណ៍ផ្លូវគោក
-ផលប៉ះពាល់អំពើហិង្សាក្នុងគ្រួសារ ទាក់ទងនឹងយេនឌ័រ
-ជំរុញអោយប្រជាពលរដ្ឋមានអាយុ១៥ឆ្នាំឡើងទៅធ្វើអត្តសញ្ញាណប័ណ្ណអោយបានគ្រប់ៗគ្នា
-ការផ្តល់អត្តសញ្ញាណប័ណ្ណ, សៀវភៅ (ក២) និងសៀវគ្រួសារ (ក៤) ដោយឥតគិតថ្លៃ
-ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយល់ដឹងពីធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (គ្រឹះស្ថានឯកជន) ដែលស្របច្បាប់ និងគ្មានច្បាប់ ក្នុងការផ្តល់សេវាប្រាក់កម្ចី និងប្រាក់បញ្ញើ ដើម្បីកុំឲ្យចាញ់បោកគេ
-ផ្សព្វផ្សាយអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស
-បានចែកលេខទូរស័ព្ទនគរបាលជូនប្រជាពលរដ្ឋ មានប្រជាពលរដ្ឋចូលរួមចំនួន៤៨នាក់ ស្រី៣៧នាក់ ៕

## រដ្ឋាភិបាលត្រូវរង់ចាំ MoU សម្រាប់ស្ត្រីបម្រើការងារតាមផ្ទះនៅប្រទេសម៉ាឡេស៊ី

https://www.khmertimeskh.com/ ឈុន ស៊ុនលី July 12, 2022

កម្ពុជានឹងរង់ចាំការស្នើសុំអនុស្សរណៈនៃការយោគយល់គ្នា (MoU) ដែលក្រសួងធនធានមនុស្សម៉ាឡេស៊ីគ្រោងនឹងដាក់ជូនគណៈរដ្ឋមន្ត្រីម៉ាឡេស៊ី ដើម្បីនាំពលករបរទេស ជាពិសេសអ្នកបម្រើការងារតាមផ្ទះដែលកាន់សាសនាមូស្លីមពីកម្ពុជាទៅកាន់ប្រទេសម៉ាឡេស៊ី។ ក្រសួងការងារកម្ពុជាបាននិយាយថាក្រសួងមិនទាន់ទទួលបានដំណឹងពីម៉ាឡេស៊ីទាក់ទងនឹងចេតនានាំស្ត្រីបម្រើការងារតាមផ្ទះពីកម្ពុជាទៅធ្វើការនៅប្រទេសម៉ាឡេស៊ីទេ។

នៅពេលទាក់ទងលោក ហេង សួរ អ្នកនាំពាក្យក្រសួងបាននិយាយថា វាអាស្រ័យលើបុគ្គលម្នាក់ៗប្រសិនបើគាត់ចង់ទៅធ្វើការនៅបរទេស។ លោកបន្តថា៖ «ពួកគេមានសិទ្ធិក្នុងការជ្រើសរើស ប៉ុន្តែក្រសួងនឹងសិក្សា MoU ដែលបានស្នើឡើង ហើយនឹងផ្តល់យោបល់ដល់ពលរដ្ឋយើងទៅតាមនោះ»។ កាសែត ខ្មែរថាមស៍ បានទាក់ទងទៅលោក ហេង សួរ ដើម្បីសុំការអត្ថាធិប្បាយបន្ទាប់ពីរបាយការណ៍របស់កាសែត Straits Times ដែលដកស្រង់សម្តីលោក M.Saravanan រដ្ឋមន្ត្រីក្រសួងធនធានមនុស្សម៉ាឡេស៊ី ថាក្រសួងរបស់លោកនឹងបង្ហាញ MoU ដែលស្នើទៅគណៈរដ្ឋមន្ត្រី ដើម្បីនាំពលករបរទេស ជាពិសេសស្ត្រីបម្រើការងាតផ្ទះដែលកាន់សាសនាឥស្លាមពីកម្ពុជា។ លោកបាននិយាយកាលពីថ្ងៃសៅរ៍ថាក្រសួងរបស់លោកបានឆ្លងកាត់ដំណាក់កាលជាច្រើនពាក់ព័ន្ធនឹងបញ្ហានេះ ហើយ MoU ត្រូវបានគេរំពឹងថានឹងបញ្ចប់ក្នុងពេលឆាប់ៗនេះ។ លោកបន្តថា៖ «យើងកំពុងស្ថិតក្នុងដំណើរការ (នៃការបញ្ចប់ព័ត៌មានលម្អិត) ហើយវានឹងត្រូវការពេលវេលា ប៉ុន្តែយើងកំពុងព្យាយាមបង្កើនល្បឿនហើយ»។ លោកត្រូវបានគេដកស្រង់សម្តីថា៖ «ខ្ញុំបានពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជា ហើយពួកគេនឹងផ្តល់ឱកាសដល់យើង (ដើម្បីនាំអ្នកបម្រើការងារតាមផ្ទះមកធ្វើការវិញ)»។ លោក ហេង សួរ បាននិយាយថា លោកមិនប្រាកដថាតើមានពលរដ្ឋខ្មែរប៉ុន្មាននាក់ដែលកំពុងធ្វើការនៅប្រទេសម៉ាឡេស៊ីនោះទេ។ លោកបន្តថា៖ «ប្រហែល ២០ ភាគរយនៃកម្មករចំនួន ១០០.០០០ នាក់ត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសម៉ាឡេស៊ី ដោយសារជំងឺកូវីដ-១៩ ប៉ុន្តែអ្នកបម្រើមួយចំនួននៅតែបន្តលាក់ខ្លួន និងធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ីមកដល់សព្វថ្ងៃនេះ»។

លោក មឿន តុលា នាយកប្រតិបត្តិ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សមិនពេញចិត្តនឹងការបញ្ជូនពលរដ្ឋខ្មែរទៅធ្វើការជាអ្នកបម្រើនៅបរទេស។ លោកនិយាយថា៖ «ខ្ញុំដឹងពីករណីរំលោភបំពានអ្នកបម្រើយ៉ាងហោចណាស់ប្រាំមួយករណី រួមមានការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការធ្វើការដោយគ្មានប្រាក់ខែ»។ លោកបន្តថាមានបញ្ហាជាច្រើនពាក់ព័ន្ធនឹងស្ត្រីបម្រើការងារនៅបរទេស ហើយរដ្ឋាភិបាលត្រូវតែសិក្សាករណីនេះឲ្យបានហ្មត់ចត់ និងបង្កើតគោលនយោបាយ និងយន្តការនានា ដើម្បីធានាថាប្រជាពលរដ្ឋរបស់

យើងត្រូវបានការពារ និងយកចិត្តទុកដាក់នៅពេលទៅធ្វើការនៅក្រៅប្រទេស។ លោកថា៖ «ការបំពានត្រូវតែបញ្ឈប់។ រដ្ឋាភិបាលមិនត្រូវប្រញាប់ប្រញាល់ចុះហត្ថលេខាលើ MoU នោះទេ ប៉ុន្តែត្រូវចំណាយពេលរៀបចំយន្តការដើម្បីទប់ស្កាត់រាល់បញ្ហាដែលអាចកើតឡើង។ យើងត្រូវតែការពារសិទ្ធិរបស់ស្ត្រី»៕

## ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២
## ជនជាតិវៀតណាមដែលត្រូវបានគេជួញដូរមកកម្ពុជា ត្រូវបានសន្យាផ្តល់អត្ថប្រយោជន៍ខ្ពស់ ដែលពួកគេមិនអាចបដិសេធបាន

https://www.khmertimeskh.com/ July 12, 2022

ឈ្មួញកណ្តាលបានប្រើប្រាស់រូបថតអគារប្រណីតៗ និងពិធីជប់លៀងក្រុមហ៊ុនថតនៅកម្ពុជា ដើម្បីទាក់ទាញពលករវៀតណាម បន្ថែមពីលើការសន្យាផ្តល់ការងារសមរម្យ ជាមួយនឹងប្រាក់ខែខ្ពស់។ បន្ទាប់ពីត្រូវបានជួយសង្គ្រោះកាលពីខែមិថុនា Nguyen Van Chien អាយុ១៩ ឆ្នាំបានទៅរកភ្នាក់ងារស៊ើបអង្កេតសន្តិសុខនៃប៉ូលីសខេត្ត Thanh Hoa ដើម្បីទៅរាយការណ៍អំពី Trang Ngoc Chung អាយុ១៩ឆ្នាំ។ Chien បាននិយាយថា គាត់ស្គាល់ Chung ដែលមកពី Sam Son Town រយៈពេល៧ ឆ្នាំមកហើយ ហើយគាត់បានឮពីChung កាលពីខែកុម្ភៈថា មានការងារដែលមានប្រាក់បៀវត្សរ៍ប្រចាំខែពី៥០០-១០០០ ដុល្លារក្នុងប្រទេសកម្ពុជា។ Chung បានប្រាប់គាត់ថាការចំណាយ និងការរៀបចំការធ្វើដំណើរទាំងអស់នឹងត្រូវបានចេញដោយថៅកែ។ Chien មានការចាប់អារម្មណ៍និងទទួលយកការផ្តល់ជូននេះ ដោយសារតែគាត់មិនមានការងារពិតប្រាកដនៅពេលនោះ ហើយគិតថា Chung ជាមិត្តជិតស្និទ្ធ។ នៅដើមខែមីនា Chung បានប្រាប់ Chien ឱ្យមកហាងកាហ្វេអ៊ីនធឺណិតក្នុងក្រុង Sam Son ហើយ "មាននរណាម្នាក់នឹងមកទទួល"។ Chien បានជួបមនុស្សបីនាក់ផ្សេងទៀត ដែលនឹងទៅប្រទេសកម្ពុជាតាមការណែនាំរបស់ Chung។

អ្នកបើកតាក់ស៊ីម្នាក់បានមកយកពួកគេទាំងបួននាក់នៅម៉ោងប្រហែល ២ទៀបភ្លឺ ហើយបាននាំពួកគេទៅតាមឡានក្រុងឆ្ពោះទៅទីក្រុងហូជីមិញ។ នៅផ្លូវរថភ្លើងក្រោមដី មានក្រុមមួយបានដឹកពួកគេឡើងទៅតំបន់ភ្នំក្នុងខេត្តឡុងអាន ដើម្បីរង់ចាំដល់យប់ទើបឆ្លងដែនដោយម៉ូតូ។ ពេលនោះគឺងងឹត ពួកគេត្រូវបានជនមិនស្គាល់មុខម្នាក់នាំពួកគេឆ្លងព្រៃមកប្រទេសកម្ពុជា។ ពួកគេបានមកដល់នៅម៉ោងប្រហែល៤ទៀបភ្លឺ។

Chien បានប្រាប់ថា ការងាររបស់គាត់រួមមានកុំព្យូទ័រ និងទាក់ទាញមនុស្សឱ្យលេងហ្គេមកាតអនឡាញ និងបង្កើនការប្រាស្រ័យទាក់ទងគ្នានៅលើបណ្តាញសង្គម។ គាត់នៅជាន់ទីពីរនៃអគារការិយាល័យខ្ពស់មួយ ហើយជាន់អគារនោះមានបុគ្គលិកប្រហែល ៣០០ នាក់ ដែលភាគច្រើនជាជនជាតិវៀតណាម។ គាត់បានប្រាប់ប៉ូលីសថា ពួកគេជាច្រើននាក់ត្រូវបានវាយដំយ៉ាងឃោរឃៅក្នុងរយៈពេលមួយខែដែលគាត់នៅទីនោះ។ «អ្នកខ្លះហូរឈាមច្រមុះបន្ទាប់ពីគេវាយយ៉ាងចាស់ដៃ ព្រមទាំងប្រើដំបងធក់វាយយើងទៀតផង។ "ការស្រែកឈឺចាប់អាចត្រូវបានគេឮជាញឹកញាប់នៅក្នុងអគារ" ។ មានបន្ទប់ដាក់ទណ្ឌកម្មនៅជាន់ទី២សម្រាប់នណារម្នាក់ព្យាយាមរត់គេចមិនព្រមធ្វើការ ឬឈ្លោះជាមួយថៅកែ ហើយគាត់នឹងឮថ្ងូរឈឺចាប់រាល់ពេលដែលគាត់ដើរកាត់បន្ទប់នេះទៅបន្ទប់ទឹក។ "មិនមានការងារដែលមានប្រាក់ខែខ្ពស់ដូចការសន្យានោះទេ។ «យើងត្រូវបានគេគំរាមកំហែងឥតឈប់ឈរ និងបង្ខំឲ្យធ្វើអ្វីខុសច្បាប់»។ គាត់ត្រូវធ្វើការ ១៣-១៥ ម៉ោងក្នុងមួយថ្ងៃ ហើយត្រូវបានពិន័យប្រសិនបើគាត់មិនអាចសម្រេចគោលដៅបាន ឬព្យាយាមតវ៉ា។ អ្នកដែលចង់លាឈប់ពីការងារ ត្រូវបង់លុយពី ១២០-១៥០ លានដុង (៥.១០០-៦.៤០០ ដុល្លារ) ហើយអ្នកណាដែលព្យាយាមរត់គេច ឬរាយការណ៍ទៅប៉ូលីសត្រូវប្រឈមមុខនឹងការធ្វើបាប។

បុគ្គលិកម្នាក់បានស្លាប់បន្ទាប់ពីធ្វើការបានជាងមួយខែ ហើយប៉ូលីសចុះទៅដល់ និងស៊ើបអង្កេត។ «ពេលយើងឃើញអាជ្ញាធរ យើងស្រែកឲ្យគេជួយ»។

នៅថ្ងៃទី២៩ ខែមេសា Chien និងអ្នកមួយចំនួនទៀតបានត្រឡប់ទៅវៀតណាមវិញ។ "យើងមានសំណាងណាស់ដែលត្រូវបានរកឃើញ និងជួយសង្គ្រោះទាន់ពេល"។ Chien ស្ថិតក្នុងចំណោមមនុស្សរាប់រយនាក់ក្នុងខេត្ត Thanh Hoa ដែលត្រូវបានបោកបញ្ឆោតមកធ្វើការនៅកម្ពុជាដោយក្រុមជនពាលជួញដូរ។

Tran Chi Duy អាយុ ១៩ ឆ្នាំមកពីតំបន់ Sam Son ថ្មីៗនេះត្រូវបានសាច់ញាតិលោះបន្ទាប់ពីធ្វើការច្រើនខែនៅក្នុងកាស៊ីណូនៅប្រទេសកម្ពុជា។ គាត់និយាយថាគាត់នៅតែ "ភ័យខ្លាច" គ្រប់ពេលដែលគាត់គិតអំពីពេលវេលារបស់គាត់នៅទីនោះ។ ដោយសារជីវភាពក្រីក្រ Duy និងសាច់ញាតិធ្លាប់ឆ្លងដែនទៅធ្វើការនៅប្រទេសចិន ប៉ុន្តែវាប្រថុយពេក ហើយគាត់ក៏ប្តូររកការងារនៅជិតផ្ទះវិញ។ ពេលកំពុងស្វែងរកការងារ មិត្តចាស់ម្នាក់មកពីខេត្ត Nam Dinh ភាគខាងជើងបានប្រាប់គាត់អំពី "ការងារដែលបានប្រាក់ខែល្អ" នៅក្នុងប្រទេសកម្ពុជា ហើយគាត់ក៏បានទទួលការផ្តល់ជូននេះ។ បន្ទាប់ពីបុណ្យចូលឆ្នាំថ្មីនៅដើមឆ្នាំ២០២២ 2022 Duy និងមិត្តភក្តិបានធ្វើដំណើរទៅទីក្រុងហូជីមិញ ដើម្បីជួបបុរសម្នាក់ ហើយត្រូវបានគេនាំទៅកាន់ច្រកទ្វារព្រំដែនអន្តរជាតិ Long Binh ក្នុងខេត្ត An Giang ដើម្បីឆ្លងចូលប្រទេសកម្ពុជា។ Duy ត្រូវបានគេនាំទៅកាស៊ីណូក្បែរព្រំដែន។ ពេលគាត់ចូលទៅដល់ភ្លាមក៏បាត់ការទាក់ទងជាមួយនឹងមេខ្យល់។ ក្រោយមកថៅកែកាស៊ីណូបានប្រាប់គាត់ថាគាត់ត្រូវបានលក់ក្នុងតម្លៃ ២,៧០០ ដុល្លារ។ ទោះបីជាដឹងថាចាញ់បោកគេក៏ដោយ ក៏គាត់គ្មានជម្រើសអ្វីក្រៅពីយល់ព្រមទៅធ្វើការដោយសង្ឃឹមថានឹងអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ដើម្បីត្រឡប់ទៅផ្ទះវិញ។ បន្ទាប់ពីធ្វើការជាអ្នកវត់តុនៅកាស៊ីណូអស់រយៈពេលបីខែDuyត្រូវបានគេប្រាប់ថាគាត់ត្រូវបានគេលក់ទៅកាស៊ីណូមួយផ្សេងទៀតក្នុងតម្លៃ4៦០០ដុល្លារ។ នៅកន្លែងថ្មី គាត់ត្រូវបានគេផ្តល់កុំព្យូទ័រ និងទូរស័ព្ទដើម្បីបញ្ចុះបញ្ចូលអតិថិជនអោយលេងល្បែងតាមអនឡាញ។

"រៀងរាល់ថ្ងៃ ខ្ញុំត្រូវធ្វើការ ១៤-១៥ ម៉ោង ខណៈដែលត្រូវបានសន្តិសុខត្រួតពិនិត្យជាប់ជានិច្ច ដោយពួកគេមានកាន់កាំភ្លើង និងគំរាមខ្ញុំ។ គាត់មិនបានទទួលប្រាក់ខែទេ ដោយអ្នកគ្រប់គ្រងនិយាយថាប្រាក់ខែរបស់គាត់បានចំណាយទៅលើការរស់នៅរបស់គាត់។ បន្ទាប់ពីគេងមិនលក់ជាច្រើនយប់ដោយសារតែការភ័យខ្លាច Duy និងមិត្តម្នាក់និយាយថាពួកគេចង់ត្រឡប់ទៅប្រទេសវៀតណាមវិញ ប៉ុន្តែត្រូវបានថៅកែប្រាប់ពួកគេថាពួកគេត្រូវការបង់ប្រាក់ចំនួន១៤០ លានដុង ឬនឹងត្រូវលក់ទៅកាស៊ីណូផ្សេងទៀត។ ត្រង់ចំណុចនេះ Duy ត្រូវបង្ខំចិត្តទូរស័ព្ទទៅផ្ទះ និងស្វែងរកជំនួយពីក្រុមគ្រួសារ។ គ្រួសារគាត់បានបញ្ចាំផ្ទះដើម្បីយកប្រាក់លោះ។

យោងតាមលោកវរសេនីយ៍ឯក Nguyen Thanh Binh ប្រធាននាយកដ្ឋានសន្តិសុខប៉ូលីសខេត្ត Thanh Hoa ភាគច្រើននៃជនរងគ្រោះទាំង១៩ នាក់ដែលទើបត្រូវបានជួយសង្គ្រោះដោយអាជ្ញាធរកម្ពុជាត្រូវបានបោកបញ្ឆោតដោយមនុស្សដែលពួកគេបានស្គាល់ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមជាមួយនឹងការផ្តល់ជូនអត្ថប្រយោជន៍ដ៏គួរឱ្យទាក់ទាញ។ ជនរងគ្រោះទាំងអស់សុទ្ធតែជាយុវជនដែលមានសុខភាពល្អ គ្មានការងារធ្វើជាប់លាប់ ដែលចូលចិត្តលេង និងចេះប្រើប្រាស់កុំព្យូទ័រ។ ឈ្មួញកណ្តាលជួយអ្នកនៅក្នុងប្រទេសកម្ពុជា ទាក់ទាញជនរងគ្រោះដោយប្រើរូបថតនៃពិធីជប់លៀង និងអគារនានាក្នុងប្រទេសកម្ពុជាដើម្បីធ្វើជានុយ។

យោងតាមនាយកដ្ឋានសន្តិសុខខាងក្រៅ មានករណីចំនួន ៣៨១នាក់ដែលទៅធ្វើការដោយខុសច្បាប់នៅកម្ពុជា។ ក្នុងចំណោមពួកគេ ១៧៩នាក់ បានត្រឡប់មកផ្ទះវិញ ខណៈអ្នកនៅសេសសល់កំពុងធ្វើការខុសច្បាប់ក្នុងប្រទេសកម្ពុជា ក្នុងនោះមាន ២១នាក់នៅទីតាំងល្បែងស៊ីសង។ រហូតមកដល់ពេលនេះ ប៉ូលីសបានចោទប្រកាន់ចំនួន ៨ នាក់ពីបទឆបោក និងជួញដូរមនុស្សមកកម្ពុជា។

ក្រសួងការបរទេសកម្ពុជា បានប្រកាសកាលពីពេលថ្មីៗនេះថា មកទល់នឹងពេលនេះ អាជ្ញាធរវៀតណាម និងកម្ពុជា បានសហការគ្នាធ្វើមាតុភូមិនិវត្តន៍ ជនជាតិវៀតណាមចំនួន ៤០០នាក់ ដែលត្រូវបានក្រុមជួញដូរបោកបញ្ឆោត និងលក់នៅកម្ពុជា។

ក្រសួងសន្តិសុខសាធារណៈបានក្រើនរំលឹកប្រជាពលរដ្ឋឲ្យប្រុងប្រយ័ត្ននឹងការចាញ់បោកដោយសន្យាផ្តល់ការងារមានប្រាក់ខែខ្ពស់នៅកម្ពុជា។ មុនពេលសម្រេចចិត្តទៅធ្វើការ ចាំបាច់ត្រូវធ្វើការស្រាវជ្រាវឲ្យបានត្រឹមត្រូវអំពីទិសដៅ និងអត្តសញ្ញាណរបស់អ្នកដែលផ្តល់ការងារនោះ។ *VnExpress*

## ជនជាតិវៀតណាម ៤០០នាក់ ដែលត្រូវបានគេបោកបញ្ឆោតមកធ្វើការខុសច្បាប់នៅកម្ពុជា ត្រូវបានជួយសង្គ្រោះ

https://www.khmertimeskh.com/ July 12, 2022

អាជ្ញាធរវៀតណាម និងកម្ពុជា បានសហការគ្នាធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋវៀតណាម ៤០០នាក់ ដែលត្រូវបានបោកបញ្ឆោតនិងលក់មកកម្ពុជា។ មកទល់ពេលនេះ អាជ្ញាធរក្នុងប្រទេសវៀតណាម និងកម្ពុជា បានធ្វើការរួមគ្នា ដើម្បីផ្ទៀងផ្ទាត់ករណីដែលជនជាតិវៀតណាម ត្រូវបានក្រុមជួញដូរមនុស្សនាំមកកម្ពុជា។

អ្នកនាំពាក្យក្រសួងការបរទេសលោកស្រី Le Thi Thu Hang បាននិយាយកាលពីសប្តាហ៍មុនថា កិច្ចសហប្រតិបត្តិការនេះនាំឱ្យជនជាតិវៀតណាមជិត ៤០០ នាក់ត្រូវបានជួយសង្គ្រោះ និងនាំយកមកផ្ទះវិញ។ មួយរយៈចុងក្រោយនេះ ត្រូវបានគេរាយការណ៍កាន់តែច្រើនឡើងថា មានជនជាតិវៀតណាមជាច្រើនត្រូវបានបោកបញ្ឆោតឱ្យមកធ្វើការនៅកម្ពុជា។ ក្នុងករណីភាគច្រើន ក្រុមជួញដូរបានផ្សព្វផ្សាយសេវាកម្មរបស់ពួកគេនៅលើ Facebook និង Zalo ដែលជាកម្មវិធីផ្ញើសារ និងហៅទូរសព្ទរបស់វៀតណាម ដោយផ្តោតលើមនុស្សដែលគ្រប់អាយុធ្វើការ ប៉ុន្តែមិនមានការងារជាប់លាប់ ដោយសន្យាផ្តល់ប្រាក់បៀវត្សរ៍ប្រចាំខែរហូតដល់រាប់ពាន់ដុល្លារ។ ជាធម្មតាជនរងគ្រោះត្រូវបានរត់ពន្ធចូលប្រទេសកម្ពុជាខុសច្បាប់ ហើយត្រូវបានបញ្ជូនទៅធ្វើការនៅក្រុមហ៊ុនបរទេស។ ម្ចាស់ក្រុមហ៊ុនទាំងនេះនឹងស្នើឱ្យបុគ្គលិកវៀតណាមរបស់ពួកគេបង្កើតគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗគ្នា ដែលក្លែងបន្លំជាគេហទំព័រពាណិជ្ជកម្ម ឬវេទិកាវិនិយោគហិរញ្ញវត្ថុដើម្បីទាក់ទាញអតិថិជនដែលមិនអោយមានការសង្ស័យ។

យោងតាមនគរបាលបានឱ្យដឹងថា បើមិនព្រមធ្វើទេកម្មករវៀតណាមទាំងនោះនឹងត្រូវគេវាយនិងបង្អត់អាហារ។ ក្នុងករណីផ្សេងទៀតមនុស្ស ដែលគេរត់ពន្ធមកកម្ពុជារួមមានស្ត្រីវ័យក្មេងដែលត្រូវបានបង្ខំឱ្យធ្វើជាពេស្យាចារ។ ជនរងគ្រោះបានប្រាប់ប៉ូលីសថា អ្នកណាដែលចង់ត្រឡប់ទៅប្រទេសវៀតណាម ត្រូវតែទាក់ទងក្រុមគ្រួសាររបស់ពួកគេជាមុនសិន ហើយបង់ប្រាក់ធានាប្រហែល ៨០-១០០លានដុង (៣,៤៤៦ ដុល្លារ)។ *VnExpress*

## អ្នកឆបោកជនជាតិថៃដល់ទៅ ៨៩នាក់ ដែលធ្វើការអោយមជ្ឈមណ្ឌលហៅទូរស័ព្ទខុសច្បាប់ ត្រូវបានចាប់ខ្លួននៅក្នុងប្រទេសថៃ-កម្ពុជា

https://www.khmertimeskh.com/ July 12, 2022

ជនឆបោកថៃរាប់សិបនាក់ត្រូវបានចាប់ខ្លួន ហើយមជ្ឈមណ្ឌលហៅទូរស័ព្ទខុសច្បាប់ត្រូវបានបិទបន្ទាប់ពីប្រតិបត្តិការអនុវត្តច្បាប់រវាងកម្ពុជា និងថៃអស់រយៈពេលជាច្រើនខែបានបិទសកម្មភាពក្លែងបន្លំរបស់ពួកគេ។ យោងតាមរបាយការណ៍ផ្សេងៗគ្នា អ្នកឆបោកជនជាតិថៃពី ១៥ ទៅ ៨៩ នាក់បានចូលរួមក្នុងសកម្មភាពខុសច្បាប់មួយចំនួនក្នុងប្រទេសកម្ពុជា ដើម្បីជំរិតទារប្រាក់ដោយវិធីក្លែងបន្លំគ្រប់យ៉ាង រួមមាន ការទាក់ទងស្រលាញ់គ្នា ក្លែងបន្លំតាម DHL និងបន្លំជាមន្ត្រីប៉ូលីស។ នគរបាលប្រឆាំងបទល្មើសតាមអ៊ីនធឺណែត (Police Cyber Taskforce

(PCT) បានរាយការណ៍ថា ឧក្រិដ្ឋជនជាតិថៃ នឹងត្រូវបានធ្វើបត្យាប័នទៅប្រទេសថៃ បន្ទាប់ពីពួកគេត្រូវបានកាត់ទោសពីបទល្មើសអន្តោប្រវេសន៍។ ប្រតិបត្តិការអនុវត្តច្បាប់ បានចាប់ផ្តើមតាមដានសកម្មភាពខុសច្បាប់ កាលពីប៉ុន្មានខែមុនក្នុងរាជធានីភ្នំពេញ ព្រះសីហនុ និងប៉ោយប៉ែត ហើយបានឈានទៅចាប់ខ្លួននៅចុងខែមិថុនា និងដើមខែកក្កដា។

នគរបាលប្រឆាំងបទល្មើសតាមអ៊ីនធឺណែត បានរាយការណ៍ថា ពួកគេត្រូវបានភ្ជាប់ទៅបណ្តាញមជ្ឈមណ្ឌលហៅទូរស័ព្ទចំនួន៤ ដែលរួមមាន phony forex និងក្រុមជួញដូររូបិយប័ណ្ណឌីជីថល កន្លែងកាស៊ីណូអនឡាញខុសច្បាប់ មជ្ឈមណ្ឌលហៅទូរស័ព្ទបោកប្រាស់ដែលក្លែងខ្លួនជាស្ថានីយ៍ប៉ូលីសថៃ និងមជ្ឈមណ្ឌលហៅទូរស័ព្ទបោកប្រាស់ដែលកំពុងផ្តល់ប្រាក់កម្ចីក្លែងក្លាយនៅខេត្តព្រះសីហនុ។ ជនសង្ស័យចំនួន២១ នាក់ ដែលបានប្រើប្រាស់ Tinder ដើម្បីបោកបញ្ឆោតជនរងគ្រោះឱ្យវិនិយោគលើរូបិយប័ណ្ណគ្រីបតូ ត្រូវបាននគរបាលប្រឆាំងបទល្មើសតាមអ៊ីនធឺណែត ចាប់ខ្លួននៅថ្ងៃទី២១ ខែមិថុនា នៅសណ្ឋាគារ ឈិងធឹង (Ching Cheng Hotel) កម្ពស់ ១២ ជាន់ ក្នុងក្រុងឆ្នេរសមុទ្រ នៃខេត្តព្រះសីហនុ។

កាលពីថ្ងៃទី៦ ខែកក្កដា ជនសង្ស័យម្នាក់ទៀតឈ្មោះ Jirayu Poemchuen ត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ថាបានក្លែងជាស្នងការនគរបាល Laem Chabang ក្នុងស្រុក Si Racha នៃខេត្ត Chon Buri ។ Jirayu បានបញ្ឆុះបញ្ចូលជនរងគ្រោះឱ្យផ្ទេរប្រាក់ទៅគាត់។ នគរបាលប្រឆាំងបទល្មើសតាមអ៊ីនធឺណែត បានចាប់ខ្លួនជនសង្ស័យចំនួន១៨ នាក់ ដែលជាផ្នែកមួយនៃការឆបោកនេះនៅ Pratu Daeng ក្នុងក្រុងព្រះសីហនុ។ នៅថ្ងៃដដែលជនសង្ស័យ១០នាក់ត្រូវបានចាប់ខ្លួននៅទីតាំងមួយទៀតក្នុងខេត្តព្រះសីហនុ។ កាលពីថ្ងៃទី៧ ខែកក្កដា ក្រុមការងារ នគរបាលប្រឆាំងបទល្មើសតាមអ៊ីនធឺណែត បានចាប់ខ្លួន២៥ នាក់ទៀតនៃក្រុមឆបោកតាម មជ្ឈមណ្ឌលហៅទូរស័ព្ទ ដែលក្លែងបន្លំជាផ្នែកមួយរបស់ក្រុមហ៊ុន DHL Express Delivery ដែលប្រតិបត្តិការនៅក្នុងក្រុងប៉ោយប៉ែតនៃប្រទេសកម្ពុជា នៅជិត Aranyaprathet ប្រទេសថៃ។

អ្នកបោកប្រាស់ជាច្រើនដែលធ្វើការនៅមជ្ឈមណ្ឌលហៅទូរស័ព្ទទាំងនេះគឺជាជនជាតិមកពីតំបន់អាស៊ីអាគ្នេយ៍ដែលត្រូវបានគេបោកឱ្យធ្វើការឱ្យក្រុមជនល្មើស ដែលត្រូវបានចោទប្រកាន់ថាទទួលបានមូលនិធិដោយក្រុមឧក្រិដ្ឋកម្មឆ្លងដែនដែលគ្រប់គ្រងដោយជនជាតិចិន។ នគរបាលប្រឆាំងបទល្មើសតាមអ៊ីនធឺណែត បានរាយការណ៍ថា ជនជាតិថៃជាង៨០០ នាក់ ត្រូវបានចាប់ខ្លួន ឬជួយសង្គ្រោះពីក្រុមជនល្មើសទាំងនេះក្នុងរយៈពេលប្រាំមួយខែចុងក្រោយនេះ ហើយយ៉ាងហោចណាស់ មនុស្ស ១០០០នាក់ទៀតកំពុងធ្វើការឱ្យពួកគេ។

ឧត្តមសេនីយ៍ឯក Damrongsak Kittiprapas អគ្គស្នងការរងនគរបាលភូមិន្ទថៃ និងជាប្រធាននគរបាលប្រឆាំងបទល្មើសតាមអ៊ីនធឺណែត បានប្រាប់អ្នកយកព័ត៌មានថា ៖ «នៅពេលដំណើរការក្តីក្តាំនៅកម្ពុជាចប់ហើយ អាជ្ញាធរកម្ពុជានឹងបញ្ជូនពួកគេទៅប្រទេសថៃ ហើយខ្ញុំរួមនឹងមន្ត្រីពីនគរបាលប្រឆាំងបទល្មើសតាមអ៊ីនធឺណែត នឹងមកយកពួកគេនៅខេត្តស្រះកែវ។ *គេហទំព័រ Thaiger.com*

## ពលករខ្មែរស្នើសុំអន្តរាគមន៍ពីអគ្គកុងស៊ុលខ្មែរនៅថៃ បន្ទាប់ពីតម្រួតថៃតម្រូវឱ្យពួកគេបង់ប្រាក់ប្រចាំខែ ៦០០បាត

https://www.rfa.org/khmer/ ដោយ សុជីវី 2022.07.12

ពលករខ្មែរជាង ១០នាក់ ស្នើសុំអគ្គកុងស៊ុលខ្មែរនៅអារញ្ញ ប្រទេសថៃ អន្តរាគមន៍កុំឱ្យប៉ូលិសថៃបង្ខំពួកគេបង់ប្រាក់ចំនួន ៦០០បាត ក្នុងមួយខែ។ អគ្គកុងស៊ុលខ្មែរនៅអារញ្ញ បដិសេធថា គ្មានការបង្ខំឱ្យបង់លុយពីតម្រួតថៃនោះទេ។ ពលករខ្មែរអូសរទេះនៅផ្សាររ៉ុងក្លឿ ជាង១០នាក់ បានទៅអគ្គកុងស៊ុលខ្មែរនៅស្រុកអារញ្ញ ខេត្តស្រះកែវជាប់ព្រំប្រទល់ខេត្តបន្ទាយមានជ័យ សុំអាជ្ញាធរខ្មែរឱ្យជួយពួកគេកុំឱ្យថៃបង្ខំបង់លុយប្រចាំខែ ៦០០បាត។

ពលករខ្មែរធ្វើការនៅថៃ លោក សៅ ណារិន បង្ហាញការព្រួយបារម្ភថា ការបង្ខំឱ្យពលករខ្មែរបង់លុយប្រចាំខែ៦០០បាតបន្ថែមនេះ នឹងធ្វើឱ្យជីវភាពរបស់លោកកាន់តែជួបការលំបាក។ លោកស្នើសុំឱ្យអគ្គកុងស៊ុលខ្មែរជួយដោះស្រាយបញ្ហានេះ៖ «បើសិនជាការយកលុយហ្នឹងវាស្របច្បាប់ត្រូវតែមានក្រដាសស្នាម មានវិក្កយបត្រ មានចុងសន្លឹកអីត្រឹមត្រូវ ប៉ុន្តែអានេះគឺជាការបំពានសិទ្ធិកម្មករធ្ងន់ធ្ងរណាស់ ហើយវាជាការគំរាមកំហែងមួយធ្ងន់ធ្ងរ អារបៀបហ្នឹងឱ្យបញ្ឈប់ជាបន្ទាន់ សកម្មភាពបែបហ្នឹងនោះ»។

ប្រធានសមាគមពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ លោក ឌិន ពុទ្ធី ចាត់ទុកការចាប់បង្ខំឱ្យពលករខ្មែរនៅផ្សាររ៉ុងក្លឿបង់លុយនេះថា ជាការជម្រិតទារប្រាក់ដោយខុសច្បាប់ ព្រោះកន្លងមក ប្រទេសកម្ពុជាបានចុះអនុស្សរណៈយោគយល់ជាមួយប្រទេសថៃថា អនុញ្ញាតដល់ពលករខ្មែរដែលធ្វើការចម្ងាយ៥០០ម៉ែត្រពីព្រំដែនខ្មែរ ថៃ មិនបាច់មានប័ណ្ណការងារ ឬការបង់លុយអ្វីផ្សេងៗឡើយ ហើយផ្សាររ៉ុងក្លឿ នៅមិនហួសពីព្រំដែនកម្ពុជា ថៃ៥០០ម៉ែត្រឡើយ ខុសពីផ្សារលើដែលនៅឆ្ងាយពីព្រំដែន។ លោកស្នើឱ្យបញ្ឈប់ជាបន្ទាន់ចំពោះការចាប់ជម្រិតទាប្រាក់នេះ ព្រោះពលករខ្មែរធ្វើការនៅប្រទេសថៃកំពុងប្រឈមជីវភាពលំបាកពីការឡើងថ្លៃសាំង និងការរីករាលដាលជំងឺកូវីដ១៩។ «»

ជុំវិញរឿងនេះដែរ ជំនួយការអគ្គកុងស៊ុលខ្មែរ លោក នៀត បាន លើកឡើងថា អគ្គកុងស៊ុលខ្មែរបានទទួលការស្នើសុំអន្តរាគមន៍ពីពលករខ្មែររួចហើយ តែលោកបានបដិសេធចំពោះការចោទប្រកាន់ថាមានតម្រួតថៃបានចាប់បង្ខំពលករខ្មែរឱ្យបង់លុយ ព្រោះគ្មានភស្តុតាងណាមួយមកបញ្ជាក់ឡើយ។ លោកបញ្ជាក់ថា វាជារឿងមិនត្រឹមត្រូវនោះទេ បើសិនជាអាជ្ញាធរថៃពិតជាចាប់បង្ខំឱ្យពលករខ្មែរបង់លុយមែននោះ អគ្គកុងស៊ុលនឹងចុះជួយពលករខ្មែរ៖ «រឿងវាអត់ទាន់មានភស្តុតាងទេ គេមិនទាន់បានចាប់ បានស្អីទេបងណា គេមិនទាន់បានចាប់ទេ ខ្ញុំចុះមកធ្វើការហើយ លោកអគ្គកុងស៊ុលឱ្យខ្ញុំចុះមកធ្វើការហើយ នៅគោលដៅខាងអើ តំបន់គោលដៅគេហៅថាអើផ្សាររ៉ុងក្លឿហ្នឹង»។

ប្រភពពីពលករខ្មែរឱ្យដឹងថា ពលករខ្មែរធ្វើការនៅប្រទេសថៃ តែងតែរងការគំរាមកំហែងកន្លងមកពីអាជ្ញាធរថៃ និងម្ចាស់ក្រុមហ៊ុនថៃ។ តម្រួតថៃ ដែលមានឈ្មោះដាន ជាអ្នកដឹកនាំ បានចាប់ពលករខ្មែរអូសរទេះជិត៤០នាក់នៅផ្សាររ៉ុងក្លឿ យកទៅកត់ឈ្មោះ លេខទូរស័ព្ទ និងបង្ខំឱ្យបង់លុយប្រចាំខែ៦០០បាត នៅប៉ុស្តិ៍នគរបាលថៃខ្លងឡឹកកាលពីថ្ងៃទី៩ កក្កដាកន្លងទៅ។ ពលករខ្លះបានបង់លុយ តែពួកគេមិនបានទទួលវិក្កយបត្រ ឬលិខិតស្នាមថា បង់ទៅលើថ្លៃអ្វីនោះទេ។ ចំពោះអ្នកដែលមិនបានបង់លុយ តម្រួតថៃបានដាក់កំហិតឱ្យបង់លុយមុនថ្ងៃទី១៥ កក្កដា នឹងបានគម្រាមថា បើសិនជាពួកគេមិនបង់លុយប្រចាំខែទេ តម្រួតថៃនឹងឃាត់ខ្លួន ដកហូតរទេះយកទៅទុក៕

## ថៃកំពុងខ្វះខាតពលករចំណាកស្រុកជាងកន្លះលាននាក់ ដើម្បីជំរុញសេដ្ឋកិច្ច

https://kohsantepheapdaily.com.kh/ ១២ ខែ កក្កដា ឆ្នាំ ២០២២ ម៉ោង ១៤:៤៩

ថៃ ៖ សភាពាណិជ្ជកម្មថៃបាននិយាយនៅថ្ងៃអង្គារ ទី ១២ ខែកក្កដា នេះថា ថៃកំពុងខ្វះកម្លាំងពលករចំណាកស្រុកជាងកន្លះលាននាក់ ខណៈដែលប្រទេសនេះកំពុងងើបឡើងវិញ ក្រោយការឆ្លងរាតត្បាតកូវីដ ១៩បានស្រាកស្រាន្ត។ តម្រូវការកម្មករមានកម្រិតខ្ពស់នៅក្នុងវិស័យពឹងផ្អែកលើកម្លាំងពលកម្មដូចជា ទំនិញកសិកម្ម និងការកែច្នៃម្ហូបអាហារសម្រាប់នាំចេញ ។ នេះបើយោងតាមការបញ្ជាក់របស់លោក Poj Aramwattananont អនុប្រធានសភាពាណិជ្ជកម្មថៃ ប្រាប់សន្និសិទសារព័ត៌មាន។ លោកបញ្ជាក់ថា «បច្ចុប្បន្ន ពលករគឺជាបញ្ហាធំសម្រាប់ជំរុញសេដ្ឋកិច្ច។ ថៃត្រូវការពលករចំណាក់ស្រុកសរុបយ៉ាងតិច៣ទៅ ៤លាននាក់ដើម្បីធ្វើឲ្យសេដ្ឋកិច្ចដើរទៅមុខ»។

លោកនិយាយថា ឧបសគ្គក្នុងការជ្រើសរើសពលកររួមមានបញ្ហានៅក្នុងប្រទេសកំណើតរបស់ពួកគេ ដូច្នេះជាភាពចលាចលនៅក្នុងប្រទេសមីយ៉ាន់ម៉ា និងការប្រកួតប្រជែងពីប្រទេសមួយចំនួនដូចជា ជប៉ុន និងចិនជាដើម។ បច្ចុប្បន្ន មានពលករប្រហែល ២,៥លាននាក់ដែលមានឯកសារមកពីប្រទេសឡាវ កម្ពុជា និងមីយ៉ានម៉ា។

លោក Pairjoj Chotikasathien ប្រធាននាយកដ្ឋានការងារនៃក្រសួងការងារបាននិយាយថា ដើម្បីដោះស្រាយបញ្ហាខ្វះខាតកម្មករ កាលពីសប្តាហ៍មុនគណៈរដ្ឋមន្ត្រីបានអនុម័តផែនការគ្រប់គ្រងការងារ រួមមានការអនុញ្ញាតិឲ្យពលករមានឯកសារអាចបន្តស្នាក់នៅក្នុងប្រទេសថៃរហូតដល់ខែកុម្ភៈ ឆ្នាំ ២០២៥។ លោកបញ្ជាក់ថា ថៃក៏នឹងអនុញ្ញាតិឲ្យពលករខុសច្បាប់ រួមមានពលករមកពីប្រទេសវៀតណាម ចុះឈ្មោះ និងធ្វើការងាររហូតដល់ខែកុម្ភៈ ឆ្នាំ ២០២៥ផងដែរ។ លោកបន្តថា ជាមួយនឹងការធ្វើឲ្យប្រសើរឡើងនៃផែនការការងារ និងការមកដល់ពលករកាន់តែច្រើន ថៃនឹងមានពលករចំណាកស្រុកជិត ៣លាននាក់នៅបំណាច់ឆ្នាំនេះ៕ (តាមប្រភព៖ Reuters)

## ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២

### សម្តេចក្រឡាហោម ស ខេង បានទទួលជួបពិភាក្សាការងារជាមួយលោក Daniel J. Kritenbrink ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិក ទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក

http://nokorwatnews.com/ 13/07/2022

ភ្នំពេញ ៖ នារសៀលថ្ងៃអង្គារ ១៤កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានទទួលជួបពិភាក្សាការងារជាមួយលោក Daniel J. Kritenbrink ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិក ទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។ សម្តេចក្រឡាហោម ស ខេង នាឱកាសនោះ បានថ្លែងនូវការស្វាគមន៍ និងចាត់ទុកដំណើរទស្សនកិច្ចរបស់ឯកឧត្តម និងសហការីមកកាន់កម្ពុជានាពេលនេះថាជាការរួមចំណែកមួយដល់ការលើកកម្ពស់នូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរកម្ពុជា និងសហរដ្ឋអាមេរិក។ សម្តេចក្រឡាហោមក៏បានសម្តែងការអបអរសាទរចំពោះលទ្ធផល និងសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរនារយៈពេលកន្លងមក ជាពិសេសនៅក្នុងឱកាសដែលកម្ពុជាទទួលតួនាទីជាប្រធានអាស៊ានប្តូរវេនក្នុងឆ្នាំ២០២២នេះ។

សម្តេចក្រឡាហោម ក៏បានថ្លែងចូលរួមអបអរសាទរចំពោះ កិច្ចប្រជុំកំពូលអាស៊ាន សហរដ្ឋអាមេរិកដែលបានប្រព្រឹត្តទៅនៅរដ្ឋធានីវ៉ាស៊ីនតោន កាលពីពេលថ្មីៗនេះ ដែលប្រធានអាស៊ានដឹកនាំដោយសម្តេចតេជោនាយករដ្ឋមន្ត្រី និងសហរដ្ឋអាមេរិកក៏ជាសហប្រធាននៃជំនួបកំពូលនេះដែលប្រព្រឹត្តទៅប្រកបដោយលទ្ធផលជាផ្លែផ្កា រួមចំណែកដល់ការពង្រឹងនូវទំនាក់ទំនងកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខណ្ឌអាស៊ាន និងសហរដ្ឋអាមេរិក ក៏ដូចជាទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិកផងដែរ។ សម្តេចក្រឡាហោម ក៏យកឱកាសនេះ ថ្លែងអំណរគុណចំពោះការជួយគាំទ្ររបស់សហរដ្ឋអាមេរិក មកលើដំណើរការអភិវឌ្ឍ ក៏ដូចជាដំណើរការស្វែងរកសុខសន្តិភាពរបស់កម្ពុជានៅក្នុងរយៈពេលកន្លងមក ជាពិសេស គឺបេសកកម្មក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ប្រកបដោយជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលក៏មានការចូលរួមចំណែកជួយគាំទ្រពីសហរដ្ឋអាមេរិកផងដែរ។ សម្តេចបានចាត់ទុកលទ្ធផលនេះថាជាការស្តែងឲ្យឃើញនូវការចូលរួមរបស់សហរដ្ឋអាមេរិក ក្នុងការជួយគាំទ្រដល់ប្រជាពលរដ្ឋកម្ពុជា នៅក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។ ជាមួយគ្នានោះដែរ សម្តេចក៏បានអបអរសាទរចំពោះ វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការងារសន្តិសុខ និងលើវិស័យអនុវត្តច្បាប់ និងមានក្តីសង្ឃឹមជឿជាក់ថាភាគីទាំងពីរនឹងបន្តពិនិត្យលទ្ធភាព ក្នុងការពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការនេះបន្ថែមទៀត។

ជាការឆ្លើយតប លោក Daniel J. Kritenbrink ឧបការីរដ្ឋមន្ត្រីការបរទេសអាមេរិកទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានថ្លែងអំណរគុណ និងបង្ហាញការគាំទ្រចំពោះការលើកឡើងតាមរយៈពាក្យពេចន៍របស់សម្តេចក្រឡាហោម អំពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ។ លោក ក៏បានបង្ហាញការចូលរួមអបអរសាទរចំពោះ លទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ាន សហរដ្ឋអាមេរិក កាលពីពេលកន្លងទៅ ដែលកម្ពុជាក្នុងនាមជាប្រធានអាស៊ាន និងសហរដ្ឋអាមេរិកក៏ជាសហប្រធាននៃជំនួបកំពូលនៅពេលនោះ រួមទាំងថ្នាក់ដឹកនាំនៃបណ្តាប្រទេសអាស៊ានផ្សេងទៀត ក៏បានជជែកពិភាក្សាផ្លាស់ប្តូរយោបល់ប្រកបដោយផ្លែផ្កា។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានសម្តែងនូវការស្វាគមន៍ចំពោះ ការប្តេជ្ញាចិត្តជួយឧបត្ថម្ភគាំទ្ររបស់សហរដ្ឋអាមេរិក ក្នុងឱកាសដែលកម្ពុជាទទួលធ្វើជាប្រធានអាស៊ានឆ្នាំ២០២២ និងបញ្ជាក់ថាកម្ពុជាស្វាគមន៍ជានិច្ច ចំពោះការគាំទ្រពីបណ្តាប្រទេសជាដៃគូ ប្រទេសជាមិត្ត រួមទាំងសហរដ្ឋអាមេរិក។ សម្តេចក្រឡាហោម និងលោកឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ក៏បានពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាព្រមទាំងបានធ្វើការវាយតម្លៃទៅលើកិច្ចសហប្រតិបត្តិការវិស័យអនុវត្តច្បាប់ ក្នុងនោះរួមមានកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រឆាំងការជួញដូរមនុស្ស និងការងារប្រយុទ្ធប្រឆាំងអំពើភេរវកម្មដោយភាគីទាំងពីរបានចាត់ទុកកិច្ចសហប្រតិបត្តិការនេះ ថាមានសារៈសំខាន់ដែលត្រូវតែបន្ត ពង្រឹង និងពង្រីក ពិសេសលើអ្វីដែលបានអនុវត្តកន្លងមករវាងភាគីទាំងពីរ។

សម្តេចក្រឡាហោម និងលោកឧបការីរដ្ឋមន្ត្រីការបរទេសក៏បានពិភាក្សាអំពីការងារពាក់ព័ន្ធនឹងការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរពីសហរដ្ឋអាមេរិក ដោយសម្តេចបានជម្រាបឯកឧត្តម និងគណៈប្រតិភូថាជាគោលការណ៍ គឺពុំមានអ្វីប្រែប្រួលនោះទេនៅក្នុងដំណើរការការងារនេះ។ ភាគីទាំងពីរនឹងបន្តជជែកពិភាក្សាទៅលើទិដ្ឋភាពបច្ចេកទេសមួយចំនួនដើម្បីបន្តដំណើរការនេះដូចអ្វីដែលភាគីទាំងពីរបានព្រមព្រៀងគ្នាកន្លងមក និងបានឯកភាពបន្តខិតខំជំរុញដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីគាំទ្រដំណើរការការងារនេះ៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 12/07/2022 Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១២ និង០០នាទី នាថ្ងៃចន្ទ ១៤កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង កម្លាំងប៉ុស្តិ៍គីឡូ១៣ បានសហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន និងកម្លាំងយោធាវរសេនាតូច៥៣៣ បានទទួលប្រជាពលរដ្ឋដែលឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ ដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១១នាក់ ស្រី៦នាក់ក្មេងស្រី១នាក់។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានបញ្ជូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅពិនិត្យ និងស្វែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ នៅមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនបន្ទាប់មកទើបបានអនុញ្ញាតឲ្យប្រជាពលរដ្ឋត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## តុលាការកំពូលជម្រះបណ្ដឹងសាទុក្ខ យុវជនម្នាក់ ពាក់ព័ន្ធនឹងការ នាំពលករថៃ៣នាក់ចូលស្រុកខ្មែរដោយមិនស្របច្បាប់

https://cen.com.kh/ Posted ByPen Srey Neat July 13, 2022

ភ្នំពេញ: តុលាការកំពូលកាលពីព្រឹកថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០២២ បានបើកសវនាការ ជំនុំជម្រះលើបណ្ដឹងសារទុក្ខរបស់ជនជាប់ចោទម្នាក់ ដែលតុលាការថ្នាក់ក្រោម កាត់ទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ ពាក់ព័ន្ធនឹងការ ជនជាតិពលករថៃ៣នាក់ចូលស្រុកខ្មែរដោយមិនស្របច្បាប់ ប្រព្រឹត្តិ នៅចំណុចក្រុមទី១០ ភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីអំឡុងឆ្នាំ ២០២១ ។

លោក ជីវ កេង ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃ តុលាការកំពូល បានថ្លែងឲ្យដឹងថា ជនជាប់ចោទរូបនេះ មានឈ្មោះ ៖ លី ចិន ភេទប្រុស អាយុ ៣៦ ឆ្នាំ រស់នៅ នៅស្រុកថ្មគោល ខេត្តបាត់ដំបង ។ នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ ត្រូវបានសាលាដំបូងបាត់ដំបង កាលពី ២០ ខែ កក្កដា ឆ្នាំ ២០២១ ផ្ដន្ទាទោស ដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ ក្រោមការចោទប្រកាន់ពីបទ ការនាំចេញដោយមិនស្របច្បាប់សម្រាប់ការនាំឆ្លងដែន និងសមគំនិតក្នុងការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ។ ជនជាប់ចោទ បានប្ដឹងឧទ្ធរណ៍។

តុលាការ ឧទ្ធរណ៍ខេត្តបាត់ដំបង បានតម្កល់ទោសរបស់គាត់ដដែល។ គាត់ក៏ប្ដឹងសាទុក្ខ មកតុលាការកំពូលទៀត។ជនជាប់ចោទ ត្រូវបានសមត្ថកិច្ច ចាប់ឃាត់ខ្លួន កាលពី ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០២១ នៅចំណុចក្រុមទី១០ ភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ។ សំណុំរឿងក្ដីនេះ, តុលាការកំពូលបានលើកពេលប្រកាសសាលដីកា នៅព្រឹកថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០២២ ខាងមុខ នេះ៕ រក្សាសិទ្ធដោយ ៖ ចន្ទា ភា

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 13/07/2022 Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១២ និង០០នាទី នាថ្ងៃចន្ទ ១៤កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង កម្លាំងប៉ុស្តិ៍គីឡូ១៣ បានសហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន និងកម្លាំងយោធាវរសេនាតូច៥៣៣ បានទទួលប្រជាពលរដ្ឋដែលឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ ដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០២លើក សរុបចំនួន១៥នាក់ ស្រី៥នាក់ ក្មេង៤នាក់ ក្មេងស្រី១នាក់ ។

ក្រោយពីទទួលបាន បងប្អូនប្រជាពលរដ្ឋទាំងអស់ត្រូវបាន អប់រំណែនាំ និងបញ្ជូនទៅពិនិត្យ និងស្កេនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់នៅមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ទើបបានអនុញ្ញាតឲ្យប្រជាពលរដ្ឋត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២

## កម្ពុជា នឹងធ្វើជាម្ចាស់ផ្ទះ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ អាស៊ានទទួលបន្ទុក ឧក្រិដ្ឋកម្មឆ្លងដែន

https://dap-news.com/national/ ByTR110Posted on July 17, 2022

**ភ្នំពេញ ៖ ដោយបានការអនុញ្ញាត ដ៏ខ្ពង់ខ្ពស់របស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រុមការងារ SOMTC-កម្ពុជា នឹងធ្វើជាម្ចាស់ផ្ទះរៀបចំ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី២២ និងកិច្ចប្រជុំពាក់ព័ន្ធ (22nd SOMTC and Its Related Meetings) ចាប់ពីថ្ងៃទី១៩-២១ ខែកក្កដា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ។**

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ ក្រសួងមហាផ្ទៃ នាថ្ងៃទី១៦ កក្កដា បានឲ្យដឹងថា កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី២២ គឺវេទិកាសម្រាប់មន្ត្រីជាន់ខ្ពស់ មកពីបណ្តារដ្ឋសមាជិកអាស៊ាន ជួបពិភាក្សាលើកម្មវិធីការងារ និងពិនិត្យឡើងវិញ នូវផែនការសកម្មភាពដែលបានដាក់ចេញកន្លងមក ដើម្បីឈានទៅកំណត់ទិសដៅអនុវត្តបន្ត ព្រមទាំងផ្លាស់ប្តូរយោបល់ និងចែករំលែកបច្ចុប្បន្នភាពអំពីនិន្នាការនៃឧក្រិដ្ឋកម្មឆ្លងដែនក្នុងតំបន់ ជាពិសេសលើវិស័យទាំង១០ ក្រោមក្របខណ្ឌ នៃកិច្ចសហប្រតិបត្តិការរបស់ SOMTS រួមមាន៖ ការរត់ពន្ធអាវុធ អំពើភេរវកម្ម ការសម្អាតប្រាក់ អំពើប្លន់លើផ្ទៃសមុទ្រ ការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស បទល្មើសសេដ្ឋកិច្ចអន្តរជាតិ បទល្មើសបច្ចេកវិទ្យា ការជួញដូរគ្រឿងញៀនខុសច្បាប់ និងការជួញដូរសត្វព្រៃ និងឈើខុសច្បាប់។ លើសពីនេះទៀត ក្នុងក្រខណ្ឌនៃកិច្ចប្រជុំលើកទី២២ នេះដែរ ក្រុមការងារ SOMTC-កម្ពុជា ក៏នឹងធ្វើជាប្រធានដឹកនាំកិច្ចប្រជុំលើកទី១៩ រវាងមន្ត្រីជាន់ខ្ពស់អាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ជាមួយដៃគូសន្ទនា ចិន-ជប៉ុន-កូរ៉េខាងត្បូង (19th SOMTC+3)៕

## ស្ថានទូតរំលឹកពលរដ្ឋចិននៅកម្ពុជានៅឲ្យឆ្ងាយពីក្រុមលេងល្បែងស៊ីសងតាមអ៊ីនធឺណិត

https://www.khmertimeskh.com/ Khmer Times July 14, 2022

ស្ថានទូតចិនប្រចាំកម្ពុជា បានចេញសេចក្តីជូនដំណឹងមួយកាលពីថ្ងៃពុធនៅលើគេហទំព័ររបស់ខ្លួន ដោយក្រើនរំលឹកពលរដ្ឋចិនក្នុងប្រទេសនេះនៅឱ្យឆ្ងាយពីក្រុមលេងល្បែងស៊ីសងតាមអ៊ីនធឺណិត។ កាលពីពេលថ្មីៗនេះ ពលរដ្ឋចិនមួយចំនួនត្រូវបានជាប់ឃុំឃាំងដោយខុសច្បាប់ដើម្បីជាថ្នូរនឹងការលោះប្រាក់ បន្ទាប់ពីត្រូវបានក្រុមឆបោកទាក់ទាញអោយមកប្រទេសកម្ពុជា ដោយជឿលើការផ្សាយពាណិជ្ជកម្មមិនពិតដោយសន្យាផ្តល់ "ប្រាក់ខែខ្ពស់"។ ដោយសារការឆ្លើយតបភ្លាមៗពីក្រុមគ្រួសារជនរងគ្រោះ និងការសម្របសម្រួលជាមួយស្ថានទូតចិនប្រចាំកម្ពុជា នាយកដ្ឋានអនុវត្តច្បាប់ក្នុងប្រទេសចិន និងកម្ពុជាបានចាត់វិធានការយ៉ាងឆាប់រហ័ស និងជួយសង្គ្រោះជនរងគ្រោះដោយជោគជ័យ។ ស្ថានទូតចិនប្រចាំកម្ពុជាបានក្រើនរំឭកជាថ្មីម្តងទៀតដល់ពលរដ្ឋចិនឲ្យមកកម្ពុជាដោយស្របច្បាប់និងចៀសវាងការចាញ់បោកដែលសន្យាថានឹងបានប្រាក់ច្រើនក្នុងរយៈដ៏ខ្លី។ ស្ថានទូតក៏បានក្រើនរំលឹកពលរដ្ឋចិន ឱ្យរាយការណ៍ទៅប៉ូលីសចិន និងកម្ពុជាឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប្រសិនបើពួកគេស្ថិតក្នុងគ្រោះថ្នាក់ ឬសេរីភាពផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានរឹតត្បិត។ នៅពេលរាយការណ៍ ឬធ្វើការហៅទូរស័ព្ទបន្ទាន់ ស្ថានទូតបានបញ្ជាក់ថា វាមានសារៈសំខាន់ណាស់ក្នុងការផ្តល់ព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីឱ្យការសង្គ្រោះទាន់ពេលវេលាអាចត្រូវបានរៀបចំឡើង។

អាជ្ញាធរចិនបាននឹងកំពុងចាប់ដៃជាមួយបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ដើម្បីពង្រឹងការអនុវត្តច្បាប់រួមគ្នា និងការបង្ក្រាបសកម្មភាពឧក្រិដ្ឋកម្ម ដូចជាការឆបោកតាមអ៊ីនធឺណិតឆ្លងដែន និងការលេងល្បែងស៊ីសងតាមអ៊ីនធឺណិ

តខុសច្បាប់អស់រយៈពេលជាច្រើនឆ្នាំ។ ដោយសារតែការបង្ក្រាបលើការក្លែងបន្លំ ល្បែងតាមអនឡាញ និងសកម្មភាពខុសច្បាប់ផ្សេងទៀតនៅក្នុងប្រទេសចិន ឧក្រិដ្ឋជនជាច្រើនបានងាកទៅរកបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ដែលមានច្បាប់ធូរលុង។ រដ្ឋាភិបាលចិនតែងតែទទូចលើសារៈសំខាន់ក្នុងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃប្រទេសក្នុងតំបន់ នៅពេលដែលក្រុមហ៊ុនចិន ឬបុគ្គលចេញទៅរកស៊ី ឬធ្វើការនៅបរទេស។ ប្រទេសចិនមិនគាំទ្រអាជីវកម្មខុសច្បាប់ធ្វើឡើងដោយក្រុមហ៊ុន ឬបុគ្គលនៅបរទេសនោះទេ។ ក្រៅពីប្រទេសកម្ពុជា ហ្វីលីពីន មីយ៉ាន់ម៉ាឡាវ និងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ផ្សេងទៀត បាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលចិន ដើម្បីបង្ក្រាបឧក្រិដ្ឋកម្មអ៊ីនធឺណិតនៅក្រៅប្រទេស។ *Global Times*

## ឥណ្ឌូនេស៊ីផ្អាកបញ្ជូនពលរដ្ឋធ្វើការក្រៅប្រទេស ខណៈម៉ាឡេស៊ីខ្វះខាតពលករជាង១លាននាក់

https://kohsantepheapdaily.com.kh/ ១៤ ខែ កក្កដា ឆ្នាំ ២០២២ ម៉ោង ១០:២២

ឥណ្ឌូនេស៊ី ៖ ឥណ្ឌូនេស៊ីបានប្រកាសនៅថ្ងៃពុធ ទី ១៣ កក្កដា ម្សិលមិញនេះថា ខ្លួនបានផ្អាកបណ្ដោះអាសន្ននូវការបញ្ជូលពលរដ្ឋទៅធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ី រួមមានទាំងប្រជាពលរដ្ឋរាប់ពាន់នាក់ដែលត្រូវបានជ្រើសរើសឲ្យធ្វើការក្នុងវិស័យចម្ការ ដោយសារតែមានការរំលោភកិច្ចព្រមព្រៀងជ្រើសរើសពលករដែលបានចុះហត្ថលេខាដោយប្រទេសទាំងពីរ។ ការផ្អាករបស់ឥណ្ឌូនេស៊ីជាបញ្ហាសម្រាប់ប្រទេសម៉ាឡេស៊ី ដែលជាប្រទេសផលិតប្រេងដូងធំបំផុតទី ២ក្នុងពិភពលោក និងជាប្រទេសដ៏សំខាន់ក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ពិភពលោក។ ម៉ាឡេស៊ីកំពុងប្រឈមនឹងការខ្វះខាតពលករប្រហែល ១,២លាននាក់ដែលអាចរារាំងដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ខ្លួន។

ឯកអគ្គរដ្ឋទូតឥណ្ឌូនេស៊ីប្រចាំម៉ាឡេស៊ីលោក Hermono បានថ្លែងប្រាប់ទីភ្នាក់ងារសារព័ត៌មាន Reuters ដូច្នេះថា ការផ្អាកបណ្ដោះអាសន្ននោះកើតឡើង ក្រោយពេលអាជ្ញាធរអន្តោប្រវេសន៍ម៉ាឡេស៊ីបន្តប្រើប្រាស់ប្រព័ន្ធជ្រើសរើសពលករតាមអនឡាញ ដែលជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទជួញដូរ និងពលកម្មដោយបង្ខំ។ ការបន្តរបស់ប្រព័ន្ធនោះរំលោភលក្ខខណ្ឌនៃកិច្ចព្រមព្រៀងដែលចុះហត្ថលេខារវាងម៉ាឡេស៊ី និងឥណ្ឌូនេស៊ីនៅក្នុងខែមេសាដែលមានគោលបំណងពង្រឹងការការពារពលករធ្វើការតាមផ្ទះនៅក្នុងប្រទេសម៉ាឡេស៊ី។

សូមបញ្ជាក់ថា ម៉ាឡេស៊ីពឹងផ្អែកទៅលើពលករបរទេសរាប់លាននាក់ ដែលភាគច្រើនមកពីប្រទេសឥណ្ឌូនេស៊ី បង់ក្លាដេស និងនេប៉ាល់ ដើម្បីធ្វើការក្នុងរោងចក្រ និងចម្ការដែលអ្នកស្រុកម៉ាឡេស៊ីមិនធ្វើ។ ប្រភព៖ Reuters

## មានការពិគ្រោះយោបល់តាមទូរស័ព្ទជាង ៧00 ជំនួប ពីអំពើហិង្សាក្នុងគ្រួសារ ការបំពានផ្លូវកាយ និងផ្លូវភេទកុមារ ចាប់ពីខែមករាដល់ខែកក្កដា

https://www.postkhmer.com/ អោម ប៊ុនធឿន | Publication date 13 July 2022 | 18:16 ICT

**ភ្នំពេញៈ** មន្ត្រីអង្គការបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា បានពិគ្រោះយោបល់ពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានលើផ្លូវកាយ និងផ្លូវភេទកុមារ តាមទូរស័ព្ទបានជាង ៧00 ជំនួប ចាប់ពីដើមឆ្នាំ ២០២២ មកដល់ខែកក្កដា ឆ្នាំដដែលនេះ ក្នុងនោះមាន ១៥ ករណី ត្រូវបានរាយការណ៍ឱ្យជួយអន្តរាគមន៍បន្ទាន់ទៅសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋាន។ នេះបើតាមអ្នកស្រី ធន ស្រីពៅ ប្រធានផ្នែកពិគ្រោះយោបល់នៃបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា។

អ្នកស្រី ធន ស្រីពៅ ឱ្យដឹងនៅថ្ងៃទី ១៣ កក្កដាថា អ្នកដែលទូរស័ព្ទទៅជជែកជាមួយមន្ត្រីផ្នែកពិគ្រោះយោបល់នៃបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា ភាគច្រើនជាក្មេងស្រីដែលមានភាពក្លាហាន អាយុចាប់ពី ៨-១៨ ឆ្នាំ និងស្ត្រីដែលរងអំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានផ្លូវភេទ ព្រមទាំងហិង្សាផ្លូវចិត្តផ្សេងៗក្នុងចន្លោះអាយុពី ១៨-២៥ ឆ្នាំ។ អ្នកស្រីថ្លែងថា៖ «អ្វីដែលពួកគាត់បានខលមកហ្នឹង ភាគច្រើនយើងទទួលបានជាកុមារ។ គាត់

ទទួលរងអំពើហិង្សាលើផ្លូវកាយ និងរងនូវអំពើរំលោភបំពានផ្លូវភេទ ហ្នឹងយើងនិយាយពីកុមារ។ ដោយឡែក បើសិនយើងក្រឡេកទៅមើលមនុស្សធំពេញវ័យ គឺភាគច្រើនគាត់រងនូវអំពើហិង្សាក្នុងគ្រួសារ និងផ្លូវកាយដូចគ្នា»។ អ្នកស្រី ធន ស្រីពៅ បានឱ្យដឹងថា ក្នុងជំនួបតាមទូរស័ព្ទជាង ៧០០ នោះ ក្រុមការងារបានពិគ្រោះយោបល់ ពង្រឹងភាពក្លាហាន លើកទឹកចិត្ត និងពង្រឹងអំណាចរបស់គាត់ ឱ្យពួកគាត់មានភាពក្លាហាន ហ៊ានទៅរាយការណ៍ដោយខ្លួនឯង។ ចំណែក ១៥ ករណីនោះ គឺពួកគាត់មិនមានភាពក្លាហាន និងត្រូវការជំនួយភ្លាមៗ ដែលទាមទារឱ្យក្រុមការងារជួយបញ្ជូនព័ត៌មានទៅមន្ត្រីមានសមត្ថកិច្ចដើម្បីចុះទៅដោះស្រាយ។

បើតាមអ្នកស្រី ករណីទាំងអស់ដែលទទួលបាន គឺមន្ត្រីនៃបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា បានធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូដើម្បីផ្ដល់សេវាគាំទ្រទៅតាមតម្រូវការរបស់ពួកគាត់។ អាជ្ញាធរមូលដ្ឋានបានចូលរួមយ៉ាងសកម្ម ក្នុងការជួយអន្តរាគមន៍ដោះស្រាយបញ្ហាអំពើហិង្សាលើស្ត្រីនិងក្មេងស្រី ដែលធ្វើឱ្យការឆ្លើយតបបានកាន់តែទាន់ពេលវេលា និងមានប្រសិទ្ធភាព ហើយជនរងគ្រោះមានសុវត្ថិភាព។ អ្នកស្រីប្រាប់ថាបច្ចុប្បន្នអ្នកជួបបញ្ហាហិង្សាដូចដែលបានលើកឡើងនេះមានភាពក្លាហានច្រើនក្នុងការលើកអំពីបញ្ហារបស់ខ្លួនឯងទៅជជែកដោយផ្ទាល់ជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត។ ប៉ុន្តែមួយចំនួន នៅតែមានភាពភ័យខ្លាចក្នុងការទៅរកអាជ្ញាធរមានសមត្ថកិច្ចដោយផ្ទាល់ ពិសេសស្ត្រី និងក្មេងស្រី។ ពេលជួបបញ្ហាអំពើហិង្សាផ្លូវភេទ និងហិង្សាផ្លូវចិត្ត គឺពួកគាត់អាចត្រូវការភាពក្លាហានរាប់រយរាប់ពាន់ដង ដើម្បីយករឿងរ៉ាវទាំងអស់នោះរាយការណ៍ទៅកាន់សមត្ថកិច្ច។

អ្នកស្រីធន ស្រីពៅ បានលើកទឹកចិត្តដល់អ្នកដែលរងអំពើហិង្សាគ្រប់រូបភាព អាចទាក់ទងមកបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា ដែលមានលេខពិសេស គឺ ១២៨០ ដែលអាចទូរស័ព្ទ និងផ្ញើសារជាអក្សរក៏បានដោយឥតគិតថ្លៃ និងរក្សាការសម្ងាត់ជូន ដោយ សេវាបម្រើជូន ២៤ ម៉ោងរៀងរាល់ថ្ងៃ។ ក្រៅពីទូរស័ព្ទ ក៏មានហ្វេសប៊ុកផ្លូវការ ឈ្មោះថា Child Helpline Cambodia និង វេបសាយ http://childhelpline.org.kh/ ដែលអាចផ្ញើសារជាអក្សរ និងសំឡេងខ្លីៗ ដើម្បីស្វែងរកការពិគ្រោះយោបល់ ឬរាយការណ៍ពីអំពើហិង្សា ការរំលោភបំពានផ្សេងៗ និងបញ្ហាផ្លូវចិត្តមួយចំនួនផងដែរ។ អ្នកស្រីបញ្ជាក់ថា៖ «សូមឱ្យមានភាពក្លាហាន ហើយឈប់នៅស្ងៀម កុំលាក់បញ្ហាទាំងអស់ហ្នឹងទុក។ សូមគិតថា មានបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជាមួយដែលចាំស្ដាប់និងជួយគាំទ្រពួកគាត់»។

លោកស្រីសម្បត្តិ សុគន្ធា អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ថ្លែងនៅថ្ងៃទី ១៣ កក្កដា ថា ការរាយការណ៍តាមរយៈបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា ១២៨០ ឬការរាយការណ៍តាមប្រព័ន្ធអនឡាញ ក្នុងកិច្ចការពារកុមារមានភាពល្អប្រសើរជាងមុន ដែលបង្ហាញពីការរីកចម្រើននៃកិច្ចការពារកុមារនៅកម្ពុជា។ លោកស្រីថ្លែងថា៖ «ពីមុនមក នៅពេលមានករណីអំពើហិង្សាអីកើតឡើង មានន័យថា យើងរក្សាទុកទិន្នន័យហ្នឹង យើងអត់សូវមានការរាយការណ៍ទេ។ ប៉ុន្តែឥឡូវនេះ យើងចាប់ផ្ដើមមានការរាយការណ៍។ ទោះបីករណីនៃការរាយការណ៍មានការកើនឡើងបន្តិច ប៉ុន្តែបានបង្ហាញអំពី ការយល់ដឹងរបស់ពលរដ្ឋ ជាពិសេស គឺកុមារតែម្ដង ដែលគាត់ស្គាល់ច្បាស់ពីប្រព័ន្ធរាយការណ៍ អាចជួយសង្គ្រោះគាត់បាន»។

លោក សឿង ថៃម នាយប៉ុស្តិ៍នគរបាល រដ្ឋបាលឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបងប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ១៣ ខែកក្កដាថា តាមការសង្កេតជាក់ស្ដែងក្នុងមូលដ្ឋានរបស់លោក ករណីរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារនៅតែមាន ប៉ុន្តែមិនច្រើនទេ។ ក្នុង ១ ខែមានយ៉ាងច្រើន ១ ទៅ ២ ករណីប៉ុណ្ណោះ ហើយការរាយការណ៍នោះ ជួនកាលប្រជាពលរដ្ឋរាយការណ៍តាមទូរស័ព្ទ និងពេលខ្លះមកប្ដឹងដល់ប៉ុស្តិ៍រដ្ឋបាលតែម្ដង។ ដោយឡែកករណីអំពើហិង្សាលើកុមារ និងស្ត្រី ពាក់ព័ន្ធការរំលោភបំពានផ្លូវភេទ គឺកម្រមានណាស់។ លោកបញ្ជាក់ថា៖ «ពេលគាត់រាយការណ៍មកយើងភ្លាម ជាក់ស្ដែង គឺយើងចុះទៅដល់កន្លែងកើតហេតុតែម្ដង ព្រោះរឿងរ៉ាវអត់មានអីធំទេ

គ្រាន់តែវាយតប់គ្នាបន្តិចបន្តួច។ អ៊ីចឹងទៅ ឈ្លោះប្រកែកគ្នា ក៏យើងត្រូវតែទៅដែរ យើងធ្វើការអប់រំណែនាំគាត់ ធ្វើកិច្ចសន្យាអីទៅ គាត់រាងចាលបានយូរៗដែរ»៕

## ក្រសួងការងារ ផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១៥ កក្កដា ២០២២ដោយ deth leng

លោកស្រី ស៊ើង សរសុចិត្តា រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០២២ បានចូលរួមបើកយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងវិស័យ កសិឧស្សាហកម្ម នៅក្នុងស្រុកបន្ទាយស្រី ខេត្តសៀមរាប។ លោកស្រី ស៊ើង សរសុចិត្តា មានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការលុបបំបាត់ពលកម្មកុមារ ជាការងារអាទិភាព ក្នុងនោះក្រសួងការងារបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្តោតលើអាទិភាពចំនួន ៥ រួមមាន៖ ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ការអភិវឌ្ឍន៍ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ការអភិវឌ្ឍន៍មុខរបរ និងការងារ ការអភិវឌ្ឍន៍របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ និងការពង្រឹងអភិបាលកិច្ចល្អ ដោយសំដៅធ្វើឱ្យប្រសើរឡើងនូវការធានាលក្ខខណ្ឌការងារ បង្កើនឱកាសការងារ បង្កើតបរិយាកាសការងារ ពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ និង ពង្រឹងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យសមស្របទៅតាមតម្រូវការទីផ្សារការងារ រួមទាំងការទទួលបាននូវអត្ថប្រយោជន៍ពី កិច្ចគាំពារសង្គមប្រកបដោយសមភាព និងដោយគ្មានការរើសអើង ដើម្បីចូលរួមចំណែកដល់ការកាត់បន្ថយ ភាពក្រីក្រ លើកស្ទួយជីវភាពប្រជាពលរដ្ឋ និងអភិវឌ្ឍន៍សេដ្ឋកិច្ច ជាតិប្រកបដោយចីរភាព។

លោកស្រីបានសង្កត់ធ្ងន់ផងដែរថា ដើម្បីចូលរួមទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំក្រសួងបានកំណត់នូវចង្កោម សកម្មភាព អាទិភាពដូចជាខាងការកសាងសមត្ថភាពមន្ត្រីអធិការកិច្ចការងារ ស្តីពីការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃ ពលកម្មកុមារ និងការងារដោយបង្ខំ និងការពង្រឹងយន្តការប្រឆាំងពលកម្មកុមារនិងការងារដោយបង្ខំជាពិសេសលើវិស័យមុខរបរ និងភូមិសាស្ត្រដែលមានហានិភ័យខ្ពស់៕

## ពលករចំណាកស្រុកកម្ពុជាមានតម្រូវការខ្ពស់ ខណៈអាជីវកម្មថៃទាមទារពលករចំណាកស្រុកកន្លះលាននាក់បន្ថែមទៀត

https://www.khmertimeskh.com/ July 15, 2022

នៅក្នុងការចរចារដើម្បីបន្ធូរបន្ថយការកង្វះខាត គណៈរដ្ឋមន្ត្រីកាលពីសប្តាហ៍មុន បានអនុម័តផែនការគ្រប់គ្រងពលករ រួមទាំងការអនុញ្ញាតឱ្យពលករដែលមានឯកសារពីប្រទេសកម្ពុជា ឡាវ និង មីយ៉ាន់ម៉ាស្នាក់នៅរហូតដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥។

លោក ផៃរ៉ូត (Pairoj) បាននិយាយថា ប្រទេសថៃក៏នឹងអនុញ្ញាតឱ្យពលករខុសច្បាប់ពីកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ចុះឈ្មោះ និងធ្វើការរហូតដល់ខែកុម្ភៈ ឆ្នាំ២០២៥។ លោក Pairoj Chotikasathien អគ្គនាយកនៃនាយកដ្ឋានការងារបាននិយាយថា ជំងឺរាតត្បាតបានបណ្តាលឱ្យមានការពន្យារពេលក្នុងការនាំចូលពលករបរទេសពីប្រទេសកម្ពុជា ឡាវ និងវៀតណាម។ លោកបានបន្តថាជាមួយនឹងផែនការពលករដែលបានធ្វើឱ្យប្រសើរឡើង និងការមកដល់របស់ពលករបន្ថែមទៀត ប្រទេសថៃអាចនឹងឃើញពលករចំណាកស្រុកជិត៣លាននាក់នៅដំណាច់ឆ្នាំនេះ។

យោងតាមសភាពាណិជ្ជកម្មថៃ បានឱ្យដឹងថា គេត្រូវការពលករបរទេសបន្ថែមជាង ៥០០,០០០ នាក់ ដើម្បីគាំទ្រដល់ការកែច្នៃផលិតផលកសិកម្ម និងឧស្សាហកម្មម្ហូបអាហារសម្រាប់ការនាំចេញ សំណង់ ទេសចរណ៍ និងសេវាកម្ម។ យោងតាមលោក Poj Aramwattananont អនុប្រធានសភាពាណិជ្ជកម្មបានអោយដឹងថា ឥឡូវនេះ រដ្ឋាភិបាលបានលុបចោលការរឹតបន្តឹងការធ្វើដំណើរ និងអាជីវកម្មដែលទាក់ទងនឹងកូវីដ ស្ទើរតែទាំងស្រុង ដើម្បីពន្លឿនការស្តារសេដ្ឋកិច្ចឡើងវិញ និងតម្រូវការពលករដែលកំពុងកើនឡើង។ លោក Poj បាននិយាយថា "ពលករត្រូវបានចាត់ទុកថាជាម៉ាស៊ីនដ៏សំខាន់ក្នុងការជំរុញសេដ្ឋកិច្ចទាំងមូលរបស់ប្រទេសថៃពីឧស្សាហកម្មតម្រង់ទិសនាំចេញ ការផលិត ការកែច្នៃ និងសំណង់ រហូតដល់វិស័យទេសចរណ៍ និងវិស័យសេវាកម្ម"។ នេះត្រូវបានគេចាត់ទុកថាជាបញ្ហាធ្ងន់ធ្ងរ ដោយសារប្រទេសថៃត្រូវការពលករបរទេសយ៉ាងខ្លាំងដើម្បីជួយស្តារសេដ្ឋកិច្ចដែលរងការរាតត្បាតដោយជំងឺកូវីដ-១៩។ ឥឡូវនេះយើងមានគម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗជាច្រើនក្នុងការងារសំណង់នៃបំពង់បង្ហូរ ហើយយើងក៏មានវិស័យទេសចរណ៍ និងការងារសេវាកម្មជាច្រើនផងដែរ ដែលត្រូវបំពេញ បន្ទាប់ពីរដ្ឋាភិបាលបានប្រកាសថានឹងបើកប្រទេសឡើងវិញយ៉ាងពេញលេញដល់ភ្ញៀវទេសចរអន្តរជាតិ»។ ប៉ុន្តែបន្ទាប់ពីការបើកដំណើរការឡើងវិញរបស់ប្រទេសថៃ និងការបន្ធូរបន្ថយការផ្ទុះរាលដាល ការនាំចូលពលករបរទេសពីប្រទេសទាំងបីនេះទំនងជាមានភាពងាយស្រួលជាងមុន ជាពិសេសពីប្រទេសមីយ៉ាន់ម៉ា ដែលកម្មករចំនួន ១០០,០០០ នាក់ ត្រូវបានគេរំពឹងថានឹងត្រឡប់ទៅប្រទេសថៃវិញនៅចុងឆ្នាំនេះ។

លោក Pairoj បានមានប្រសាសន៍ថា "តាមដែលអាជ្ញាធរទទួលខុសត្រូវបានពិភាក្សារឿងនេះជាមួយប្រតិបត្តិករធុរកិច្ចថៃ ដែលធុរកិច្ចថៃទាមទារឲ្យមានការនាំចូលពលករបរទេសប្រមាណ ២៧៧,០០០ នាក់ ប៉ុន្តែមកដល់ពេលនេះមានតែប្រមាណ ២ ម៉ឺននាក់ប៉ុណ្ណោះដែលបានមកដល់"។ លោក Pairoj បានមានប្រសាសន៍ថា នៅក្រោមកាលៈទេសៈធម្មតា សេដ្ឋកិច្ចរបស់ប្រទេសថៃទាមទារពលករបរទេសប្រហែល៣ លាននាក់ ប៉ុន្តែនាពេលបច្ចុប្បន្ននេះមានពលករចំណាកស្រុកដែលមានឯកសារចំនួនប្រហែល ២,៥ លាននាក់នៅក្នុងប្រទេស។

## ស្ថានទូតចិននិយាយថា
## ចំណាប់ខ្មាំងជនជាតិចិនដែលជាប់នៅកម្ពុជាត្រូវបានគេជួយសង្គ្រោះ

https://www.khmertimeskh.com/ July 15, 2022

ជនជាតិចិនមួយក្រុមដែលត្រូវបានបោកបញ្ឆោតមកកម្ពុជា និងចាប់ពង្រត់ដោយក្រុមបោកប្រាស់ត្រូវបានជួយសង្គ្រោះហើយ នេះបើយោងតាមសេចក្តីថ្លែងការណ៍របស់ស្ថានទូតចិនប្រចាំប្រទេស។ ស្ថានទូតបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍មួយដែលបានចេញផ្សាយកាលពីថ្ងៃពុធ ថាជនរងគ្រោះបានទៅប្រទេសកម្ពុជាបន្ទាប់ពីត្រូវបានបោកបញ្ឆោតដោយការផ្តល់ជូនការងារក្លែងក្លាយ។ ស្ថានទូតមិនបានបង្ហាញចំនួនជនរងគ្រោះទេ។ ពួកគេត្រូវបានឃុំខ្លួនដោយខុសច្បាប់នៅកន្លែងលាក់ខ្លួនរបស់ក្រុមឆបោក ដែលទាមទារប្រាក់លោះពីគ្រួសារដើម្បីដោះលែងពួកគេ។ សេចក្តីថ្លែងការណ៍បាននិយាយថា ក្រុមគ្រួសារបានជូនដំណឹងភ្លាមៗដល់អាជ្ញាធរ ដោយអនុញ្ញាតឱ្យភ្នាក់ងារអនុវត្តច្បាប់មកពីប្រទេសចិន និងកម្ពុជា ធ្វើប្រតិបត្តិការជួយសង្គ្រោះរួមគ្នា។ ស្ថានទូតបានក្រើនរំលឹកជនជាតិចិនក្នុងប្រទេសអាស៊ីអាគ្នេយ៍ឱ្យប្រុងប្រយ័ត្នចំពោះការបោកប្រាស់តាមរយៈបណ្តាញទូរគមនាគមន៍ និងក្រុមលេងល្បែងតាមអ៊ីនធឺណេតដែលមានមូលដ្ឋាននៅក្នុងស្រុក ដែលជាទូទៅតែងតែផ្សព្វផ្សាយក្រោមពាក្យថា "ក្លាយជាអ្នកមានក្នុងរយៈពេលខ្លី"។

សារតារៈ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ មានការកើនឡើងនៃករណីចាប់ជំរិត និងការជួញដូរមនុស្ស ដែលពាក់ព័ន្ធនឹងជនជាតិចិននៅកម្ពុជា។ រឿងនេះបានកើតឡើងបន្ទាប់ពីក្រុមឆបោកល្បែងស៊ីសង និងបោកប្រាស់តាម

ទូរគមនាគមន៍របស់ចិនបានផ្លាស់ប្តូរទីតាំងទៅទីនោះ បន្ទាប់ពីមានការបង្ក្រាបជាច្រើននៅក្នុងប្រទេសចិន។ កាលពីដើមឆ្នាំនេះ របាយការណ៍អំពីជនជាតិចិនម្នាក់ដែលត្រូវបានចាប់ជំរិត និងបង្ខំឱ្យធ្វើការជា "ទាសករឈាម" ដោយក្រុមអ្នកបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណេតនៅកម្ពុជា បានធ្វើឱ្យប្រទេសចិនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ករណីជនជាតិចិនចាប់ជំរិត និងបង្ខំឱ្យធ្វើការជា "ទាសករឈាម" ដោយក្រុមបោកប្រាស់ល្បែងអនឡាញនៅកម្ពុជា គឺជា "ការប្រឌិតសុទ្ធសាធ" ស្ថានទូតចិនប្រចាំនៅកម្ពុជា និងប៉ូលីសក្នុងតំបន់បាននិយាយកាលពីខែមីនាឆ្នាំនេះ។ សកម្មភាពឧក្រិដ្ឋកម្មនេះបានកើតចេញពីទីក្រុងកំពង់ផែក្រុងព្រះសីហនុ ដែលមានវិស័យអចលនទ្រព្យរីកដុះដាលខ្លាំងក្នុងឆ្នាំ២០១៦ បានទាក់ទាញអ្នកវិនិយោគចិន រួមទាំងល្បែងស៊ីសងតាមប្រព័ន្ធអ៊ីនធឺណែត និងអ្នកបោកប្រាស់តាមបណ្តាញទូរគមនាគមន៍។ ក្នុងឆ្នាំ២០១៩ ប្រទេសចិន និងកម្ពុជាបានបង្កើតក្រុមការងាររួមគ្នាមួយ ដើម្បីដោះស្រាយសកម្មភាពឧក្រិដ្ឋកម្ម ដូចជាការចាប់ជំរិត និងចាប់ពង្រត់ជាដើម។ caixinglobal.com

## ខេត្តនៃប្រទេសវៀតណាមច្រើនប្រែងប្រយុទ្ធប្រឆាំងការជួញដូរមនុស្សឆ្លងដែនមកកម្ពុជា

https://www.khmertimeskh.com/ Khmer Times July 16, 2022

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អាជ្ញាធរ និងប្រជាជននៃខេត្ត Gia Lai ភាគកណ្តាលបានចាត់វិធានការយ៉ាងខ្លាំង ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សឆ្លងដែន។ ក្នុងសប្តាហ៍ទី១ ខែកក្កដា យុវជន៧នាក់នៅភូមិ Kloong ឃុំ Ia O ស្រុក Ia Grai ដែលជាជនរងគ្រោះនៃការជួញដូរមនុស្សឆ្លងដែន ត្រូវបានជួយសង្គ្រោះ និងនាំយកមកផ្ទះវិញដោយសុវត្ថិភាព។ ឆ្លៀតយកផលប្រយោជន៍ពីភាពមិនច្បាស់លាស់ និងកង្វះការយល់ដឹងរបស់ជនជាតិភាគតិចនៅក្នុងខេត្តភាគកណ្តាល និងស្ថានភាពសេដ្ឋកិច្ចដ៏លំបាករបស់អ្នកដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាត COVID-19 នៅ Gia Lai លេចចេញនូវល្បិចដោយផ្តល់ "ការងារសមរម្យ និងប្រាក់ខែខ្ពស់" បណ្តាលឱ្យអ្នកផ្សេងចេញពីប្រទេសដោយខុសច្បាប់។ ជនរងគ្រោះជនជាតិភាគតិចជាច្រើននៅក្នុងខេត្ត Gia Lai បានធ្លាក់ខ្លួនជាជនរងគ្រោះដោយសារមេខ្យល់ក្នុងក្រុមមេក្លោងជួញដូរមនុស្សឆ្លងដែន។

Puih Thai អាយុ២៨ ឆ្នាំ ជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះទាំងប្រាំពីរដែលត្រូវបានជួយសង្គ្រោះបាននិយាយថាគាត់បានទាក់ទងជាមួយ Tran Quang Quyet អាយុ២១ ឆ្នាំ ដែលមានដើមកំណើតនៅក្នុងខេត្ត Kon Tum ក្នុងតំបន់តាមហ្វេសប៊ុក ដែលបានជួយគាត់ឱ្យទទួលបានការងារសមរម្យជាមួយនឹងកម្រិតប្រាក់ខែខ្ពស់ នៅកម្ពុជា។ ទោះយ៉ាងណាក៏ដោយ នៅពេលដែលពួកគេមកដល់ប្រទេសកម្ពុជា ពួកគេត្រូវបានបង្ខំឱ្យធ្វើការងារយ៉ាងលំបាក ខណៈដែលនិយោជករបស់ពួកគេតែងតែវាយពួកគេដោយដំបង និងខ្សែភ្លើង។ ពួកគេក៏ត្រូវបានគេគំរាមថានឹងត្រូវគេលក់ចេញឬសម្លាប់។ តស៊ូដើម្បីរស់ Puih Thai សុំឱ្យគេបញ្ជូនត្រលប់ទៅផ្ទះវិញ។ ជនដែលបានបោកបញ្ឆោត និងលក់គាត់មកប្រទេសកម្ពុជា បានស្នើសុំឱ្យគាត់ទាក់ទងក្រុមគ្រួសាររបស់គាត់ និងបង់ប្រាក់ជានាចំនួន ៩០ លានដុង (៣៨០០ ដុល្លារ)។ បន្ទាប់មក Quyet បានប្រគល់ខ្លួនគាត់នៅស្ថានីយព្រំដែន Ia O នៃខេត្ត Gia Lai ។ បច្ចុប្បន្នជននេះត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងដើម្បីបម្រើការស៊ើបអង្កេត។ អ្នកសមគំនិតរបស់ Quyet គឺ Phan Ngoc Duc ត្រូវបានគេរកឃើញថាបានភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ជាមួយមនុស្សមួយចំនួននៅបរទេស ដើម្បីយកអ្នកស្រុកជនជាតិភាគតិចជាច្រើនមកប្រទេសកម្ពុជាដោយខុសច្បាប់។

នៅថ្ងៃទី៥ ខែកក្កដា ប៉ូលីសខេត្ត Gia Lai បានសម្រេចបើកដំណើរការនីតិវិធីផ្លូវច្បាប់ចំពោះករណីនេះ និង Duc ហើយចាប់ខ្លួនគាត់ពីបទជួញដូរមនុស្ស។ Duc បានសារភាពថា ខ្លួនបានលក់ជនរងគ្រោះចំនួនប្រាំពីរនាក់នៅឃុំ Ia O ឱ្យមនុស្សម្នាក់ក្នុងប្រទេសកម្ពុជា ដោយទទួលបានប្រាក់ជាង ៣០០លានដុង និងចែកឱ្យ Quyet ចំនួន ១២៨លានដុង។

លោកវរសេនីយ៍ឯក Ngo Gia Cuong នៃប៉ូលីស Gia Lai បានក្រើនរំលឹកអ្នកស្រុកកុំឱ្យជឿលើព័ត៌មានជ្រើសរើសបុគ្គលិកនៅលើបណ្ដាញសង្គម និងត្រូវសិក្សាឱ្យបានហ្មត់ចត់អំពីខ្លឹមសារការងារ និងអាសយដ្ឋានជាក់លាក់ ដើម្បីជៀសវាងការបោកប្រាស់។ លោកបានសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការពង្រឹងការផ្សព្វផ្សាយដល់គ្រប់គ្រួសារដើម្បីលើកកម្ពស់ការយល់ដឹងរបស់ជនជាតិភាគតិច និងពង្រឹងការល្បាត និងការសម្របសម្រួលនៅតាមតំបន់ព្រំដែន។ ដើម្បីទប់ស្កាត់ការកើតមានឡើងវិញនៃការក្លែងបន្លំការងារក្នុងមូលដ្ឋាន មន្ទីរការងារ យុទ្ធជនពិការ និងសង្គមកិច្ច កំពុងបង្កើតកម្មវិធីបណ្ដុះបណ្ដាល ដែលមានលក្ខណៈជិតទៅនឹងការព្យាករណ៍តម្រូវការការងាររបស់សហគ្រាសក្នុង និងក្រៅប្រទេស។ ខេត្តក៏កំពុងបង្កើតឱកាសសម្រាប់ប្រជាជនក្រីក្រ និងជនជាតិភាគតិចក្នុងការខ្ចីប្រាក់ដើម្បីអភិវឌ្ឍផលិតកម្ម និងអាជីវកម្ម។ *ទីភ្នាក់ងារសារព័ត៌មានវៀតណាម VNA*

## ឃាត់ខ្លួនបុរសជនជាតិវៀតណាមម្នាក់ពីបទបោកប្រាស់មនុស្សឱ្យមកធ្វើការនៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times July 16, 2022

នគរបាលខេត្ត Quang Nam បានឃាត់ខ្លួនបុរសក្នុងស្រុកម្នាក់ ខណៈដែលពួកគេកំពុងស៊ើបអង្កេតលើការចោទប្រកាន់ថា គាត់បានបញ្ជូនមនុស្សមកធ្វើការនៅប្រទេសកម្ពុជា ដោយខុសច្បាប់ក្នុងតម្លៃមេខ្យល់ជាង ២០០ ដុល្លារក្នុងមួយលើកៗ។

Truong Cong Duy អាយុ៣០ ឆ្នាំ មកពីឃុំ Que Chau ស្រុក Que Son ត្រូវបានចាប់ខ្លួនកាលពីថ្ងៃអង្គារដើម្បីសួរចម្លើយពាក់ព័ន្ធនឹងការធ្វើមេខ្យល់ខុសច្បាប់ចេញពីប្រទេសវៀតណាម។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ យុវជនជាច្រើននៅខេត្ត Quang Nam បានធ្លាក់ខ្លួនជាជនរងគ្រោះ ដោយការផ្សាយពាណិជ្ជកម្មមិនពិតតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ហើយត្រូវបានដឹកជញ្ជូនឆ្លងកាត់ព្រំដែនកម្ពុជាដោយរំពឹងទទួលបានការងារដែលកំពុងរង់ចាំពួកគេ។ យោងតាមនគរបាលមូលដ្ឋានបានឲ្យដឹងថា បន្ទាប់ពីត្រូវបានគេជួញដូរមកប្រទេសកម្ពុជា មនុស្សជាច្រើននាក់នេះត្រូវបានបង្ខំឲ្យធ្វើការដោយកម្លាំង ហើយរកឃើញថាខ្លួនមិនអាចរត់គេចខ្លួនបាន។ កាលពីដើមខែមេសា Duy បានផ្តល់ការងារដែលមានប្រាក់ខែខ្ពស់នៅកម្ពុជាដល់បុរសពីរនាក់ទៀតមកពីឃុំជាមួយគ្នា ដោយសន្យាថាពួកគេនឹងធ្វើការនៅក្រុមហ៊ុនដែលគ្រប់គ្រងដោយស្ត្រីវៀតណាម។ ជនរងគ្រោះត្រូវបានចាប់ជាឈ្លើយជាមួយនឹងជនជាតិវៀតណាមជាច្រើននាក់ទៀត។ ជារៀងរាល់ថ្ងៃ ជនរងគ្រោះដែលត្រូវបានជួញដូរត្រូវបានបង្ខំឱ្យធ្វើពលកម្មយ៉ាងធ្ងន់ធ្ងរអស់រយៈពេលប្រហែល ១២ ម៉ោង ហើយត្រូវបានអ្នកគ្រប់គ្រងធ្វើបាបរាងកាយ។ អ្នកខ្លះថែមទាំងត្រូវឲ្យក្រុមគ្រួសារបង់ថ្លៃលោះប្រសិនបើពួកគេចង់ត្រឡប់ទៅផ្ទះវិញ។ Duy ត្រូវបានបង់ប្រហែល ៥ លានដុង (២១៣ ដុល្លារ) សម្រាប់ជនរងគ្រោះដែលត្រូវបានជួញដូរម្នាក់ៗ។ ចាប់តាំងពីដើមឆ្នាំនេះ Duy បានបញ្ជូនមនុស្ស ៧ នាក់មកកម្ពុជា៕ *Tuoi Tre*

## ជនជាតិចិនត្រូវបានរកឃើញថា ជាក្រុមនាំមុខក្នុងការឆបោកជនជាតិវៀតណាមអោយមកធ្វើការខុសច្បាប់នៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times July 17, 2022

នេះបើតាមភ្នាក់ងារប៉ូលិសព្រហ្មទណ្ឌវៀតណាម ក្រុមឆបោកការងារកំណត់គោលដៅ លើជនជាតិវៀតណាមដែលចង់ស្វែងរកការងារល្អមានប្រាក់ខែច្រើនក្នុងប្រទេសកម្ពុជាត្រូវបានរកឃើញថាដឹកនាំដោយជនជាតិចិន។ នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នៃក្រសួងសន្តិសុខសាធារណៈ បានចេញផ្សាយការរកឃើញកាលពីសប្តាហ៍មុន

ដោយបន្ថែមថា មេក្លោងជនជាតិចិន ត្រូវបានជួយដោយជនជាតិវៀតណាមមួយចំនួននៅកម្ពុជា។ នាយកដ្ឋានក៏បានព្រមានដែរថា អ្នកស្វែងរកការងារធ្វើជនជាតិវៀតណាមជាច្រើននាក់ថ្មីៗនេះ រងគ្រោះដោយសារការបោកប្រាស់អោយរកការងារ។ ជនរងគ្រោះទាំងនេះដែលមានអាយុពី១៨ដល់ ៣៥ ឆ្នាំត្រូវបានបោកប្រាស់ដោយក្រុមបោកបញ្ឆោតថា "ការងារល្អ ជាមួយប្រាក់ខែខ្ពស់" នៅក្នុងប្រទេសកម្ពុជានៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា Zalo និង Facebook ដើម្បីទាក់ទាញជនរងគ្រោះរបស់ពួកគេ។

ប៉ូលិសបាននិយាយថា បន្ទាប់ពីមកដល់ប្រទេសកម្ពុជា អ្នកស្វែងរកការងារជនជាតិវៀតណាមទាំងនេះត្រូវបានបង្ខំឱ្យធ្វើការឱ្យក្រុមជនខិលខូចដូចជា ល្បែងអនឡាញ ការជួញដូរប្រាក់តាមអ៊ីនធឺណែត និងការងារខុសច្បាប់ផ្សេងទៀតនៅក្នុងអ៊ីនធឺណេត។ ជនរងគ្រោះជាច្រើនត្រូវបានបង្ខំឱ្យធ្វើការពី១២ ទៅ១៦ ម៉ោងក្នុងមួយថ្ងៃ ខណៈដែលត្រូវបានហាមឃាត់មិនឱ្យចាកចេញពីកន្លែងធ្វើការ និងមានទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ ទន្ទឹមនឹងនោះ កម្មករជាច្រើននាក់ទៀតត្រូវបានលក់ទៅឱ្យថៅកែផ្សេងទៀត ដើម្បីធ្វើការងារកាន់តែធ្ងន់ធ្ងរ និងខុសច្បាប់។

នាយកដ្ឋានបាននិយាយថា ពួកគេថែមទាំងត្រូវបានជំរុះឱ្យហៅគ្រួសាររបស់ពួកគេនៅប្រទេសវៀតណាមឱ្យបង់ប្រាក់លោះចាប់ពី ៣,០០០ ដុល្លារដល់ ៣០,០០០ ដុល្លារសម្រាប់ការបញ្ជូនទៅវិញ។ ភ្នាក់ងារបានបន្ថែមថា ជនរងគ្រោះជាច្រើនដែលបរាជ័យក្នុងការរត់គេចពីកន្លែងធ្វើការត្រូវបានវាយដំ ធ្វើបាប ឬលក់ទៅឱ្យអ្នករំលោភបំពានផ្សេងទៀត។ ក្រុមដែលរំលោភបំពានលើពលករវៀតណាម និងរំលោភយកទ្រព្យសម្បត្តិគេឃើញភាគច្រើននៅក្រុងបាវិត ក្រុងប៉ោយប៉ែត និងក្រុងព្រះសីហនុ នៃខេត្តស្វាយរៀង បន្ទាយមានជ័យ និងព្រះសីហនុ។ លើសពីនេះ ថែមទាំងមាននៅស្រុកជ្រៃធំនៃខេត្តកណ្តាល និងនៅរាជធានីភ្នំពេញផងដែរ។ ក្នុងរយៈពេលប្រាំមួយខែដំបូងនៃឆ្នាំ២០២២ វៀតណាមបានសហការជាមួយសមភាគីកម្ពុជាក្នុងការជួយសង្គ្រោះមនុស្សជាង២៥០ នាក់ដែលត្រូវបានបោកបញ្ឆោតឱ្យមកធ្វើការដោយខុសច្បាប់នៅកម្ពុជា។ នាយកដ្ឋានបាននិយាយថា ពលរដ្ឋវៀតណាមជាច្រើននាក់បានចាកចេញពីប្រទេសវៀតណាមដោយខុសច្បាប់មកប្រទេសកម្ពុជាដើម្បីធ្វើការនៅកន្លែងល្បែងស៊ីសងតាមអ៊ីនធឺណិត ធ្វើការជាកម្មករដោយបង្ខំ ឬមានទ្រព្យសម្បត្តិត្រូវបានដកហូត។

ទីភ្នាក់ងារបានផ្តល់ដំបូន្មានថា ប្រជាជនត្រូវមានការប្រុងប្រយ័ត្នខ្ពស់ចំពោះ 'ការងារងាយស្រួលដែលមានប្រាក់ខែច្រើន' ការផ្សាយពាណិជ្ជកម្មដែលត្រូវបានបង្ហោះនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីការពារខ្លួនពីជនរងគ្រោះដោយក្រុមឆបោក។ ទីភ្នាក់ងារបានណែនាំថា មុននឹងទទួលយកការផ្តល់ជូនការងារនៅក្រៅប្រទេសណាមួយ អ្នកស្វែងរកការងារគួរតែសិក្សាដោយប្រុងប្រយ័ត្ននូវរាល់ព័ត៌មានលម្អិតដែលពាក់ព័ន្ធ រួមទាំងថៅកែ ការងារ កន្លែងធ្វើការ ប្រាក់ឈ្នួល និងច្រើនទៀតពួកគេក៏គួរតែពិគ្រោះជាមួយគ្រួសារ ឬសាច់ញាតិរបស់ពួកគេ ហើយប្រាប់ពួកគេអំពីការងារ និងកន្លែងធ្វើការនាពេលអនាគតរបស់ពួកគេ មុនពេលសម្រេចចិត្តចាកចេញពីប្រទេសវៀតណាមទៅធ្វើការនៅបរទេស។ ភ្នាក់ងារបានស្នើរថា បុគ្គល ឬអង្គការណាមួយដែលបង្ហាញសញ្ញានៃការបោកបញ្ឆោតមនុស្សឱ្យចូលមកធ្វើការក្នុងប្រទេសកម្ពុជា គួរតែត្រូវបានរាយការណ៍ទៅប៉ូលីស។

ថ្មីៗនេះ ជនជាតិវៀតណាមមួយក្រុមបានជួយសង្គ្រោះក្មេងប្រុសអាយុ ១៧ ឆ្នាំម្នាក់ពីភាគខាងត្បូងប្រទេសវៀតណាមបានជាង ៣ ខែ បន្ទាប់ពីគាត់ត្រូវបានលក់មកប្រទេសកម្ពុជា និងបង្ខំឱ្យធ្វើការឱ្យក្រុមអ្នកលេងល្បែងអនឡាញជនជាតិចិន។ ក្រោយការចរចារួច ក្រុមនេះបានបង់លុយឱ្យជនជាតិចិនចំនួន៤.០០០ដុល្លារដើម្បីដោះលែង C ហើយនាំគាត់ទៅប្រទេសវៀតណាមវិញនៅថ្ងៃទី៣០ មិថុនា ។ ការសង្គ្រោះនេះត្រូវបានធ្វើឡើងបន្ទាប់ពីក្រុមនេះបានដឹងអំពីការបោកប្រាស់ការងារពីអត្ថបទមួយដែលបានចុះផ្សាយក្នុងកាសែត Tuoi Tre ( Youth ) កាលពីពាក់កណ្តាលខែមិថុនា។ *Tuoi Tre News*

# ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២

## សភាពាណិជ្ជកម្មថៃនិយាយថា ប្រទេសថៃត្រូវការពលករចំណាកស្រុកបន្ថែមទៀត

https://www.information.gov.kh/ AKP ភ្នំពេញថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២

សភាពាណិជ្ជកម្មថៃ (TCC) បានសង្កត់ធ្ងន់ទៅលើតម្រូវការសម្រាប់ពលករចំណាកស្រុកបន្ថែមទៀតក្នុងវិស័យផ្សេងៗ ដើម្បីជួយសេដ្ឋកិច្ចថៃឱ្យងើបឡើងវិញពីជំងឺរាតត្បាត។ អនុប្រធាន TCC លោក ផូច អារ៉ាមវឌ្ឍនានុន ត៍ បាននិយាយថា មានតម្រូវការខ្ពស់សម្រាប់ពលករនៅក្នុងវិស័យដែលពឹងផ្អែកទៅលើកម្លាំងពលកម្ម ដូចជាទំនិញកសិកម្ម និងការកែច្នៃម្ហូបអាហារសម្រាប់ការនាំចេញ សំណង់ ទេសចរណ៍ និងសេវាកម្មជាដើម។ ទោះជាយ៉ាងណាក៏ដោយ លោកបានសង្កត់ធ្ងន់ថា កត្តានានាដូចជាបញ្ហានៅក្នុងប្រទេសដើមរបស់ពលករចំណាកស្រុក និងការប្រកួតប្រជែងសម្រាប់ពលករមកពីប្រទេសផ្សេងៗទៀត កំពុងរារាំងដល់ការជ្រើសរើសពលករ ហើយនេះជាហេតុធ្វើឱ្យការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ប្រទេសថៃមានភាពយឺតយ៉ាវ។ អនុប្រធានរូបនេះបានប៉ាន់ប្រមាណថា ព្រះរាជាណាចក្រមួយនេះនឹងត្រូវការពលករចំណាកស្រុកយ៉ាងហោចណាស់ពី ៣លានទៅ ៤លាននាក់ ដើម្បីធ្វើឱ្យសេដ្ឋកិច្ចរបស់ខ្លួនដើរទៅមុខ។

យោងតាមលោក កៃរ៉ូច ចុតីកាសាធៀន ប្រធាននាយកដ្ឋានការងារនៃក្រសួងការងារថៃបានឱ្យដឹងថា បច្ចុប្បន្ន ប្រទេសថៃមានពលករចំណាកស្រុកចំនួន ២,៥លាននាក់មកពីប្រទេសឡាវ កម្ពុជា និងមីយ៉ាន់ម៉ា។ ដើម្បីដោះស្រាយបញ្ហាខ្វះខាតកម្លាំងពលកម្ម គណៈរដ្ឋមន្ត្រីបានអនុម័តផែនការគ្រប់គ្រងការងារ ដែលរួមមានការអនុញ្ញាតឱ្យពលករនិយោជិតដែលមានឯកសារអាចស្នាក់នៅរហូតដល់ខែកុម្ភៈ ឆ្នាំ២០២៥។ ពលករដែលមិនមានឯកសារក៏នឹងត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះ និងធ្វើការរហូតដល់កាលបរិច្ឆេទខាងលើដូចគ្នា។ លោកបាននិយាយបន្ថែមថា ជាមួយនឹងផែនការការងារដែលបានធ្វើឱ្យប្រសើរឡើងនេះ និងការមកដល់នៃពលករកាន់តែច្រើនថែមទៀត ប្រទេសថៃអាចនឹងទទួលបានពលករចំណាកស្រុកប្រមាណជិត ៣លាននាក់នៅត្រឹមដំណាច់ឆ្នាំនេះ៕ (ប្រភព VNA បកប្រែដោយលោក យា ចិន្តាខន្តី) សម្រួលផ្សាយដោយ៖ ធូ កុសល

## អង្គការសង់ត្រាល់អប់រំពលរដ្ឋ
## អំពីសិទ្ធិការងារ និងចំណាកស្រុកស្របច្បាប់នៅបន្ទាយមានជ័យ

https://www.rfa.org/khmer/ ដោយ អាស៊ីសេរី 2022.07.17

សកម្មភាពអង្គការសង់ត្រាល់អប់រំផ្សព្វផ្សាយការយល់ដឹងអំពីសិទ្ធិការងារ និងហានិភ័យនៃការធ្វើចំណាកស្រុកដោយខុសច្បាប់ដល់ពលរដ្ឋនៅស្រុកថ្មពួក នៅខេត្តបន្ទាយមានជ័យ នៅព្រឹកថ្ងៃទី១៧ កក្កដា ២០២២។ មន្ត្រីអង្គការសង់ត្រាល់(CENTRAL)ចុះអប់រំផ្សព្វផ្សាយការយល់ដឹងអំពីសិទ្ធិការងារ និងហានិភ័យនៃការធ្វើចំណាកស្រុកដោយខុសច្បាប់ដល់ពលរដ្ឋនៅស្រុកថ្មពួក នៅខេត្តបន្ទាយមានជ័យ នៅព្រឹកថ្ងៃទី១៧ កក្កដា ។ ពលរដ្ឋ និងអាជ្ញាធរសាទរចំពោះការអប់រំនេះថា ជារឿងល្អ ដើម្បីកុំឱ្យប្រជាពលរដ្ឋចាញ់បោកមេខ្យល់នាំឆ្លងដែនប្រថុយប្រថានទៅប្រទេសថៃដោយខុសច្បាប់។ ការអប់រំអំពីសុវត្ថិភាព នៃការធ្វើចំណាកស្រុកនេះមានពលរដ្ឋចូលរួមចំនួន ៤១នាក់ ដែលធ្វើឡើងនៅឃុំគោគរមៀត ស្រុកថ្មពួក នៅពីថ្ងៃទី១៧ ខែកក្កដា ក្នុងនោះក៏មានអាជ្ញាធរមូលដ្ឋានចូលរួមក្នុងកម្មវិធីនេះដែរ។

ពលរដ្ឋរស់នៅឃុំគោគរមៀត លោកស្រី ធៀន ថៃ ប្រាប់វិទ្យុអាស៊ីសេរីថ្ងៃ ១៧កក្កដា ថា ការអប់រំនេះជាការល្អប្រសើរ និងទទួលបានចំណេះដឹងថ្មីៗទាក់ទងនឹងហានិភ័យនៃការធ្វើចំណាកស្រុក និងច្បាប់ការងារមួយចំនួនបន្ថែម ។ លោកស្រីបន្តថា កន្លងមកលោកស្រីមិនយល់អំពីហានិភ័យ នៃការចំណាកស្រុកខុសច្បាប់ ដោយប្រថុយ

ប្រឋាននោះទេ ។ លោកស្រីអះអាងថា លោកស្រីក៏ធ្លាប់មានមេខ្យល់នាំឆ្លងដែនទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ដែរ ហើយទទួលបានប្រាក់តិចតួចទៅតាមក្រុមមេខ្យល់អោយ ដោយមិនហ៊ានតវ៉ាជាមួយគេនោះទេ ព្រោះខ្លាចអាជ្ញាធរថៃចាប់ដាក់ពន្ធនាគារ ។ លោកស្រីបញ្ជាក់ថា ក្រោយពីចូលរួមវគ្គផ្សព្វផ្សាយនេះរួច គឺលោកស្រីយល់ច្បាស់ថាកន្លងមក លោកស្រីបានចាញ់បោកក្រុមមេខ្យល់ គេងប្រវ័ញ្ចកម្លាំងពលករ៖ «គាត់បានមកពន្យល់ គាត់ក៏ពន្យល់ល្អ ដើម្បីដាស់តឿនយើង យើងទៅធ្វើការនៅប្រទេសថៃ ។ បើសិនជាគេបោកគេអីគាត់អោយទំនាក់ទំនងតាមលេខទូរស័ព្ទ ហើយបើយើងទៅណាមកណា ក៏ទៅតាមច្បាប់ ឱ្យមានប័ណ្ណឆ្លងព្រំដែន (Border pass) ក្រដាសឆ្លងដែនអីណា ។ ពីមុនខ្ញុំមិនដឹងអីផង បើលោកគ្រូគាត់មកពន្យល់អ៊ីចឹង មានន័យថាមានការយល់ច្រើន ខ្ញុំចង់ឱ្យគាត់មកពន្យល់មកឱ្យបានច្រើនជាងហ្នឹង ។ គាត់មកញឹកកាន់តែល្អ បានយល់ច្រើន បើសម្រាប់កូនចៅទៅណាមកណា យើងក៏មានលេខទូរស័ព្ទ លេខអីទាក់ទងទៅរកពួកគាត់ហ្នឹងណា ។ លោកគ្រូគាត់ដែលឱ្យលេខទូរសព្ទមកហ្នឹងណា»។

ទាក់ទងនឹងបញ្ហានេះនាយករងរដ្ឋបាលស្រុកថ្មពួក លោក ធុង សារ៉េត ប្រាប់វិទ្យុអាស៊ីសេរី ថា លោកសប្បាយចិត្ត និងសហការជាមួយអង្គការសង់ត្រាល់ ក្នុងការផ្សព្វផ្សាយពីសិទ្ធិការងារ និងការចំណាកស្រុកស្របច្បាប់ដល់ពលរដ្ឋក្នុងសហគមន៍ ។ លោកបន្តថា កន្លងមកអាជ្ញាធរស្រុកក៏តែងតែអប់រំពលរដ្ឋក្នុងសហគមន៍ឱ្យយល់ដឹងអំពីការធ្វើចំណាកស្រុកដែរ ប៉ុន្តែលោកក៏ទទួលស្គាល់ថានៅមានចន្លោះប្រហោងខ្លះចំពោះការអនុវត្តការងារមួយចំនួនពីការផ្សព្វផ្សាយ ដោយសារមានអាជ្ញាធរមានការងារមមាញឹកច្រើន ។ លោក ធុង សារ៉េត ឱ្យដឹងថា គិតត្រឹមខែ មិថុនា មានពលរដ្ឋខ្មែរស្រុកថ្មពួក ធ្វើចំណាកស្រុកជាង ១ពាន់៥០០នាក់ (១.៥៤៦ )នាក់ ក្នុងនោះមានស្ត្រី ៧៥០ នាក់ នេះជារបាយការណ៍ឆមាសទី១ ឆ្នាំ២០២២របស់អាជ្ញាធរស្រុក៖ «ក្នុងនាមខ្ញុំជាអាជ្ញាធរ គឺមានវិធានការសម្រាប់ជួយឱ្យអនុវត្តបានទូលំទូលាយតាមបណ្តាភូមិឃុំទី១ គឺទាក់ទង និងការជំរុញដល់អាជ្ញាធរដូចជាឃុំភូមិអី យកចិត្តទុកដាក់បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋតាមរយៈកិច្ចប្រជុំអី ជំរុញឱ្យគាត់ផ្សព្វផ្សាយ ដាក់ក្នុងរបៀបវារៈកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ ក៏ដូចជាក្រុមប្រឹក្សាស្រុក ឱ្យមេភូមិជួយសហការជាមួយខាងអង្គការដៃគូ ក៏ដូចជាជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋបន្ថែមទៀត ។ ហើយចំពោះក្នុងនាមខ្ញុំជាអាជ្ញាធរមួយរូបដែរ ខ្ញុំ នឹងកៀរគរក៏ដូចជាអំពាវនាវ ស្នើសុំអង្គការដៃគូ ឱ្យជួយគាំទ្រសកម្មភាពឱ្យបានច្រើនបន្ថែមទៀត ។ ក្រៅពីអង្គការសង់ត្រាល់ ក៏យើងនៅតែកៀរគរអង្គការដៃគូផ្សេងៗឱ្យមានការប្រជុំផ្សព្វផ្សាយដែរ»។

ជុំវិញរឿងនេះ អ្នកសម្របសម្រួល(Coordinator) នៅមជ្ឈមណ្ឌល ធនធានពលករ ទេសន្តរប្រវេសន៍ នៃអង្គការសង់ត្រាល់ ខេត្តបន្ទាយមានជ័យ លោក ស៊ាប សីហា ប្រាប់វិទ្យុអាស៊ីសេរីថា អង្គការសង់ត្រាល់បានអប់រំពលរដ្ឋពីសិទ្ធិការងារ និងការធ្វើចំណាកស្រុកដោយស្របច្បាប់ ហើយការអប់រំផ្សព្វផ្សាយ និងបន្តធ្វើនៅស្រុកផ្សេងៗទៀតក្នុងខេត្តបន្ទាយមានជ័យ ដើម្បីឱ្យពលរដ្ឋយល់ដឹងច្បាស់លាស់ពីសិទ្ធិការងារ និងការចំណាកស្រុកដោយស្របច្បាប់ ជៀសវាងការរំលោភបំពានផ្សេងៗពីថៅកែ និងមេខ្យល់ ក្នុងកំឡុងពេលទៅការងារនៅក្រៅប្រទេស ។ លោកអះអាងថា អ្នកចូលរួមអប់រំភាគច្រើន ជាសាច់ញាតិគ្រួសាររបស់ពលរដ្ឋធ្វើចំណាកស្រុក និងទទួលបានបញ្ហាជាច្រើនពីពលរដ្ឋ ហើយអាជ្ញាធរ ក៏សប្បាយចិត្ត ដោយទទួលបានព័ត៌មានជាច្រើនពីពលរដ្ឋ ។ លោក ស៊ាប សីហា បញ្ជាក់ថា កាលពីខែមិថុនាកន្លងទៅ ក៏បានអប់រំពលរដ្ឋប្រមាណជិត ១ពាន់នាក់ ស្រុកព្រះនេត្រព្រះ ស្រុកភ្នំស្រុក ស្រុកថ្មពួក ស្រុកស្វាយចេក និងស្រុកមង្គលបុរីដែរ៖ «ដើម្បីឱ្យប្រជាពលរដ្ឋគាត់សំណាកស្រុកហ្នឹងមានសុវត្ថិភាព ទាំងការធ្វើចំណាកស្រុកពេលដែលគាត់ទៅដល់ប្រទេសគោលដៅហ្នឹង អោយគាត់ស្គាល់អំពីសិទ្ធិរបស់គាត់ ថា ការធ្វើការងារហ្នឹង មិនត្រូវបានរំលោភបំពានពីថៅកែ ហើយមួយវិញទៀតឱ្យគាត់មានប្រាក់សល់អីផ្ញើមកក្រុមគ្រួសារដែលនៅស្រុកវិញណាបង ។ យើងឃើញថាប្រជាពលរដ្ឋគាត់មានបញ្ហាត្រង់ថា ការចំណាកស្រុកទាំងមានឯកសារ

ក្ដី ពុំមានឯកសារក្ដីក៏ជាបញ្ហាមួយដែលពេលគាត់ឆ្លងទៅដល់ប្រទេសគោលដៅអ៊ីចឹង គាត់មានបញ្ហារំលោភបំពានពីថៅកែអ៊ីចឹង ។ អង្គការសង់ត្រាល់ហ្នឹង មានកម្មវិធីមួយ គឺចងក្រងក្រុមស្ម័គ្រចិត្តគេហៅថា ស្មា(SMA) ហ្នឹងទៅតាមមូលដ្ឋាន ដើម្បីបញ្ជ្រាបផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋ ដែលនៅតាមមូលដ្ឋានហ្នឹងឯង»។

អង្គការសង់ត្រាល់អប់រំពលរដ្ឋអំពីចំណេះដឹងសុវត្ថិភាព នៃការធ្វើចំណាកស្រុក និងការពារខ្លួនកុំឱ្យចាញ់បោកមេខ្យល់ និងអំពីក្រុមហ៊ុនដែលបានចុះបញ្ជី(MOU)អនុស្សរណៈយោគយល់គ្នាជាមួយកម្ពុជានិងថៃ រួមទាំងឯកសារស្របច្បាប់ពលរដ្ឋត្រូវមាន ដើម្បីចៀសវាងមានការកេងប្រវ័ញ្ចពីថៅកែ ។ អង្គការសង់ត្រាល់រកឃើញថា ពលរដ្ឋជាង២ពាន់នាក់ត្រូវបានចាញ់បោកក្រុមមេខ្យល់ ក្នុងរយៈពេល៦ខែ ដែលនាំទៅធ្វើការនៅក្រៅប្រទេស ពិសេសគឺប្រទេសថៃ ចាប់ពីខែមករា ២០២២ មក៕

## ពលករខ្មែរប្រមាណ៤0នាក់នៅតែមិនទាន់ទទួលបានប្រាក់ខែ ពីថៅកែថៃ

https://www.rfa.org/khmer/ ដោយ ជាតិ ចំណាន 2022.07.16

ពលករខ្មែរធ្វើការជាកម្មករសំណង់ប្រមាណ៤០នាក់ រស់នៅក្នុងការដ្ឋានសំណង់មួយនៅទីក្រុងបាងកក (Bangkok) ប្រទេសថៃ ត្អូញត្អែរថា ពួកគាត់មិនមានអាហារហូបចុក និងលុយចាយប្រចាំថ្ងៃទេ ព្រោះថៅកែមិនបានបើកប្រាក់ខែឲ្យពួកគាត់៤៣ថ្ងៃមកហើយ។ ពួកគាត់ទទូចដល់ស្ថានទូតខ្មែរ និងអង្គការសប្បុរសនានា ជួយផ្ដល់ជាស្បៀងអាហារតិចតួច និងជួយអន្តរាគមន៍ឲ្យថៅកែបើកប្រាក់ខែឲ្យពួកគាត់។ ពលករ ពលការិនីប្រមាណ៤០នាក់ ដែលធ្វើការសំណង់នៅប្រទេសថៃ កំពុងបន្តទន្ទឹងរង់ចាំប្រាក់ឈ្នួលពីថៅកែជាងមួយខែមកហើយ ប៉ុន្តែថៅកែចេះតែសន្យាពីមួយអាទិត្យហើយ មួយអាទិត្យទៀត។ ពលករទាំងអស់ថ្លែងថា ស្ថានភាពពួកគាត់លំបាកជាង ១ខែហើយ គឺមិនមានម្ហូបអាហារបរិភោគ ប្រាក់ចំណាយផ្សេងៗ ពេលខ្លះឈឺមិនហ៊ានទៅមន្ទីរពេទ្យ ព្រោះគ្មានលុយបង់ថ្លៃព្យាបាល។

ពលការិនីធ្វើការសំណង់នៅទីក្រុងបាងកកលោកស្រី ញឹម សារម្យ រស់នៅប្រទេសថៃ ៥ឆ្នាំ មកពីស្រុកសង្កែខេត្តបាត់ដំបង ប្រាប់វិទ្យុអាស៊ីសេរីនៅរសៀលថ្ងៃទី១៦ ខែកក្កដាថា ពលករទាំងអស់នៅការដ្ឋានសំណង់ខណ្ឌចតុចក្រនេះ ដេកចាំឲ្យថៅកែបើកប្រាក់ខែឲ្យ ។ លោកស្រីបន្តថា ថៅកែសន្យានឹងសងថ្លៃពលកម្មឲ្យទាំងអស់ និងស្នើសុំឲ្យពួកគាត់ទៅធ្វើការសិន តែលោកស្រីបានបដិសេធព្រោះគ្មានលុយទិញអង្ករ ម្ហូប ចំណី គ្មានកម្លាំងធ្វើការទេ។ លោកស្រីស្នើដល់ស្ថានទូតខ្មែរសូមចុះជួយដល់ពលករទាំងអស់ ដោយជួយចរចាជាមួយថៅកែ ដើម្បីបើកប្រាក់ឈ្នួលដល់កម្មករសំណង់ទាំងអស់ផង៖ «ចាស! គេថាឲ្យ ឲ្យ ប៉ុន្តែដល់ខ្ញុំមកបីថ្ងៃទទឹកភ្លៀង ទទឹកអីមកទៅ ដល់ពេលមកអត់ ដល់អត់មកអត់ ដល់ពេលគេថាហោចាំមើលថ្ងៃនេះថ្ងៃនោះទៀត។ បើថាឲ្យមិនបានពេញក៏ហីចុះ ក្នុងរយៈពេលជាង១ខែហ្នឹងណា បានត្រឹមតែថ្លៃម្ហូបតិចតួចកូនង៉ាន(កូនឈ្នួល)គ្នាក៏អស់ចិត្តដែរ យកទៅសង ថ្លៃកាប់ខាវគេ ថ្លៃម្ហូបគេ រួចហើយចាំទៅណាទៅណីទៀត ថាចាំមើលមើល ។ កំណត់ដូចពាក្យគេនិយាយ។កុំឲ្យថាយើង គេនិយាយអីចឹងហើយ យើងជឿនេះជឿនោះមកខ្លាចគេខឹងយើងអីចេះទៀត ព្រោះធម្មតាខ្មែរវា ដូចថាវាត្រូវគេធ្វើបាបគេជិះជាន់អីចឹង បើមិនថានិយាយទៅ នៅលើតែគេថា នៅលើតែមាត់គេ»។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងសុំការស្រាយបំភ្លឺជុំវិញរឿងនេះពីមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃលោក ផៃ លន បានទេនៅល្ងាចថ្ងៃទី១៦ខែកក្កដា ដោយទូរស័ព្ទហៅចូលជាច្រើនដងតែពុំមានអ្នកទទួល។ ជុំវិញរឿងនេះមន្ត្រីគម្រោងនៃអង្គការសង់ត្រាល់(Central) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន លើកឡើងថា បញ្ហាដែលពលករចេះតែជួបគឺរឿងដែលថៅកែច្រើនតែយកប្រៀប និងកេងចំណេញលើកម្លាំងពលកម្មរបស់ពលករនោះ ដោយសារពួកថៅកែទាំងនោះមើលឃើញថាពួកគាត់មិនមានឯកសារស្របច្បាប់ដើម្បីធ្វើការ ។ ម្យ៉ាងទៀតនៅពេលដែលពលករទៅធ្វើការឲ្យ ថៅកែមិនបាននិយាយរឿងលក្ខខណ្ឌប្រាក់ឈ្នួលឲ្យបានច្បាស់។ លោកបញ្ជាក់ថា ទោះក្នុងករណី

ណាក៏ដោយភាគច្រើនអ្នកដែលរងគ្រោះគឺពលករខ្មែរ ។ លោកផ្ដាំដល់ពលករទាំងអស់មុននឹងមកធ្វើការ ត្រូវសិក្សាឈ្វេងយល់ឲ្យបានច្បាស់នូវច្បាប់ការងារ និងអំពាវនាវដល់ស្ថានទូតខ្មែរ សុំចុះពិនិត្យ និងដោះស្រាយរាល់ទុក្ខលំបាករបស់ប្រជាពលករឲ្យបានទាន់ពេល៖ «មិនបើកប្រាក់ខែឲ្យ ពន្យារថាហ៊ឹះ បើកខែប៉ុណ្ណេះៗអីចឹងណា ព្រោះអីខ្ញុំឃើញ ករណីខ្លះវាអីចឹងណ៎ា ។ ករណីខ្លះពន្យារ ពន្យារ មិនចង់បើកឲ្យគ្នាទេថា អឺ! ចាំថ្ងៃនេះ ចាំថ្ងៃនោះអីចឹងណ៎ា វាឃើញច្រើនអីចឹង ហើយមួយរយៈនេះឃើញបងប្អូនពលករហ្នឹងគាត់ ខលមកទំនាក់ទំនងតាមខ្ញុំដែរ តែដល់ពេលខ្ញុំនិយាយជាមួយទៅ គាត់សន្យាថាអឺ! ចាំមើលថ្ងៃនេះ ចាំមើលថ្ងៃនោះអីចឹងណ៎ា វាអត់ច្បាស់លាស់ត្រង់ណាអីចឹងណ៎ា ជាពិសេសគឺពលករសំណង់រ៉ាប់ម៉ៅហ្នឹងឯង»។

ពលករសំណង់តែងតែរស់នៅជាក្រុមៗមានគ្នាប្រមាណពី៤០នាក់ទៅ៥០នាក់ ហើយពួកគាត់តែងបោះតង់នៅក្បែរការដ្ឋានដែលពួកគាត់ធ្វើការនោះ។ ស្ថានភាពដែលពលកររស់នៅគឺជាខ្ទមប្រក់ពីស័ង្កសី និងជញ្ជាំងបិទបាំងដោយតង់កៅស៊ូ ។ ពលករសំណង់ថា កន្លែងស្នាក់នៅរបស់ពួកគាត់គឺរស់នៅតែបែបនេះរហូតមក បន្ទាប់ពីផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត ក្រោយពីសំណង់បានសង់រួចរាល់។ ពេលមានភ្លៀងម្ដងៗ ទឹកដក់ប៉ប៊ិចប៉ប៉ាច់ និងមានមូសច្រើន តែពួកគាត់ចេះតែទ្រាំ ស៊ូធ្វើការដោយមិនត្អូញត្អែរ ដើម្បីរកអង្ករប្រេកផ្ទាំង រកលុយផ្ញើឲ្យកូនរៀន និងម្ដាយឪពុកនៅផ្ទះ។ របាយការណ៍អង្គការសង់ត្រាល់ថា សព្វថ្ងៃមានពលករខ្មែររស់នៅ និងធ្វើការនៅប្រទេសថៃទាំងស្របច្បាប់ និងមិនស្របច្បាប់មានប្រមាណជាងពីរលាននាក់៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/07/18/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ ថ្ងៃចន្ទ ៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ នៅវេលាម៉ោង១៥ និង០០នាទី ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្ដមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ បានចាត់កម្លាំងប៉ុស្ដិ៍គីឡូ១៣ ចំនួន០៣នាក់ សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០៣នាក់ និងកម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១៥នាក់ ស្រី៨នាក់ ក្មេងស្រី១នាក់ ។ ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើការពិនិត្យ និងស្ដែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២
## រដ្ឋាភិបាលបើកយុទ្ធនាការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ

https://www.khmertimeskh.com/ ទិត្យ គង់នៅ July 19, 2022

រដ្ឋាភិបាលបានកំណត់គោលដៅលុបបំបាត់ពលកម្មកុមារនៅកម្ពុជាជាអាទិភាព ហើយបានអំពាវនាវដល់អាជ្ញាធរពាក់ព័ន្ធ ទប់ស្កាត់សមាហរណកម្មកុមារក្នុងវិស័យសិប្បកម្ម ផលិតឥដ្ឋ និងវិស័យកសិឧស្សាហកម្ម។ លោក ច័ន្ទ សុខុមចិន្តា ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាបបាននិយាយកាលពីម្សិលមិញថា ការប្រើប្រាស់កុមារក្នុងឧស្សាហកម្មមួយចំនួននៅតែមាន ខណៈកុមារមួយចំនួនបានទៅជួយឪពុកម្តាយ ដើម្បីធ្វើឲ្យជីវភាពគ្រួសារធូរស្បើយ។ លោកបន្តថា៖ «ពលកម្មកុមារនៅខេត្តសៀមរាបមានការថយចុះ ប៉ុន្តែខ្ញុំសង្កេតឃើញថាការងារផលិតឥដ្ឋមួយចំនួនហាក់មិនបានដឹងថាកុមារកំពុងធ្វើការឲ្យក្រុមហ៊ុនរបស់ពួកគេទេ ខណៈកុមារជាច្រើនរួមដំណើរជាមួយឪពុកម្តាយទៅធ្វើការដើម្បីជួយពួកគេ»។ លោកថានៅខេត្តសៀមរាប កុមារកំពុងជួបគ្រោះថ្នាក់ពេលទៅធ្វើការ ឬជួយការងារឪពុកម្តាយ។ លោកបន្ថែមថានៅទូទាំងខេត្តសៀមរាប មានកន្លែងផលិតឥដ្ឋជាង ៩០ កន្លែងដែលកំពុងដំណើរការ និងផ្គត់ផ្គង់ឥដ្ឋនៅលើទីផ្សារ ដោយសារបច្ចុប្បន្នតម្រូវការឥដ្ឋក្នុងខេត្តមានកម្រិតខ្ពស់។ លោកនិយាយថាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបើកយុទ្ធនាការនៅថ្ងៃទី១៤ ខែកក្កដា ដើម្បីទប់ស្កាត់ និងបញ្ឈប់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្ម ផលិតឥដ្ឋ និងវិស័យកសិឧស្សាហកម្មទូទាំងប្រទេសកម្ពុជា។

លោក យី គឹមថាន អនុប្រធានប្រចាំប្រទេសរបស់អង្គការ Plan International Cambodia បានយល់ស្របថាការប្រើប្រាស់ពលកម្មកុមារក្នុងកម្ពុជានៅតែមាន ហើយកុមារមួយចំនួនបានទៅធ្វើការជាមួយឪពុកម្តាយរបស់ពួកគេ។ លោកក៏បានបញ្ជាក់ដែរថា ប្រសិនបើក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានគម្រោងលុបបំបាត់ពលកម្មកុមារ ក្រសួងគួរតែកែប្រែច្បាប់ ដើម្បីកុំឲ្យកុមារធ្វើការនៅឧស្សហកម្មផលិតឥដ្ឋទៀត។លោកបន្តថា៖ «ខ្ញុំគិតថា មធ្យោបាយដ៏ល្អបំផុតក្នុងការបញ្ឈប់ម្ចាស់សិប្បកម្មឥដ្ឋពីការប្រើប្រាស់ពលកម្មកុមារ គឺក្រសួងត្រូវចាត់វិធានការយ៉ាងតឹងរ៉ឹង ដោយចាប់ខ្លួនម្ចាស់ក្រុមហ៊ានដែលប្រើប្រាស់ពលកម្មកុមារ និងដកហូតអាជ្ញាប័ណ្ណក្រុមហ៊ុននោះ»។

លោកស្រី ស៊ើង សរសុចិត្តា រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិយាយកាលពីសប្តាហ៍មុនថា យុទ្ធនាការទប់ស្កាត់ពលកម្មកុមារក្នុងវិស័យសិប្បកម្ម ផលិតឥដ្ឋ និងវិស័យកសិឧស្សាហកម្ម មានគោលបំណងបីគឺ ទី១ ផ្តល់ការណែនាំដល់មន្ត្រីអធិការកិច្ចការងារ និងសមត្ថកិច្ចពាក់ព័ន្ធដែលទទួលសិទ្ធជានគរបាលយុត្តិធម៌ ធ្វើអន្តរាគមន៍ក្នុងការដកហូត ទប់ស្កាត់ សមាហរណកម្មកុមាររងគ្រោះ និងកុមារ ងាយរងគ្រោះនៅ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងវិស័យកសិឧស្សាហកម្ម។ ទីពីរបង្កើនការយល់ដឹង និងលើកកម្ពស់យុទ្ធនាការប្រឆាំងពលកម្មកុមារ ការលាតត្រដាងអំពីមូលហេតុ និងផលប៉ះពាល់នៃពលកម្មកុមារ គោលនយោបាយ និងបទដ្ឋានគតិយុត្ត និងវិធានការ នានា ដើម្បីប្រឆាំងពលកម្មកុមារនៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងវិស័យកសិឧស្សាហកម្ម។ ជាចុងក្រោយ ផ្តល់ប្រតិភូកម្មដល់ផ្នែកអធិការកិច្ចការងារ យន្តការទប់ស្កាត់ បង្ក្រាបបទល្មើស និងប្រព័ន្ធត្រួតពិនិត្យ តាមដានពលកម្មកុមារនៅកន្លែងរបស់កុមារ (សិប្បកម្មផលិតឥដ្ឋ) នៅសាលារៀន និង នៅតាមសហគមន៍ដែលកុមារ និងក្រុមគ្រួសាររបស់ពួកគេរស់នៅ ជូនស្ថាប័នថ្នាក់ក្រោមជាតិបន្តអនុវត្ត។

នៅដើមខែកក្កដា ឆ្នាំ២០២១ ក្រសួងការបរទេសសហរដ្ឋអាមេរិកបានចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស(TIP) ដែលបានបញ្ជាក់ថា នៅកម្ពុជាមានប្រជាជនជាង ១០,០០០ នាក់ រួមទាំងកុមារជិត ៤,០០០ នាក់ដែលកំពុងធ្វើការក្នុងឧស្សាហកម្មផលិតឥដ្ឋនៅទូទាំងប្រទេស៕

# រយៈពេល ១ ឆ្នាំ គម្រោងកិច្ចការពារកុមារនៃអង្គការទស្សនៈពិភពលោក ផ្តល់ផលឱ្យពលរដ្ឋ និងអ្នកពាក់ព័ន្ធជាង ៣៥ ម៉ឺននាក់

https://www.postkhmer.com/national/ ឡុង គីមម៉ារីតា | Publication date 18 July 2022 | 18:14 ICT

**ភ្នំពេញៈ** ក្នុងរយៈពេល ១ ឆ្នាំកន្លងទៅនេះ គម្រោងកិច្ចការពារលើកុមាររបស់អង្គការទស្សនៈពិភពលោក បានផ្តល់ផលទៅកាន់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ៣៥៥ ០០០ នាក់។ មន្ត្រីអង្គការនេះ លើកឡើងថា ស្ថានភាពនៃការប្រើអំពើហិង្សាលើកុមារ ហាក់មានការធ្លាក់ចុះ ប៉ុន្តែក៏នៅតែជាក្តីបារម្ភ ដែលត្រូវរួមគ្នាបន្តទៀត ក្នុងការលុបបំបាត់ និងបញ្ឈប់អំពើហិង្សាលើកុមារកម្ពុជា។ រយៈពេលជាច្រើនឆ្នាំមកហើយ ដែលអង្គការទស្សនៈពិភពលោក បានអនុវត្តគម្រោងនានា ពាក់ព័ន្ធនឹងកិច្ចការការពារ និងការចូលរួមរបស់កុមារ ជាពិសេសនោះ គឺការបញ្ឈប់អំពើហិង្សាលើកុមារគ្រប់រូបភាព បន្ទាប់ពីតួលេខនៃអំពើហិង្សាលើកុមារ ត្រូវបានរកឃើញថា មានកម្រិតខ្ពស់ ។

លោកស្រី ឈឹម រតនា ប្រធានយុទ្ធនាការគំរូអហិង្សា នៃអង្គការទស្សនៈពិភពលោក ប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ១៨ កក្កដាថា ដោយសារតែតួលេខនៃអំពើហិង្សាលើកុមារ មានកម្រិតខ្ពស់ អង្គការទស្សនៈពិភពលោក បានអនុវត្តគម្រោងនានាជាច្រើន។ ក្នុងនោះយុទ្ធនាការគំរូអហិង្សា អ្នកធ្វើបាន ខ្ញុំធ្វើបាន ក៏ជាផ្នែក១នៃគម្រោងរបស់ខ្លួនផងដែរ ដើម្បី ចូលរួមចំណែកបញ្ចប់អំពើហិង្សាលើកុមារ ជាពិសេសការដាក់ទណ្ឌកម្មលើរាងកាយទាំងនៅសាលារៀន និងនៅផ្ទះ។ លោកស្រីបញ្ជាក់ថា៖ «ដោយសារតែគម្រោងទាំងនេះ [គឺជា] ផ្នែក ១ នៃកិច្ចការពារលើកុមារ និងការចូលរួមរបស់កុមារក្នុងឆ្នាំ ២០២១ កន្លងទៅ កម្មវិធីនេះ បានផ្តល់ផលដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធចំនួន ៣៥៥ ០០០ នាក់ ដែលយើងធ្វើក្នុង ៣៣ ក្រុង-ស្រុក ក្នុងចំណោម ៩ រាជធានី-ខេត្ត។ ក្នុងចំណោមនោះ គឺមានកុមារ ១៥០ ០០០ នាក់ បានទទួលផលពីគម្រោងរបស់យើង»។

បើតាមលោកស្រី ឈឹម រតនា របាយការណ៍អង្កេតថ្នាក់ជាតិឆ្នាំ ២០១៣ ពីអំពើហិង្សាលើកុមារ ដែលបង្ហាញដោយក្រសួងកិច្ចការនារី កុមារជាង ៧៥% ធ្លាប់ទទួលរងទម្រង់ ១ នៃអំពើហិង្សា មុនពួកគេឈានចូលវ័យ ១៨ ឆ្នាំ។ ប៉ុន្តែការសិក្សាថ្មី ១ របស់ក្រសួងសុខាភិបាល ធ្វើឡើងកាលពីឆ្នាំ ២០២១ បានរកឃើញថា អំពើហិង្សាលើកុមារ បានធ្លាក់ចុះ មកត្រឹមរង្វង់ជាង ៦០ ភាគរយ ដែលធ្លាប់ទទួលរងនូវការដាក់ពិន័យបែបហិង្សា មុនពួកគេឈានចូលវ័យ ១៨ វិញ។ លោកស្រី ឈឹម រតនា អះអាងថា បើប្រៀបធៀបនឹងការរកឃើញកាលពីឆ្នាំ ២០១៣ និងការរកឃើញក្នុងពេលបច្ចុប្បន្នឃើញថា ចំនួននៃការប្រើប្រាស់អំពើហិង្សាលើកុមារ គឺមានការថយចុះ។ ប៉ុន្តែលោកស្រីនិយាយថា ការថយចុះ គឺនៅតែស្ថិតក្នុងការព្រួយបារម្ភដដែល ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងការរួមគ្នាបន្ថែមទៀត។ លោកស្រីបញ្ជាក់ថា៖ «បើប្រៀបធៀបជាមួយតួលេខរកឃើញទាំងនេះ គឺមានការថយចុះដែរ តែវានៅតិចតួច។ អ៊ីចឹងគឺទាមទារឱ្យមានការងារច្រើនដែលត្រូវធ្វើ និងការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ ដើម្បីលុបបំបាត់ការប្រើអំពើហិង្សាលើកុមារ»។

របាយការណ៍អង្កេតថ្នាក់ជាតិឆ្នាំ ២០១៣ ពីអំពើហិង្សាលើកុមាររបស់ក្រសួងកិច្ចការនារីឱ្យដឹងថា ការប្រើប្រាស់អំពើហិង្សាលើកុមារ បានជះផលអវិជ្ជមានដល់កុមារ។ អំពើហិង្សាមានផលប៉ះពាល់អវិជ្ជមានយូរអង្វែងចំពោះសុខុមាលភាព អាកប្បកិរិយា និងឈានទៅបាត់បង់ធនធានមនុស្ស ដែលប្រកបដោយចំណេះ និងជំនាញ។ របាយការណ៍នោះ បានអះអាងថា ផលប៉ះពាល់ទាំងនេះ រួមមាន រៀនខ្សោយ សុខភាពខ្សោយ មានបញ្ហាក្នុងការរកការងារធ្វើ និងទំនាក់ទំនងក្នុងសង្គម។

ប្រឈមនឹងបញ្ហានេះ លោកស្រី ឈឹម រតនា បញ្ជាក់ថា មានតែការផ្តល់ឱ្យកុមារ នូវបរិយាកាស និងឱកាសទេ ដែលអាចឱ្យពួកគេទទួលបានលទ្ធផលល្អក្នុងជីវិត។ លោកស្រីអំពាវនាវដល់អាណាព្យាបាល ឬឪពុកម្តាយ គ្រូ

បង្រៀន ផ្លាស់ប្តូរឥរិយាបថ ដោយឈប់ប្រើប្រាស់អំពើហិង្សាជាវិធីសាស្ត្រ ក្នុងការអប់រំកុមារ ហើយងាកមកប្រើប្រាស់ការអប់រំបែបវិជ្ជមានជំនួសវិញ។

លោកស្រី ម៉ាន ចិន្តា អ្នកនាំពាក្យក្រសួងកិច្ចការនារី មិនអាចសុំអត្ថាធិប្បាយបានទេ នាថ្ងៃទី ១៨ កក្កដា ដោយលោកស្រី អះអាងថា កំពុងជាប់រវល់៕

# ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២

## អាមេរិកដាក់វៀតណាម កម្ពុជា ប្រុយណេ និងម៉ាកាវ ក្នុងបញ្ជីខ្មៅជួញដូរមនុស្ស

https://kohsantepheapdaily.com.kh/ ២០ ខែ កក្កដា ឆ្នាំ ២០២២ ម៉ោង ១៦:២៦

អាមេរិក ៖ សហរដ្ឋអាមេរិកបានដាក់ប្រទេសវៀតណាម, កម្ពុជា, ប្រុយណេ និងម៉ាកាវចូលក្នុងបញ្ជីខ្មៅនៃការជួញដូរមនុស្ស កាលពីថ្ងៃអង្គារ ទី ១៩ កក្កដា ម្សិលមិញនេះ ដោយអាមេរិកលើកឡើងថា ប្រទេសទាំងនេះមានកិច្ចប្រែងប្រែងខ្សោយក្នុងការបញ្ឈប់ការងារផ្លូវភេទដោយបង្ខំ ឬជួយដល់ពលករចំណាកស្រុក។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ អាមេរិកក៏បានដាក់បញ្ចូលរបបដឹកនាំផ្តាច់ការបេឡារុសក្នុងបញ្ជីខ្មៅផងដែរ និងដាក់ប៊ុលហ្គារីក្នុងបញ្ជីតាមតានជុំវិញការព្រួយបារម្ភថាប្រទេសនេះមិនយកចិត្តទុកដាក់លើការជួញដូរមនុស្ស។ រដ្ឋមន្ត្រីការបរទេសអាមេរិកថ្លែងដូច្នេះថា អំពើពុករលួយគឺជាឧបករណ៍ដ៏សំខាន់បំផុតរបស់ក្រុមជួយដូរដែលអាចឲ្យពួកគេគេចផុតពីភ្នែករបស់រដ្ឋាភិបាល។ «នៅពេលយើងដោះស្រាយបញ្ហានេះដូចទៅនឹងបញ្ហាអាកាសធាតុ និងអំពើពុករលួយទូទាំងការទូត យើងក៏ត្រូវដោះស្រាយពីវិធីដែលពួកគេជួបការជួយដោយផ្ទាល់ផងដែរ»។ ប្រទេសដែលស្ថិតក្នុងបញ្ជីខ្មៅនេះអាចរងទណ្ឌកម្មអាមេរិក ទោះបីរដ្ឋបាលអាមេរិកតែងតែលើកលែងការដាក់ទណ្ឌកម្មសម្រាប់ប្រទេសជាមិត្តដែលសន្យាថានឹងមានការកែលម្អ។

លោកស្រី Kari Johnstone មន្ត្រីជាន់ខ្ពស់ក្រសួងការបរទេសទទួលបន្ទុកប្រឆាំងការជួយដូរមនុស្ស បាននិយាយថា រដ្ឋាភិបាលអាស៊ីជាច្រើនត្រូវបានបន្ទាបចំណាត់ថ្នាក់ដោយសារពួកគេធ្លាប់ស្ថិតក្នុងបញ្ជីតាមដាន និងមិនបានបង្ហាញសញ្ញាកែលម្អ។ លោកស្រីថ្លែងដូច្នេះថា «ជាអកុសល ក្នុងឆ្នាំនេះ មានប្រទេសមួយចំនួននៅក្នុងតំបន់មិនបានបង្កើនកិច្ចប្រឹងប្រែង»៕ (យោងតាមប្រភព៖ AFP)

## លោកស្រី ជូ ប៊ុនអេង៖
## អយុត្តិធម៌ ដែលអាម៉េរិកដាក់កម្ពុជាចូលក្នុងបញ្ជីខ្មៅនៃការជួញដូរមនុស្ស

https://thmeythmey.com/ 20, Jul 2022 , 6:18 pm ដោយ: ឡាយ សុភាវតី

ភ្នំពេញ៖ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស យល់ថា មិនយុត្តិធម៌ឡើយ ដែលក្រសួងការបរទេសអាម៉េរិក សម្រេចឲ្យកម្ពុជាជាប់លេខ៣ ជាប្រទេស ដែលមានការជួញដូរមនុស្ស។ ចំណាត់ថ្នាក់លេខ៣នេះ ធ្វើឲ្យកម្ពុជា ចូលក្នុងបញ្ជីខ្មៅនៃការជួញដូរមនុស្ស។ លោកស្រី ជូ ប៊ុនអេង ស្នើឲ្យភាគីដែលដឹងឮ ពីករណីជួញដូរមនុស្សនៅកម្ពុជា រាយការណ៍ដល់អាជ្ញាធរ ដើម្បីសហការគ្នាដោះស្រាយបញ្ហា។ ឆ្លើយតបនឹងរបាយកាណ៍របស់ក្រសួងការបរទេសអាម៉េរិក ដែលចេញ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការដាក់កម្ពុជាចូលក្នុងបញ្ជីខ្មៅនៃការជួញដូរមនុស្ស លោកស្រី មានប្រសាសន៍ថា «មិនយុត្តិធម៌ទាល់តែសោះ»។

# អាមេរិកថា កម្ពុជាមិនបានបំពេញតាមស្តង់ដារអប្បបរមា ដើម្បីលុបបំបាត់ការជួញដូរមនុស្ស

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី2022.07.20

ក្រសួងការបរទេសអាមេរិកចេញរបាយការណ៍ជួញដូរមនុស្សក្នុងប្រទេសកម្ពុជា ឆ្នាំ២០២២ នេះថា រដ្ឋាភិបាលកម្ពុជាបានដើរថយក្រោយក្នុងការលុបបំបាត់ការជួញដូរមនុស្ស។ មន្ត្រីរដ្ឋាភិបាល សោកស្ដាយចំពោះការវាយតម្លៃនេះ ដោយថា រដ្ឋាភិបាលបានប្រឹងប្រែងលុបបំបាត់ការជួញដូរមនុស្សយ៉ាងសកម្ម ទោះបីក្នុងស្ថានភាពរីករាលដាលជំងឺកូវីដ១៩ ក្ដី។ ដោយឡែក មន្ត្រីសង្គមស៊ីវិលលើកឡើងថា របាយការណ៍នេះ ឆ្លុះបញ្ចាំងពីការពិតនៃការរីករាលដាលការជួញដូរមនុស្សនៅកម្ពុជាពីអ្នកជំនួញចិន។ របាយការណ៍ជួញដូរមនុស្សកម្ពុជាឆ្នាំ២០២២ ចេញដោយក្រសួងការបរទេសអាមេរិក នៅថ្ងៃទី២០ កក្កដា បានវាយតម្លៃថា រដ្ឋាភិបាលកម្ពុជាមិនបានបំពេញតាមស្តង់ដារអប្បបរមា ក្នុងការប្រឹងប្រែងលុបបំបាត់ការជួញដូរមនុស្សនោះទេ។ របាយការណ៍បង្ហាញថា កម្ពុជាដើរថយក្រោយក្នុងការលុបបំបាត់ការជួញដូរមនុស្សដោយសារ បញ្ហាអំពើពុករលួយជាប្រព័ន្ធ ដែលបានរារាំងដល់ការអនុវត្តច្បាប់ បណ្ដោយឱ្យជនល្មើសនៅតែអាចប្រព្រឹត្តបទល្មើស ឬគេចខ្លួនពីការកាត់ទោស ហើយជនរងគ្រោះនៅតែមិនអាចទទួលបានការជួយសង្គ្រោះ។ របាយការណ៍ក៏បានបង្ហាញថា រដ្ឋាភិបាលកម្ពុជាមិនបានផ្តល់ការគាំទ្រគ្រប់គ្រាន់ដល់ជនរងគ្រោះទាំងក្នុងស្រុក និងបរទេសពីការជួញដូរនោះទេ ដោយបានពឹងផ្អែកស្ទើរទាំងស្រុងពីម្ចាស់ជំនួយបរទេស និងអង្គការក្រៅរដ្ឋាភិបាលទៅវិញ។

ទាក់ទងនឹងបញ្ហានេះ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបការជួញដូរ និងរត់ពន្ធមនុស្សអ្នកស្រី ជូ ប៊ុនអេង ប្រាប់វិទ្យុអាស៊ីសេរីថា អ្នកស្រីសោកស្ដាយ ចំពោះការវាយតម្លៃនេះ។ អ្នកស្រីយល់ថា របាយការណ៍នេះមិនឆ្លុះបញ្ចាំងពីតថភាពជាក់ស្ដែងអំពីបញ្ហាការជួញដូរមនុស្សនៅកម្ពុជានោះទេ ព្រោះវាបានបញ្ចូលករណីឆបោករបស់បរទេស និងការកេងប្រវ័ញ្ចកម្លាំងពលកម្មចូលក្នុងរបាយការណ៍។ អ្នកស្រីថា រដ្ឋាភិបាលបានប្រឹងប្រែងលុបបំបាត់ការជួញដូរមនុស្សយ៉ាងសកម្ម ទោះបីក្នុងស្ថានភាពរីករាលដាលជំងឺកូវីដ១៩ ក្ដី ដោយក្នុងឆ្នាំ២០២១ កន្លងទៅ ក្រសួងមហាផ្ទៃបានបង្ក្រាបការជួញដូរមនុស្សកើនឡើង ២ដង ច្រើនជាងឆ្នាំ២០២០៖ «មានករណីជាច្រើន ដែលពាក់ព័ន្ធជាមួយជនបរទេសតែវាអត់មានចូលក្នុងករណីជួញដូរ វាពាក់ព័ន្ធជាមួយនឹងការចាប់ជំរិត រឿងជនបរទេសគ្នាគាត់ ឬមួយក៏និយាយពីរឿងវិវាទការងារ ឬក៏យកករណីចាញ់ ការឆបោករបស់ ប្រូកឃើរ៍ (Broker ឈ្មួញកណ្ដាល) គ្នាគាត់ ដែលមកពីក្រៅប្រទេសហ្នឹង ហើយមកទម្លាក់លើប្រទេសកម្ពុជាទាំងអស់អ៊ីចឹង ខ្ញុំវាមិនដឹងថា យ៉ាងម៉េចដែរទេ ប៉ុន្តែចំពោះយើងខ្ញុំគ្រាន់តែចង់ប្រាប់ថា យើងបានប្រឹងប្រែងខ្លាំងណាស់»។

ជុំវិញរឿងនេះ នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស លោក មឿន តុលា លើកឡើងថា របាយការណ៍ដែលចេញដោយក្រសួងការបរទេសអាមេរិកប្រចាំកម្ពុជានេះ ឆ្លុះបញ្ចាំងការពិតទាក់ទងនឹងបញ្ហាជួញដូរមនុស្សនៅកម្ពុជា។ លោកបន្ថែមថា ប្រទេសកម្ពុជាបច្ចុប្បន្នកំពុងប្រឈមនឹងការជួញដូរមនុស្សកាន់តែខ្លាំងឡើង ដោយមានអ្នកជំនួញចិន បានប្រើប្រាស់កម្លាំងពលកម្មជនជាតិបង់ក្លាដេស នេប៉ាល់ ក្នុងវិស័យសំណង់ដោយបង្ខិតបង្ខំ ហើយរដ្ឋាភិបាលក៏មិនទាន់មានអន្តរាគមន៍គ្រប់គ្រាន់ក្នុងការរកដោះស្រាយបញ្ហាការបោកប្រាស់តាមអ៊ីនធើណិត (Cyber Scam) ដែលមានថៅកែជាជនជាតិចិន និងមានពាក់ព័ន្ធជាមួយការជួញដូរជនជាតិថៃ (Thai) ម៉ាឡេ (Malaysian) ហ្វីលីពីន (Filipinos) និងវៀតណាម (Vietnamese) បម្រើអាជីវកម្មខុសច្បាប់នេះផងដែរ។ ជាមួយគ្នានេះ លោកយល់ស្របជាមួយរបាយការណ៍ ដែលបានលើកឡើងបញ្ហាពុករលួយជាប្រព័ន្ធ ដែលបណ្ដាលឱ្យបទល្មើសជួញដូរមនុស្សមានការកើនឡើង៖ «ព្រោះដោយសារអី ដោយសារតែឈ្មួញទាំងអស់ហ្នឹងគឺ ផ្តល់ជាសំណូកដល់មន្ត្រីគ្រាក់ៗ ហ្នឹងណា ហើយតែកាលណាផ្តល់ជាសំណូកដល់មន្ត្រីគ្រាក់ៗ ហើយយើងយកលុយគេហើយ យើងអត់មានវិធានការអីទៅលើក្រុមហ៊ុនឯកជនទាំងអស់ហ្នឹងទេ ឬឈ្មួញទាំងអស់ហ្នឹងទេ

នៅពេលដែលឈ្មួញទាំងអស់ហ្នឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ដូចជា ការជួញដូរមនុស្ស ការធ្វើទារុណកម្មលើមនុស្សអ៊ីចឹងទៅណា»។

របាយការណ៍ជួញដូរមនុស្ស ចេញដោយក្រសួងការបរទេសអាមេរិកប្រចាំកម្ពុជា កាលពីឆ្នាំ២០២១ បានផ្តល់ចំណាត់កម្ពុជាកម្រិត២ ដោយឡែកក្នុងឆ្នាំ២០២២ នេះ កម្ពុជាធ្លាក់ទៅកម្រិត៣ វិញ ដែលការធ្លាក់ចំណាត់ថ្នាក់នេះនឹងធ្វើឱ្យអាមេរិកពិចារណាបន្ថែមលើការផ្តល់ប្រាក់ជំនួយដល់កម្ពុជានាពេលខាងមុខ៕

## កម្ពុជាធ្លាក់ចំណាត់ថ្នាក់ទាបបំផុតក្នុងរបាយការណ៍របស់អាមេរិកស្តីពីការជួញដូរមនុស្ស

https://khmer.voanews.com/ 20 កក្កដា 2022ណឹម សុភ័ក្រ្តបញ្ញា

ភ្នំពេញ — របាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្សនៅលើពិភពលោករបស់ក្រសួងការបរទេសអាមេរិកបង្ហាញថា កម្ពុជាធ្លាក់ចំណាត់ថ្នាក់ពីកម្រិតពីរ (Tier 2) មកកម្រិតបី (Tier 3) ដែលជាចំណាត់ថ្នាក់ទាបបំផុតមួយ និងមានន័យថា រដ្ឋាភិបាលកម្ពុជាមិនបានខិតខំធ្វើអ្វីជាដុំកំភួន ដើម្បីកែលម្អ ហើយមិនបានបំពេញតាមបទដ្ឋានអប្បបរមា ដូចដែលបានកំណត់។ នៅក្នុងរបាយការណ៍ដែលចេញផ្សាយកាលពីថ្ងៃអង្គារ ក្រសួងការបរទេសអាមេរិកឲ្យដឹងថា អំពើពុករលួយនៅតែជាឧបសគ្គក្នុងកិច្ចការបង្ក្រាបបទល្មើសជួញដូរមនុស្ស។ របាយការណ៍បញ្ជាក់ថា៖ «រដ្ឋាភិបាលកម្ពុជាមិនបានបំពេញបទដ្ឋានអប្បបរមា ហើយមិនបានប្រឹងប្រែងជាដុំកំភួននៅក្នុងការលុបបំបាត់ការជួញដូរមនុស្សនោះទេ សូម្បីតែពិចារណាពីផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ១៩ មកលើសមត្ថភាពប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។ ដូច្នេះ កម្ពុជាត្រូវបានទម្លាក់ចំណាត់ថ្នាក់ចូលក្នុងកម្រិតTier 3»។

កម្រិតបី (Tier 3) បានសេចក្តីថា រដ្ឋាភិបាលម្ចាស់ប្រទេសមិនបានប្រឹងប្រែងជាដុំកំភួន និងតាមបទដ្ឋានដូចមានចែងនៅក្នុងច្បាប់ស្តីពីការការពារជនរងគ្រោះដោយការជួញដូរ (TVPA)។ កម្រិតពីរស្ថិតក្នុងបញ្ជីតាមដាន (Tier 2 Watch List) បានសេចក្តីថាទោះរដ្ឋាភិបាលម្ចាស់ប្រទេសបានធ្វើកិច្ចការជាច្រើនគួរឱ្យកត់សម្គាល់ តែមិនទាន់បានបំពេញគ្រប់និយាមអប្បបរមាដែលមានចែងក្នុងនិយាមអប្បបរមាអំពីការជួញដូរមនុស្ស ហើយចំនួនជនរងគ្រោះនៅតែច្រើន ខណៈរដ្ឋាភិបាលមិនទាន់ខិតខំដល់កម្រិត និងមិនបង្ហាញភស្តុតាងជាតឹកតាងគ្រប់គ្រាន់ថាខ្លួនបានព្យាយាម។ របាយការណ៍បន្តថា បើទោះបីមានចំណាត់ការខ្លះពីរដ្ឋាភិបាលកម្ពុជាក្នុងការទប់ស្កាត់និងបង្ក្រាបការជួញដូរមនុស្ស អំពើពុករលួយញាំញី និងកង្វះការស៊ើបអង្កេតនិងចំណាត់ការលើមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធនឹងការជួញដូរមនុស្សនៅតែបង្កជាចំណោទបញ្ហាចំពោះការអនុវត្តច្បាប់ ការឲ្យជនល្មើសរាប់រងទោសទណ្ឌរបស់ខ្លួន និងការផ្តល់សេវាផ្សេងៗដល់ជនរងគ្រោះ។ របាយការណ៍បានលើកឡើងអំពីការជួញដូរក្មេងទៅកន្លែងកម្សាន្តសប្បាយកន្លែងផលិតឥដ្ឋ និងការជួញដូរបោកបញ្ឆោតតាមបច្ចេកវិទ្យា ឬហៅថា Scam។ របាយការណ៍ឆ្នាំ២០២២នេះចងក្រងព្រឹត្តិការណ៍ដែលកើតឡើងតាំងពីដើមខែមេសា ឆ្នាំ២០២១ រហូតដល់ចុងខែមីនា ឆ្នាំ២០២២។

ក្រៅពីកម្ពុជា គេឃើញបណ្តាប្រទេសនៅក្នុងតំបន់អាស៊ានដូចជាម៉ាឡេស៊ី មីយ៉ាន់ម៉ា ព្រុយណេ និងវៀតណាម ក៏ស្ថិតនៅក្នុងចំណាត់ថ្នាក់កម្រិតទាបបំផុត Tier 3 ផងដែរ។ កាលពីកន្លងទៅ មានសេចក្តីរាយការណ៍ថាកម្ពុជាត្រូវបានប្រើប្រាស់ជាកន្លែងបោកបញ្ឆោតតាមប្រព័ន្ធអ៊ីនធឺណិត ឬគេហៅថា Scam ដោយប្រើប្រាស់កម្លាំងបរទេស ក្នុងនោះមានជនជាតិថៃ និងចិន ធ្វើការនៅតាមអគារក្នុងប្រទេសកម្ពុជា រហូតមានសេចក្តីរាយការណ៍អំពីការបង្ខាំងទុកពួកគេ មិនឲ្យមានសេរីភាព ការធ្វើទារុណកម្ម និងការជំរិតទារប្រាក់ជាដើម។

អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ធ្លាប់បានបង្ហាញការព្រួយបារម្ភពាក់ព័ន្ធនឹងការបង្ខាំងមនុស្សប្រើប្រាស់ក្នុងការងារ ដែលជាញឹកញាប់ទាក់ទងនឹងប្រតិបត្តិការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណិត ដែលដាក់គោលដៅលើជនបរទេសរស់នៅខាងក្រៅប្រទេសកម្ពុជា។ នេះបើតាមសេចក្តីថ្លែងការណ៍របស់អង្គការសង្គមស៊ីវិលចេញ

ផ្សាយកាលពីខែមីនា ឆ្នាំ២០២២។ ពួកគេស្នើឱ្យអាជ្ញាធរកម្ពុជាស៊ើបអង្កេតឱ្យបានពេញលេញទៅលើករណីនេះ។ ការចេញផ្សាយរបាយការណ៍នេះ ស្របពេលមានការចុះផ្សាយពីសារព័ត៌មានអន្តរជាតិ Al Jazeera ដែលជាព័ត៌មានស៊ើបអង្កេតស្តីពីការឆបោកតាមបច្ចេកវិទ្យានៅកម្ពុជា។ វីដេអូព័ត៌មានស៊ើបអង្កេតរយៈពេលជាង៤០នាទីចេញកាលពីថ្ងៃទី១៤ ខែកក្កដា ក្រោមចំណងជើងថា«បង្ខំឲ្យធ្វើការឆបោកៈ ទាសករតាមអ៊ីនធឺណិតនៅកម្ពុជា» (Forced to Scam: Cambodia's Cyber Slaves) រៀបរាប់ពីសកម្មភាពជួញដូរមនុស្ស និងការធ្វើទាសភាពលើជនជាតិចិន ក្រោមប្រតិបត្តិការបោកប្រាស់តាមប្រព័ន្ធអ៊ីនធឺណិត និងបណ្តាញរបស់ឧក្រិដ្ឋជនទាំងនោះជាមួយមន្ត្រីរដ្ឋាភិបាលកម្ពុជា។ ទីតាំងមួយចំនួនក្នុងខេត្តព្រះសីហនុ កោះកុង ពោធិ៍សាត់ និងប៉ោយប៉ែតត្រូវបានរាយការណ៍ថាត្រូវបានប្រើប្រាស់ ដើម្បីប្រព្រឹត្តអំពើឆបោក និងការវាយដំនៅទីនោះ។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកស្រី ជូ ប៊ុនអេង ឲ្យដឹងថា ប្រហែលក្រសួងការបរទេសអាមេរិកឃើញព័ត៌មានផ្សេងៗដែលរៀបរាប់ពីការជួញដូរមនុស្សនៅកម្ពុជា ទើបមានការចាត់ចំណាត់ថ្នាក់កម្ពុជាបែបនេះ។ យ៉ាងណាក្តី អ្នកស្រីបញ្ជាក់ថា អាជ្ញាធរកម្ពុជាតែងបង្ក្រាបការជួញដូរមនុស្សគ្រប់រូបភាពកាលពីពេលកន្លងមក។ អ្នកស្រីប្រាប់វីអូអេថាៈ «យើងមិនដែលគិតថាខ្លួនយើងហ្នឹងធ្វើការវាសុក្រឹត្យមួយរយភាគរយនោះទេ។ ប៉ុន្តែអ្វីដែលយើងធ្លាប់បានប្តូរផ្តាច់ជាមួយគ្នាកន្លងមកហ្នឹង មានន័យថា សូម្បីស្ថានទូតសហរដ្ឋអាមេរិកថាយើងនឹងធ្វើការសហការគ្នាឲ្យបានជិតស្និទ្ធ។ អ៊ីចឹង រឿងអីក៏ដោយ យើងគួរតែដឹងទាំងអស់គ្នាហើយ ថាវាមានរឿងអីកើតឡើង។ ហើយនៅក្នុងករណីកន្លងមក វាមិនដែលមានរឿងហ្នឹងកើតឡើងនៅកម្ពុជានោះទេ។ ប៉ុន្តែដំណាក់កាលចុងក្រោយ វាលេចឮព័ត៌មាន ហើយយើងក៏បានឆ្លើយតបជាបន្តបន្ទាប់»។ អ្នកស្រីបន្ថែមថាពាក់ព័ន្ធនឹងករណីដូចការចេញផ្សាយរបស់សារព័ត៌មាន Al Jazeera អាជ្ញាធរកម្ពុជាស្នើសុំការសហការក្នុងការផ្តល់ព័ត៌មានច្បាស់លាស់ពីប្រទេសពាក់ព័ន្ធ ដើម្បីអាចចាត់វិធានការបានប្រកបដោយប្រសិទ្ធភាព។

នាយករងទទួលបន្ទុកផ្នែកឃ្លាំមើលនៃអង្គការលីកាដូ លោក អំ សំអាត ចាត់ទុកការធ្លាក់ចុះចំណាត់ថ្នាក់នេះជា«ការព្រួយបារម្ភ»មួយ ចំពោះបញ្ហាជួញដូរមនុស្សនៅកម្ពុជា។ លោកថ្លែងថាៈ «អ៊ីចឹង ចំណាត់ថ្នាក់ក្នុងរបាយការណ៍នេះបង្ហាញថាការជួញដូរមនុស្សនៅកម្ពុជាយើងគឺ មិនទាន់មានការថយចុះទេ ប៉ុន្តែផ្ទុយទៅវិញមានការកើនឡើង»។ មន្ត្រីសិទ្ធិមនុស្សរូបនេះបន្តថា អង្គការសង្គមស៊ីវិលទទូចឲ្យរដ្ឋាភិបាលជំរុញបន្ថែមលើការទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈការពង្រឹងយន្តការដែលមានស្រាប់ ការបង្កើនប្រសិទ្ធភាព និងបង្កើតយន្តការបន្ថែមទៀត ការចាត់វិធានការដាច់ខាតលើរាល់បុគ្គលជាប់ពាក់ព័ន្ធក្នុងការជួញដូរមនុស្ស និងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស៕

## សមត្ថកិច្ចខេត្តបាត់ដំបងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/07/20/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃពុធ ៧រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់ ឯកលោកឧត្តមសេនីយ៍ទោ សាត គឹមសានស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ និងបានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែក

សឹករងសំពៅលូន ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន(មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន២លើក សរុបចំនួន១៩នាក់ ស្រី៧នាក់ ក្មេង៤នាក់ ក្មេងស្រី៣នាក់ ។ ប្រជាពលរដ្ឋដែលវិលត្រឡប់មកវិញទាំងអស់ ត្រូវបានអប់រំណែនាំ និងប្រគល់បងប្អូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើពិនិត្យ និងស្តែនប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់ មុននឹងអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

## អាមេរិកនិយាយថា ជនរងគ្រោះ 25លាននាក់រងការជួញដូរនៅទូទាំងពិភពលោក ពលរដ្ឋអ៊ុយក្រែនភាគច្រើនងាយរងគ្រោះ

https://www.btv.com.kh/ 2022/07/20 02:53:11 pm

សហរដ្ឋអាមេរិក៖ ក្រសួងការបរទេសសហរដ្ឋអាមេរិកបាននិយាយកាលពីថ្ងៃអង្គារថា មនុស្ស 25លាននាក់នៅជុំវិញពិភពលោកគឺជាជនរងគ្រោះនៃការជួញដូរមនុស្ស រួមទាំងប្រជាជនអ៊ុយក្រែនច្រើននាក់ដែលងាយរងគ្រោះបន្ទាប់ពីការវាយលុករបស់រុស្ស៊ី។ ក្នុងអំឡុងពេលនៃការចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ស្តីពីការជួញដូរមនុស្ស រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកលោក Antony Blinken បានផ្តល់កិត្តិយសដល់ក្រុមសកម្មជនប្រឆាំងការជួញដូរមនុស្ស។ របាយការណ៍របស់សហរដ្ឋអាមេរិកបានដាក់ប្រទេសរុស្ស៊ី ក្នុងបញ្ជីប្រទេសដែលពាក់ព័ន្ធក្នុងគោលនយោបាយនៃការជួញដូរមនុស្ស ពលកម្មដោយបង្ខំ ឬកងកម្លាំងសន្តិសុខ ឬក្រុមប្រដាប់អាវុធរបស់ខ្លួនដែលគាំទ្រដោយរដ្ឋាភិបាលក្នុងការជ្រើសរើស ឬប្រើប្រាស់ទាហានកុមារ។

រុស្ស៊ីមានជាញឹកញាប់តាមរយៈរបាយការណ៍ ដោយសារតែការវាយលុកលើអ៊ុយក្រែនចាប់តាំងពីថ្ងៃទី24 ខែកុម្ភៈ និងជាអ្វីដែលឯកសារបានចាត់ទុកថា ភាពងាយរងគ្រោះចំពោះការជួញដូរមនុស្សនៃជនភៀសខ្លួនអ៊ុយក្រែនរាប់លាននាក់ ដែលបានភៀសខ្លួនចេញពីប្រទេសរបស់ពួកគេ។ ស្ថានទូតរុស្ស៊ីនៅទីក្រុងវ៉ាស៊ីនតោនមិនបានឆ្លើយតបភ្លាមៗ ចំពោះសំណើសុំការអត្ថាធិប្បាយលើការចោទប្រកាន់នៅក្នុងរបាយការណ៍នេះទេ។ របាយការណ៍នេះក៏មានបញ្ជីដាច់ដោយឡែកពីគ្នានៃប្រទេសចំនួន 12 ដែលបានជួល ឬជ្រើសរើសទាហានកុមារ ដែលវារួមបញ្ចូលទាំងប្រទេសរុស្ស៊ី៕ អត្ថបទ៖ ប៊ុនថន

# ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

## កម្ពុជាសោកស្តាយដែលអាមេរិក ដាក់ចំណាត់ថ្នាក់លេខ៣ ចូលក្នុងបញ្ជីខ្មៅនៃការជួញដូរមនុស្ស

https://www.btv.com.kh/ 2022/07/21 11:11:38 am

ភ្នំពេញ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសម្តែងការខកចិត្ត និងសោកស្តាយបំផុត បន្ទាប់ពីអាមេរិកបានដាក់កម្ពុជាជាប់ចំណាត់ថ្នាក់លេខ៣ ជាប្រទេសចូលក្នុងបញ្ជីខ្មៅនៃការជួញដូរមនុស្ស ខណៈកម្ពុជាបានខិតខំយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បើទោះបីជាកម្ពុជាជួបវិបត្តិកូវីដ-១៩ នាពេលកន្លងទៅយ៉ាងណាក៏ដោយ។

ថ្លែងប្រាប់ទូរទស្សន៍ BTV នាព្រឹកថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២នេះ លោកជំទាវ ជូ ប៊ុនអេង បានមានប្រសាសន៍ថា ខណៈកម្ពុជាជួបនូវវិបត្តិកូវីដ-១៩ ប៉ុន្មានឆ្នាំចុងក្រោយក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជាបានខិតខំយ៉ាងខ្លាំង ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សដោយគ្មានការរុញរា និងក៏មានការសហការគ្នាជាមួយសហរដ្ឋអាមេរិក និងដៃគូផ្សេងៗទៀតផងដែរ រហូតដល់កម្ពុជាសម្រេចឲ្យអាមេរិកដាក់ស្នាក់ការរបស់ខ្លួន សម្រាប់ពិគ្រោះយោបល់ និងពិភាក្សាគ្នាទាក់ទងនឹងការជួញដូរមនុស្សនៅអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជាផងដែរ។

លោកជំទាវ ជូ ប៊ុនអេង បានបញ្ជាក់ឲ្យដឹងផងដែរថា សហរដ្ឋអាមេរិកបានដាក់កម្ពុជាជាចំណាត់ថ្នាក់លេខ២ អស់រយៈពេលពីរឆ្នាំមកហើយ ខណៈចំណាត់ថ្នាក់លេខ២ នេះគឺជាប្រទេសមានការខិតខំប្រឹងប្រែង និងមានការឆ្លើយតប និងមានភាពចន្លោះប្រហោងដែលត្រូវបំពេញបន្ថែម ក្នុងកិច្ចការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនេះ។ ប៉ុន្តែសម្រាប់ឆ្នាំ២០២២ នេះដែលអាមេរិកសម្រេចដាក់កម្ពុជាជាប្រទេសជាប់ចំណាត់ថ្នាក់លេខ៣ គឺគេចង់និយាយថា កម្ពុជាមានភាពប្រងើយកន្តើយ គ្មានការយកចិត្តទុកដាក់ និងគ្មានការខ្វាយខ្វល់ ចំពោះកិច្ចការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស រហូតដល់គេអាចសម្រេចដាក់ទណ្ឌកម្មដល់ប្រទេសកម្ពុជាផងដែរនោះ។

យ៉ាងណាក៏ដោយលោកជំទាវ ជូ ប៊ុនអេង បានសម្ដែងការខកចិត្តយ៉ាងខ្លាំង ចំពោះការសម្រេចរបស់ក្រសួងការបរទេសអាមេរិកដាក់កម្ពុជាចូលក្នុងបញ្ជីខ្មៅនេះ ដោយការដាក់នេះគឺចង់មានន័យថា អាមេរិកពុំបានធ្វើការសហការជាមួយកម្ពុជានោះទេ ពោលគឺអាមេរិកធ្វើការនេះតែឯកឯងមានលក្ខណៈបែបផ្សេង ខណៈអាមេរិកបានផ្ដល់ជំនួយដល់កម្ពុជារហូតមកក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនេះ តែបែរជាដាក់ប្រទេសដែលខ្លួនកំពុងជួយនេះចូលក្នុងបញ្ជីខ្មៅទៅវិញនោះ៕ អត្ថបទ៖ បាន ចក់

## មន្ត្រីកម្ពុជាមិនយល់ស្របលើរបាយការណ៍ស្ដីពីការជួញដូរមនុស្ស ដែលចេញដោយក្រសួងការបរទេសអាមេរិកទម្លាក់ចំណាត់ថ្នាក់កម្ពុជា

https://www.postkhmer.com/ នៀម ឆេង and មុំ គន្ធា | Publication date 21 July 2022 | 09:53 ICT

**ភ្នំពេញៈ** មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃមិនយល់ស្របចំពោះការលើកឡើងនៅក្នុងរបាយការណ៍ស្ដីពីការជួញដូរមនុស្សចេញផ្សាយដោយក្រសួងការបរទេសអាមេរិក ដែលទម្លាក់កម្រិតកម្ពុជាពីចំណាត់ថ្នាក់ទី ២ ឃ្លាំមើលទៅចំណាត់ថ្នាក់ទី ៣។ មន្ត្រីនិយាយថា ការវាយតម្លៃនឹងដាក់ចំណាត់ថ្នាក់នេះមិនឆ្លុះបញ្ចាំងពីកិច្ចប្រឹងប្រែងរបស់កម្ពុជា និងធ្វើឡើងដោយយកបញ្ហាថ្មីទៅភ្ជាប់ជាមួយនឹងចំណុចខ្វះខាតដែលកម្ពុជាមាន។

ការប្រានចោលនេះធ្វើឡើងដោយលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បន្ទាប់ពីក្រសួងការបរទេសអាមេរិកចេញផ្សាយ «របាយការណ៍ជួញដូរមនុស្សខែកក្កដា ឆ្នាំ ២០២២» ចេញផ្សាយកាលពីថ្ងៃទី ១៩ ខែកក្កដា។ ស្ថានភាពជួញដូរមនុស្សនៅកម្ពុជាត្រូវក្រសួងការបរទេសអាមេរិកដាក់ចំណាត់ថ្នាក់ទី ២ ដែលជាចំណាត់ថ្នាក់ល្អពីឆ្នាំ ២០១៦-២០១៨។ ប៉ុន្តែពីឆ្នាំ ២០១៩-២០២១ ចំណាត់ថ្នាក់នេះធ្លាក់ទៅនៅពាក់កណ្ដាល ឬ «ចំណាត់ថ្នាក់ទី ២ ស្ថិតក្រោមការឃ្លាំមើល» និងបន្តធ្លាក់ទៅចំណាត់ថ្នាក់ទី ៣ នៅឆ្នាំនេះ។

របាយការណ៍នេះបានថ្លែងថា កម្ពុជាបានចាត់វិធានការជាច្រើន ដើម្បីដោះស្រាយបញ្ហាជួញដូរមនុស្ស រួមមានការបន្តចាប់ខ្លួនជនល្មើស កាត់ទោស និងផ្ដន្ទាទោសជនល្មើស ការស្វែងរកអត្តសញ្ញាណជនរងគ្រោះដោយបុរេសកម្ម និងការជួយដល់ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ និងអ្នកដែលងាយរងគ្រោះដោយការជួញដូរមនុស្សនៅក្រៅប្រទេស។ ប៉ុន្តែរបាយការណ៍ដដែលនេះលើកឡើងថា កិច្ចប្រឹងប្រែងចម្បងៗផ្សេងទៀតនៅតែខ្វះចន្លោះនៅឡើយ ហើយបានលើកឡើងនូវអំណះអំណាងជាច្រើនដើម្បីវាយតម្លៃស្ថានភាពនៅកម្ពុជា ដូចជាការមិនបានស៊ើបអង្កេត និងនាំយកជនល្មើសដែលជាមន្ត្រីពាក់ព័ន្ធមកទទួលខុសត្រូវចំពោះមុខច្បាប់ ជាពិសេសពាក់ព័ន្ធនឹងម្ចាស់

អាជីវកម្មដែលជាប់ពាក់ព័ន្ធនឹងមនុស្សរាប់ពាន់នាក់ រួមទាំងកុមារផង ដូចជាអាជីវកម្មកម្សាន្ត ឡូតដូ និងប្រតិបត្តិការឆបោកតាមអនឡាញ។

របាយការណ៍នេះលើកឡើងនូវទិដ្ឋភាពជាច្រើន ដើម្បីគាំទ្រការវាយតម្លៃរបស់ពួកគេ ដូចជា ការខកខានស៊ើបអង្កេត ឬឱ្យមន្ត្រីទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពាក់ព័ន្ធក្នុងការរួមគំនិតគ្នា ជាពិសេសម្ចាស់ជំនួញទុច្ចរិតដែលដាក់មនុស្សរាប់ពាន់នាក់ បុរស ស្ត្រី និងកូនក្មេងទូទាំងប្រទេសនៅក្រោមការជួញដូរមនុស្សនៅក្នុងកន្លែងកម្សាន្តឡូតដូ និងប្រតិបត្តិការឆបោកតាមអនឡាញ។ របាយការណ៍នេះក៏បានចោទប្រកាន់រដ្ឋាភិបាលពុំបានផ្តល់សេវាគាំពារគ្រប់គ្រាន់សម្រាប់ជនរងគ្រោះ ទាំងក្នុងស្រុក និងក្រៅប្រទេស ហើយរដ្ឋាភិបាលបានពឹងផ្អែកច្រើនលើអ្នកជំនួយ បរទេស និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់ការថែទាំងចាំបាច់ច្រើន។

របាយការណ៍លើកឡើងថា៖ «រដ្ឋាភិបាលពុំបានរក្សាកំណត់ត្រាប្រមូលផ្តុំ ឬឃ្លាំងទិន្នន័យនៃការស៊ើបអង្កេត និងនីតិវិធីតុលាការ ដូច្នេះ ទិន្នន័យអនុវត្តច្បាប់ជារួមមិនពេញលេញ»។ ដោយសំអាងលើរបាយការណ៍ព័ត៌មាន និងដោយមិនផ្តល់រយៈពេលនៃការវាយតម្លៃ រាយណ៍ក្រសួងការបរទេសសហរដ្ឋអាមេរិកបានលើកឡើងថា អាជ្ញាធរកម្ពុជាបានចាប់ខ្លួនជនសង្ស័យ ជួញដូរមនុស្សចំនួន ៣៧០ នាក់ រួមទាំងឈ្មួញកណ្តាលរកការងារចំនួន ៣៣២ តែរដ្ឋាភិបាលពុំបានរាយការណ៍ពីបច្ចុប្បន្នភាពស្តីពីការចាប់ខ្លួនទាំងនេះ។ របាយការណ៍ដដែលនេះបានបន្តថា ក្នុងឆ្នាំ ២០២១ រដ្ឋាភិបាលបានកាត់ទោសជនសង្ស័យជួញដូរចំនួន ១០៩ នាក់ ដែលក្នុងនោះ ៦៤ ករណី មានការពាក់ព័ន្ធនឹងច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស ៤ ករណី ពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទ, ៣៧ ករណីពាក់ព័ន្ធនឹងការធ្វើការដោយបង្ខំ និង ២៣ ករណីពាក់ព័ន្ធនឹងទម្រង់នៃការកេងប្រវ័ញ្ចមិនជាក់លាក់។ រដ្ឋាភិបាលក៏បានកាត់ទោសទៅលើអ្នកជួញដូរចំនួន ៣៨ នាក់ផងដែរ ដែលក្នុងនោះមានម្នាក់ជាប់ចោទពីបទជួញដូរផ្លូវភេទ និង ៣៥ នាក់ទៀតពីបទធ្វើការដោយបង្ខំ។ ប្រភពដដែលបានបន្តថា រដ្ឋាភិបាលបានផ្តល់វគ្គបណ្តុះបណ្តាលចំនួន ២៥៦ វគ្គ និងរៀបចំសិក្ខាសាលាស្តីពីច្បាប់ប្រឆាំងនឹងការជួញដូរ បច្ចេកទេសនៃការស៊ើបអង្កេត និងការប្រមូលភស្តុតាងសម្រាប់មន្ត្រីអនុវត្តច្បាប់ចំនួន ១២ ៨១៤ នាក់ផងដែរ។ ពួកគេក៏បានផ្តល់នូវវគ្គបណ្តុះបណ្តាលចំនួន ៧ លើកផងដែរ សម្រាប់អ្នកចូលរួមចំនួន ២៨៦ នាក់ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការណែនាំពីការការពារខ្លួន។

របាយការណ៍បានលើកឡើងថា៖ «ទោះបីជាមានការបណ្តុះបណ្តាលទាំងនេះក៏ដោយ ក៏មន្ត្រីនគរបាលជាច្រើន ជាពិសេសនៅតាមតំបន់ជនបទនៅតែមិនដឹងពីរបៀបធ្វើការងារប្រឆាំងការជួញដូរដែរ ដោយសារភាគច្រើនមិនបានទទួលការបណ្តុះបណ្តាលស្តីពីបច្ចេកទេសអនុវត្តច្បាប់ជាមូលដ្ឋាន»។ របាយការណ៍នេះបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិប្រឆាំងការជួញដូរ (NCCT) ក្នុងការទប់ស្កាត់នូវឧក្រិដ្ឋកម្មនានា ប៉ុន្តែប្រភពដដែលនេះបានបញ្ជាក់ថា រដ្ឋាភិបាលមិនបានរាយការណ៍ពីថវិកានៃការប្រឆាំងការជួញដូរក្នុងឆ្នាំ ២០២១ ទេ ខណៈឆ្នាំ ២០២០ បានកំណត់ប្រមាណ ២,២ ពាន់លានរៀល (៥៤៣ ០៨០ ដុល្លារ)។

លោកស្រី ជូ ប៊ុនអេង បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា លោកស្រីមិនយល់ស្របចំពោះរបាយការណ៍នេះឡើយ ដោយសារវាផ្ទុយនឹងអ្វីដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងធ្វើ។ លោកស្រីថ្លែងថា៖ «តើដឹងហើយឬនៅថា រាជរដ្ឋាភិបាលប្រឹងប៉ុនណា ឬការងារប្រឆាំងការជួញដូរមនុស្សយើងតាំងពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ រដ្ឋាភិបាលនិងអង្គការដៃគូរួមគ្នាធ្វើទាំងអស់គ្នាប៉ុនណា? សម្រាប់របាយការណ៍នេះគឺខ្ញុំយល់ថាមិនល្អ យើងមិនសប្បាយចិត្ត ព្រោះអ្វីដែលយើងខំប្រឹងបែរជាចេញលទ្ធផលមិនដូចអ្វីដែលយើងប្រាថ្នា»។ លោកស្រី ជូ ប៊ុនអេង បានបន្តថា មួយវិញទៀត ការផ្តួបផ្សំទៅលើចំណុចខ្វះខាតនោះគឺ [គាត់] បូកទៅក្នុងរឿងថ្មីដែលទើបតែកើតមានឡើងក្នុងឆ្នាំ ២០២២ នេះ តែអ្វីដែល [យើង] និយាយគ្នារួចហើយថា អ្វីដែលធ្វើ គឺធ្វើពីខែ ១ ដល់ខែ ១២។ លោកស្រីថា៖ «បើ

ជាលទ្ធផល យើងមើលនៅក្នុងអំឡុងពេលហ្នឹងថា តើយើងធ្វើបានច្រើនប៉ុនណា? ប៉ុន្តែទីបំផុតជាលទ្ធផលបែបជាបែបនេះគឺយើងមិនសប្បាយចិត្តនោះទេ»។

លោក ឆាយ គឹមខឿន អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិបានថ្លែងថា កម្ពុជាមានស្ថាប័នទទួលបន្ទុកដោះស្រាយរឿងជួញដូរមនុស្ស ហើយលោកសុំមិនអត្ថាធិប្បាយអំពីការដាក់ចំណាត់ថ្នាក់នៅក្នុងរបាយការណ៍នេះទេ។ យ៉ាងណាក៏ដោយលោកថា ទោះបីកម្ពុជាធ្វើល្អយ៉ាងណា អាមេរិកអាចនិយាយថា កម្ពុជាមិនបានធ្វើតាមតែគេចង់បាន។ លោកថ្លែងថា៖ «គាត់ថា ល្អ គាត់ថា អាក្រក់ស្រេចតែលើគាត់ទេ។ តែបើនិយាយពីកិច្ចខិតខំប្រឹងប្រែងរបស់បងប្អូនប៉ូលិស គឺគាត់ខិតខំប្រឹងប្រែងខ្លាំងណាស់។ យើងបង្កើតជាហតឡាញ យើងបង្កើតមន្ត្រីទំនាក់ទំនង ហើយយើងសហការ ពេលខ្លះយើងទទួលព័ត៌មានតាមបណ្តាញទំព័រហ្វេសប៊ុកដើម្បីជួយសម្រួលនារីរងគ្រោះនៅក្រៅប្រទេស ក៏ច្រើនណាស់ដែរហើយ។ តែខ្ញុំមិនអាចបង្ហាញតួលេខទាំងស្រុងបានទេ»។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអ្នកពាក់ព័ន្ធកាលពីពេលថ្មីៗនេះបានបើកយុទ្ធនាការប្រឆាំងនឹងពលកម្មកុមារ និងការងារដោយបង្ខំ។ យុទ្ធនាការចុងក្រោយត្រូវបានធ្វើឡើងកាលពីសប្តាហ៍មុន នៅស្រុកបន្ទាយស្រី ខេត្តសៀមរាប ដោយផ្តោតគោលដៅលើសិប្បកម្មឡឥដ្ឋ និងកសិឧស្សាហកម្ម។ នេះបើតាមក្រសួងការងារ៕

## នគរបាលម៉ាឡេស៊ីបន្តស៊ើបអង្កេតលើករណីជនជាតិ Sawakians ៦ នាក់ដែលត្រូវបានគេនិយាយថាស្ថិតក្នុងកណ្តាប់ដៃអ្នកឆបោកនៅកម្ពុជា

https://www.khmertimeskh.com/ Khmer Times July 21, 2022

នគរបាលកំពុងបន្តស៊ើបអង្កេតលើករណីជនជាតិសារ៉ាវ៉ាគីទាំង៦នាក់ ដែលជាប់ក្នុងប្រទេសកម្ពុជាបន្ទាប់ពីត្រូវបានគេបោកបញ្ឆោតឱ្យធ្វើការឱ្យក្រុមឧក្រិដ្ឋកម្មនៅទីនោះ។ យោងតាមស្នងការនគរបាល Sarawak លោក Datuk Mohd Azman Ahmad Sapri បានអោយដឹងថា ការស៊ើបអង្កេតនៅតែត្រូវបានអនុវត្តដោយក្រុមរបស់គាត់ដោយមានជំនួយពីស្នងការនគរបាល Bukit Aman ។ «យើងកំពុងរង់ចាំការវិវឌ្ឍបន្ថែមទៀតព្រោះពីមុនមានរបាយការណ៍ថា ជនជាតិម៉ាឡេស៊ីដែលជាប់គាំងនៅទីនោះ(កម្ពុជា)រួមទាំងជនជាតិសារ៉ាវ៉ាគីម្នាក់ (Sarawakian) បានត្រឡប់ទៅម៉ាឡេស៊ីវិញ។

គាត់បានប្រាប់អ្នកយកព័ត៌មានបន្ទាប់ពីចូលរួមសន្និបាតប្រចាំខែរបស់ទីស្នាក់ការកណ្តាល (IPK) របស់នគរបាល Sarawak កាលពីម្សិលមិញថា "នៅក្នុងការបញ្ជាក់នេះ ខ្ញុំសង្ឃឹមថា មនុស្សគ្រប់គ្នានឹងតែងតែប្រុងប្រយ័ត្នក្នុងការរកមើលការផ្សាយពាណិជ្ជកម្មអំពីការងារដែលផ្តល់ប្រាក់ខែខ្ពស់ ភាគច្រើននៃការផ្តល់ជូនបែបនេះគឺមិនមានទេ" ។ នៅក្នុងសន្និសិទសារព័ត៌មានមួយដែលត្រូវបានហៅនៅថ្ងៃទី២៥ ខែមេសាឆ្នាំនេះត្រូវបានប្រកាសថា នគរបាលភូមិន្ទម៉ាឡេស៊ី (PDRM) នឹងស្វែងរកជំនួយពីនគរបាលអន្តរជាតិ (Interpol) ក្នុងការតាមដាន ជនជាតិសារ៉ាវ៉ាគីទាំងប្រាំមួយនាក់នោះ។

នៅក្នុងសន្និសីទសារព័ត៌មាននោះ លោក Mohd Azman បាននិយាយថា នាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្មពាណិជ្ជកម្ម (CCID) Sarawak បានបើកឯកសារស៊ើបអង្កេតចំនួនពីរក្រោមផ្នែកទី៤២០ នៃក្រមព្រហ្មទណ្ឌ។ លោកត្រូវបានដកស្រង់សម្តីដែលបាននិយាយនៅពេលនោះថា "យើងបានទទួលរបាយការណ៍នគរបាលចំនួនប្រាំមួយនៅចន្លោះថ្ងៃទី២០ និង២២ ខែមេសា ឆ្នាំ២០២២ ពីសមាជិកគ្រួសាររបស់ជនរងគ្រោះដែលត្រូវបានគេនិយាយថាត្រូវបានគេបោកប្រាស់ឱ្យមកធ្វើការនៅក្នុងប្រទេសកម្ពុជា" ។ កាលពីពេលថ្មីៗនេះ Bernama បានរាយការណ៍ពីឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក Eldeen Husaini Mohd Hashim ថាមានករណីជាង៦០

ដែលពាក់ព័ន្ធនឹងជនជាតិម៉ាឡេស៊ីដែលធ្លាក់ខ្លួនធ្វើជាទាសករពីការបោកប្រាស់ការងារ ដែលទាំងអស់កំពុងរង់ចាំសកម្មភាពបន្ថែមទៀត។ Eldeen ក៏ត្រូវបានដកស្រង់សម្ដីផងដែរថា រហូតមកដល់ពេលនេះ ស្ថានទូតម៉ាឡេស៊ីប្រចាំទីក្រុងភ្នំពេញ បានជួយសង្គ្រោះជនជាតិម៉ាឡេស៊ីចំនួន ៤៦ នាក់នៅកម្ពុជា ដែលគេជឿថាត្រូវបានបោកបញ្ឆោតដោយការផ្ដល់ជូនការងារដែលមានប្រាក់កម្រៃខ្ពស់នៅក្រៅប្រទេស។

ករណីថ្មីបំផុតពាក់ព័ន្ធនឹងជនជាតិម៉ាឡេស៊ី ៤នាក់ ដែលមានអាយុចន្លោះពី២៩ ទៅ៤១ ឆ្នាំ។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេបានត្រៀមត្រឡប់ទៅផ្ទះវិញ ដោយមកដល់អាកាសយានដ្ឋានអន្តរជាតិគូឡាឡាំពួរកាលពីថ្ងៃទី៩ ខែកក្កដា។ ក្នុងឆ្នាំ២០១៩ ជនជាតិម៉ាឡេស៊ីចំនួន៤៧ នាក់ ដែលភាគច្រើនមកពីរដ្ឋ Sarawak ត្រូវបានអាជ្ញាធរកម្ពុជាឃាត់ខ្លួនដោយសង្ស័យថាមានជាប់ពាក់ព័ន្ធក្នុងសកម្មភាពខុសច្បាប់នៅក្នុងខេត្តបន្ទាយមានជ័យ។ ជនជាតិម៉ាឡេស៊ីបានអះអាងថា ពួកគេត្រូវបានសន្យាថានឹងធ្វើការជាមួយនឹងប្រាក់កម្រៃរហូតដល់ ១,៥០០ បន្ទាប់មកទើបដឹងថា វាជាការបោកប្រាស់នៅពេលពួកគេមកដល់ប្រទេសកម្ពុជា។ ខណៈពេលដែលប្រព័ន្ធផ្សព្វផ្សាយម៉ាឡេស៊ី និងកម្ពុជាផ្ដោតលើ "ជនរងគ្រោះនៃការបោកប្រាស់ការងារ" នោះ ខ្មែរថាមស៍ បានដឹងពីប្រភពដែលអាចទុកចិត្តបានថា ក្រុមនេះពិតជាមានចំណេះដឹងពីមុនអំពីប្រតិបត្តិការ និងកំពុងកាន់កាប់ផ្ទះដែលត្រូវបានរចនាឡើងដើម្បីជួយសម្រួលដល់អ្នកបោកប្រាស់ដើម្បីដំណើរការការឆបោកតាមទូរស័ព្ទ VoIP ដែលគេស្គាល់ថាជាក្រុមបោកប្រាស់ម៉ាកាវ៕ *Borneo Post/Khmer Times*

## រដ្ឋបាលពិសេសម៉ាកាវ
## ប្រឆាំងដាច់ខាតនូវ របាយការណ៍របស់អាមេរិក ស្តីពីការជួញដូរមនុស្ស

https://dap-news.com/ ByKD102Posted on July 21, 2022

**ម៉ាកាវ៖ រដ្ឋាភិបាលតំបន់រដ្ឋបាលពិសេសម៉ាកាវ (SAR) កាលពីថ្ងៃពុធបានសម្តែងការ ប្រឆាំងយ៉ាងខ្លាំង ចំពោះឯកសារយោងទាក់ទង នឹងម៉ាកាវនៅក្នុងរបាយការណ៍ ស្តីពីការជួញដូរមនុស្សឆ្នាំ២០២២ ដែលចេញដោយក្រសួងការបរទេស សហរដ្ឋអាមេរិកនាពេលថ្មីៗនេះ។** ការិយាល័យលេខាធិការ សម្រាប់សន្តិសុខក្រោមរដ្ឋបាលពិសេសម៉ាកាវបានឲ្យដឹងថា ឯកសារយោងលើម៉ាកាវ នៅក្នុងរបាយការណ៍នេះបានប៉ុនប៉ងដោយ "ការសន្និដ្ឋាន និងលំអៀង" ដើម្បីបដិសេធកិច្ចខិតខំប្រឹងប្រែង ជាបន្តបន្ទាប់ដែលធ្វើឡើង ដោយរដ្ឋាភិបាលម៉ាកាវ លើការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងលទ្ធផលល្អដែលសម្រេចបានពីនោះ។ រដ្ឋាភិបាលម៉ាកាវ តែងតែសម្របសម្រួលយ៉ាងសកម្ម ដល់នាយកដ្ឋានរដ្ឋាភិបាល និងផ្នែកផ្សេងៗនៃសង្គម ដើម្បីទប់ស្កាត់ និងប្រឆាំងការជួញដូរមនុស្ស ក៏ដូចជាការពារជនរងគ្រោះផងដែរ។ ការិយាល័យបានឲ្យដឹងថា ទោះបីជាមានផលប៉ះពាល់ ធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ចាប់តាំងពីឆ្នាំ២០២០ ក៏ដោយ ការងារទាក់ទងនឹងការប្រយុទ្ធប្រឆាំង នឹងការជួញដូរមនុស្ស បានដំណើរការជាធម្មតា ដោយរក្សាបាននូវស្ថានភាពល្អ របស់ម៉ាកាវនៃអត្រាឧក្រិដ្ឋកម្មទាប រយៈពេលវែង ឬសូម្បីតែឧក្រិដ្ឋកម្មសូន្យនៅក្នុងបញ្ហានេះ។

អស់រយៈពេលជាច្រើនឆ្នាំ របាយការណ៍របស់សហរដ្ឋអាមេរិក បានខកខានក្នុងការបង្ហាញការ ពិតនៅទីក្រុងម៉ាកាវ ដោយបានកត់សម្គាល់ការិយាល័យនេះ ដោយបន្ថែមថា រដ្ឋាភិបាលម៉ាកាវ មានអារម្មណ៍សោកស្តាយ និងខឹងសម្បារយ៉ាងខ្លាំង ចំពោះការបញ្ចេញមតិមិនត្រឹមត្រូវ ដែលធ្វើឡើងដោយភាគី សហរដ្ឋអាមេរិក លើការអនុវត្តច្បាប់ និងការងារតុលាការរបស់ម៉ាកាវ ទោះបីជាមានតំណាងជាច្រើនឆ្នាំ ស្នាក់នៅដោយម៉ាកាវ ក៏ដោយ។ ការិយាល័យបានឲ្យដឹងទៀតថា រដ្ឋាភិបាលម៉ាកាវ នឹងរួមដៃយ៉ាងរឹងមាំជាមួយ គ្រប់វិស័យនៅក្នុងម៉ាកាវ ដើម្បីទប់ស្កាត់ និងគ្រប់គ្រងការជួញដូរមនុស្ស និងធានាសុវត្ថិភាព និងសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់អ្នកស្រុក និងមិនមែនជនជាតិដើមដូចគ្នា ៕ ប្រែសម្រួល ឈូក បូរ៉ា

## មន្ត្រីកម្ពុជា-ថៃ រួមគ្នាពិនិត្យមើលទីតាំងសាងសង់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីសម្រួលដល់ពលករចំណាកស្រុក

http://freshnewsasia.com/ 2022-07-21 02:56pm

**(បន្ទាយមានជ័យ)៖** លោក ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ត្រីអាជ្ញាធរថៃ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២នេះ បានសហការរួមគ្នាចុះត្រួតពិនិត្យការសាងសង់មជ្ឈមណ្ឌល សំចតប៉ោយប៉ែត ដើម្បីសម្រួលដល់ពលករចំណាកស្រុក ស្នាក់នៅប្រកបដោយផាសុខភាព និងសុវត្ថិភាពបន្ថែមទៀតពិសេសបង្កើនកិច្ចការពារទប់ស្កាត់ជំងឺកូវីដ១៩។ ការចុះត្រួតពិនិត្យនេះ ក៏មានការចូលរួមពីសំណាក់លោក ង៉ោ ម៉េងជ្រួញ អភិបាលរងខេត្តបន្ទាយមានជ័យ, លោក យូ សុភ័ក្រ ប្រធាននាយកដ្ឋានគាំពារជនរងគ្រោះ, លោកស្រី ឈា មានិត ប្រធានមជ្ឈមណ្ឌល លោក លោកស្រី តំណាង អាជ្ញាធរមូលដ្ឋាន និងលោកស្រី ហេង ស្រីលក្ខ័ណ អនុប្រធានមន្ទីរ ស.អ.យ តំណាងលោកប្រធានមន្ទីរ តំណាងមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សុរិយោដី កិច្ចប្រជុំនេះបន្តជជែក និងត្រួតពិនិត្យបច្ចេកទេស ជាមួយភាគីថៃ អំពីទីតាំងបោះបង្គោលព្រំសម្រាប់សាងសង់មជ្ឈមណ្ឌល ដែលនឹងត្រូវអនុវត្តខែក្រោយ ។

បន្ទាប់មក លោក ញឹក វណ្ណារ៉ា ឯកឧត្តម ភិបាលរងខេត្ត បានចុះវាយតម្លៃផលប៉ះពាល់គម្រោង និងទីតាំងដើម្បីសម្របសម្រួលរកដំណោះស្រាយ។ នាឱកាសនោះដែរ ភាគីកម្ពុជា-ថៃ បានសម្រេចឯកភាពកំណត់ទីតាំងព្រំដីតាមប្លង់ ដែលបានកំណត់, សាងសង់អាគារខាងក្នុង អាចរំកិលបានតាមការជាក់ស្តែង, ក្រុមហ៊ុនសាងសង់ថៃ និងតំណាងភាគីថៃ នឹងរាយការណ៍ទៅស្ថានទូតថៃ ដើម្បីចាប់ផ្តើមសាងសង់, ភាគីកម្ពុជា ស្នើសុំឱ្យភាគីថៃ ជូនដំណឹងមកកម្ពុជា ដើម្បីធ្វើរបាយការណ៍ឱ្យស្របតាមនីតិវិធីដែលបានព្រមព្រៀង និងខាងភាគីថៃ ឯកភាពតាមសំណើ របស់ភាគីកម្ពុជាគ្រប់យ៉ាង។ លោក ញឹក វណ្ណារ៉ា បានថ្លែងថា ការពិនិត្យមើលទីតាំងសាងសង់មជ្ឈមណ្ឌលសំចតប៉ោយប៉ែតនេះ គឺមានអត្ថប្រយោជន៍ដើម្បីសម្រួលដល់ពលករចំណាកស្រុក ជាពិសេសបង្កើននូវផាសុខភាព និងសុវត្ថិភាពបន្ថែមទៀត។ ម្យ៉ាងទៀតក្រុមការងារ បានចុះពិនិត្យទីតាំងសាងសង់ និងពិនិត្យកន្លែងផលប៉ះពាល់ដើម្បីសម្របសម្រួលរកដំណោះស្រាយ។ ឆ្លៀតក្នុងឱកាសនេះ លោកក៏បានចុះពិនិត្យអង្គការដៃគូ ដែលមានកិច្ចសហការជាមួយមជ្ឈមណ្ឌល ក្នុងការផ្តល់សេវានៅក្នុងមណ្ឌល ព្រមទាំងសាកសួរសុខទុក្ខជាមួយពលករចំណាកស្រុកដោយប្រថុយប្រថាន ដែលបានបញ្ជូនមកចូលមជ្ឈមណ្ឌល៕

## កម្ពុជាទទួលអនុសាសន៍៤៨ចំណុច ឱ្យបង្កើនកិច្ចការពារកុមារ

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២២ វិទ្យុជាតិកម្ពុជា , វ៉ាង ភក្តី

គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ បានផ្តល់អនុសាសន៍ចំនួន៤៨ ដែលបានពីការសង្កេតចុងក្រោយ របស់ខ្លួន ទាក់ទងនឹងកិច្ចការពារកុមារពីការរំលោភបំពាន។ ថ្លែងក្នុងកិច្ចពិភាក្សាតុមូលលើការអនុវត្តន៍អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅកម្ពុជា នៅថ្ងៃទី២១ ខែកក្កដានេះ ឯកឧត្តម គីម សុវណ្ណឌី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានឱ្យដឹងថា អនុសាសន៍ទាំងនោះគ្រាន់តែជាការចូលរួមស្ថាបនា ដើម្បីឱ្យកម្ពុជាបន្តអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារឱ្យកាន់តែល្អប្រសើរឡើង ស្របតាមស្ថានភាពវិវត្ត ជាក់ស្តែងរបស់កម្ពុជាតែប៉ុណ្ណោះ។

ឯកឧត្តម នឹម ថូត រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សំណូមពរដល់ក្រសួងស្ថាប័នពាក់ព័ន្ធ យកចិត្តទុកដាក់ពិចារណាលើអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ ដោយដាក់បញ្ចូលអនុសាសន៍ ទាំងនោះទៅក្នុងច្បាប់ គោលនយោបាយ ផែនការ និងលិខិតបទដ្ឋាន

នានា ក្នុងទិសដៅខិតខំការពារឧត្តមប្រយោជន៍របស់កុមារ នៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។ ឯកឧត្តម មានប្រសាសន៍ថា រាជរដ្ឋាភិបាលបានបង្កើតយន្តការការពារកុមារ ដែលមានលក្ខណៈ ប្រទាក់ក្រឡាជាពហុវិស័យទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបគ្រោះមហន្តរាយភាពក្រីក្រ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុក ការទុកកូនចោល ឪពុកម្តាយជាប់ពន្ធនាគារ ដែលជាហេតុធ្វើឱ្យកុមារទទួលរង នូវបញ្ហា ប្រឈមនានារួមមាន៖ កុមារបែកចេញពីគ្រួសារ ជួញដូរ រងអំពើហិង្សា ការគំរាមកំហែង ការរំលោភបំពានទាំងផ្លូវកាយ ផ្លូវចិត្ត និង ផ្លូវភេទ រួមទាំងការកេងប្រវ័ញ្ចតាមទម្រង់ផ្សេងៗទៀត។

កម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ហើយក្នុងនាមជារដ្ឋភាគី កម្ពុជាមាន កាតព្វកិច្ចធ្វើរបាយការណ៍ទៀងទាត់រៀងរាល់៥ឆ្នាំម្តង ទាក់ទងនឹងស្ថានភាពរស់នៅរបស់កុមារ ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ ជាដើម៕

## ក្រសួងការបរទេសចិន ឆ្លើយតបនឹងរបាយការណ៍ ប្រចាំឆ្នាំរបស់អាមេរិក ស្តីពីការជួញដូរមនុស្ស របស់សហរដ្ឋអាមេរិកថា សហរដ្ឋអាមេរិក គឺជាប្រទេសជួញ ដូរមនុស្សធំទី១ នៅលើពិភពលោក

https://dap-news.com/ ByPH104Posted on July 21, 2022

**លោក Wang Wenbin អ្នកនាំពាក្យ ក្រសួងការបរទេសចិន បានថ្លែង កាលពីថ្ងៃទី ២០ ខែកក្កដាថា មួយឆ្នាំទៅមួយឆ្នាំទៀត សហរដ្ឋអាមេរិក មិនអើពើនឹងការពិត ដោយប្រឌិតម្តង ហើយម្តងទៀត "របាយការណ៍" មិនពិតស្តីពីបញ្ហាជួញ ដូរមនុស្ស ដើម្បីបញ្ឆោតពិភពលោក។ តាមពិត សហរដ្ឋអាមេរិកវិញទេ ដែលជាប្រទេសជួញដូរ មនុស្សធំទី១ នៅលើពិភពលោក ។** តាមការផ្សាយដំណឹងឱ្យដឹងថា កាលពីថ្ងៃទី ១៩ ខែកក្កដា តាមម៉ោងក្នុងតំបន់ ក្រសួងការបរទេសអាមេរិក បានចេញ ផ្សាយរបាយការណ៍ ស្តីពីការជួញដូរមនុស្ស ប្រចាំឆ្នាំ ដោយបានបន្តដាក់ប្រទេសចិន ក្នុងបញ្ជីឈ្មោះប្រទេស និងតំបន់ប្រភេទទីបី ដែលមានភាព អាក្រក់បំផុត ព្រមនិងបានវាយប្រហារ និងលាបពណ៌ប្រទេសចិនតាមរយៈបញ្ហាដូចជា"ការបង្ខិតបង្ខំឱ្យធ្វើពលកម្ម"នៅក្នុងភូមិភាគស្វយ័ត Xinjiang ជាដើម។

នៅពេលឆ្លើយសំណួរពាក់ព័ន្ធ លោក Wang Wenbin បានលើកឡើងថា យោងតាមការប៉ាន់ប្រមាណរបស់ក្រសួង ការបរទេសអាមេរិក ជារៀងរាល់ឆ្នាំ មានមនុស្សចំនួន ១០ ម៉ឺននាក់ត្រូវបានជួញដូរពីបរទេស ទៅកាន់សហរដ្ឋអាមេរិក សម្រាប់ធ្វើពលកម្មក្រោមការបង្ខិតបង្ខំ ។ ប្រទេសចិនជាស់តឿន ឱ្យភាគីសហរដ្ឋអាមេរិក ផ្តោតការយកចិត្តទុក ដាក់លើបញ្ហាសិទ្ធិមនុស្ស ដោយប្រតិបត្តិការជាក់ស្តែង ដើម្បីប្រយុទ្ធប្រឆាំង បទឧក្រិដ្ឋសិទ្ធិមនុស្ស ដូចជាការជួញដូរមនុស្ស និង ការបង្ខំឱ្យធ្វើពលកម្ម ជាដើមនៅក្នុងប្រទេសខ្លួន ព្រមនិងពិនិត្យមើលខ្លួនឯង តាម"ស្តង់ដាខ្ពស់បំផុត" ដែលខ្លួនតែងអួតអាងនោះ ហើយឈប់មួលបង្កាច់ និងលាបពណ៌ប្រទេសផ្សេងទៀត៕

# ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២

## សម្តេច ស ខេង ភ្ញាក់ផ្អើលចំពោះការសម្រេចរបស់អាមេរិក ដែលដាក់កម្ពុជាក្នុងចំណាត់ថ្នាក់ លេខ៣ លើការជួញដូរមនុស្ស

https://www.kampucheathmey.com/ ២៥ វិនាទី មុន នៅ ថ្ងៃអាទិត្យ ២៤ កក្កដា ២០២២ដោយ Sovath

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានសំដែងនូវការភ្ញាក់ផ្អើលចំពោះការសម្រេចរបស់សហរដ្ឋអាមេរិក ដែលដាក់កម្ពុជាក្នុងចំណាត់ថ្នាក់លេខ៣ លើការជួញដូរមនុស្ស។

យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ក្រសួងការបរទេសអាមេរិក បានបង្ហាញឲ្យដឹងថា កម្ពុជាបានរអិលធ្លាក់ទៅក្នុងបញ្ជីខ្មៅ ឬចំណាត់ថ្នាក់កម្រិត៣ ដែលមិនបានទប់ស្កាត់បទល្មើសជួញដូរមនុស្សតាមស្តង់ដារជាអប្បរមា។ ក្នុងបញ្ជីខ្មៅ ឬកម្រិត៣ កម្ពុជានឹងអាចប្រឈមការរឹតត្បិតជំនួយ ឬឈានទៅដល់ការផ្តាច់ជំនួយពីសហរដ្ឋអាមេរិក ពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស។

នៅក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាក្នុងស្រុកអង្គស្នួល កាលពីថ្ងៃទី២៣ ខែកក្កដា សម្តេចក្រឡាហោម ស ខេង បានមានប្រសាសន៍ថាចំពោះការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស សម្តេចមានការភ្ញាក់ផ្អើលចំពោះការសម្រេចរបស់រដ្ឋាភិបាលអាមេរិក ដែលដាក់កម្ពុជាក្នុងចំណាត់ថ្នាក់លេខ៣ ដែលមានន័យថារាជរដ្ឋាភិបាលកម្ពុជាគ្មានឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ យ៉ាងណាក៏ដោយ សម្តេចបានសង្កត់ធ្ងន់ថាកម្ពុជានឹងមិនដកថយឡើយ ផ្ទុយទៅវិញ គឺនឹងខិតខំរកឱ្យឃើញចំណុចខ្សោយដើម្បីដោះស្រាយបញ្ហានេះ។

ចំពោះបញ្ហាគ្រឿងញៀនវិញ សម្តេចស ខេង បានបន្តថាបច្ចុប្បន្នកម្ពុជាកំពុងរៀបចំសេចក្តីព្រាងច្បាប់មួយដើម្បីគ្រប់គ្រងការនាំចូលសាធាតុគីមី និងទប់ស្កាត់កុំឱ្យមានការបង្វែរយកទៅផលិតជាគ្រឿងញៀន។ សម្តេចបន្ថែមថាបញ្ហាគ្រឿងញៀននេះ ក៏មានការជាប់ពាក់ព័ន្ធនឹងបទល្មើសសម្អាតប្រាក់ អំពើភេរវកម្ម និងការរីកសាយភាពអាវុធមហាប្រល័យផងដែរ។

ជាមួយគ្នានេះដែរសម្តេចក្រឡាហោម ស ខេង ក៏បានមានប្រសាសន៍អំពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងមហាផ្ទៃក្នុងការដោះស្រាយបញ្ហាចង្អៀតណែនក្នុងពន្ធនាគារ ក្នុងនោះសម្តេចក៏បានអំពាវនាវឱ្យប្រជាពលរដ្ឋចូលរួមគាំទ្រចំពោះការអនុវត្តវិធានការដោះលែងអ្នកជាប់ឃុំមួយចំនួនឱ្យនៅក្រៅឃុំដោយមានលក្ខណ្ឌ និងការអនុវត្តទោសសហគមន៍។ សម្តេចបន្តថាការងារនេះកំពុងអនុវត្តសាកល្បង ហើយប្រសិនបើអនុវត្តបានជោគជ័យ ក្រសួងនឹងពង្រីកការងារនេះទៀតដោយមានកិច្ចសហការជាមួយក្រសួងយុត្តិធម៌៕ អត្ថបទ៖ សំអឿន

## ក្រសួងមហាផ្ទៃ បង្ហាញលទ្ធផល
## កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ អាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន

https://dap-news.com/ ByPH104Posted on July 21, 2022

**ភ្នំពេញ ៖ ដោយបានការ អនុញ្ញាតពី សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ SOMTC-កម្ពុជា បានអញ្ជើញ ដឹកនាំ និងធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំ មន្ត្រីជាន់ខ្ពស់អាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី២២ និងកិច្ចប្រជុំពាក់ព័ន្ធ (22nd SOMTC and Its Related Meetings) សរុបចំនួន ១១កិច្ចប្រជុំ ចាប់ពីថ្ងៃទី ១៩-២១ ខែកក្កដា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ ។**

យោងតាមសេចក្តីប្រកាសព័ត៌មាន របស់ ក្រសួងមហាផ្ទៃ នាថ្ងៃទី២១ កក្កដា នេះ បាន ឱ្យ ដឹង ថា តាមរយៈកិច្ចពិភាក្សា និងការផ្លាស់ប្តូរយោបល់ ព្រមទាំងការចែករំលែក បច្ចុប្បន្នភាព អំពីនិន្នាការ នៃឧក្រិដ្ឋកម្មឆ្លងដែនក្នុងតំបន់ មន្ត្រីជាន់ខ្ពស់ នៃរដ្ឋសមាជិកអាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់ស្ថាប័នអនុវត្តច្បាប់ នៃបណ្តារដ្ឋសមាជិកអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ទោះបីស្ថិតក្នុងស្ថានភាពប្រឈម ដ៏ស្មុគស្មាញនៃវិបត្តិជំងឺកូវីដ-១៩។

សូមបញ្ជាក់ថា ក្រៅពីកិច្ចប្រជុំពេញអង្គ និងកិច្ចប្រជុំបូកបី ខាងលើនេះ ក្រុមការងារ SOMTC-កម្ពុជា ក៏បានធ្វើ ជាម្ចាស់ផ្ទះរៀបចំ និងចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ រវាងមន្ត្រីជាន់ខ្ពស់អាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន

ប្ញកជាមួយប្រទេសដៃគូសន្ទនាដទៃទៀត (SOMTC + Dialogue Partner Consultation) រួមមាន៖ កាណាដា ចិន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា សហភាពអឺរ៉ុប សហរដ្ឋអាមេរិក នូវែលសេឡង់ និង អូស្ត្រាលី ៕

## នាយករដ្ឋមន្ត្រីថៃស្វាគមន៍ចំពោះភាពប្រសើរឡើងរបស់ប្រទេសថៃនៅក្នុងរបាយការណ៍ TIP

https://www.information.gov.kh/ AKP ភ្នំពេញថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២

នាយករដ្ឋមន្ត្រីថៃ លោក ប្រាយុធ ចាន់អូចា បានសាទរចំពោះការសម្រេចចិត្តរបស់សហរដ្ឋអាមេរិកក្នុងការធ្វើឱ្យប្រសើរឡើងចំពោះប្រទេសថៃពីបញ្ជីចំណាត់ទី២ ដោយមានការឃ្លាំមើលទៅជាចំណាត់ថ្នាក់ទី២ នៅក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្ស (TIP) របស់សហរដ្ឋអាមេរិកឆ្នាំ២០២២ ដោយបានលើកឡើងពីកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសនេះក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សដោយគ្មានទីបញ្ចប់។

យោងតាមក្រសួងការបរទេសសហរដ្ឋអាមេរិកបានឱ្យដឹងថា ប្រទេសថៃបានកែលម្អការងាររបស់ខ្លួនយ៉ាងខ្លាំងក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការចាប់ខ្លួនជនល្មើស។ ទីភ្នាក់ងារសហរដ្ឋអាមេរិកបានបញ្ជាក់ថា កិច្ចខិតខំប្រឹងប្រែងទាំងនោះរួមមាន ការបង្កើនចំនួនការស៊ើបអង្កេត ការបញ្ចប់យន្តការបញ្ជូនបន្តថ្នាក់ជាតិ (NRM) ការអនុញ្ញាតឱ្យមានការឆ្លុះបញ្ចាំងរយៈពេល ៤៥ថ្ងៃ ក៏ដូចជាការបញ្ចប់គោលការណ៍ណែនាំសម្រាប់ការអនុវត្តបទញ្ញត្តិពលកម្មដោយបង្ខំនៃច្បាប់ប្រឆាំងការជួញដូរមនុស្ស និងចាប់ផ្តើមការស៊ើបអង្កេតប្រឆាំងនឹងមន្ត្រីចំនួន ១៧នាក់ដែលត្រូវបានចោទប្រកាន់ថាជាសហការីនៅក្នុងបទល្មើសជួញដូរមនុស្សកាលពីក្នុងឆ្នាំ២០២១។

អ្នកនាំពាក្យរដ្ឋាភិបាលថៃ លោក ថាណាកន វ៉ាំងប៊ុនគង់ចាណា បាននិយាយថា រដ្ឋបាលថៃបានកំណត់អាទិភាពទៅលើការបង្ក្រាប និងទប់ស្កាត់អំពើជួញដូរមនុស្សជាបញ្ហាបន្ទាន់ ដោយបច្ចុប្បន្ននេះ រដ្ឋាភិបាលកំពុងសហការជាមួយអង្គការក្នុងស្រុក និងអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់នៅក្នុងប្រទេសថៃ។ យោងតាមលោក ថាណាកន បានឱ្យដឹងថា លោកឧត្តមសេនីយ៍ ប្រាយុធ ក៏បានថ្លែងអំណរគុណដល់ភ្នាក់ងារពាក់ព័ន្ធ និងអ្នកដែលចូលរួមទាំងអស់នៅក្នុងបេសកកម្មដើម្បីកែលម្អស្ថានភាពរបស់ប្រទេសថៃសម្រាប់របាយការណ៍ TIP ។

នៅក្នុងរបាយការណ៍ TIP កាលពីឆ្នាំមុន ប្រទេសថៃត្រូវបានទម្លាក់ពីចំណាត់ថ្នាក់ទី២ ទៅជាចំណាត់ថ្នាក់ទី២ ដោយមានការឃ្លាំមើល។ ប្រសិនបើប្រទេសនេះនៅតែស្ថិតក្នុងការឃ្លាំមើលរយៈពេលពីរឆ្នាំជាប់គ្នា វានឹងធ្វើឱ្យប្រទេសថៃប្រថុយទៅនឹងការទម្លាក់ចំណាត់ថ្នាក់ដោយស្វ័យប្រវត្តិទៅចំណាត់ថ្នាក់ទី៣៕(ប្រភព NNT បកប្រែដោយលោក យា ចិន្តាឧត្តី) សម្រួលផ្សាយដោយ៖ ធូ កុសល

## របាយការណ៍៖ រយៈពេល៧ខែ មានពលករខ្មែរជាង៤ម៉ឺននាក់ បានវិលត្រឡប់មកប្រទេសវិញ តាមច្រកព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តបាត់ដំបង

http://freshnewsasia.com/ 2022-07-22 03:50pm

**(បាត់ដំបង)៖** បើយោងតាមរបាយការណ៍ស្តីពី ស្ថានភាពពលករតាមច្រកទ្វារព្រំដែនកម្ពុជា-ថៃ ប្រចាំថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ ពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តបានបង្ហាញឱ្យដឹងថា ក្នុងរយៈពេល០៧ខែ ដោយចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ មានពលករខ្មែរត្រឡប់ពីប្រទេសថៃ មកស្រុកកំណើតវិញសរុប៤១,៥០៩ម៉ឺននាក់ ក្នុងស្រុកចំនួន២ ជាប់ព្រំដែនកម្ពុជា-ថៃ នៃខេត្តបាត់ដំបង និងខេត្តប៉ៃលិន។

តាមសមត្ថកិច្ចមូលដ្ឋាន បានឱ្យដឹងថា ប្រជាពលរដ្ឋរស់នៅក្នុងស្រុកចំនួន២ នៅជាប់ព្រំដែនប្រទេសថៃ ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បានធ្វើចំណាកស្រុកជាបន្តបន្ទាប់ទាំងខុសច្បាប់ និងមួយចំនួនមានច្បាប់រាប់មុឺននាក់ នេះ បើគិតចាប់ពីដើមខែ០១ រហូតដល់ខែ០៧ ខែកក្កដានេះ។

របាយការណ៍បានគូសបញ្ជាក់ថា៖ «**ក្នុងរយៈពេល០៧ខែ ដោយចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី២០ ខែកក្កដាឆ្នាំ២០២២ មានពលករខ្មែរដែលមានលំនៅឋានក្នុងស្រុកចំនួន២ជាប់ព្រំដែនថៃមានជាង៤មុឺននាក់ បានត្រឡប់ចូលមកស្រុកកំណើតដើម្បីប្រកបរបរនៅស្រុកកំណើតវិញ**»។ របាយការណ៍ដដែល បានបញ្ជាក់ថា មានពលករចូលសរុបរួម ៤១,៥០៩នាក់ ស្រី១៨,៧៥៨នាក់ ក្មេង៥,៣៥៩នាក់ ស្រី២,២២៣នាក់ ក្នុងនោះមាន៖ ស្រុកកំរៀង មានពលករចូលចំនួន ៤១,៤៤៦នាក់ ស្រី ១៨,៧៣៤នាក់ក្មេង ៥,៣៥៧នាក់ ស្រី ចំនួន ២,២២៣នាក់ និងស្រុកភ្នំព្រឹក មានពលករចូលចំនួនសរុប ៤៣នាក់ ស្រី ២៤នាក់ ក្មេង០២នាក់ ស្រី០នាក់។

ប្រធានមន្ទីរ ក៏បានបញ្ជាក់ផងដែរថា ចំពោះពលករចំណាកស្រុកចេញទៅធ្វើការតាមរដូវ នៅក្នុងខេត្តច័ន្ទបុរី ប្រទេសថៃ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ មានចំនួនសរុប ៦៨នាក់ ស្រី២១នាក់។ លោកបានបន្តថា ពាក់ព័ន្ធនឹងពលករខ្មែរធ្វើសំណាកស្រុកនេះ ខាងមន្ទីរការងារក៏បានចូលរួមរៀបចំវគ្គផ្សព្វផ្សាយអប់រំស្តីពី សុវត្ថិភាពនៅក្នុងមូលដ្ឋានចំនួន២ភូមិ នៃឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង ដែលមានអ្នកចូលរួមសរុប ៧៩នាក់ ស្រី ៥៣នាក់ ក្នុងនោះមាន៖ ភូមិទួលទិល ចំនួន៣១នាក់ ស្រី២០នាក់ និងភូមិចម្លងក្រោម ចំនួន៤៨នាក់ ស្រី ៣៣នាក់ ផងដែរ៕

## ៦ខែ ក្នុងឆ្នាំ២០២២ នេះ ពលករខ្មែរ ដែលត្រូវបានថៃចាប់បញ្ជូន និងអ្នកវិលត្រឡប់មកវិញ មានជាង ១៧មុឺននាក់

https://kohsantepheapdaily.com.kh/ ភ្នំពេញ២២ ខែ កក្កដា ឆ្នាំ ២០២២ ម៉ោង ២១:០៧

បន្ទាយមានជ័យ៖ ពលករខ្មែរ ដែលត្រូវបានថៃ ចាប់បញ្ជូនត្រឡប់មកវិញ និងវិលត្រឡប់មកវិញ តាមច្រកចំនួន៤ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ នាឆមាសទី១ ក្នុងឆ្នាំ២០២២ មានជាង ១៧មុឺននាក់។ នេះបើយោងតាមរបាយការណ៍ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយ នៅថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ នៅសាលប្រជុំក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ។

លោកស្រី រស់ សុផានី អភិបាលរងខេត្តបន្ទាយមានជ័យ បានមានប្រសាសន៍ថា ដោយយោងតាមរបាយការណ៍មណ្ឌលសំចត ប៉ោយប៉ែត នៅដើមឆ្នាំ២០២២ ឆមាសទី១ មានចំនួន៤ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ ពលករខ្មែរ ដែលត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនមកវិញ និងវិលត្រឡប់មកវិញ មានចំនួន ១៧៤.១៤៨នាក់ ក្នុងនោះ មានស្រីចំនួន៣០.២៩៨នាក់ និងកុមារ មានចំនួន ៩.០៧៧នាក់ ក្នុងនោះ មានពលករខ្មែរត្រូវអាជ្ញាធរថៃចាប់បញ្ជូនមានចំនួន ៧៤.១៤៨នាក់ មាន១.ច្រកអន្តរជាតិប៉ោយប៉ែតមានចំនួន២៥.៤៤៣នាក់ ២.ច្រកអូរបីជាន់មានចំនួន៣៧.៣២៣នាក់ ៣.ច្រកម៉ាឡៃមានចំនួន៩.៥១២នាក់ ៤.ច្រកបឹងត្រកួនមានចំនួន១.៩៧០នាក់។

លោកស្រី បានបញ្ជាក់ថា ជាការខិតខំប្រឹងប្រែងពីក្រុមការងារមណ្ឌលសំចតប៉ោយប៉ែត និងក្រុមការងារទទួលពលករខ្មែរ ដែលត្រូវបានភាគីថៃចាប់បញ្ជូន និងពលករដែលត្រឡប់មកវិញដែលត្រូវបានទទួល និងយកចិត្តទុកដាក់ពិនិត្យសុខភាព ក្នុងបរិបទកូវីដ.១៩ បានបញ្ជូនទៅដាក់តាមមណ្ឌលចត្តាលីស័ក និងព្យាបាលកូវីដ.១៩ រហូតពេលនេះ ខេត្តបន្ទាយមានជ័យ ត្រូវបានលុបបំបាត់មណ្ឌលធ្វើចត្តាឡីស័ក ខណៈពេលដែលកូវីដ.១៩ត្រូវបានធូរស្រាលនៅកម្ពុជា។

ចំណែកលោក ឈួរ សុបញ្ញា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកនៃមូលនិធិជាតិជំនួយសង្គម បានមានប្រសាសន៍ថា ដើម្បីទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ ការពារសុវត្ថិភាពប្រជាពលរដ្ឋ លួចឆ្លងទៅរកការងារធ្វើនៅប្រទេសជិតខាង ដោយខុសច្បាប់ ក្រសួងសង្គមកិច្ច និងអាជ្ញាធរពាក់ព័ន្ធ បានផ្សព្វផ្សាយដល់ពលរដ្ឋអោយដឹងពីហានិភ័យនៃឆ្លងដែនដោយខុសច្បាប់ និងមានវិធានការចំពោះមេខ្យល់ ដែលបានបោកប្រាស់ពលរដ្ឋ និងទប់ស្កាត់ពលករចំណាក់ស្រុក និងការជួញដូរមនុស្ស ប្រកបដោយប្រសិទ្ធភាព។ លោកបានបញ្ជាក់ថា ជាការខិតខំយកចិត្តទុកដាក់ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានវិធានការទប់ស្កាត់កូវីដ.១៩ និងផ្ដល់វ៉ាក់សាំងការពារកូវីដ.១៩ ជូនប្រជាពលរដ្ឋទូទាំងប្រទេសកម្ពុជា ទទួលបានរហូតដូសទី៥ ហើយកូវីដ.១៩ នៅកម្ពុជា បានធូរស្រាល និងបើកអោយភ្ញៀវជាតិ-អន្តរជាតិ មកកំសាន្តនៅកម្ពុជា ដោយពុំចាប់បាច់ធ្វើចត្តាឡីស័កនោះទេ ទោះជាអ្នកដំណើរនោះ មិនបានចាក់វ៉ាក់សាំង បង្ការជំងឺកូវីដ១៩ ក៏ដោយ៕ ប៊ុន ធឿន

## អាស៊ានប្ដេជ្ញាចិត្តទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន

https://www.postkhmer.com/ រី សុចាន់ | Publication date 22 July 2022 | 11:17 ICT

**ភ្នំពេញៈ** ស្ថាប័នអនុវត្តច្បាប់ នៃបណ្ដារដ្ឋសមាជិកអាស៊ានប្ដេជ្ញាចិត្តទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន ទោះបីស្ថិតក្នុងស្ថានភាពប្រឈមដ៏ស្មុគស្មាញ នៃវិបត្តិជំងឺកូវីដ ១៩ ក៏ដោយ ខណៈបទល្មើសមួយចំនួនបន្តមានការកើនឡើងនៅក្នុងតំបន់។ ការប្ដេជ្ញាចិត្តនេះធ្វើឡើងក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន (SOMTC) លើកទី ២២ និងកិច្ចប្រជុំពាក់ព័ន្ធចាប់ពីថ្ងៃទី ១៩-២១ ខែកក្កដា តាមប្រព័ន្ធវីដេអូ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។ សេចក្ដីប្រកាសព័ត៌មានក្រសួងមហាផ្ទៃកម្ពុជាបញ្ជាក់នៅថ្ងៃទី ២១ ខែកក្កដា ថា៖ «មន្ត្រីជាន់ខ្ពស់នៃរដ្ឋសមាជិកអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនបានកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែង និងការប្ដេជ្ញាចិត្តរបស់ស្ថាប័នអនុវត្តច្បាប់នៃបណ្ដារដ្ឋសមាជិកអាស៊ានក្នុងកិច្ចសហប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ទោះបីស្ថិតក្នុងស្ថានភាពប្រឈមដ៏ស្មុគស្មាញនៃវិបត្តិជំងឺកូវីដ ១៩»។

កិច្ចប្រជុំក៏បានពិភាក្សាអំពីការបន្តសុពលភាពឯកសារសហប្រតិបត្តិការមួយចំនួន ដែលបានផុតសុពលភាព ឬជិតផុតសុពលភាព ដើម្បីកំណត់ និងដាក់ចេញនូវទិសដៅការងារបន្តនៅក្នុងដំណើរការកិច្ចសហប្រតិបត្តិការលើវិស័យអាទិភាពនានា ដែលស្ថិតក្រោមឧក្រិដ្ឋកម្មឆ្លងដែន។ យោងតាមប្រភពដដែល មន្ត្រីជាន់ខ្ពស់ទាំងនេះក៏បានកត់សម្គាល់ឃើញថា ទោះបីស្ថិតក្នុងបរិការណ៍នៃការរឹតបន្តឹងការធ្វើដំណើរដោយសារការរាតត្បាតនៃជំងឺកូវីដ១៩ យ៉ាងណាក៏ដោយ ក៏បទល្មើសមួយចំនួនបន្តមានការកើនឡើងនៅក្នុងតំបន់ រួមមាន ការជួញដូរគ្រឿងញៀន ការរត់ពន្ធមនុស្សឆ្លងដែន បទល្មើសពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មានអំពើជួញដូរមនុស្ស បទល្មើសសម្អាតប្រាក់ និងបទល្មើសសេដ្ឋកិច្ចអន្តរជាតិ ជាដើម។

សេចក្ដីប្រកាសព័ត៌មានដដែលបន្តថា៖ «បទល្មើសទាំងនេះក៏ជារបៀបវារៈយ៉ាងសំខាន់ សម្រាប់មន្ត្រីជាន់ខ្ពស់ក្នុងវិស័យអនុវត្តច្បាប់នៃបណ្ដារដ្ឋសមាជិកអាស៊ាន ធ្វើការពិភាក្សា និងស្វែងរកដំណោះស្រាយ ដើម្បីរួមគ្នាបង្ការ ទប់ស្កាត់ និងបង្ក្រាប ប្រកបដោយប្រសិទ្ធភាព ដើម្បីបុព្វហេតុសន្តិសុខ ការអភិវឌ្ឍ វិបុលភាព និងភាពសុខដុមរមនា សម្រាប់សហគមន៍ អាស៊ានទាំងមូល»៕

# ស្ថាប័នពាក់ព័ន្ធឆ្លើយតបចំពោះ UNCRC ដែលព្រួយបារម្ភលើការអនុវត្តការលើកកម្ពស់សិទ្ធិកុមារ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 22 July 2022 | 10:48 ICT

**ភ្នំពេញៈ** ក្រសួង និងស្ថាប័នពាក់ព័ន្ធនានារបស់កម្ពុជាបង្ហាញការប្តេជ្ញា និងការឆ្លើយតបចំពោះអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ អង្គការសហប្រជាជាតិ (UNCRC) ចំនួន ៤៨ អនុសាសន៍ ដែលជាការព្រួយបារម្ភរបស់ស្ថាប័ននេះលើការអនុវត្តការលើកកម្ពស់សិទ្ធិកុមារ ដូចជា ការអប់រំ និងកិច្ចការពារកុមារនៅកម្ពុជាកាលពីខែមិថុនា ឆ្នាំ ២០២២។ ការឆ្លើយតបរបស់តំណាងមកពីក្រសួងនានានេះធ្វើឡើងតាមរយៈកិច្ចពិភាក្សាតុមូលស្តីពីអនុសាសន៍នៃសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ រៀបចំដោយ អង្គការយូនីសេហ្វ នាថ្ងៃទី ២១ កក្កដា នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។ កាលពីខែមិថុនា ឆ្នាំ ២០២២ UNCRC ពិនិត្យរបាយការណ៍លើកទី ៤ និងទី ៦ ស្តីពី ស្ថានភាពសិទ្ធិកុមារនៅប្រទេសកម្ពុជា។ គណៈកម្មាធិការបានទទួលស្គាល់វឌ្ឍនភាព ដែលសម្រេចបានដោយរដ្ឋាភិបាលកម្ពុជានៅចន្លោះឆ្នាំ ២០១១ និងឆ្នាំ ២០២២ ប៉ុន្តែទន្ទឹមនឹងនេះក៏បានបង្ហាញពីចំណុចគួរឱ្យព្រួយបារម្ភ ជុំវិញបញ្ហាមួយចំនួន ដូចជាការអប់រំ និងកិច្ចការពារកុមារ។

លោក នឹម ថូត រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារថ្លែងពេលធ្វើជាអធិបតីកិច្ចពិភាក្សានេះថា ទោះបីមានការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល តាមរយៈការបង្កើតនូវយន្តការជាច្រើនក្នុងការគ្រប់គ្រង និងផ្តល់សេវាដល់មុខសញ្ញាកុមារទូទៅ និងកុមាររងគ្រោះយ៉ាងណាក្តី ក៏នៅមានកុមារមួយចំនួនកំពុងរស់នៅក្នុងស្ថានភាពលំបាក រងគ្រោះ ដែលត្រូវការការគាំទ្រ និងអន្តរាគមន៍ជាចាំបាច់ និងទាន់ពេលវេលា។ លោកថា ឆ្លើយតបនឹងកាតព្វកិច្ចជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ កាលពីខែឧសភា ឆ្នាំ ២០២២ រាជរដ្ឋាភិបាល បានរៀបចំចាត់ប្រតិភូនៃក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារដឹកនាំដោយលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារទៅចូលរួមការពាររបាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមាររបស់កម្ពុជាក្នុងកិច្ចប្រជុំលើកទី ៩០ របស់ UNCRC នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដោយទទួលបានលទ្ធផលគួរជាទីមោទនៈ។ លោកថ្លែងថា៖ «បន្ទាប់ពីកិច្ចប្រជុំ កម្ពុជាបានទទួលអនុសាសន៍មួយចំនួនដែលជាសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារមាន ៤៨ អនុសាសន៍ ដែលយើងនឹងលើកយកមកពិភាក្សានាថ្ងៃនេះ»។

លោក គីម សុវណ្ណឌី អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារថ្លែងក្នុងកិច្ចពិភាក្សាតុមូលនេះថា កាលពីថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០២២ កម្ពុជាបានទទួលអនុសាសន៍មួយចំនួនដែលជាសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារមាន ៤៨ អនុសាសន៍ ដែលជាអនុសាសន៍ក្នុងន័យស្ថាបនា ដើម្បីឱ្យកម្ពុជាបន្តអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារឱ្យកាន់តែល្អប្រសើរឡើង ស្របតាមស្ថានភាពវិវឌ្ឍន៍ជាក់ស្តែងរបស់កម្ពុជា។ លោកថ្លែងថា៖ «ជាទិសដៅបន្ត អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារនឹងជំរុញការអនុវត្តអនុសាសន៍ទាំងអស់នេះឱ្យបានជោគជ័យ ដូចជា រៀបចំសារាចរណែនាំរបស់រាជរដ្ឋាភិបាល និងបែងចែកអនុសាសន៍ទៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ និងគោលបំណងជំរុញការអនុវត្តអនុសាសន៍ឱ្យមានប្រសិទ្ធភាព។ លើកកម្ពស់ការផ្សព្វផ្សាយអនុសាសន៍នេះដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ ក្រោមជាតិ និងដល់ក្មួយៗកុមារឱ្យបានទូលំទូលាយ»។

លោកស្រី ជូ ប៊ុនអេង ថ្លែងថា កន្លងមក កម្ពុជាតែងតែសហការគ្នាជាមួយភាគីពាក់ព័ន្ធ ដើម្បីបំពេញបន្ថែមនូវចំណុចដែលនៅខ្វះចន្លោះ ដើម្បីធានាថា កុមារទាំងឡាយ ទោះបីចេញពីប្រភពណាក៏ដោយនៅក្នុងប្រទេសកម្ពុជាឱ្យនៅក្រោមដំបូលនៃច្បាប់ និងគោលនយោបាយដើម្បីកុមារ។ លោកស្រីថ្លែងថា៖ «ទាក់ទងនឹងក្រសួងមហាផ្ទៃ

គឺយើងបានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាក់ព័ន្ធ និងដឹកនាំរៀបចំផែនការច្បាស់លាស់លើការគាំពារកុមារនេះ ពីព្រោះយើងមានគោលនយោបាយ យើងចាំបាច់ត្រូវតែរៀបចំស្តង់ដានៃការអនុវត្តកិច្ចការពារកុមារនេះ»។

លោកស្រី ញាណ សុចិត្រា អគ្គនាយិកានៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី ឆ្លើយតបនឹងអនុសាសន៍នេះទាក់ទងនឹងការដាក់ទណ្ឌកម្មលើរាងកាយ ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទលើកុមារថា ក្រសួងកិច្ចការនារីកំពុងធ្វើការប៉ាន់ប្រមាណ និងពិនិត្យឡើងវិញនៃការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ លោកស្រីថ្លែងថា៖ «ក្រសួងកិច្ចការនារីបាននិងកំពុងធ្វើការប៉ាន់ប្រមាណ និងពិនិត្យ ឡើងវិញអំពីប្រសិទ្ធភាពនៃការអនុវត្តច្បាប់នេះ គឺដើម្បីកំណត់ឱ្យឃើញអំពីចំណុចខ្លាំង និងខ្សោយនៃការអនុវត្តច្បាប់ ដើម្បីធ្វើជាមូលដ្ឋាន ថា តើត្រូវសម្រេចធ្វើវិសោធនកម្មច្បាប់នេះលើមាត្រាណាខ្លះ»។

លោក ឌី ខាំប៉ូលី អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡាឆ្លើយតបនឹងអនុសាសន៍នេះដែរថា៖ «យើងមានជំនឿក្នុងការសម្រេចឱ្យបាននូវអនុសាសន៍ ដែលបានដាក់ឱ្យដោយ UNCRC នេះ ដោយសារតែយើងមានសសរស្តម្ភជាតិចំនួន ២ ធំៗ គឺសន្តិភាព និងការអភិវឌ្ឍ។ សសរស្តម្ភ ២ នេះបង្ហាញថា យើងអាចធ្វើអ្វីៗបានទាំងអស់ឱ្យតែប្រទេសជាតិយើងមានសន្តិភាព និងមានការអភិវឌ្ឍក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល»។

លោកស្រី Foroogh Foyouzat តំណាង យូនីសេហ្វប្រចាំកម្ពុជាថ្លែងក្នុងវេទិកានេះថា UNCRC បានទទួលស្គាល់វឌ្ឍនភាព ដែលសម្រេចបានដោយរដ្ឋាភិបាលកម្ពុជាចន្លោះឆ្នាំ ២០១១ និងឆ្នាំ ២០២២។ ទន្ទឹមនឹងនេះក៏បង្ហាញពីចំណុចគួរឱ្យព្រួយបារម្ភជុំវិញបញ្ហាមួយចំនួន ដូចជាការអប់រំ និងកិច្ចការពារកុមារ។ លោកស្រីថ្លែងថា៖ «ខ្ញុំសូមជំរុញឱ្យរដ្ឋាភិបាលរួមបញ្ចូលអនុសាសន៍នៅក្នុងច្បាប់ ផែនការ គោលនយោបាយ និងក្របខ័ណ្ឌបទប្បញ្ញត្តិដែលមានស្រាប់ និងមានថ្មីណាមួយរបស់ខ្លួន ក៏ដូចជានៅក្នុងផែនការស្តារឡើងវិញនូវកូវីដ ១៩»។ លោកស្រីថា៖ «កិច្ចពិភាក្សាថ្ងៃនេះ គឺជាឱកាសមួយដើម្បីស្តាប់អំពីផែនការរបស់ក្រសួងផ្សេងៗគ្នា ដើម្បីចាត់វិធានការលើអនុសាសន៍ទាំងនេះ ហើយខ្ញុំទន្ទឹងរង់ចាំយ៉ាងខ្លាំងក្នុងការសិក្សាអំពីពួកគេ»៕

## នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង ច្រានចោលការចុះផ្សាយព័ត៌មានមិនពិតលើបណ្តាញសង្គម ថាមន្ត្រីយកលុយពីពលករមានឯកសារប៉ាសស្ព័រត្រឹមត្រូវ ក្នុងម្នាក់ ១,៥០០បាត

http://freshnewsasia.com/ 2022-07-24 09:20am

**(ភ្នំពេញ)៖** ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង បានចេញមកបំភ្លឺជុំវិញករណីផ្សព្វផ្សាយព័ត៌មានមិនពិតតាមបណ្តាញសង្គម ដែលបានចោទប្រកាន់ថា **«មន្ត្រីអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិដូង យកលុយពីប្រជាជនមានឯកសារប៉ាសស្ព័រត្រឹមត្រូវហើយ បែរជាយកលុយពួកគាត់ក្នុងម្នាក់ ១,៥០០បាត និងថតចម្លងឯកសារ១០០បាត»។**

**បើយោងតាមលិខិតបំភ្លឺ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២នេះ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង សូមធ្វើការបកស្រាយបំភ្លឺដូចខាងក្រោម៖**

*ចំពោះការចោទប្រកាន់មកលើមន្ត្រីនគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង ថាបានយកលុយពីប្រជាជនមានឯកសារប៉ាសស្ព័រត្រឹមត្រូវហើយ បែរជាយកលុយពួកគាត់ក្នុងម្នាក់ ១,៥០០បាត និងថតចម្លងឯកសារ១០០បាត បន្ថែមទៀតនោះ ប៉ុស្តិ៍សូមធ្វើការបដិសេធទាំងស្រុងគឺមិនមានមន្ត្រីអន្តោប្រវេសន៍ណាម្នាក់យកលុយពីប្រជាជនប្រ ថាប់ត្រាឆ្លងដែនក្នុងម្នាក់ ១,៥០០បាត និងថតចម្លងឯកសារ ១០០បាត ដូចការចោទប្រកាន់របស់សមាគមអ្នកសារព័ត៌មានយុវជននោះទេ។ ម្យ៉ាងទៀតទីតាំង និងរូបភាពដែលបានបង្ហោះក្នុងបណ្តាញសង្គមនោះមិនស្ថិតនៅក្នុងរង្វង់ភូមិសាស្ត្រប្រតិបត្តិការរបស់មន្ត្រីនគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូងឡើយ។

*ចំពោះការចោទប្រកាន់ដែលមិនមានមូលដ្ឋានច្បាស់លាស់របស់សមាគមអ្នកសារព័ត៌មានយុវជនម ករលើមន្ត្រីនគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូងក្នុងបណ្តាញសង្គមធ្វើឱ្យប៉ះពាល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់មន្ត្រីក៏ដូចជាប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូងផងដែរ៕

## ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២

## ក្រសួងមហាផ្ទៃ នឹងបើកប្រតិបត្តិការ ត្រួតពិនិត្យការ រស់នៅជនបរទេស លើកលែងតែមន្ត្រីទូត ក្រោយអាមេរិក ដាក់កម្ពុជាក្នុងបញ្ជីខ្មៅ

https://dap-news.com/national/ ByPH104Posted on July 26, 2022

**ភ្នំពេញ ៖ សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអះអាងយ៉ាងម៉ឺងម៉ាត់ថា នឹងបើកប្រតិបត្តិការជាលក្ខណៈទ្រង់ទ្រាយធំ ត្រួតពិនិត្យការរស់នៅ របស់ជនបរទេសទាំងអស់នៅកម្ពុជា លើកលែងតែមន្ត្រីការទូត តែប៉ុណ្ណោះ។** ការត្រួតពិនិត្យការ រស់នៅ របស់ជនបរទេស នៅកម្ពុជាបែបនេះ បន្ទាប់ពីសហរដ្ឋអាមេរិក បានដាក់កម្ពុជា ចូលក្នុងបញ្ជីខ្មៅ ជាប្រទេសជាប់ ចំណាត់ថ្នាក់លេខ៣ នៃការជួញដូរមនុស្ស។

ក្នុងពិធីបិទវគ្គសុក្រឹតការ ថ្នាក់ដឹកនាំនគរបាល កម្រិត១ និងកម្រិត២ ជំនាន់ទី១ នៅបណ្ឌិត្យសភានគរបាលកម្ពុជា នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ សម្តេច ស ខេង បានសម្តែងការងឿងឆ្ងល់យ៉ាងខ្លាំង ចំពោះក្រសួងការបរទេសអាមេរិក ដាក់កម្ពុជា ចូលជាបញ្ជីខ្មៅ ជាប្រទេសជាប់ចំណាត់ថ្នាក់លេខ៣ ចំពោះការជួញដូរមនុស្ស ខណៈកម្ពុជា បានខិតខំយ៉ាងសកម្ម ក្នុងការសហការទប់ស្កាត់ អំពើជួញដូរមនុស្សនេះ។ សម្តេចបានបញ្ជាក់ថា «ដើម្បីលុបបំបាត់ការសង្ស័យ និងភាពចន្លោះប្រហោង ចំពោះការជួញដូរមនុស្សនេះ ក្រសួងមហាផ្ទៃ ត្រូវតែបើកប្រតិបត្តិការ ទ្រង់ទ្រាយធំ ត្រួតពិនិត្យរាល់ការរស់នៅរបស់ជនបរទេសទាំងអស់ មិនថា នៅតាមសណ្ឋាគារ ការដ្ឋាន និងតាមក្រុមហ៊ុននានានោះទេ លើកលែងតែមន្ត្រីការទូត» ។

ទោះយ៉ាងណា ក៏ដោយ សម្តេច ស ខេង ក៏បានសម្តែងការខកចិត្តយ៉ាងខ្លាំង ចំពោះការសម្រេច របស់ក្រសួងការបរទេសអាមេរិក ដាក់កម្ពុជាចូល ក្នុងបញ្ជីខ្មៅនេះ ប៉ុន្តែកម្ពុជានៅតែមានឆន្ទៈមុះមុត ក្នុងការសហការប្រយុទ្ធប្រឆាំង នូវអំពើជួញដូរមនុស្សជានិច្ច ហើយនឹងបើកប្រតិបត្តិការធំ ដើម្បីសម្អាត អំពើជួញដូរមនុស្សនៅកម្ពុជានេះ ស្របទៅតាមការចង់បាន របស់រាជរដ្ឋាភិបាលកម្ពុជា។

សូមរំលឹកថា សហរដ្ឋអាមេរិក បានដាក់កម្ពុជា ជាចំណាត់ថ្នាក់លេខ២ អស់រយៈពេលពីរឆ្នាំមកហើយ ខណៈចំណាត់ថ្នាក់លេខ២ នេះគឺជាប្រទេសមានការខិតខំប្រឹងប្រែង និងមានការឆ្លើយតប និងមានភាពចន្លោះប្រហោង ដែលត្រូវបំពេញបន្ថែម ក្នុងកិច្ចការប្រយុទ្ធប្រឆាំង ការជួញដូរមនុស្សនេះ។ ប៉ុន្តែសម្រាប់ឆ្នាំ២០២២នេះ ដែលអាមេរិកសម្រេច ដាក់កម្ពុជា ជាប្រទេសជាប់ចំណាត់ថ្នាក់លេខ៣ គឺគេចង់និយាយថា កម្ពុជាមានភាពព្រងើយកន្តើយ គ្មានការយកចិត្តទុកដាក់ និងគ្មានការខ្វាយខ្វល់ ចំពោះកិច្ចការប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស រហូតដល់គេអាចសម្រេច ដាក់ទណ្ឌកម្មដល់កម្ពុជា ផងដែរនោះ ៕

## កាស៊ីណូអត់ច្បាប់ និងបនស្រីពេស្យាចិន-វៀតណាម បើកទទួលអន្តោប្រវេសន៍ខុសច្បាប់ចិន គគ្រឹកគគ្រេងក្នុងទឹកដីខណ្ឌសែនសុខ លោក ឃួង ស្រេង ដឹងឬទេ?!

https://cen.com.kh/ Posted ByPen Srey NeatJuly 25, 2022

ភ្នំពេញ ៖ សណ្ឋាគារខ្ពស់ស្កឹមស្កៃមួយកន្លែង ត្រូវបានថៅកែជនជាតិចិន ៤នាក់សហការគ្នា ជួលពីម្ចាស់ជាជនជាតិខ្មែរ ទៅបើកជា កាស៊ីណូ (ល្បែងស៊ីសងជាច្រើនប្រភេទ) និងក្លិបកម្សាន្ត បម្រើអន្តោប្រវេសន៍លួចលាក់ជនជាតិចិនខុសច្បាប់ ក្នុងនោះមានទាំងបម្រើសេវាផ្លូវភេទមួយសេតតែម្តង ដែលពេលនេះកំពុងដំណើរការយ៉ាងត្រដាក់មេត្រដាក់កូន, រឿងនេះ មិនដឹងថាអាជ្ញាធរដែកជី លោក ហួរ ម៉េងវ៉ាង អធិការ និងលោក ម៉ូវ ម៉ានិត អភិបាល ដឹងដែរ តែបណ្តែតបណ្តោយ ឬក៏មិនបានដឹងសោះហ្មង ឬយ៉ាងណា?! ម្យ៉ាងទៀត អាចថា ក្រុមមន្ត្រីអាជ្ញាធរខណ្ឌសែនសុខ ព្យាយាមបិទបាំងរឿងអាស្រូវនេះមិនឱ្យ លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ ដឹងឡើយព្រោះខ្លាចបែកផ្ទាំងបាយរបស់ពួកគេ។

អូយយ៉ូយ ! CEN ស្តាប់ទៅព្រឺសម្បុរខ្លាំងណាស់ ត្រង់ថា កាស៊ីណូខុសច្បាប់ មានល្បែងស៊ីសងគ្រប់ប្រភេទដូចជា តុបៀ ហ្គេមអនឡាញ ស្លុតម៉ាស៊ីន និងសេវាស្រីស្រស់ ស្រីស្អាត ជនជាតិចិន និងវៀតណាម សម្រាប់បម្រើផ្លូវភេទដល់បុរសជនជាតិចិនដែលធ្វើអន្តោប្រវេសន៍លួចលាក់មកក្នុងប្រទេសកម្ពុជា។ រឿងអាស្រូវខុសច្បាប់ធំយ៉ាងនេះ ហេតុអ្វីក្រុមមន្ត្រីអាជ្ញាធរខណ្ឌសែនសុខ បែរជាថ្លើមធំ ហ៊ានគប់គិតគ្នាផ្តល់ឱ្យកាស៊ីណូអត់ច្បាប់ និងបនស្រីពេស្យាល្មើសច្បាប់ លុកលុយ បំពារបំពានវប្បធម៌សង្គមកម្ពុជាដ៏ល្អ បំបាក់មុខប្រមុខរាជរដ្ឋាភិបាល និងលួចលាក់មិនឲ្យអភិបាលរាជធានីភ្នំពេញ លោក ឃួង ស្រឹង ដឹងថែមទៀត តើវាស័ក្តិសមនឹងទំនុកចិត្តរបស់ប្រជាពលរដ្ឋដែរទេ?!

សណ្ឋាគារបង្កើតបទល្មើសដ៏អសោចិ៍មួយកន្លែងនេះ មានកម្ពស់ខ្ពស់គ្រាន់បើ ស្ថិតនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ (ស្គាល់ច្បាស់លេខផ្ទះ លេខផ្លូវ ប៉ុន្តែសុំលាក់បន្តិចសិន ទុកមុខទុកមាត់ឱ្យអាជ្ញាធរដែនដី ចាំមើលថា ចេះរកឃើញឬអត់?), ទីតាំងកាស៊ីណូ និងវិមានបនពេស្យានារីចិន និងវៀតណាម លួចលាក់នេះ មាន២អាគារ គឺអគាខាងមុខ និងអគារខាងក្រោយ, មានច្រកចូល ២កន្លែង គឺច្រកចូលខាងកើតមួយកន្លែង និងច្រកចូលខាងជើងមួយកន្លែង។

តាមប្រភពពីប្រជាពលរដ្ឋ និងក្រុមមន្ត្រីស្មោះត្រង់ បានឱ្យដឹងថា សណ្ឋាគារនេះមានឈ្មោះ... (សុំលាក់សិន) មានម្ចាស់ជាជនជាតិខ្មែរ ប៉ុន្តែបានជួលឲ្យថៅកែជនជាតិចិនមានគ្នា ៤នាក់, ដំបូងឡើយគេនិយាយគ្នាពីការជួលបើកក្លិបកម្សាន្ត របៀបជា ភោជនីយដ្ឋាន ខារ៉ាអូខេ ស្ទីម ម៉ាស្សា តែប៉ុណ្ណោះ ប៉ុន្តែ ថៅកែចិន ដែលមានផ្នត់គំនិតម៉ាហ្វីយ៉ា និងចរិតរកស៊ីកាប់ដាវ (រកស៊ីខុសច្បាប់) មិនខ្លាចញញើតច្បាប់ប្រទេសកម្ពុជានោះ បែរជាទៅបើកកាស៊ីណូ អត់ច្បាប់ (ល្បែងស៊ីសងជាច្រើនប្រភេទ មាន តុបៀ ហ្គេមអនឡាញ ស្លុតម៉ាស៊ីន) និង សេវាផ្លូវភេទសម្រាប់អន្តោប្រវេសន៍ចិនលួចលាក់ខុសច្បាប់ទៅវិញ។

ភ្នាក់ងារសម្ងាត់របស់ CEN រួមជាមួយក្រុមមន្ត្រីស្មោះត្រង់ បាននិយាយប្រាប់ថា បនល្បែងកាស៊ីណូតុបៀ គេរៀបចំនៅអគារខាងក្រោយជាន់ក្រោយ, ល្បែងហ្គេមអនឡាញគេរៀបចំនៅអគារខាងក្រោយដែរ តែជាន់ទី១, រីឯកន្លែងម៉ាស្សា និងបន្ទប់បម្រើសេវាផ្លូវភេទ គេរៀបចំនៅជាន់ខាងលើៗទៀត, សម្រាប់នារីបម្រើផ្លូវភេទវិញ គឺមានតែនារីចិន និងនារីវៀតណាម តែប៉ុណ្ណោះ, ចំណែកនារីខ្មែរវិញ គេមិនអនុញ្ញាតឱ្យមាននៅក្នុងនេះទេ។ ស្ថានភាពនៃការចូលលេងល្បែងស៊ីសង និងសេវាផ្លូវភេទ គេរៀបចំប្រព័ន្ធការពារ ឬសន្តិសុខយាមកាម តឹងតែងណាស់, តាមប្រភពថា ជាកម្លាំងនគរបាលព្រហ្មទណ្ឌកម្រិតស្រាលមកពីក្រសួងមហាផ្ទៃទៀតផង។

អ្នកដែលអាចចូលលេង ឬចេញ-ចូលក្នុងកាស៊ីណូអត់ច្បាប់នេះបាន គឺលុះណាតែ នារី-បុរស ជនជាតិចិន ឬនារីជនជាតិវៀតណាម ទើបគេអនុញ្ញាតឲ្យចូល, បើឃើញបុរស-នារី ជនជាតិខ្មែរវិញ គេមិនអនុញ្ញាតឱ្យចូលទេ, បើអាច លុះណាតែ នារីខ្មែរហ្នឹង ត្រូវបានបុរសជនជាតិចិននាំចូល។ ប្រភពខាងលើ បានបញ្ជាក់ឱ្យដឹងថា បនល្បែងកាស៊ីណូខុសច្បាប់ និងសេវាបម្រើផ្លូវភេទរបស់ថៅកែចិនទាំង ៤នាក់នេះ ចាប់ផ្តើមបើកដំណើរការយ៉ាងសប្បាយរីករាយ ត្រជាក់មេ ត្រជាក់កូន ចាប់តាំងពីដើម ខែមិថុនា ឆ្នាំ២០២២មកម្ល៉េះ គិតមកដល់ចុង ខែកក្កដានេះ គឺប្រហែលពីរខែហើយ, សភាពទូទៅនៅក្នុងសណ្ឋាគារបង្កប់កាស៊ីណូ និងបនស្រីពេស្យានេះ គឺមានសកម្មភាពអ៊ូអរ ឬចាប់ផ្តើមបម្រើសេវាគ្រប់យ៉ាង តែពេលយប់ៗប៉ុណ្ណោះ, ចាប់ពីម៉ោង ៧ព្រឹក រហូតដល់ម៉ោង ៥ល្ងាច ទីនេះនៅស្ងាត់នៅឡើយទេ, តែចាប់ពីម៉ោង ៧យប់ ឡើងទៅ គឺដំណើរការពេញទី, រហូតដល់ម៉ោងជាង៤ទៀបភ្លឺ ទើបភាពអ៊ូអរត្រូវបានរសាយបាត់បន្តិចម្តងៗ។

សូមបញ្ជាក់ថា ទីតាំងកាស៊ីណូ និងបនពេស្យាខុសច្បាប់ខាងលើនេះ គេបម្រើ និងបើកឲ្យចេញចូលចំពោះតែជនអន្តោប្រវេសន៍ចិនលួចលាក់ខុសច្បាប់ចូលមកស្នាក់នៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ, ជនជាតិខ្មែរ គេមិនឱ្យចេញ-ចូលកម្សាន្តនៅទីនេះ នោះទេ ព្រោះថា ខ្លាចបែកការណ៍។ ចំពោះករណីនេះ តើអាជ្ញាធរខណ្ឌសែនសុខមាន លោក ហួរ ម៉េងរ៉ាង អធិការនគរបាល និងលោក ម៉ូវ ម៉ានិត អភិបាលខណ្ឌ បានចឹង ឬក៏អត់? បើដឹងហើយហេតុម្តេច មិនបង្ក្រាប ?! បែរជាទុកឲ្យកាស៊ីណូល្បែងស៊ីសងច្រើនប្រភេទ និងបនស្រីពេស្យាបម្រើផ្លូវភេទខុសច្បាប់នេះ បើកដំណើរការ បង្កកលិយុគក្នុងរាជធានីភ្នំពេញបែបនេះ?! បើថាថ្នាក់ដឹកនាំខណ្ឌសែនសុខ ទាំងពីរនាក់នេះ មិនបានដឹងរឿងអាស្រូវនេះវិញ តើសមត្ថភាពរបស់ពួកគេក្នុងការដឹកនាំអភិវឌ្ឍន៍ខណ្ឌ នឹងទៅជាយ៉ាងណា?! ត្រង់ចំណុចនេះ សូម លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ មេត្តាពិនិត្យមើលអំពីសកម្មភាពការងារ និងសមត្ថភាពរបស់ថ្នាក់ដឹកនាំខណ្ឌសែនសុខឡើងវិញផង។

រឿងរ៉ាវអាស្រូវក្នុងទឹកដីខណ្ឌសែនសុខនេះ មជ្ឈមណ្ឌលព័ត៌មាន CEN បានទាក់ទងទៅសុំការបំភ្លឺបកស្រាយពីថ្នាក់ដឹកនាំផងដែរ គឺ លោក ហួរ ម៉េងរ៉ាង អធិការនគរបាល និងលោក ម៉ូវ ម៉ានិត អភិបាលខណ្ឌ ប៉ុន្តែមិនអាចទាក់ទងបាន ដោយពួកលោក ខ្លះខលចូលហើយ មិនលើកទូរស័ព្ទ, អ្នកខ្លះជាប់ប្រជុំ និងអ្នកខ្លះសូមឱ្យរង់ចាំ ហើយក៏មិនបានឆ្លើយតប៕ ពិសិដ្ឋ CEN

## ថៃ ចាប់បាន មេខ្លោង
## ជួញដូរមនុស្សឆ្លងដែន មកធ្វើការក្នុងក្រុមជម្រិតទារប្រាក់តាមទូរស័ព្ទនៅ កម្ពុជា

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២៦ កក្កដា ២០២២ដោយ Sok Sovann

បុរសជនជាតិចិនម្នាក់ ដែលគេតាមចាប់ខ្លួន ករណីជួញដូរជនជាតិចិនឆ្លងដែនទៅធ្វើការក្នុងក្រុមជម្រិតទារប្រាក់តាមទូរស័ព្ទនៅប្រទេសឡាវ និងកម្ពុជា ត្រូវបានចាប់ខ្លួននៅអាកាសយានដ្ឋានសុវណ្ណភូមិ ទីក្រុងបាងកក កាលពីថ្ងៃសៅរ៍ទី២៣ខែកក្កដា។ មេប៉ូលិស Suwat Chaengyordsook បានទទួលទូរស័ព្ទកាលពីថ្ងៃសុក្រ ទី២២ ខែកក្កដា ដោយព្រមានថា ជនជាតិចិនដែលប៉ូលិសអន្តរជាតិ Interpol កំពុងតាមចាប់ខ្លួនបំផុត នឹងធ្វើដំណើរទៅកាន់អាកាសយានដ្ឋានសុវណ្ណភូមិក្នុងទីក្រុងបាងកក នៅថ្ងៃបន្ទាប់។ លោក Zhou Dawei ត្រូវបានគេប្រកាសតាមចាប់ខ្លួននៅក្នុងប្រទេសចិន ក្រោមការសង្ស័យជាមេខ្លោងជួញដូរមនុស្សក្នុងនិងក្រៅប្រទេស។ លោក Dawei ត្រូវប៉ូលិសថៃចាប់ខ្លួន ពេលគាត់មកដល់ទីក្រុងបាងកកនៅថ្ងៃសៅរ៍ ហើយត្រូវបានសួរចម្លើយនៅមជ្ឈមណ្ឌលឃុំឃាំងអាកាសយានដ្ឋានសុវណ្ណភូមិ។ លោក Dawei សារភាពថា បាននាំជនជាតិចិនចូលទៅក្នុងប្រទេសឡាវនិងកម្ពុជា

ដើម្បីធ្វើការនៅក្នុងក្រុមជម្រិតទារប្រាក់តាមទូរស័ព្ទ។ អាជ្ញាធរចិនបានប្រាប់ប៉ូលិសថៃថា លិខិតឆ្លងដែនរបស់ Dawei ត្រូវបានដកហូតរួចហើយ ហើយបានស្នើឲ្យនិរទេសគាត់ត្រឡប់ទៅប្រទេសចិនវិញ ដើម្បីកាត់ទោស។ ប៉ូលិសថៃ បានដាក់លោក Dawei ក្នុងជើងហោះហើរ CZ 3082 របស់ក្រុមហ៊ុនអាកាសចរណ៍ China Southern Airlines ឆ្ពោះទៅកាន់ទីក្រុង Guangzhou នៅម៉ោង ៥ល្ងាច ថ្ងៃទី២៥ខែកក្កដា៕ **Vann Vann ប្រភព៖** Sanook

## ពលករខ្មែរ៤០នាក់ឆ្លងដែនខុសច្បាប់ ត្រូវយោធាថៃឃាត់ខ្លួន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៦ ខែ កក្កដា ឆ្នាំ ២០២២ ម៉ោង ១៤:៤១

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរប្រុសស្រីចំនួន៣៩នាក់ ដែលចាញ់បោកមេខ្យល់លួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ត្រូវបានយោធាថៃ ឃាត់ខ្លួនក្នុងភូមិសាស្ត្រ ស្រុកអារញ្ញ ស្រុកតាប់ប្រាយ៉ាខេត្តស្រះកែវ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ដើម្បីយកទៅសួរនាំ ។

តាមប្រភពព័ត៌មានបានឲ្យដឹងថាកម្លាំងសមត្ថកិច្ចការពារព្រំដែនរបស់ថៃជាច្រើនគោលដៅ ដោយមានកម្លាំងទាហានប្រាណអង្គភាពទី១២ អង្គភាពចំពោះកិច្ចទាហានជើងគោកទី១១១ ស្រុកតាព្រះយ៉ា នឹងសមត្ថកិចកចទាហានប្រាណអង្គភាពទី១៣ បានធ្វើការដើរល្បាត ត្រួតពិនិត្យ ដើម្បីការពារនឹងទប់ស្កាត់ការលួចឆ្លងដែនចូលប្រទេសដោយខុសច្បាប់ បរិវេណព្រំដែនថៃ-កម្ពុជា ក្នុងភូមិសាស្ត្រស្រុកអារញ្ញ នឹងស្រុកតាបប្រាយ៉ា របស់ខេត្តស្រះកែវ តាមវិធានការការពារនឹងគ្រប់គ្រងការរាតត្បាតជម្ងឺកូវីដ-១៩ រួមទាំងជម្ងឺអុតស្វាផងដែរនោះ។ តាមប្រភពបន្តថា សមត្ថកិច្ចថៃល្បាតនឹងត្រួតពិនិត្យ និងភូមិសាស្ត្រទទួលខុសត្រូវ ក៏បានជួបប្រទះមនុស្សជាច្រើននាក់គួរឲ្យសង្ស័យ ស្របពេលដើរមកតាមច្រករបៀងទើបហៅឲ្យឈប់ដើម្បីត្រួតពិនិត្យ នឹងបានប្រទះឃើញពលករខ្មែរប្រុស ស្រី ចំនួន ៣៩នាក់ ក្រោយធ្វើការឆែកឆេរ សមត្ថកិច្ចថៃបាននាំខ្លួនយកទៅសួរនាំបន្ថែម នឹងបញ្ជូនខ្លួនពលករខ្មែរទាំងអស់យកទៅ ដើម្បីចាត់ការតាមនីតិវិធី៕

## ពលរដ្ឋខ្មែរជាច្រើននាក់<br>នៅតែបន្តឆ្លងដែនខុសច្បាប់ទៅប្រទេសថៃដោយសារអត់ការងារធ្វើនៅកម្ពុជា

https://www.rfa.org/khmer/ ដោយ សុជីវ៍2022.07.26

ប្រជាពលរដ្ឋខ្មែរជាច្រើននៅតែព្យាយាមឆ្លងដែនដោយខុសច្បាប់ចូលទៅរកការងារធ្វើនៅប្រទេសថៃ បើទោះបីជាពួកគាត់ដឹងថា ប្រឈមនឹងគ្រោះថ្នាក់ខ្លាំងក៏ដោយ ដោយសារតែជីវភាពខ្វះខាត និងពុំមានការងារធ្វើនៅក្នុងស្រុក។ សង្គមស៊ីវិលយល់ថា មូលហេតុដែលពលករខ្មែរឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ដោយសារពួកគេគ្មានប្រាក់ធ្វើលិខិតឆ្លងដែន។ ពលករខ្មែរលើកឡើងថា មូលហេតុដែលពួកគាត់ចេះតែឆ្លងដែនចូលទៅរកការងារធ្វើនៅប្រទេសថៃទាំងប្រថុយនឹងគ្រោះថ្នាក់នោះ ដោយសារក្នុងស្រុកលំបាករកការងារធ្វើឲ្យបានទៀងទាត់ ស្របពេលដែលធ្វើស្រែចម្ការបានផលមកគ្មានទីផ្សារលក់កសិផលក្នុងតម្លៃសមរម្យ ហើយពួកគាត់ជំពាក់បំណុលធនាគារវ័ណ្ឌក។

ពលការិនី ធ្វើការជាអ្នករៀបបន្លែផ្លែឈើដាក់កេះម្នាក់នៅខេត្តប៉ាថុមថានី(Pathum Thani) លោកស្រី សាវេន អាយុ៣៥ឆ្នាំ មកពីស្រុកកោះក្រឡ ខេត្តបាត់ដំបង ទើបតែរស់នៅប្រទេសថៃបានជិតមួយខែ ប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី២៥ ខែកក្កដា ថា លោកស្រីសម្រេចចិត្តទៅរកការងារធ្វើនៅប្រទេសថៃ ដោយសារផលដំឡូងមីរបស់លោកស្រីលក់បានថោក ហើយមិនគ្រប់ដោះស្រាយជីវភាពប្រចាំថ្ងៃ។ លោកស្រីបន្តថា លោកស្រីបានឆ្លងដែនចូលទៅប្រទេសថៃដោយខុសច្បាប់តាមរយៈមេខ្យល់ ព្រោះលោកស្រីមិនចង់ធ្វើឯកសាររកការងារតាមរយៈក្រុមហ៊ុន

ដែលបង់ប្រាក់ថ្លៃវត់ការច្រើនដំណាក់កាល និងស៊ីពេលយូរ។ លោកស្រីបញ្ជាក់ថា សព្វថ្ងៃលោកស្រីនៅតែមានក្តីកង្វល់ ពេលដែលប៉ូលិសថៃចុះឆែកឆេរតាមកន្លែងធ្វើការ ព្រោះលោកស្រីមិនទាន់មានឯកសារស្របច្បាប់ ដើម្បីធ្វើការនៅឡើយទេ៖ «ធ្វើវាបានតិចពេកខ្ចិល អត់ធ្វើក៏មកនេះ។ខុសគ្នាស្រុកយើងវាអត់ដូចស្រុកគេ ប្រជាជនគេសុខសាន្តជាង។ និយាយទៅគេមកគ្រប់តែគ្នាមករកការងារធ្វើបានអីចឹងទៅណា។ យើងនៅឯណោះរកបានដែរ ប៉ុន្តែអត់ដូចគេ»។

ស្រដៀងគ្នានេះដែរ ពលការិនីម្នាក់ទៀតដែលធ្វើការជាមួយគ្នាលោកស្រី ភាព ស្រីរត្ន ប្រាប់ថា លោកស្រីមិនចង់ទៅធ្វើការនៅប្រទេសគេទាំងខុសច្បាប់ដូច្នេះទេ ព្រោះពេលចូលទៅត្រូវកាត់វាលកាត់ព្រៃទាំងមិនដឹងទិសតំបន់ និងមានហានិភ័យខ្លាំង តែដោយសារជីវភាពខ្វះខាតទើបផ្សងគ្រោះថ្នាក់ ដើម្បីរកប្រាក់ដោះស្រាយជីវភាពគ្រួសារ៖ «ចង់ស្នើឲ្យរាជរដ្ឋាភិបាលថៃ បើសិនជាប្រជាពលរដ្ឋខ្មែរមកខុសច្បាប់ សុំកុំឲ្យចាប់យកទៅដាក់ឃុំឃាំង សុំឲ្យមានការធ្វើប័ត្រធ្វើប៉ាស្ព័រ។ហើយឲ្យប្រជាជនខ្មែរមានការងារធ្វើ មានអីត្រឹមត្រូវទាំងអស់ ។ ជួយមានការងារធ្វើហើយកុំឲ្យថា កុំឲ្យរើសអើងខ្មែរ ឬក៏ស្តីថា»។

វិទ្យុអាស៊ីសេរី មិនអាចសុំការអត្ថាធិប្បាយជុំវិញរឿងនេះ ពីស្ថានទូតខ្មែរប្រចាំប្រទេសថៃ បានទេនៅថ្ងៃទី២៥ខែកក្កដា ដោយទូរស័ព្ទហៅចូលជាច្រើនដងតែពុំមានអ្នកទទួល។

របាយការណ៍របស់ទាហានថៃខេត្តស្រះកែវថា កាលពីថ្ងៃទី២៤ ខែកក្កដា ក្រុមទាហានថៃប្រចាំការនៅស្រុកអារញ្ញប្រទេស និងស្រុកតាព្រះយ៉ា ខេត្តស្រះកែវ (Sra Keo) បានស្កាត់ចាប់ពលរដ្ឋខ្មែរចំនួន៣៣នាក់ ដែលឆ្លងដែនខុសច្បាប់ចូលទៅប្រទេសថៃ តាមព្រំដែនខេត្តបន្ទាយមានជ័យ ដោយបំណងចូលទៅធ្វើការនៅខេត្តប៉ាថុមថានី (Pathum Thani) ខេត្តឈុនប៊ុរី (Chun Buri) និងខេត្តរ៉ះយ៉ង(Ra Yong)។

ជុំវិញរឿងនេះ មន្ត្រីគម្រោងនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស អង្គការសង់ត្រាល់ (CENTRAL)ប្រចាំប្រទេសថៃលោក លឹង សុផុន ឲ្យដឹងថា អំឡុងរយៈពេលប្រមាណ៧ខែក្នុងឆ្នាំ២០២២នេះ ពលរដ្ឋខ្មែរបានឆ្លងដែនខុសច្បាប់ទៅប្រទេសថៃប្រមាណ២ពាន់នាក់(២.០០០) ដែលត្រូវក្រុមទាហានថៃតាមបណ្តោយព្រំដែនចាប់បាន។ លោកលើកឡើងថា មូលហេតុដែលពលករខ្មែរឆ្លងដែននេះ ដោយសារពួកគេមានជីវភាពកាន់តែលំបាកទៅ រកប្រាក់ចំណូលមិនបានគ្រប់គ្រាន់ ទប់ទល់នឹងប្រាក់ចំណាយ ហើយពេលពួកគាត់ចង់ទៅប្រទេសថៃស្របច្បាប់ត្រូវបង់ថវិកាច្រើន ហើយបំពេញបែបបទប្រើពេលយូរ ទើបធ្វើឲ្យពួកគាត់ហ៊ានប្រថុយចូលទៅប្រទេសថៃទាំងគ្រោះថ្នាក់៖ «វាអាស្រ័យទៅខាងថៃ អឺ!អីចឹងណាបង ហើយណាមួយទៀត ទាល់តែខាងរដ្ឋាភិបាលថៃគេអនុលោមទៅ យើងក៏បានទៅ។ តែផ្ទុយទៅវិញ ខាងរដ្ឋាភិបាលខ្មែរយើង ហាក់បីដូចជាមិនសូវមានប្រសិទ្ធភាពទេ ក្នុងវិធានការបែបសម្របសម្រួលឲ្យបងប្អូនពលករខ្មែរ ធ្វើយ៉ាងណាឲ្យពួកគាត់មានភាពងាយស្រួលក្នុងការឆ្លងដែនចូលមកថៃ ហើយក្នុងការគាត់ធ្វើឯកសារផ្សេងៗអីចឹងទៅណ៎ា»។

បច្ចុប្បន្នមានស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលមួយចំនួន ដែលធ្វើការគ្រប់គ្រងចំពោះពលករចំណាកស្រុក មានស្ថានទូតខ្មែរប្រចាំប្រទេសថៃ បានចុះទៅអប់រំដល់ពលករចំណាកស្រុកអំពីហានិភ័យនៃការឆ្លងដែនខុសច្បាប់ជូនពលករខ្មែរ ក៏ប៉ុន្តែនៅតែមានប្រជាពលរដ្ឋខ្មែរជាច្រើននាក់លបឆ្លងដែនចូលទៅប្រទេសថៃដដែល ។ មន្ត្រីសង្គមស៊ីវិល យល់ថា ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលខ្មែរគួរតែបង្កើនការងារនៅក្នុងស្រុកឱ្យបានច្រើន ដើម្បីឱ្យប្រជាពលរដ្ឋរកប្រាក់ដោះស្រាយជីវភាព និងជួយរកទីផ្សារលក់កសិផលក្នុងតម្លៃសមរម្យជូនដល់កសិករ៕

## សមត្ថកិច្ចខេត្តបាត់ដំបងបន្តចុះត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

https://gdlf-kh.com/ 2022/07/26/ Vicheka បាត់ដំបង

ខេត្តបាត់ដំបង៖ នាថ្ងៃអង្គារ ១៣រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង១១ និង០០នាទី ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា–ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា–ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០៣នាក់ និងកម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០៣នាក់ បានទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១លើក សរុបចំនួន១៤នាក់ ស្រី៥នាក់ ក្មេងប្រុស១នាក់ ។

ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើកត់ឈ្មោះ ចុះកំណត់ហេតុប្រចាំថ្ងៃ អប់រំណែនាំ រួចបានបញ្ជូនប្រជាពលរដ្ឋទាំងអស់ឱ្យទៅពិនិត្យ និងស្វែងប័ណ្ណចាក់វ៉ាក់សាំងចេញត្រឹមត្រូវទាំងអស់នៅមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនបន្ទាប់មកទើបបានអនុញ្ញាតឲ្យប្រជាពលរដ្ឋត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន។

# ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២

## ក្រសួងមហាផ្ទៃ នឹងបើកប្រតិបត្តិការត្រួតពិនិត្យការស្នាក់នៅរបស់ជនបរទេសនៅកម្ពុជា លើកលែងតែមន្ត្រីការទូត ដើម្បីពិនិត្យភាពស្របច្បាប់ និងរកមុខសញ្ញាជួញដូរ

http://freshnewsasia.com/ 2022-07-27 10:36am

**(កណ្ដាល)៖** សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថា ក្រសួងមហាផ្ទៃ នឹងបើកប្រតិបត្តិការត្រួតពិនិត្យការរស់នៅរបស់ជនបរទេសទាំងអស់នៅក្នុងប្រទេសកម្ពុជា លើកលែងតែមន្ត្រីការទូតប៉ុណ្ណោះ ដើម្បីពិនិត្យភាពស្របច្បាប់ និងរកមុខសញ្ញាដែលពាក់ព័ន្ធនឹងជួញដូរមនុស្ស។ សម្តេចក្រឡាហោម ស ខេង ថ្លែងបែបនេះនៅក្នុងពិធីបិទវគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាលកម្រិត១ និងកម្រិត២ ជំនាន់ទី១ នៅបណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ កន្លងទៅ។ សម្តេចក្រឡាហោម ស ខេង បានបញ្ជាក់ថា ដើម្បីលុបបំបាត់ការសង្ស័យ និងភាពចន្លោះប្រហោងចំពោះការជួញដូរមនុស្សនេះ ក្រសួងមហាផ្ទៃត្រូវតែបើកប្រតិបត្តិការទ្រង់ទ្រាយធំត្រួតពិនិត្យ រាល់ការរស់នៅរបស់ជនបរទេសទាំងអស់ មិនថានៅតាមសណ្ឋាគារ ការដ្ឋាន និងក្រុមហ៊ុននានានោះទេ លើកលែងតែមន្ត្រីការទូត។

បើតាមសម្តេចក្រឡាហោម ស ខេង បានឲ្យដឹងទៀតថា ពាក់ព័ន្ធការងារបើកប្រតិបត្តិការទ្រង់ទ្រាយធំមួយនេះ ក្រសួងនឹងរៀបចំផែនការឱ្យបានហ្មត់ចត់បំផុត ដើម្បីរកមុខសញ្ញានៃការជួញដូរមនុស្ស។ **«អ្នកមកធ្វើការងារនៅកន្លែងការដ្ឋានផ្សេងៗ ក្រុមហ៊ុន វិនិយោគទាំងអស់ហ្នឹង គឺត្រូវតែត្រួតពិនិត្យ ហើយត្រួតពិនិត្យនេះគ្មានក្នុងបំណងអីទេ គឺក្នុងបំណងឱ្យរកឃើញថា អ្នកដែលមកកម្ពុជាហ្នឹង គឺចូលដោយត្រឹមត្រូវតាមច្បាប់ ឬមិនត្រឹមត្រូវ ធ្វើការនៅកម្ពុជាហ្នឹង មានច្បាប់ការងារអត់ ហើយរកឱ្យឃើញអ្នក ដែលជាមុខសញ្ញានៃជួញដូរមនុស្ស»**។

នេះជាការបញ្ជាក់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ សហរដ្ឋអាមេរិក កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ បានផ្សព្វផ្សាយរបាយការណ៍ ឆ្នាំ២០២២ ស្តីពីការជួញដូរមនុស្ស។ ក្នុងរបាយការណ៍នោះ អាមេរិកបានដាក់កម្ពុជា វៀតណាម តំបន់ម៉ាកាវរបស់ចិន និងប្រទេស៣ទៀតនៅអាស៊ាន ពីបញ្ជីស្ថិតក្រោមការឃ្លាំមើលនៅកម្រិត២ ទៅកម្រិត៣ ដែលគេស្គាល់ជាទូទៅថា បញ្ជីខ្មៅ ដែលជាកម្រិតដ៏អាក្រក់។ អាមេរិកចោទប្រកាន់ថា កម្ពុជា និងប្រទេសទាំងនោះ មានកិច្ចខិតខំតិចតួច និងមិនបានគោរពតាមស្តង់ដារនៃការលុបបំបាត់ការជួញដូរមនុស្ស។

សម្តេចក្រឡាហោម ស ខេង ដែលជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២២ ក៏បានចេញការប្រតិកម្មជាលើកដំបូង ក្រោយក្រសួងការបរទេសអាមេរិក ទម្លាក់ចំណាត់ថ្នាក់កម្ពុជាដល់លេខ៣ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ក្នុងពិធីសម្ពោធសមិទ្ធផលអគារសិក្សាក្នុងខេត្តកណ្តាល សម្តេចក្រឡាហោម បានអះអាងថា ទោះកម្ពុជាទទួលបានចំណាត់ថ្នាក់បែបនេះ ក៏មិនបន្ធូរដៃក្នុងការងារលុបបំបាត់ការជួញដូរមនុស្សដែរ។ សម្រាប់របាយការណ៍ស្តីពីការជួញដូរមនុស្សរបស់អាមេរិក ត្រូវបានបែងចែកជា ៥កម្រិត ដោយកម្រិត១ គឺល្អ និងគោរពស្តង់ដារអប្បបរមា, កម្រិត២ រដ្ឋាភិបាលគោរពស្តង់ដារនៃការជួញដូរ មិនបានពេញលេញ ប៉ុន្តែមានកិច្ចខិតខំក្នុងការកែលម្អ, កម្រិត២ ស្ថិតក្នុងបញ្ជីឃ្លាំមើល គឺរដ្ឋាភិបាលគោរពស្តង់ដារនៃការជួញដូរមិនបានពេញលេញ និងមានកិច្ចខិតខំកែលម្អបញ្ហានេះ ប៉ុន្តែអត្រានៃការជួញដូរនៅតែបន្តកើនឡើង, កម្រិត៣ ជាកម្រិតដែលរដ្ឋាភិបាលមិនគោរពស្តង់ដារអប្បបរមានៃការជួញដូរឱ្យបានពេញលេញ និងមិនមានកិច្ចខិតខំទប់ស្កាត់ការជួញដូរមនុស្ស និងកម្រិតចុងក្រោយ គឺករណីពិសេស។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស (គ.ជ.ប.ដ) បានចាត់ទុកថា របាយការណ៍របស់រដ្ឋាភិបាលអាមេរិក ដែលបានដាក់រាជរដ្ឋាភិបាលកម្ពុជា ទៅក្នុងបញ្ជីខ្មៅនៃការជួញដូរមនុស្ស គឺជារបាយការណ៍ ដែលរៀបចំឡើងដោយគ្មានមូលដ្ឋានច្បាស់លាស់ឡើយ។ សម្រាប់លោកស្រី ជូ ប៊ុនអេង ដែលជាមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកពាក់ព័ន្ធនឹងការងារការលុបបំបាត់ការជួញដូរមនុស្ស នៅអាស៊ានក៏មានប្រទេសពាក់កណ្តាល ដែលអាមេរិកដាក់ចូលក្នុងបញ្ជីខ្មៅ លើរឿងជួញដូរមនុស្ស ហើយប្រទេសទាំងនោះ រួមមាន វៀតណាម ម៉ាឡេស៊ី ព្រុយណេ មីយ៉ាន់ម៉ា ខណៈដែលថៃ បានហក់ទៅលេខ២ វិញ៕

## កម្ពុជានឹងបើកការត្រួតពិនិត្យជនបរទេស
## ក្រោយអាមេរិកថាគ្មានឆន្ទៈប្រឆាំងការជួញដូរមនុស្ស

https://www.khmertimeskh.com/ តន វិបុល July 28, 2022

ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ នឹងបើកប្រតិបត្តិការត្រួតពិនិត្យជនបរទេសទាំងអស់ដែលស្នាក់នៅកម្ពុជា លើកលែងតែមន្ត្រីទូត។ ផែនការបើកប្រតិបត្តិការនេះត្រូវបានលោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រកាសនៅក្នុងពិធីបិទវគ្គសិក្សាថ្នាក់ដឹកនាំនគរបាលនៅបណ្ឌិត្យសភានគរបាលកម្ពុជាកាលពីថ្ងៃអង្គារ។ លោកនិយាយថា ជនបរទេសដែលមកធ្វើការនៅកន្លែងការដ្ឋាន ក្រុមហ៊ុនឯកជន វិនិយោគទាំងអស់ គឺត្រូវតែត្រួតពិនិត្យ ដើម្បីរកឲ្យឃើញថា ជនបរទេសដែលចូលមកកម្ពុជាត្រឹមត្រូវ ឬមិនត្រឹមត្រូវតាមច្បាប់ និងរកឲ្យឃើញអ្នក ដែលជាមុខសញ្ញានៃការជួញដូរមនុស្ស។ លោកថា៖ «ជួនកាលយកមកលាក់ទុកនៅផ្ទះសំណាក់ណាមួយ នៅសណ្ឋាគារណាមួយ ឬក៏បង្កប់នៅក្នុងកាស៊ីណូណាមួយ ហើយនឹងការធ្វើទារុណកម្មធ្វើបាបជួញដូរនៅក្នុងកាស៊ីណូណាមួយ គឺត្រូវត្រួតពិនិត្យឲ្យច្បាស់»។ ការប្រកាសបើកប្រតិបត្តិការត្រួតពិនិត្យជនបរទេសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ធ្វើឡើងបន្ទាប់ពីអាមេរិកដាក់កម្ពុជាជាប្រទេសលំដាប់ទី៣នៃការជួញដូរមនុស្ស ដែលមានន័យថាកម្ពុជាគ្មានឆន្ទៈក្នុងកាប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរ

មនុស្ស។ លោក ស ខេង បញ្ជាក់ថា ដើម្បីលុបបំបាត់ការសង្ស័យ និងភាពចន្លោះប្រហោងចំពោះការជួញដូរមនុស្ស ក្រសួងនឹងរៀបចំផែនការប្រតិបត្តិការមួយនឹងធ្វើការងារនេះឲ្យបានម៉ត់ចត់ ដើម្បីត្រួតពិនិត្យជនបរទេស និងដើម្បីរកមុខសញ្ញានៃការជួញដូរមនុស្សនៅកម្ពុជា។

ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរងនគរបាលជាតិ បាននិយាយថា ការបើកប្រតិបត្តិត្រួតពិនិត្យជនបរទេសនៅកម្ពុជាកំពុងសហការជាមួយស្ថាប័នពាក់ព័ន្ធនានា ដូចជាក្រសួងការងារ ក្រសួងមហាផ្ទៃ និងពាក់ព័ន្ធជាមួយស្ថាប័នផ្សេងៗទៀត ព្រោះវាជាយុទ្ធនាការដ៏ធំមួយដែលទាមទារការរៀបចំផែនការច្បាស់លាស់ ដើម្បីចុះអនុវត្តផែនការ។ លោកបន្តថា៖ «ក្នុងករណីរកឃើញជនបរទេសរស់នៅកម្ពុជាមានកំហុសឆ្គង គឺយើងមិនមានធ្វើអ្វីក្រៅពីអនុវត្តវិធានការច្បាប់នោះទេ។ គ្រប់យ៉ាង គឺអាស្រ័យលើច្បាប់របស់យើង ប្រសិនបើច្បាប់តម្រូវឱ្យបញ្ជូនគាត់ទៅស្រុកកំណើតវិញ គឺយើងបញ្ជូនគាត់ទៅ ហើយប្រសិនបើច្បាប់តម្រូវឱ្យពិន័យគាត់ គឺយើងត្រូវតែពិន័យ»។ លោកបន្ថែមថា នៅតាមច្រកព្រំដែនអន្តរជាតិជាធម្មតា ជាច្រកត្រូវបានបើកចំហរ ដែលកន្លងមកត្រូវបានបន្តរឹតបន្តឹង និងអនុវត្តដោយមន្ត្រីអន្តោតប្រវេសន៍ ប៉ុន្តែជនបរទេសដែលចេញចូលកម្ពុជាសុទ្ធតែមានឯកសារត្រឹមត្រូវ។

នាយឧត្តមសេនីយ៍ កែវ វណ្ណថន អគ្គនាយករង និងជាអ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍មិនអាចផ្តល់បទសម្ភាសដល់កាសែតខ្មែរថាមស៍ឡើយ ដោយលោកប្រាប់ថាកំពុងស្ថិតនៅឯក្រៅប្រទេស។ តាមរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចាប់ពីឆ្នាំ២០១៤ មកដល់ដំណាច់ឆ្នាំ២០២១ កម្ពុជាបានបណ្តេញចេញជនបរទេសខុសច្បាប់ចំនួន ២០ ៨២៤នាក់ចេញពីកម្ពុជា ក្នុងនោះមាន១០២សញ្ជាតិ។ នៅក្នុងឆ្នាំ២០២១ កម្ពុជាបានបណ្តេញចេញចំនួន ៣៥៩៤នាក់ ក្នុងនោះមាន១៥សញ្ជាតិ ប៉ុន្តែរបាយការណ៍មិនបានបញ្ជាក់ថា សញ្ជាតិច្រើនជាងគេនោះទេ។

យ៉ាងណាលោក ស៊ឹង សែនករុណា មន្ត្រីអង្កេតផ្នែកសិទ្ធិមនុស្សនៃសមាគមន៍អាដហុក បង្ហាញការគាំទ្រចំណាត់ការរបស់មន្ត្រីរដ្ឋមន្ត្រីភិបាលចំពោះជនបរទេសដែលយកទឹកដីកម្ពុជធ្វើជាមូលដ្ឋាន ដើម្បីប្រព្រឹត្តិបទល្មើស ព្រោះលោកព្រួយបារម្ភនូវការប៉ះពាល់ដល់មុខមាត់របស់ប្រទេស។ លោកបានបញ្ជាក់ថា៖ «ចំណាត់ការនេះ គឺធ្វើសម្រាប់តែជនបរទេសដែលប្រព្រឹត្តនូវបទល្មើសប៉ុណ្ណោះ សម្រាប់ជនបរទេសដែលមករស់នៅប្រកបរបរដោយសុចរិតនៅកម្ពុជា គឺពុំប៉ះពាល់ដល់សិទ្ធិរបស់ពួកគាត់ឡើយ។ ប៉ុន្តែយ៉ាងណាមន្ត្រីដែលចុះអនុវត្តបទបញ្ជាគួរធ្វើឱ្យបានត្រឹមត្រូវ ដើម្បីចៀសវាងការរិះគន់ពីបរទេស»។

កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ ក្រសួងការបរទេសអាមេរិក បានចេញរបាយការណ៍អំពីការជួញដូរមនុស្សតាមបណ្តាប្រទេសនានា។ ក្នុងរបាយការណ៍នោះ ក្រសួងការបរទេសនៃប្រទេសមហាអំណាចមួយនេះ បានដាក់កម្ពុជា វៀតណាម និងដែនដីម៉ាកាវ ចូលក្នុងបញ្ជីខ្មៅនៃប្រទេសដែលមានការជួញដូរមនុស្ស។

អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានប្រសាសន៍ថា ជារឿងអយុត្តិធម៌ ដែលក្រសួងការបរទេសអាមេរិកដាក់កម្ពុជាចូលក្នុងបញ្ជីខ្មៅ។ អ្នកស្រីស្នើឲ្យភាគីដែលដឹងឮពីករណីជួញដូរមនុស្សនៅកម្ពុជា រាយការណ៍ដល់អាជ្ញាធរ ដើម្បីរួមគ្នាដោះស្រាយ៕

## អគ្គស្នងការនគរបាលជាតិ ជួបពិភាក្សាការងារជាមួយ តំណាងក្រសួងសន្តិសុខមាតុភូមិ និង អន្តោប្រវេសន៍ (HSI) អមស្ថានទូតអាមេរិកប្រចាំកម្ពុជា

http://freshnewsasia.com/ 2022-07-27 05:00pm

**(ភ្នំពេញ)៖** នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ នៅព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២នេះ បានអនុញ្ញាតឲ្យលោក JAMES PODBOY តំណាងក្រសួងសន្តិសុខមាតុភូមិ និងអន្តោប្រវេសន៍ HSI អមស្ថានទូតសហរដ្ឋអាមេរិក ប្រចាំកម្ពុជា និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។ ក្នុងជំនួបនោះ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានស្វាគមន៍ចំពោះលោក JAMES PODBOY តំណាងក្រសួងសន្តិសុខមាតុភូមិ និងអន្តោប្រវេសន៍ HSI អមស្ថានទូតសហរដ្ឋអាមេរិក ប្រចាំកម្ពុជា និងសហការី និងបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័នអនុវត្តច្បាប់ នៃប្រទេសទាំងពីរនាពេលកន្លងមក រួមទាំងការផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ និងការបណ្តុះបណ្តាល ជាពិសេសការទប់ស្កាត់បទល្មើសជួញដូរមនុស្ស និងបទល្មើសគ្រឿងញៀន។

ជាការឆ្លើយតប លោក JAMES PODBOY តំណាងក្រសួងសន្តិសុខមាតុភូមិ និងអន្តោប្រវេសន៍ HSI អមស្ថានទូតសហរដ្ឋអាមេរិក បានថ្លែងអំណរគុណដល់នគរបាលកម្ពុជា ដែលបានរួមសហការគ្នាល្អ ក្នុងការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេសទប់ស្កាត់បទល្មើសជួញដូរមនុស្ស និងបទល្មើសគ្រឿងញៀន។ លោក JAMES PODBOY ក៏បានថ្លែងការកោតសរសើរដល់ស្ថាប័នអនុវត្តនៃប្រទេសកម្ពុជា ដែលបានបំពេញការងារប្រកបដោយវិជ្ជាជីវៈ ជួយឲ្យកម្ពុជារួចផុតពីបញ្ជីឈ្មោះ ជាប្រទេសគោលដៅទេសចរណ៍ផ្លូវភេទកុមារ។

ជាចុងក្រោយ ភាគីទាំងពីរបានឯកភាពគ្នា បន្តពង្រឹងកិច្ចសហប្រតិបត្តិលើការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ និងការកសាងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ផងដែរ៕

## នាយឧត្តមសេនីយ៍ នេត សាវឿន ជួបអនុព័ន្ធផ្នែកច្បាប់ FBI របស់ស្ថានទូតអាមេរិកចប់អាណត្តិ និងអ្នកដែលត្រូវចូលកាន់តំណែងថ្មី

http://freshnewsasia.com/ 2022-07-27 04:55pm

**(ភ្នំពេញ)៖** នៅព្រឹកថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២នេះ នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានអនុញ្ញាតឲ្យ លោក STEVEN STUEHSER អនុព័ន្ធផ្នែកច្បាប់ FBI អមស្ថានទូតសហរដ្ឋអាមេរិក ប្រចាំកម្ពុជា (ចប់អាណត្តិ) និងលោកស្រី AMY SHUMAN អនុព័ន្ធផ្នែកច្បាប់ FBI អមស្ថានទូតសហរដ្ឋអាមេរិក ប្រចាំកម្ពុជា (ចូលកាន់តំណែងថ្មី) ព្រមទាំងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។

ជាកិច្ចចាប់ផ្តើម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានស្វាគមន៍ចំពោះលោកស្រី AMY SHUMAN អនុព័ន្ធផ្នែកច្បាប់ FBI អមស្ថានទូតសហរដ្ឋអាមេរិក ប្រចាំកម្ពុជាថ្មី និងបានថ្លែងអំណរគុណចំពោះលោក STEVEN STUEHSER អនុព័ន្ធផ្នែកច្បាប់ FBI អមស្ថានទូតសហរដ្ឋអាមេរិក ប្រចាំកម្ពុជា ដែលបានចប់អាណត្តិការងារ ដែលរយៈកាលកន្លងមកបានសហប្រតិបត្តិការគ្នាបានល្អ។ ក្នុងជំនួបភាគីទាំងពីរ បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការនាពេលកន្លងមក និងពិភាក្សាសំខាន់ផ្តោតទៅលើទំនាក់ទងកិច្ចសហប្រតិបត្តិការ និងការជួយគាំទ្រគ្នាទៅវិញទៅមកលើការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ការជួយគាំទ្រផ្នែកមធ្យោបាយ សម្ភារសម្រាប់បម្រើឲ្យកិច្ចសហប្រតិបត្តិការ ដើម្បីរួមគ្នាឈានទៅប្រយុទ្ធប្រឆាំង និងទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់

ប្រភេទ ជាពិសេសបទល្មើសជួញដូរមនុស្ស បទល្មើសគ្រឿងញៀន បទល្មើសបច្ចេកវិទ្យា និងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ។

ភាគីទាំងពីរ បានសម្តែងនូវសេចក្តីរីករាយក្នុងការចូលរួមសហប្រតិបត្តិការរវាងស្ថាប័នអនុវត្តច្បាប់ នៃប្រទេសទាំងពីរ ជាពិសេសការផ្លាស់ប្តូរព័ត៌មាន និងចែករំលែកបទពិសោធន៍ ទៅវិញទៅមកក្នុងកិច្ចប្រតិបត្តិការបង្ក្រាបទប់ស្កាត់បទល្មើសនានា នាពេលកន្លងមកផងដែរ។ ឆ្លៀតក្នុងឱកាសនេះ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ក៏បានជូនពរដល់លោកស្រី AMY SHUMAN អនុព័ន្ធផ្នែកច្បាប់ FBI អមស្ថានទូតសហរដ្ឋអាមេរិកថ្មី រួមទាំងសហការីទាំងអស់ សូមមានសុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច និងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនគរបាលកម្ពុជា ឲ្យកាន់តែល្អប្រសើរបន្ថែមទៀត៕

## សិក្ខាសាលាស្តីពី ផែនការកិច្ចការពារកុមារ ៣ឆ្នាំរំកិល(២០២៣-២០២៥) ខេត្តសៀមរាប

http://nokorwatnews.com/ 27/07/2022

ខេត្តសៀមរាប ៖ នៅថ្ងៃពុធ ទី២៧ ខែកក្កដា ឆ្នាំ២០២២ នៅបន្ទប់ប្រជុំលេខ១ សាលាខេត្តសៀមរាប បានបេ ីកសិក្ខាសាលាស្តីពី ផែនការកិច្ចការពារកុមារ ៣ឆ្នាំរំកិល (២០២៣-២០២៥)ខេត្ត ក្រោមសហអធិបតីភាព លលោកស្រី ស៊ិន ណម សមាជិកាក្រុមប្រឹក្សាខេត្ត និងជាប្រធាន គ ក ស ក និង លោកស្រី យូ សុភា អភិបាលរងខេត្តតំណាង លោក ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងមានការអញ្ជើញចូលរួមពី លោក ភី ណូ ប្រធាននាយកដ្ឋានសុខមាលភាពកុមារ លោក លោកស្រី តំណាងអង្គការយូនីសេហ្វ លោក លោកស្រី មន្ត្រីរាជការរដ្ឋបាលខេត្ត តំណាងមន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូជាតិ អន្តរជាតិ សរុបចំនួន ៧៤នាក់។

ក្នុងសិក្ខាសាលានេះដែរ លោក គង់ សំអឿន ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានរាយការណ៍ពីសកម្មភាព និងលទ្ធផលការងាររបស់ក្រុមការងារកិច្ចការពារកុមារខេត្ត ប្រចាំឆមាសទី១ ឆ្នាំ២០២២ និងលេ ីកទិសដៅអនុវត្តបន្តឆមាសទី២ ឆ្នាំ២០២២។

លោកស្រី អភិបាលរងខេត្ត ក៏បានលើកឡើងអំពើហិង្សាលើកុមារ គឺជាបរិបទសាកល ដែលនៅតែបន្តកើតមានអាស្រ័យកត្តាសំខាន់បី គឺការអប់រំសង្គម ការអនុវត្តច្បាប់ និងការឆក់ឱកាសពីជនល្មើស ដែលបានស្តែងចេញតាមរូបភាព អំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈ អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ អំពើកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឬការរំលោភបំពានទៅលើសិទ្ធិនិងសេរីភាពរបស់កុមារ ក៏ដូចជាការទទួលរងគ្រោះពីគ្រោះមហន្តរាយនានាជាដើម។ តាមរយៈការសិក្សាស្រាវជ្រាវមុនៗបានបង្ហាញថា ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងប្រទេសកម្ពុជា មានតម្រូវការចម្រុះដែលមិនអាចបំពេញបានពេញលេញ ដោយអ្នកផ្តល់សេវាតែម្នាក់ ឬ ការផ្តល់សេវាមិនបានសម្របសម្រួលត្រឹមត្រូវតាមច្បាប់ ។ កន្លងមកតាមរយៈ ការអនុវត្តផ្ទាល់ជាលទ្ធផលទាំងស្ថាប័នរដ្ឋ និងអង្គការបានជួបប្រទះនូវបញ្ហាមួយចំនួន ក្នុងការបញ្ជូនជនរងគ្រោះ និងការគ្រប់គ្រងទិន្នន័យនៃការផ្តល់ និងទទួលសេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅមានកម្រិត ពិសេសកុមារ។

សិក្ខាសាលានេះរៀបចំឡើង ដើម្បីពិនិត្យលើវឌ្ឍនភាព នៃការអនុវត្តផែនការកិច្ចការពារកុមារឆ្នាំ២០២១ ព្រមទាំងលើកបញ្ហាប្រឈមមកពិភាក្សារកដំណោះស្រាយ និងការរៀបចំផែនការខេត្តស្តីពីកិច្ចការពារកុមាររយៈពេល ៣ឆ្នាំរំកិល (ឆ្នាំ២០២៣-២០២៥)៕

## ឃាត់ខ្លួនពលរដ្ឋខ្មែរ ២១នាក់ ខណៈបម្រុងលួចឆ្លងដែនទៅប្រទេសថៃ

https://gntimes.com/ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២

បន្ទាយមានជ័យ ៖ កម្លាំងចម្រុះឈរជើងតាមបន្ទាត់ព្រំដែន បានឃាត់ខ្លួនពលរដ្ឋខ្មែរ ២១នាក់ ខណៈបម្រុងលួចឆ្លងដែនទៅប្រទេសថៃ ។ ការឃាត់ខ្លួននេះ សមត្ថកិច្ចធ្វើឡើងកាលពីវេលាម៉ោងជាង ១១យប់ ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០២២ ត្រង់ចំណុចមាត់អូរព្រំដែន ស្ថិតក្នុងភូមិអូរស្មំ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានឱ្យដឹងថា នៅវេលាម៉ោងខាងលើ កម្លាំងប៉ុស្តិ៍ដើមត្រសេក ៤នាក់ដឹកនាំដោយលោក វរសេនីយ៍ត្រី ណុប អឿន នាយប៉ុស្តិ៍ សហការជាមួយកម្លាំងផ្នែកសឹករងស្រុកម៉ាឡៃ ៣នាក់ ដឹកនាំដោយលោក វរសេនីយ៍ត្រី ជា រិទ្ធ មេបញ្ជាការកងអនុសេនាធំ បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរបម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ២១នាក់ (ស្រី ៩នាក់ កុមារម្នាក់) ។ ក្នុងចំណោមពលរដ្ឋដែលកម្លាំងឃាត់ខ្លួន គឺមកពីខេត្តបន្ទាយមានជ័យ ១៤នាក់, កំពង់ចាម ៣នាក់, ក្រចេះ ២នាក់, និងខេត្តកំពត ២នាក់ ។ លោកមេបញ្ជាការ បានបន្តថា បន្ទាប់ពីធ្វើការសួរនាំ និងធ្វើកិច្ចសន្យារួច សមត្ថកិច្ចបានប្រគល់ពួកគាត់ជូនផ្នែកជំនាញរបស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់ ៕ ដោយ ចន្រ្ទា

# ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២

## អភិបាលខេត្តស្វាយរៀង ជំរុញឱ្យគ្រប់អង្គភាពចូលរួមទប់ស្កាត់ការជួញដូរមនុស្សគ្រប់រូបភាព

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២៨ កក្កដា ២០២២ដោយ Sophal Tuon

លោក ម៉ែន វិបុល អភិបាលខេត្តស្វាយរៀង និងជាប្រធានគណៈកម្មាធិការប្រឆាំងអំពើជួញដូរមនុស្ស បានក្រើនរំលឹកដល់មន្រ្តីទាំងអស់ ត្រូវយកចិត្តទុកដាក់ចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសនៅក្នុងមូលដ្ឋានខេត្តស្វាយរៀង ដើម្បីរក្សាសុខសុវត្ថិភាពជូនប្រជាពលរដ្ឋ។ លោកថ្លែងដូច្នេះថា« *ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាការងារយើងទាំងអស់គ្នា ដែលទាមទារឲ្យមានការចូលរួមពីគ្រប់សមាសភាពពាក់ព័ន្ធទាំងអស់ ទាំងរដ្ឋ ប្រជាពលរដ្ឋ វិស័យឯកជន និងអង្គការសង្គមស៊ីវិល ទើបការងារនេះ អាចសម្រេចទៅបានដោយរលូន និងទទួលបានលទ្ធផលជោគជ័យ*»។

លោក ម៉ែន វិបុល ថ្លែងបែបនេះ នៅក្នុងកិច្ចប្រជុំ ស្តីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី១ និងទិសដៅបន្តឆមាសទី២ ឆ្នាំ២០២២ នៅព្រឹកថ្ងៃទី ២៨ ខែកក្កដា។ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់សម្តេចតេជោ ហ៊ុន សែន ជានាយករដ្ឋមន្រ្តី ដែលនៅតែចាត់ទុកថា ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោម អាទិភាពជាច្រើនទៀត សម្រាប់ការលើកកម្ពស់សន្តិសុខ និងសុវត្ថិភាពសង្គម។ នេះជាការបន្ថែមរបស់លោក ម៉ែន វិបុល។ ប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរំពឹងថា តាមរយៈកិច្ចប្រជុំនេះ ដោយមានការចូលរួមធ្វើបទអន្តរាគមន៍ ពីសំណាក់អង្គភាពពាក់ព័ន្ធផងនោះ នឹងរួមចំណែកធ្វើឲ្យកិច្ចការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅក្នុងខេត្តមានដំណើរការដោយរលូន មានការចូលរួមកាន់តែទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាពលើការអនុវត្តផងដែរ៕ ដោយៈភក្តី

## មន្ត្រីសង់ត្រាល់ប្រចាំថៃ៖
## ៦ខែ ពលករជាង ២០០០នាក់ ត្រូវបានទាហានថៃ ឃាត់ខ្លួនតាមព្រំដែន

https://thmeythmey.com/ 28, Jul 2022 , 6:59 pm ដោយ៖ ញឹក សំអូន

រយៈពេល ៦ខែ ឆ្នាំ២០២២នេះ ពលករជាង ២០០០នាក់ ត្រូវបានទាហានថៃឃាត់ខ្លួន អំឡុងពេលដែលលួចឆ្លងដែនទៅធ្វើការនៅក្នុងប្រទេសថៃ។ នេះបើតាមលោក លឹង សុផុន មន្ត្រីសិទ្ធិការងារទទួលបន្ទុកផ្នែកពលករចំណាកស្រុករបស់អង្គការសង់ត្រាល់ប្រចាំប្រទេសថៃ។ លោក លឹង សុផុន បានឱ្យដឹងថា ពលករទៅធ្វើការនៅប្រទេសថៃមានច្រើន ខណៈពលករជាង ៧ម៉ឺននាក់ បានត្រឡប់មកមាតុភូមិកំណើតវិញ។ក្រៅពីពលករចូលទៅធ្វើការស្របច្បាប់នោះ ក៏មានពលករឆ្លងដែនខុសច្បាប់នៅបន្តលួចលបចូលទឹកដីថៃដែរ។ បើតាមមន្ត្រីសិទ្ធិការងារនៃអង្គការសង់ត្រាល់រូបនេះ ពលករខុសច្បាប់ ភាគច្រើនធ្វើដំណើរតាមច្រកធម្មជាតិ ដូចជាតាមព្រៃ តាមជើងភ្នំ និងឆ្លងកាត់តាមតំបន់តម្រូតថៃជាដើម។ លោក សុផុន បន្ថែមថា ពលករខុសច្បាប់ខ្លះ បានធ្វើដំណើរទៅដល់គោលដៅ ហើយអ្នកខ្លះមិនបានទៅដល់គោលដៅឡើយ។

លោក លឹង សុផុន បានប្រាប់សារព័ត៌មានថ្មីៗ(ThmeyThmey) តាមប្រព័ន្ធ WhatsApp បែបនេះ៖ « ចាប់ពីខែមករា រហូតដល់ខែមិថុនា ពលករចំណាកស្រុកជាង ២០០០នាក់ ដែលត្រូវបានតម្រួតថៃឃាត់ខ្លួននៅតាមច្រកតំបន់ព្រំដែន។ ពលករទាំងនោះភាគច្រើន ត្រូវបានបញ្ជូនមកកម្ពុជាវិញ»។ កន្លងមករដ្ឋាភិបាលកម្ពុជា បានចេញសេចក្ដីណែនាំ អប់រំ ជុំវិញពីផលប៉ះពាល់ ដែលពលករលួចឆ្លងដែនខុសច្បាប់ និងឱ្យបញ្ឈប់សកម្មភាពបែបនេះ។ ជាពិសេសណែនាំពួកគេឱ្យទៅធ្វើការនៅថៃតាមប្រព័ន្ធ MOU ផងដែរ។ នេះបើតាមលោក លឹង សុផុន។

សារព័ត៌មានថ្មីៗ បានទាក់ទងលោក ហេង សួរ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមប្រព័ន្ធតេឡេក្រាម និងហៅតាមទូរស័ព្ទដែរ តែពុំមានការឆ្លើយតបនោះទេ។

លោក កែវ វណ្ណថន អ្នកនាំពាក្យអគ្គនាយដ្ឋានអន្តោប្រវេសន៍ បានប្រាប់សារព័ត៌មានថ្មីៗថា អគ្គនាយកដ្ឋានអន្តោប្រវេសន៍ តែងតែណែនាំមន្ត្រីច្រកទ្វារព្រំដែន ពង្រឹងការគ្រប់គ្រង ជៀសវាងកុំឱ្យមានការលួចឆ្លងដែនខុសច្បាប់ ទាំងជនបរទេសចូលមកកម្ពុជា ទាំងពលរដ្ឋខ្មែរទៅក្រៅប្រទេស។ បើតាមលោក វណ្ណថន កន្លងមកមន្ត្រីអន្តោប្រវេសន៍ ក៏ឃាត់បានអ្នកឆ្លងដែនខុសច្បាប់ជាបន្តបន្ទាប់ តែលោកមិនបានលម្អិតតួលេខជាក់លាក់នោះទេ។

សូមជម្រាបថា ចាប់ពីខែមករា ដល់ចុងខែឧសភា ពលករដែលចូលទៅធ្វើការនៅប្រទេសថៃខុសច្បាប់ មានជិត ៣០០០នាក់ ។ ចំណែកអ្នកទៅធ្វើការស្របច្បាប់តាមប្រព័ន្ធ MOU មានជាង ៣០០០នាក់។ ប៉ុន្តែបើធៀបនឹងអ្នកចេញចូលខុសច្បាប់ គឺមានចំនួនច្រើនជាងអ្នកស្របច្បាប់។ នេះបើតាមការលើកឡើងរបស់លោក លឹង សុផុន៕

---